# រឿង

# ស្នេហ៍ចាកផុតទៅ

និពន្ធ  គូរគំនូរ និង រចនាក្រុបដោយ
អ្នកស្រី កែវ ចន្ទ័បូរណ៍
មិនីសូតា សហរដ្ឋអាមេរិក

P.O.Box 600279
Saint Paul, MN 55119
USA
khmervissal @ yahoo.com

ទាក់ទងទូទៅ
016-318-023
012-774-751

ខែវិច្ឆិកា ២០០៦

រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO . COM

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៌

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្ទឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យ
១០- រឿង អំបែងអណ្តែត
១១- រឿង បើសិននៅមានថ្ងៃស្អែក
១២- រឿង លំអងផ្កាស្នេហ៍
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង ស្អែកចាកផុតទៅ
១៦- រឿង តន្ត្រីបេះដូង
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្នើយវាសនា
១៩- រឿង បើអាចបង្វិលផែនដី
២០- រឿង សីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីសួនសុបិន
២៦- រឿង ពិជេដ្ឋភាណុមា
២៧- រឿង មួយខែក្បែរមច្ចុរាជ
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ក្រមុំព្រៃកូនខ្លា
៣២- រឿង ពណ្ណរាយពេជ្រ
៣៣- រឿង បទុមបឹងបិសាច
៣៤- រឿង ផ្ការាជបឹងរាំង
៣៥- រឿង ស្រីនាថភ្លួងមាលា
៣៦- រឿង វាយោដួងចិត្ត
៣៧-រឿង សោភាមាសបង
៣៨-រឿង មេឃរងា
៣៩-រឿង ស៊ូស្លាប់ឬស៊ូរស់ ?
៤០-រឿង សារិកា
៤១-រឿង ក្រោមស្បៃសនៀម
៤២-រឿង ម្លប់អសោក

CHANBOKEO.COM

ISBN: 99950-79-05-4
9 789995 079055

# សូមឧទ្ទិសស្នាដៃនេះជូនចំពោះ

- លោក មេងស្ងួងសុវណ្ណធី ជាស្វាមី
-  កុមារី សុវណ្ណធីធម្មិកាបារមីបុណ្យជាបុត្រី
- លោកឪពុក ប៊ុនថង អ្នកម្ដាយ កែវយឿង ប្អូនទាំងបួនព្រមទាំងក្រុមគ្រួសារ
- លោកឪពុកក្មេក មេងស្ងួង និងអ្នកម្ដាយក្មេក កូវសារ៉ាន់ ព្រមទាំងកូនចៅ
- សាស្ត្រាចារ្យគិមមាសកូយ រស់សាន់ អ្លួននឿង ចាន់សុខា បណ្ឌិតឃួគិមទូយ
- អ្នកស្រីនៅសារិម វិទ្យុសម្លេងសហរដ្ឋអាមេរិក VOA
- អ្នកស្រី ប៊ិចសង្វារ៉ាន វិទ្យុបារាំងអន្តរជាតិ RFI
- លោក លីតាយហុង អ្នកគ្រូ ទូចសារៀង អ្នកគ្រូ កែវសុផុន លោករើនរស់ អ្នកស្រីប៉ក់ដារិនី
- អ្នកគ្រូម៉ៀចសុខារី វិទ្យាល័យនេតយ៉ង់ បាត់ដំបង ។
- លោកអ៊ុំមសុនាថ លោកជិនសៅរិន លោកជាសយនា កាសែតកោះសន្តិភាព
- លោកខូតារាឫទ្ធិ  នាយកកម្មវិធីសម្ងហកម្មអក្សរសិល្ប៍នូហាច ភ្នំពេញ
- សាស្ត្រាចារ្យ យូសុភា មជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម
- លោក ខេងពិទូកិត្យា អ្នកស្រីអ៊ំ តារាណៃត មជ្ឈមណ្ឌលខេមរសិក្សាសៀមរាប
- អ្នកស្រី ភាគ្យ ផលា និងក្រុមគ្រួសារ

CH KEO . COM



អ្នកស្រី កែវ ចន្ទ័បូរណ៍

# វាចាអ្នកនិពន្ធ

កាលពីខែសីហាឆ្នាំ២០០៦ អ្នកនិពន្ធបានទទួលសេចក្ដីស្នើមួយ ពីសុភាពស្ត្រីម្នាក់ ដែលសុំឲ្យនាងខ្ញុំសរសេររៀបរៀងជាសៀវភៅ ឡើង ដើម្បីបង្ហាញជូននូវជីវិតរបស់នារីម្នាក់ មកពីកម្ពុជាក្រោម ដែលត្រូវតស៊ូជាមួយជីវភាពនៅភ្នំពេញ ដើម្បីក្រុមគ្រួសាររបស់ នាងផង និងដើម្បីអនាគតរបស់ខ្លួនផង ។

ដោយពិនិត្យឃើញថា រឿងនេះមានបង្កប់នូវខ្លឹមអត្ថរសផ្នែក មូលដ្ឋានសីលធម៌ និងសុភមង្គលក្នុងសង្គមគ្រួសារ នាងខ្ញុំក៏សំរេច ចិត្តនិពន្ធកែឆ្នៃអត្ថរសសាច់រឿងចំនួន៨០ភាគរយថែមទៀត ដោយ ប្រតិស្ឋចំណងជើងឲ្យថា "ស្នេហ៍កចាកផុតទៅ" ដើម្បីឆ្លើយតបទៅ សុភាពស្ត្រីមួយរូបនោះផង និងដើម្បីកំដរអារម្មណ៍ប្រិយមិត្តអ្នក អានទាំងឡាយដែល ធ្លាប់គាំទ្រស្នាដៃរបស់នាងខ្ញុំកន្លងមកនោះ ផង ។ នាងខ្ញុំសូមទទួលនូវមតិយោបល់ពីមិត្តអ្នកអាន តាមរយៈ អាសយដ្ឋានដូចខាងក្រោមនេះ ៖

Pannalai Khmer Vissal
P.O.Box 600279
Saint Paul, MN 55119, USA
Khmervissal@yahoo.com

អ្នកស្រី កែវ ចន្ទ័បូរណ៍
មិនីសូតា សហរដ្ឋអាមេរិក
ខែវិច្ឆិកា ២០០៦

CHANBOKEO.COM

# កំណាព្យ

=========================================

## ពេលឃើញកូនខុស

ពេលកូនធ្វើខុសកុំស្តីថែម　　ម៉ែឪត្រូវត្រៀមហៅពិគ្រោះ
ណែនាំផ្លូវល្អចាកផុតគ្រោះ　　កុំជេរបន្ទោសស្តីច្រំដែល ។
កូនកាន់កាំបិតចិតមុតដៃ　　ម៉ែឪគប្បីប្រៀនឲ្យក្រែល
ប្រាប់របៀបថ្មីលែងដដែល　　កុំឲ្យមុតដៃសាម្តងទៀត ។
កូនជិះកង់ដួលកុំឡើយសើច　　ពន្យល់ប្រយោជន៍ស្វែងរកស្នៀត
ឲ្យកូនដើបឡើងសាកម្តងទៀត　　សំភីគ្រប់ស្នៀតលុះត្រាជ័យ ។
កូនឡើងដើមឈើធ្លាក់ដួលដំ　　កុំជេរចិញ្ច្រាំឲ្យកូនភ័យ
ណែនាំកូនយើងរបៀបអ្វី　　ពេលឡើងជាថ្មីលែងមានគ្រោះ ។
កូនធ្វើលំហាត់មានខុសខើច　　កុំជេរបញ្ឆើចថាកូនដោះ
ឲ្យគ្នាស្រពោនទឹកចិត្តអស់　　ថ្ងៃក្រោយកូនច្បាស់គេចសាលា ។
កូនមានសង្ស័យហៅប្រៀនប្រាប់　　ពិគ្រោះប្រញាប់ពន្យល់សា
តឹងពេកនាំដាច់ ធូរធ្លោយការ　　គប្បីពិចារណាផ្លូវកណ្តាល ។
ធ្វើជាម៉ែឪត្រូវសំភី　　វែកឧបាយទីល្អត្រកាល
ប្រៀនការណែនាំល្អវិសាល　　ទើបកូនយល់ថ្កាលភព្វរុងរឿង ។

CHANBOKEO.COM

## ចង់រាក់អោយដីក ចង់រីកអោយហាលថ្ងៃ

បាយដាំស្ពុះឆ្នាំងចង់អោយរាក់ យកវែកជ្រោយដាក់អោយរសោះ
បាយប្រៃពោរឡើងពេញឆ្នាំងអស់ រួចហើយដួសដោះឆីភោគ្គា ។
ដូចការសិក្សាមានជំរៅ ចង់រាក់ដីកទៅអោយសព្វសារ
គាស់យកមករៀនច្រើនសាស្ត្រា អាត្មាលៃងលង់ជំរៅល្វិត ។
ឯគរកប្បាសច្បាស់ជារីក បេះប្រឡេះហែកហាលថ្ងៃពិត
សំពោងធំក្រៃសំបើមឫទ្ធិ ច្រកខ្នើយកើយនិត្យចិត្តក្សេមក្សាន្ត ។
ចង់រីកចំរើនខាងភោគផល ហាលថ្ងៃរចល់កុំអោយខាន
ធ្វើស្រែចំការ កបង្កើន ឧស្សាហ៍ក្រវើនគង់សំរេច ។
ពាក្យចាស់លោកផ្តាំយើងចាំទុក គំនិតនាំសុខកុំងាកគេច
ស្តាប់ហើយវិភាគន័យសារពេជ្រ យើងច្បាស់សំរេចគោលដៅល្អ ។

CHANBOKEO . COM

# តំណក់ទឹក

តំណក់ទឹកស្រក់អាចច្រោះថ្ម　　ស្រក់តក់ៗយូរពេញបំពង់
ស្រក់ចុះតិចៗអាចលិចលង់　　ស្រក់យូរៗគង់ដំបូលដាច ។
វិស័យរូបយើងអ្នកទាបខ្សោយ　　រូបតូចតែមួយគង់សំរេច
បើប្រឹងតក់ៗយ៉ាងប្តូរផ្តាច់　　ថ្ងៃមួយសំរេចការងារធំ ។
ពង្វាតអំណាចដោយប្រាជ្ញ　　ស្មារតីហានក្លាថ្លាឧត្តម
សីលធម៌តម្រេះជាគោលមុំ　　ពង្រីកទីធំថ្កើងកល្យាណ ។
កុំឡើយលះបង់ចិត្តតស៊ូ　　តក់ៗយូរៗគង់នឹងថ្កាន
ចេះតូចធ្វើតិចគ្រាន់ជាងខាន　　យូរប្រមូលបានបំពង់ពេញ ។

CHANBOKEO . COM

# ជោគជ័យព្រោះអ្វី ?

សិស្សរៀនជោគជ័យត្បិតឧស្សាហ៍ ឱហាតសិក្សាមិនទំនេរ
ជីកឫសចាប់គល់ប្រឹងថែមទ្វេ រៀនចេះពូកែព្រោះព្យាយាម ។
គន្លឹះមួយទៀតគឺម៉ែឪ ណែនាំប្រដៅអោយកូនត្រៀម
ជួយលើកទឹកចិត្តមិនឲ្យក្រៀម កូនញញឹមភ្លាមប្រឹងលើសដើម ។
ម្យ៉ាងព្រោះសិស្សមានគ្រូបវរ ជួយត្រាយផ្លូវល្អជាងផ្ដើម
នាំការសិក្សារីកចំរើន សិស្សរៀនក្រវើនមិនច្រអូស ។
ចុងក្រោយគឺមកពីសង្គម ជួយជ្រោងឧបត្ថម្ភច្រើនចម្រុះ
ក្រសួងរដ្ឋាមិនបង់បោះ ហុចដៃជួយអូសតម្រង់ទ្រើង ។
បើយើងសាមគ្គីកូនចៅលូត ពគជ័យរហូតខ្ពស់ថ្កុំថ្កើង
កូនជាឫស្សីស្នងជាតិយើង អនាគតថ្កុំថ្កើងពឹងកូនហើយ... ។

CHANBOKEO . COM

# ស្រលាញ់កាយកប់ ស្អប់កាយឡើង

ស្រលាញ់ផ្លែផ្កាចូរដាក់គ្រាប់ ស្រវាកាយកប់ដាំដាក់ទ្រើង
ស្អប់ស្មៅទន្ទ្រានត្រូវកាយឡើង ដីកឫសរំលើងកុំសល់ឡើយ ។
ស្រលាញ់សាស្ត្រចាប់សៀវភៅ អានកប់ខ្លួនទៅកុំខ្វល់ខ្វាយ
បើស្អប់ចិត្តពាលប្រទុស្តរាយ កាយកាត់បោះឆ្ងាយកុំសន្សំ ។
ស្រលាញ់ម៉ែឪត្រូវត្រងត្រាប់ កប់ពាក្យម៉ែប្រាប់ក្នុងអារម្មណ៍
ពិចារណាអក្សរសល្អភិរម្យ កប់ក្រឹត្យឧត្តមក្នុងបេះដូង ។
ស្អប់ភាពក្រក្រី...កាយកុំស្ញៀម ឧស្សាហ៍ព្យាយាមទាំងដើងត្បូង
ធ្វើការសស្រាំផលអឺងកង ភោគទ្រព្យសហោងថ្កើងកល្យាណ ។
ច្នេះបើស្រលាញ់សូមកាយកប់ បើសិនជាស្អប់កាយកុំខាន
កវីជំរាបលោកអ្នកអាន បើសិនភ្លេចប្រាណ...ខានប្រយោជន៍ ។

CHANBOKEO.COM

# អ្នកនិពន្ធអភិវឌ្ឍន៍

រឿងប្រលោមលោកមនុស្សយក្សនាគ　　រឿងកុនតភាគជូនផងញាតិ
កំប្លែងលើឆាកស្តែងព្រោងព្រាត　　តែងឆ្លៀតបញ្ជាំងនូវសង្គម ។
សង្គមបុរាណឬសម័យ　　សង្គមប្រពៃខ្ពស់ឧត្តម
សង្គមអរិថីពលរដ្ឋយំ　　បង្ហាញគ្រប់មុំរសប្លែកៗ ។
ថៃងន្យសម័យស្រុកជឿនលឿន　　គេនិពន្ធរឿងលែងរារែក
ធ្វើកញ្ចក់ឆ្លុះយ៉ាងល្អឯក　　ថែមពន្លាកដែកឆ្លាក់ខាត់ផង ។
ខេមរានិពន្ធច្រើនក្បួនខ្នាត　　អ្នកប្រាជ្ញសង្វាតក្បួនចំបង
សរសេរស្រាវជ្រាវស្រាយចំណង　　ឆ្លាក់គំនិតផងឲ្យចរណៃ ។
អ្នកមើលអ្នកអានអ្នកទស្សនា　　ជួបរឿងពិស្តារមានអត្ថន័យ
បង្កប់គំនិតល្អប្រពៃ　　លែងអីមិនត្រង់គតិស្លូន ។
បំណាច់ចាយពេលមានតម្លៃ　　ចងក្រងស្នាដៃអស់ផងក្បួន
គួរនាំគំនិតល្អនឹមនួន　　ចែករំលែកជូនជាប្រយោជន៍ ។
សម័យនិពន្ធអភិវឌ្ឍន៍　　លូតលាស់បំផុតយ៉ាងរុងរោចន៍
គួរស្មេរគតិនាំប្រយោជន៍　　អ្នកអានបានបោចប្រយោជន៍ថ្កើង ។

CHANBOKEO.COM

# ឫស្សីសាយគុម្ព

ឫស្សីមួយមែកដាំសាយគុម្ព          ព្រោះទំពាំងធំលូតលាស់មក
ភ្លោះកូនថ្មីៗមិនឈប់ឈរ          ជាឫស្សីល្អខ្ពស់លើសមុន ។
បើឫស្សីក្រោយក្លាយតូចស្គួច          គុម្ពច្បាស់ជាហោចប្រែសិយស៊ុន
ស្រកម្តងបន្តិចតូចជាងមុន          គុម្ពទ្រោមតត្រុនលែងឲ្យផល ។
ដូចប្រទេសជាតិក្លាយខ្សោយទន់          បើបច្ឆាជនយន់កាយកល
ទំពាំងក្រោយទ្រោមស្រុតគុម្ពគល់          ជាតិច្បាស់ជាយល់ហាយនៈ ។
ឫស្សីសាយគុម្ពពឹងទំពាំង          ជាន់ក្រោយធំខ្លាំងខ្ពស់ប្រត្យក្ស
លើសឫស្សីមុនយ៉ាងអនគ្ឃ          សាយគុម្ពឥតអាក់ស្តុកស្តម្ភក្រៃ ។
មិនខុសប្រទេសដែលជឿនលឿន          ពលរដ្ឋជំរឿនសព្វវិស័យ
ក្មេងមានវិជ្ជាខ្ពស់លលៃ          លើសចាស់សម័យពីបុរាណ ។
ច្នេះយើងចាស់ៗគួរបណ្តុះ          ឲ្យក្មេងលូតលាស់ខ្ពស់ថ្កើងថ្កាន
គំនិតប្រាជ្ញវិជ្ជាបាន          ចំណេះសំខាន់ជួយជាតិយើង ។
ហើយទទួលផងថាយើងចាញ់          ក្មេងក្រោយត្របាញ់ខ្ពស់ថ្កុំថ្កើង
កាន់តែលាស់ទៅលើសរូបយើង          សាយគុម្ពរីកឡើងយ៉ាងវិសាល ។

CHANBOKEO.COM

# ទុកទៅវាចាស់ ប្រើណាស់វាថ្មី

កាំបិតទុកយូរមិនប្រើការ ច្រេះចាប់មុខវាគឺរិលអស់
បើប្រើរាល់ថ្ងៃថ្មីចាំងណាស់ សម្លៀងកាប់រះមុតលែងអី ។
ដូចជាគំនិតប្រាជ្ញមនុស្ស ប្រើណាស់គង់ភ្លឺថ្លាដូចថ្ងៃ
បើខ្ជិលមិនប្រើក្លាយអប្រិយ គិតអីមិនចេញស្រាយមិនបាន ។
បញ្ចេញប្រាជ្ញាប្រើគំនិត មិនត្រូវលាក់ទុកឆ្អើរពិដាន
ឆ្លៀតពេលទំនេរសរសេរអាន យូរគង់នឹងច្រើនកើនតម្រេះ ។
ដុសខាត់គំនិតរិតភ្លឺថ្លា ស្មារតីប្រាជ្ញយល់ជ្រៅជ្រះ
ប្រើណាស់ដុះណាស់ភ្លឺផ្លេកជះ ជំនះកម្លៅខ្លៅអន្តរាយ ។

CHANBOKEO.COM

## សាង...

ស្រុកផុតសង្គ្រាមនាំគ្នាសាង ភូមិគ្រិះស្រឡាងសាងផ្លូវជាតិ
សាងសណ្ឋាគារស្រស់វរនាថ វត្តអារាមទៀតល្អរមណីយ៍ ។
គ្រឹស្ថានតូចធំដុះស្មេកស្កុះ លូតលាស់ត្រចះវាតដីធ្លី
ទេសចរណ៍ចេញចូលច្រើនមូលមីរ សំភីចង់ស្គាល់ខ្មែរលូតលាស់ ។
ថៃដន្យយើងសាងអាគារល្អ ភ្លេចសាងសីលធម៌ខ្ពស់ត្រចះ
ឃ្លាតឃ្លាវិន័យតាមធម៌ព្រះ ខេមរានិរាសចាកគុណធម៌ ។
សម័យជឿនលឿនអភិវឌ្ឍន៍ ខ្មែររៀនចេះស្ទាត់កុំព្យូទ័រ
បែរភ្លេចខំសាងអំពើល្អ ដល់ញាតិក្រីក្ររស់វិនាថ ។
សាងសង់ប្រទេសមានគ្រប់ជ្រោយ សាងអាគារហើយសាងមនុស្សទៀត
សាងទាំងសីលធម៌វប្បធម៌ជាតិ ទើបខ្មែរចាកឃ្លាតហាយនភព ។

## អំពៅ

ពៅអើយអំពៅនូវរសជាតិផ្អែម បានផឹកបានក្លែមចាប់ចិត្តកន្លង
អំពៅពេញទឹកប្រជាប្រិយ៍ហោង កៀបអស់ទឹកផងញាតិលែងរាប់រក ។
ធ្វើជាមនុស្សត្រូវមានប្រាជ្ញ កុំអោយកុនការអ្នកផ្សេងកៀបយក
កេងយកប្រយោជន៍អោយយើងស្អុយខក ដូចអំពៅកាកគេកៀបអស់ជាតិ ។

អ្នកស្រី កែវ ចន្ទ័បូរណ៍

CHANBOKEO.COM

# វគ្គទី១

## ចាំស្អែក...!

- ចាំស្អែក ចាំអូនប្រាប់បង តែពេលនេះ អូនងុយគេងហើយ...!
- ប្រាប់បងសិនមើល៍ អូននី! បងចង់ដឹងពិតមែនណា៎! ប្រាប់បង មើល៍ ថាអូនស្រឡាញ់បង...ដូចបងស្រឡាញ់អូនអញ្ចឹង!
- តែអូនកំពុងអស់កម្លាំងងងុយគេងណាស់...បងកិត្យា!
- នេះ ជារាត្រីទីមួយរបស់យើងណា៎អូន... ហេតុអីក៏ឆាប់ងុយគេង ម្ល៉េះព្រលឹង ? ឬក៏អូនអៀននឹងប្ដី ?

មាលីនីលូកដៃបិទកុងតាក់ភ្លើងនៅក្នុងបន្ទប់គេង តែត្រូវកិត្យា ចាប់ដៃជាប់ ហើយស្រដីថែមទៀតថា ៖

- កុំទាន់បិទ...! បងសម្លឹងមុខគូស្នេហ៍របស់បងមិនទាន់ឆ្អែតទេ! ហើយបងក៏ចង់និយាយអ្វីៗជាមួយអូនច្រើនទៀតណា៎!

មាលានីញញឹម ឆ្លើយថា ៖

- បងមានពេលចាប់ពីថ្ងៃនេះតទៅរហូតមួយជីវិតឯណោះ មើលថ្ងៃ ណាក៏បានដែរ ម៉េចចាំបាច់តែយប់នេះផង... ?
- នោះព្រោះតែយប់នេះ ជាយប់ដែលយើងទើបនឹងទទួលចំណង ដៃផ្កាស្លានោះអី! គឺជាយប់ពិសេសតែមួយដែលមានតម្លៃបំផុត សំរាប់គូស្នេហ៍កម្លោះក្រមុំដែលរៀបការដំបូង ។

កិត្យាស្រដីដាក់គូស្នេហ៍ផង ឈ្ងោកមុខយកនាសាត្រដុសនឹង ថ្ពាល់ដ៏រលោងរបស់នាងផង ហាក់ចង់បង្ហាញនូវអារម្មណ៍រំភើបត្រេ ព្រួចរបស់គេចំពោះនារីគូជីវិត ។ ចៃដន្យ មាលនីបែរជាបិទភ្នែក លួចជ្រួញចិញ្ចើមទៅវិញ នៅពេលនាងទទួលនូវការថ្នាក់ថ្នមរបស់ស្វាមី ។ ឃើញដូច្នោះ ក្យាទុចង៉ក់ ងើបមុខឡើង សួរនារីថា ៖

CHANBOKEO.COM

- មានអ្វីរំខានចិត្តអូនឬ មាលានី ?

មាណវីបើកភ្នែកឡើងមកវិញ ឃើញកិត្យាធ្វើទឹកមុខប្លែក ក៏ ប្រែទឹកមុខញញឹមមកវិញ ហើយនិយាយបន្លប់ថា ៖

- គឺអូនអស់កម្លាំងពេកនោះអីបង! សូមទោសណា៎ ដែលអូនធ្វើ អោយបងខ្វាយខ្វល់!

តែកិត្យាហាក់ដូចជាមិនអស់ចិត្តសោះ ចំពោះកិរិយាមាលានី ប៉ុន្តែ គេមិនហ៊ានសួរនាងអោយល្អក់អារម្មណ៍ទេ ត្បិតគិតថាថ្ងៃនេះ ជាថ្ងៃមង្គល មិនគួរនិយាយអ្វីធ្វើអ្វីដែលបង្កនូវរឱស្លានក្នុងជីវិត គ្រួសារជាលើកដំបូងរបស់គេឡើយ ។ គេក៏ងើបអង្គុយឡើង ស្រវា ទាញភួយមកដណ្តប់អោយមាលានី ហើយស្រដីថា ៖

- បើអញ្ចឹង អូនសំងំគេងយកកម្លាំងទៅណា៎! បងលែងរំខានអូន ហើយ ។ ចាំព្រឹកស្អែក យើងនិយាយគ្នាទៀត ។

គេក៏ឈ្ងោកថើបថ្ងាសភរិយាបន្ថើរៗ រួចដើបដើរចេញពីបន្ទប់ ដោយបិទទ្វារថ្នមៗ ហាក់មិនចង់អោយមានសម្លេងមករំខានដល់ អារម្មណ៍របស់ប្រពន្ធដ៏ស្រស់ស្អាតរបស់គេនោះឡើយ ។

មាលានីលួចសម្លឹងតាមកិរិយារបស់ស្វាមី នឹកស្តាយក្នុងចិត្ត ដែលកិត្យាដើរចេញពីបន្ទប់ផ្សំដំណេកនាពេលនោះ ។ ចិត្តមួយចង់ ស្រែកហៅអោយគេត្រឡប់មកវិញ ចិត្តមួយទៀតរារែក មិនហ៊ាន ហៅ ព្រោះហាក់ដូចជាអៀនខ្មាសបន្តិច ដូចជាឃ្នាន់ខ្នាញ់បន្តិច ដែលគេមិនសំដែងភាពទន់ភ្លន់យកចិត្តនាង ។ មាលានីប្រែខ្លួនចុះ ឡើងនៅក្នុងគ្រែយ៉ាងរសាប់រសល់ នឹកចម្លែកតែក្នុងថា ហេតុអ្វី បានជារូបនាងតប់ប្រមល់ចំពោះរាត្រីផ្កាស្លាយ៉ាងដូច្នេះ ?

ការពិត នាងជាអ្នកសំរេចចិត្តជ្រើសរើសកិត្យាជាគូជីវិតដោយ ខ្លួនឯង ដោយគ្មានចាស់ទុំមេបាណាបង្ខិតបង្ខំនាងទេ ប៉ុន្តែ ហេតុ ម្តេចក៏នាងមិនមានការរំភើបរំជើបរំជួលចិត្ត ចំពោះកូនកម្លោះកិត្យា សោះអញ្ចឹង ? មាលានីមិនយល់ចិត្តខ្លួនឯងទេ... ភ្លាមនោះ ទឹក ភ្នែកច្រើនដំណក់ក៏ស្រក់ចុះមកប្រឡៀងថ្ពាល់របស់មាណវី...

យូរម៉ោងកន្លងទៅ...

CHIANBOKEO.COM

មាលានីប្រែខ្លួនឡើង ឃើញម៉ោងជាងពីរអាធ្រាតទៅហើយ ។ រីឯកិត្យាក៏បាត់រូបទៅ មិនឃើញវិលត្រឡប់មកបន្ទប់គេងវិញដែរ មិនដឹងថានាយចេញទៅគេងឯណា យប់នោះ ។ មាលានីនឹក ពិភាល់ក្នុងចិត្តភ្លាម ក៏ស្ទុះដើបដើរចេញមកក្រៅ ដើម្បីហៅនាយ អោយទៅគេងខាងក្នុងបន្ទប់វិញ ។ ថែដន្យ កិត្យាមិនបាននៅក្នុង ផ្ទះទេ ។ មាលានីស្ទុះរត់ទៅមើលម៉ូតូ ឃើញចតទុកនៅកន្លែង ដដែល ក៏ធូរទ្រូងខ្សាកនឹកថា នាយប្រហែលមិនបានចេញដើរទៅ ក្រៅទេ សង្ស័យតែទៅលួចពួនសំងំគេងជាមួយប្អូនៗរបស់នាង ហើយ ។

ដោយឮសូរិបជើងដើរចុះដើរឡើង ស្ត្រីចាស់ម្នាក់ដើប ចេញពីមុងមកសួរថា ៖

- អានី! មានការអីកូន បានជាត្រិះត្រុះកណ្ដាលយប់អាធ្រាត ?

មាលានីឮហើយបែរក្រោយ ឃើញម្ដាយនាងដើបដើរមករក នាងទាំងសើងម៉ើង ក៏ឆ្លើយតបថា ៖

- គឺ... អត់មានអីទេ ម៉ែ គ្រាន់តែកូនមានការភ្ញាក់ផ្អើលក្នុងចិត្ត បន្តិច ដែលកូនកំពុងផ្លាស់ប្តូរដំណើរជីវិត ព្រោះកូនមិនធ្លាប់គេង បន្ទប់ចែកគ្រែជាមួយនរណាពីមុនមក ។

- ប៉ុន្តែ នេះជាយប់ផ្សំដំណេកណ៎ាកូន! តាមទម្លាប់ចាស់បុរាណ គេ ហាមមិនអោយកូនកម្លោះក្រមុំដើរចេញពីបន្ទប់ នៅរាត្រីផ្សំដំណេក ទេណ៎ា ព្រោះវាជាប្រផ្នូលមិនល្អរបស់គូស្រករយើង ។

មាលានីនៅស្ងៀម មិនហ៊ានមាត់កជាមួយម្ដាយទេ ហើយក៏មិន ហ៊ានប្រាប់ដែរថា កិត្យាមិននៅក្នុងបន្ទប់ ។

- ចា៎សម៉ែ! កូនទៅគេងវិញហើយ ។

ថាហើយ នាងក៏ឈ្ងោកមុខដើរចូលបន្ទប់វិញ ក្នុងចិត្តនៅគិត ឆ្ងល់ថាតើកិត្យាគេគេចទៅគេងនៅឯណា យប់នេះ ? ដោយក្ដីតប់ ប្រមល់ មាលានីគេងរសាប់រសល់ទៀតហើយ ។ ទ្រាំមិនបាន នាង ក៏លួចបើកទ្វារចេញពីបន្ទប់ ដើរត្រិះត្រុះក្នុងផ្ទះ អើតរកសត្យា តាម ក្ដារដឿ និងកន្លែងទំនេរៗដទៃទៀតក្នុងផ្ទះ ។ ថែដន្យ គេមិនបាន នៅកន្លែងណាដែលអាចអោយមាលានីរកគេឃើញទេ ។ ខកចិត្ត ពេក មាលានីក៏ទាញក្រមាដណ្ដប់ខ្លួនសំកុកនៅក្នុងកៅអីផ្ដៅមួយក្នុង បន្ទប់គ្រួសារ

CHANBOKEO.COM

ដែលមានតាំងកូនទូរទស្សន៍តូចមួយ ក្តារជឿមួយ និងរូបថតក្រុមគ្រួសាររបស់នាង រង់ចាំការវិលត្រឡប់របស់កិត្យា ។

ការពិត មាលានីជាកូនទី៦ ក្នុងចំណោមកូនទាំង១២នាក់របស់ ពូនងនិងមីងមៀន ដែលទើបតែផ្លាស់ទីមករស់នៅឯភ្នំពេញនេះ កាលពី៤ឆ្នាំមុន ។ ពីដើម គ្រួសារពូនងមីងមៀននៅស្រុកផ្នូរលើ ខែត្រព្រះត្រពាំង កម្ពុជាក្រោម ធ្វើស្រែចិញ្ចឹមជីវិត ។ ប៉ុន្តែ ដោយ ហេតុថា គាត់មានកូនច្រើនផង ស្រែស្រូវក៏មិនសូវផ្តល់ផលល្អ សំរាប់លៀងជីវិតផង ណាមួយចង់អោយកូនចៅរៀនសូត្រអក្សរ សាស្ត្រខ្មែរអោយបានជ្រៅជ្រះផង ណាមួយគាត់ឮល្បីថានៅភ្នំពេញ សំបូរការងារធ្វើផង ពូនងមីងមៀនដាច់ចិត្តលើកស្រែចំការ អោយ ទៅញាតិសន្តានរបស់គាត់ រួចហើយក៏បបួលគ្នានាំកូនចៅ ផ្លាស់ទី លំនៅមករស់នៅឯក្រុងភ្នំពេញនេះទៅ ។ ពេលនេះ គាត់ជួលផ្ទះ តូចមួយនៅម្តុំគីឡូលេខ៥ ។ កូនចៅធំៗខ្លះដែលមានប្តីប្រពន្ធ ក៏ បានចូលធ្វើការរោងចក្រ ។ រីឯកូនតូចៗក៏បានចូលរៀនសាលា ដូចបំណងមែន ។ ចៃដន្យ កូនខ្លះដែលស្ថិតនៅក្នុងយុវវ័យ បាន ទទួលការសិក្សាខ្លះៗកាលពីនៅកម្ពុជាក្រោម មិនអាចបន្តការសិក្សា នៅភ្នំពេញបានទេ ព្រោះដោយសារការខ្វះខាតក្នុងគ្រួសារផង និង ដោយសារសេវានៃការទទួលចុះឈ្មោះចូលរៀន មានបែបបទខុស គ្នាផង មិនអាចអោយកូនទាំងនោះចូលរៀនបានតាមកំរិតដែលខ្លួន ត្រូវរៀន ម្ល៉ោះហើយ ក្មេងៗក៏បាក់ទឹកចិត្ត នាំគ្នាចេញរកការធ្វើ អស់រលីងទៅ ។ នៅក្នុងចំណោមនោះ មានមាលានីម្នាក់ដែរ ។

ភ្លឺស្រាងៗ...

សូរសម្លេងមនុស្សចាក់សោររួចហើយបើកទ្វារចូលមក ធ្វើឲ្យ មាលានីភ្ញាក់ព្រើត ងើយបែរមើល ឃើញកិត្យាដើរចូលមកទាំង ទម្រេតទម្រោត ។ នាងក៏ស្ទុះដើបទៅជួយគ្រាប់មាណពឡើង ព្រម ទាំងលាន់មាត់សួរនាយថា ៖

- បងកិត្យា! ទើបតែមកពីណាហ្នឹង ? ដឹងទេ ថាអូនបារម្ភពីបង ពេញមួយយប់ ?

កិត្យាងើបមុខឡើងញញឹម នាំក្លិនស្រាមកជាមួយផង ៖

- គឺមកពីជប់លៀងជាមួយពួកម៉ាក ។
- ជប់លៀង ? ហេតុអ្វីជប់លៀងកណ្តាលអាធ្រាតអញ្ចឹង ?
- គឺជប់លៀងលាភាពកម្លោះរបស់បងនោះអី!

CHANBOKEO.COM

ឮសំដីនេះភ្លាម មាលានីធ្លាក់ថ្លើមក្តុក... ស្រុតទឹកចិត្តអស់រលីង ពីខ្លួន ។ ចិត្តដែលនឹកបារម្ភអំពីសុខទុក្ខរបស់កិត្យាកាលពីយប់ ក៏រលត់បាត់កំសួលពីបេះដូងរបស់នាងភ្លាម ។ រីឯភាពឃ្នាន់ខ្នាញ់និងការតូចចិត្តក៏ត្រឡប់វិលមកសាងនាទីជំនួសភ្លិប ពេញឱវាទនិយាយ មិនចេញតែម្តង ។

ពេលនោះ មាណវីគិតក្នុងចិត្តតែម្នាក់ឯងថា ៖

- នេះ គ្រាន់តែខ្ញុំធ្វើជារអ៊ូថាអស់កម្លាំងបន្តិច បងក៏យកលេសលួច ចេញទៅក្រៅទៅរកស្រីញីបណ្តោះភាពកម្លោះរបស់ខ្លួន ជំនួស ប្រពន្ធដែលខ្លួនរៀបការត្រូវផ្សំដំណេកជាមួយ... នេះ យើងរៀប ការនឹងគ្នាមិនទាន់បានមួយថ្ងៃផង ប្តីហ៊ានដើរចេញពីផ្ទះទៅរកស្រី កំដរៗនៅក្រៅទៅហើយ ចុះទំរាំរស់នៅជាមួយគ្នារាប់ឆ្នាំទៅទៀត តើបងនឹងព្រហើនដាក់ប្រពន្ធថែមយ៉ាងណាទៀតទៅ ? នេះហើយ ឬមារយាទរបស់មនុស្សប្រុស ? ពិតជាគួរអោយស្អប់មែន!

មាលានីគិតនៅក្នុងចិត្តផង ខ្នាញ់ខឹងនឹងកិត្យាផង លួចខាំធ្មេញ តែម្នាក់ឯង ស្ទើរតែស្រក់ទឹកភ្នែកម្តងៗ ប៉ុន្តែ នាងខំតាំងចិត្តយ៉ាង មុតមាំថា នាងមិនចុះចាញ់ស្ថានការណ៍នោះជាដាច់ខាត ។ បន្ទាប់ពី គ្រាហ៍កិត្យាទៅដាក់នៅលើគ្រែរួចហើយ មាលានីក៏បិទទ្វារ លួចដើរ ចេញទៅក្រៅផ្ទះ ដងទឹកត្រជាក់ទទះមុខជាច្រើនសា អោយស្វាងពីកំហឹងដែលកិត្យាចេញទៅជប់លៀងនៅក្រៅ ក្នុងរាត្រីផ្សំដំណេក មង្គលការ ។ ប៉ុន្តែ មិនថានាងយកទឹកត្រជាក់ជះមុខប៉ុន្មានដងទេ ចិត្តមាលានីនៅតែពុះកញ្ជ្រោលដដែល... មិនព្រមថមថយបន្តិច សោះឡើយ ។

បែរមកកិត្យាវិញម្តង...

ការពិត ពេលកិត្យាដើរចេញពីបន្ទប់ទៅ ពីក្បាលព្រលប់នោះ ព្រោះគេប្រាថ្នាចង់សាកចិត្តមាលានី ថាតើនាងមានការចាប់អារម្មណ៍ លើរូបគេជាប្តីប៉ុនណា ហើយចង់ដឹងថា តើប្រពន្ធនឹងមកហៅគេ វិញដែរឬទេ ? ប៉ុន្តែ គេរង់ចាំច្រើនម៉ោងទៅហើយ មិនឃើញ នាងចេញមកហៅនរៈត្រឡប់ទៅរកបន្ទប់វិញសោះ ។ ពេលនោះ គេក៏នឹកភ្នកទៅដល់តិរិយាបថរបស់នារីដែលបញ្ចេញភាពតោះតើយ ដាក់ខ្លួនពេលផ្សំដំណេក ។ កិត្យាក៏នឹកអន់ចិត្តភ្លាមតែម្តង ៖

CHANBOKEO.COM

- ប្រហែលជាគេមិនស្រឡាញ់យើងទេដឹង បានជាមិនឃើញមាន អារម្មណ៍ មានកិរិយារំជើបរំជួលរីករាយជាមួយយើងអ្វីបន្តិចយ៉ាង នេះអញ្ចឹង ? តើយើងមានធ្វើអ្វីខុសចំពោះនាងមែនទេ ? ហេតុអ្វី បាន ជានាងធ្វើព្រងើយៗមិនចាប់អារម្មណ៍អំពីរាត្រីទីមួយរបស់ យើងដូច្នេះ ?

គេអង្គុយគិតផង សួរខ្លួនឯងផង ជាច្រើនលើកច្រើនសា ប៉ុន្តែ នៅតែរកចម្លើយមិនឃើញដដែល ។ ដោយការធុញថប់ក្នុងចិត្ត ខ្លាំងពេក កិត្យាក៏ទាញទូរសព្ទ័ឡើង ៖

- សំរោង! គ្នាសុំពឹងឯងបន្តិចបានទេ ?
- មានការអ្វីទៅ កិត្យា ?
- មកទទួលខ្ញុំម៉ាភ្លែតម៉ោ... ចាំខ្ញុំប្រាប់!
- ពុទ្ធោ! យប់នេះ ជាយប់ផ្សំដំណេកណា៎! កិត្យាទៅណាមិនបាន ទេ ខុសតំណមបុរាណ ។
- ប៉ុន្តែ គ្នាមានរឿងតប់ប្រមល់ក្នុងចិត្ត គ្មានអ្នកពិគ្រោះ ទើបចង់ និយាយជាមួយឯងបន្តិច ។
- ហ៊ឺ! ការពិតទៅ គ្នាមិនចង់ទៅយកឯងទេ... ដឹងដល់ចាស់កាល ណា ខ្ញុំច្បាស់ជាត្រូវត្មោងចាស់ៗបាក់ឆ្អឹងខ្នងហើយ ។
- ហេតុអ្វីចាស់ៗគាត់វាយឯងបាក់ឆ្អឹងផង ?
- ព្រោះ ខ្ញុំទៅដឹកឯងចេញពីផ្ទះនៅយប់ផ្សំដំណេកនោះអី ? ទី មួយវាខុសនឹងទំនៀមទម្លាប់ ទីពីរចាស់ៗអាចនឹងសង្ស័យ ហើយ គិតថាខ្ញុំនេះជាសង្សារខ្ទើយរបស់ឯងក៏មិនដឹង បានជាប្រចណ្ឌ័រហូត ដល់មកឌុបដឹកឯងចេញពីផ្ទះ មិនអោយផ្សំដំណេកជាមួយប្រពន្ធ ទាំងយប់អាធ្រាត ។
- ឯងនេះនិយាយតែផ្តាសមែន ។ ណ្ហើយចុះ! មិនមកយកខ្ញុំក៏ បានដែរ! ចាំខ្ញុំរកម៉ូតូឌុបជិះទៅផ្ទះឯងចុះ ។
- ស្លាប់ហើយ! កុំម៉ោអី! ផ្ទះខ្ញុំមិនទទួលពួកម៉ាកប្រុសកណ្តាល អាធ្រាតដូចគ្នា ។
- ហេតុអី ?
- គ្នាប្រាប់ហើយតើហ៎ ថាមិនចង់អោយអ្នកស្រុកគិតថា សំរោងខ្ញុំ នេះជាសង្សារខ្ទើយរបស់ឯងនោះអី... ចំមែន!

គ្រាន់តែសំរោងទម្លាក់ទូរសព្ទ័ចុះភ្លាម កិត្យាខឹងឆេវ ឆេវថា ៖

CHANBOKEO.COM

- រាប់គ្នាជាពួកម៉ាកធ្វើអ្វី កាលបើមិនយល់ទុក្ខធុរៈគ្នាអញ្ចឹង ? បើ ឯងមិនមកទទួល ក៏យើងនៅមានផ្លូវដើរដដែលហ្នឹង ។

សត្យាក៏ទាញអាវពាក់ ឈរសម្លឹងម៉ូតូមួយស្របក់ ក៏គិតថា ៖

- ខ្ញុំមិនត្រូវយកម៉ូតូទៅជាមួយទេ ព្រោះខ្ញុំចង់ផឹកស្រា... ផឹក អោយណីម្តង... ផឹកលាងភាពធុញថប់ក្នុងចិត្ត ព្រោះតែនារីដែល យើងស្រឡាញ់ គេមិនស្រឡាញ់យើង មិនចាប់អារម្មណ៍ពីយើង... យើងនឹងផឹក! ផឹក! ផឹកហើយ ដេកតាមផ្លូវអោយឆ្កែលិទ្ធមាត់ម្តង ដើម្បីអោយពិភពលោកដឹងថា យើងឆ្កួតចិត្ត ត្បិតប្រពន្ធមិនព្រម អោយរួមដំណេកជាមួយ... ថ្វីបើយើងបានរៀបការត្រឹមត្រូវតាម ប្រពៃណីហើយក៏ដោយ ។

បន្ទាប់មក គេក៏ដើរចេញពីផ្ទះ សំដៅថ្នល់ធំ... ពេលនោះយប់ ជ្រៅបន្តិចហើយ ចរាចរក៏ស្ងាត់ ។ នរណាៗក៏ចូលនិទ្រាអស់ដែរ តើនឹងទៅរកម៉ូតូឌុបជិះនៅឯណាបាន ។ កិត្យាចេះតែដើរផង គិត ផង មិនដឹងដល់ត្រង់ណាទេ ក៏លើកទូរសព្ទ័ហៅមិត្តរបស់គេម្តង ទៀត ៖

- សំរោង! បើឯងមិនមកទទួលយើងពេលនេះទេ យើងនឹងឡើង ស្ពានជ្រោយចង្វារលោតទឹកសម្លាប់ខ្លួនយប់នេះហើយ ។

- នែ៎! នាយកិត្យាចំកួតអើយ! ហេតុអ្វីឯងគិតឆ្កួតៗអញ្ចឹង ? កុំធ្វើអ្វីផ្តេសផ្តាសណា៎ ពួទេ ? ការសម្លាប់ខ្លួនមិនមែនជាចម្លើយ សំរាប់ដោយស្រាយបញ្ហាក្នុងជីវិតទេ!

- យើងមិនធ្វើផ្តាសទេ បើសិនជាយើងមានគេឯងយល់ចិត្តយើង ខ្លះៗ!

- អឺ... អញ្ចឹង ចាំគ្នាស្តាប់រឿងឯងចុះ ក្រែងគ្នាយល់ចិត្តឯង ដើម្បី កុំអោយឯងធ្វើអ្វីផ្តេសផ្តាសដូច្នោះ ។ ឯងនៅចាំយើងត្រង់ហ្នឹង ហើយ ។ បន្តិចទៀត គ្នាទៅទទួល ។

ពាក្យគម្រាមរបស់កិត្យាពិតជាមានប្រសិទ្ធិភាពមែន ។

មិនបានកន្លះម៉ោងផង សំរោងក៏ជិះម៉ូតូមកដល់ ឌុបកិត្យាចេញ ទៅ ។

- ឯងទៅណាហ្នឹង សំរោង ?

- ទៅផ្ទះរបស់ខ្ញុំ ។

- ហើយ... នៅផ្ទះឯងហ្នឹងមានស្រាផឹកទេ ?

- ខ្ញុំមានដែលលក់ស្រាឯណា នឹងមានស្រាស្តុកទុកក្នុងផ្ទះនោះ ?

- បើអញ្ចឹង ខ្ញុំមិនទៅទេ... ខ្ញុំចង់ទៅកន្លែងណាដែលមានស្រាផឹក

CHANBOKEO.COM

វិញ ដើម្បីលាងអារម្មណ៍ហ្មួហ្មង ។
- យប់អាធ្រាតហើយ សម្លាញ់! តើមានហាងស្រាឯណាគេបើកថ្មើរ
នេះ ?
- ថីក៏មិនមាន ម៉េចក៏ថាអត់កើត ?
- មាននៅឯណាទៅ ?
- នៅហាងការ៉ាអូខេនោះអី ? ទៅទីនោះមានស្រាផឹក ហើយមាន
ចំរៀងអោយយើងស្រែកច្រៀងឡូឡាម៉ាសាឡាញ់ផង ។ ខ្ញុំកំពុង ចង់ច្រៀង...
- គ្នាមិនដែលឃើញឯងចេះច្រៀងផង ហេតុអីថ្ងៃនេះ ឯងចង់ ច្រៀងអីចឹង កិត្យា ?
- គឺអាស្អីដែលរុកគួនក្នុងបេះដូងខ្ញុំនេះ វារំខានពេក បានជាចង់
ស្រែកច្រៀងទម្លាយអារម្មណ៍ខ្លះៗ...!
សំរោងដកដង្ហើមយូ បន្ទូរទ្រូងជន្លួសពួកម៉ាក...

នៅក្នុងបន្ទប់ការ៉ាអូខេមួយដែលមានតែសំរោងនិងកិត្យា...
នារីបំរើពីរនាក់គោះទ្វារហើយដើរចូលមក សួរថា ៖
- បង! ត្រូវការនារីកំដរប៉ុន្មាននាក់ដែរ ?
កិត្យាងើបមុខឡើងមើលនារីដ៏ស្រស់សោភាពីរនាក់នោះ ឃើញ
នាងផាត់ម្សៅលាបក្រែមយ៉ាងស្រស់ ។ គេក៏ឆ្លើយថា ៖
- យើងមិនត្រូវការនារីមកបំរើទេ... យើងចង់បានតែខ្ទើយ!
នារីពីរនាក់នោះបែរសម្លឹងមុខគ្នា ញញឹមហើយក៏ស្រដីថា ៖
- សំណាងល្អណាស់! នាងខ្ញុំបាទ ទាំងពីរនេះក៏ខ្ទើយល្មម!
- ហ្អ៊ាស ? ថាម៉េច ?
- គឺ... ដូចបងចង់បាននោះអី!
កិត្យាយកដៃទះថ្ងាស ប៉ាច់ៗ ឧទានថា ៖
- ស្រេចហើយ អាវ៉ាអើយ! ហេតុអីក៏យើងមាត់ទិព្វម្ល៉េះលោក ?
សំរោងលួចញញឹម ហើយស្រដីតិចៗដាក់ពួកម៉ាក ថា ៖
- សមមុខហើយ! និយាយធ្វើដូចមិនដែលដឹងថា ស្រុកខ្មែរឥឡូវ មានខ្ទើយស្អាតៗ
បំរើភ្ញៀវដែរទេហ្អីហ្នឹង ?

CHANBOKEO.COM

រំពេចនោះ កិត្យាបែរមុខនិយាយទៅពីរនាក់នោះវិញថា ៖

- តែយើងមិនពេញចិត្តនឹងមីអូនតយ័យឯងពីរនាក់ហ្នឹងទេ យើង ចង់បានចំរៀងការាអូខេ បទណាក៏បានដែរ អោយតែយើងអាច ស្រែកច្រៀងទម្លាយដួងចិត្តមកក្រៅ មានប្រសិទ្ធភាពបំផុត ។
- បទណាមួយទៅបងសម្លាញ់ ? (នារីខ្មើយសួរ)
- សួរច្រើនម៉េះ ?... យើងប្រាប់ហើយ ថាអាបទណាក៏បានដែរ អោយតែជាបទដែលធ្វើអោយយើងអាចស្រែកម៉ាវ៉ាសភ្លាម ធ្លាយពោះវៀនចេញតាមមាត់ទាំងចង្វាយ !

នារីបំរើពីរនាក់នោះបើកភ្នែកធំដោយការភ្ញាក់ផ្អើល រួចហើយ ក៏សួរកិត្យាព្រមគ្នា ថា ៖

- នៅស្រុកខ្មែរនេះ មានអាបទបែបហ្នឹងដែរ ?
- ខ្វះអី ! មានទាំងអាបទដែលដាក់ម៉ាវ៉ាស ធ្លាយចេញគ្រប់កន្លែង យាត់មិនជាប់ផង សូម្បីតែអ្នកស្តាប់ក៏ធ្លាយតាមដែរ (កិត្យាឆ្លើយ)
- អូហ៍ មានបទស្ទីអញ្ចឹងដែរ ? នាងខ្ញុំបាទដូចជាមិនដែលដឹង..!
- ម៉េចក៏ថាមិនដែលដឹង ? នោះគឺបទព្រាបសុវត្ថិនោះអី !
- ហ្វាក់ ! ខ្ញុំថាព្រាបសុវត្ថិច្រៀងពិរោះណាស់ ! ម៉េចក៏បានជាអ្នកច្រៀងក្តី អ្នកស្តាប់ក្តី បែរជាធ្លាយគ្រប់កន្លែងយ៉ាងហ្នឹង ?

កិត្យាញាក់មុខហើយអង្គុយធ្វើព្រងើយមិនចង់ឆ្លើយ ។ សំរោង ឃើញហើយក៏តបជំនួសថា ៖

- គឺមកពីស្រែកច្រៀងកាលណា បែកញើសចេញតាមរោមគ្រប់ កន្លែង កាលហ្នឹងនោះអី !
- អូហ៍ អញ្ចឹងទេហ្វ៉ស !

នារីខ្មើយពីរនាក់នោះសើចហៃសៗ ហើយក៏ដើរចេញទៅ ។

ការពិត កិត្យាមិនដែលដើរលេងផឹកស្រាពីមុនមកទេ ។ នេះជាលើកទីមួយហើយដែលគេធ្វើបញ្ជោះជីវិតខ្លួនឯង ។ សំរោងឃើញកិត្យាលើកស្រាអកទាំងមុខជូរហួញ ហាក់បីដូចជាស្រានោះមានដាក់គ្រាប់ពងថ្ងៃឲ្យគេផឹកលេបទាំងគ្រាប់អញ្ចឹង ។ បន្តិចមក កិត្យាក៏លើកក្បាលមីក្រូមកស្រែកវ៉ូងវ៉ាងឡើង... ទំនងដូចជាកំពុងចង់ បារពោះវៀនអោយចេញតាមមាត់ដូចគេថានោះហើយ ។

CHANBOKEO.COM

- បានហើយកិត្យា! នេះឯងច្រៀងឡើងដោះអាវដោះខោជិតអស់ ពីខ្លួនហើយ ។
គ្នាដូចជាវេទនាភ្នែកដល់ហើយ ។ តើកាលណាបាន ឯងច្រៀងអស់ចិត្តហ្នឹង ?
- មិនទាន់អស់ចិត្តទេ... សុំស្រែកម៉ាសន្ទុះទៀតសិន ។
ថាហើយ កិត្យាក៏ចាប់ស្រែកច្រៀងវ៉ូងៗតទៅទៀត ។ សំរោង ក៏គ្រវីក្បាលឡើង ។
- គ្រវីក្បាលរឿងអីហ្នឹងសំរោង ?
សំរោងមិនឆ្លើយទេ បែរជាសួរត្រឡប់ទៅវិញថា ៖
- ដឹងទេ ថាកិរិយាឯងពេលនេះ ដូចស្អីដែរ ?
- ដូចអ្វីទៅ សំរោង ?
- គឺដូចយក្សស៊ីដីរីហាល់ ក្លៀនជុះមិនចេញ!
កិត្យាភ្ញាក់ព្រើតស្វាងស្រាតែម្តង ៖
- តោះទៅផ្ទះវិញ! (កិត្យាពោល)
- ឈប់ច្រៀងហើយហ្ន៎ស ?
- ឈប់ហើយ ព្រោះគ្នាមិនមែនជាយក្សក្លៀនដីពេញពោះ ។
- ល្អ! គ្នាកំពុងងុយគេងស្រាប់ផង!
សំរោងក៏បើកទ្វារបក់ដៃហៅនារីបំរើមកគិតប្រាក់ ស្រាប់តែនារី ខ្មើយពីរនាក់នោះលាន់មាត់ ៖
- ស្លាប់ហើយ ច្រៀងមិនទាន់បានប៉ុន្មានបទផង ម៉េចប្រញាប់ទៅ ម្ល៉េះបង ?
យើងនៅមានអ្វីល្អៗទទួលបងទៀត ។
- អឺ... បើអញ្ចឹង យើងសុំផ្ញើទុកសិន ចាំលើកក្រោយមកតរឿង ទៀត (សំរោងឆ្លើយ)
អស់ថ្លៃប៉ុន្មានដែរ ?
- ៣៨ដុល្លារ!
- ហ្ន៎ស ថាម៉េច ? ៣៨ដុល្លារ ? អីក៏ថ្លៃម្ល៉េះនាងអូនតយង៉យ ?
- មិនថ្លៃទេ! នេះជាតម្លៃស្តង់ដារចំរៀង បើសិនជាមានការបំរើ ពិសេស
ត្រូវអស់ជិត១០០ដុល្លារឯណោះ ។
សំរោងមិននិយាយអីទេ ក៏រាវប្រាក់អោយគេ ។ តាមផ្លូវត្រឡប់ មកវិញ
សំរោងរអ៊ូរដ៉ូវដាក់កិត្យា ៖
- ថ្ងៃក្រោយយកលុយមកសង កុំភ្លេចសងការផងណា៎ សម្លាញ់!
នេះប្រាក់ខែរបស់គ្នាមួយខែតែ៨៥ដុល្លារទេ គ្រាន់តែចូលកាភាអូខេ

CHANBOKEO.COM

ពីរម៉ោងអស់ដល់ទៅ៣៨ដុល្លារ... អោយតែរបៀបនេះតែពីរដង ខ្ញុំច្បាស់ជាងាប់មុនឯងមិនខានឡើយ ។

តែកិត្យាឆ្លើមិនរួច ព្រោះស្រវឹងដល់បន្ទុកហើយ ។ គេបែរជា សួរសំរោងថា ៖

- នែ៎! សំរោង! ឯងធ្លាប់មានប្រពន្ធហើយ តើឯងប្រាប់ល្បិចខ្លះក្នុងការលួងលោមប្រលោមចិត្តស្រីៗអោយគ្នាខ្លះបានទេ ?

សំរោងញញឹមហើយឆ្លើយថា ៖

- មានន័យថា ប្រពន្ធឯងមិនអោយឯងចូលមុង យប់នេះមែនទេ បានជាក្រហល់ក្រហាយនៅមិនសុខ ?

- គឺស្រដៀងៗហ្នឹង...

- មានន័យថាម៉េច ? គេដេញឯងមែនហ្អ៎ស ?

- គឺ... គេមិនបានដេញចំៗទេ តែគេធ្វើឫកតោះតើយមិនអោយខ្ញុំ ប៉ះខ្លួនគេទេ ។

- ស្រីក្រមុំព្រហ្មចារីយ៍ គេប្រកាន់ខ្លួនបន្តិចអញ្ចឹងឯង ។ គ្រាន់តែ ថ្នមចិត្តគេបន្តិចទៅអ្វីៗក៏តាមសម្រួលដែរ ។ យី! កិត្យាឯងនេះ តែប៉ុនហ្នឹងសោះ ក៏ធ្វើឫកជាងដីក់ដាក់ប្រពន្ធវិញ! ចំមែនតែម្តង!

- មានន័យថា...

- ត្រូវហើយ... ម្តងនេះ ឯងទៅសាកម្តងទៀតទៅ... យ៉ាងណាៗ ក៏កុំគិតខុសហើយនឹកតូចចិត្តតែផ្តេសតែផ្តាស ។ ម្យ៉ាងទៀត ឯងមិនត្រូវដើរចេញពីបន្ទប់ផ្សំដំណេកពេលយប់អាធ្រាត ទៅរកលោត ទឹកសម្លាប់ខ្លួនដូច្នេះទៀតទេ ឮហើយឬនៅ ?

កិត្យាងក់ក្បាល ទំនងដូចជាបានធូរចិត្ត ប៉ុន្តែ ជាតិស្រវឹងក្នុង ខ្លួនបានធ្វើអោយគេធីងធោង ដើរមិនរួចដោយខ្លួនឯង ។ សំរោងក៏ ជួយគ្រាហ៍មិត្តចុះពីម៉ូតូដើររហូតដល់មាត់ទ្វារផ្ទះ រួចផ្តាំថា ៖

- គ្នាសុំទៅដេកហើយ សម្លាញ់! ព្រឹកនេះ គ្នាអត់បើកទូរស័ព្ទទេ ដូច្នេះ យ៉ាងម៉េចយ៉ាងម៉ា... រៀនដោះស្រាយជីវិតដោយខ្លួនឯងខ្លះ ទៅ ឮហើយឬនៅ ?

ផ្តាំហើយ សំរោងក៏បត់ម៉ូតូត្រឡប់ក្រោយចេញទៅវិញ ។ កិត្យាក៏ឈ្ងោកដើរទ្រេតទ្រោតចូលផ្ទះវិញ ជួនអីមាលានីនៅអង្គុយងក់ចាំផ្លូវនរៈនៅក្នុងបន្ទប់ទទួលភ្ញៀវស្រាប់ ក៏ស្ទុះមកជួយគ្រាហ៍រូបគេ យកទៅដាក់ក្នុងបន្ទប់គេង ។

CHANBOKEO.COM

ប៉ុន្តែ ដោយហេតុតែស្រវឹងខ្លាំងផង ងងុយខ្លាំងផង គេក៏ប្រាសខ្លួនលើគ្រែ លង់លក់ស្រមុកខ្ញុរនៅមុន ពេលដែលគេអាចនិយាយពន្យល់អ្វីអោយមាលានីស្តាប់បាន ។ រីឯមាលានីវិញ រិតតែខ្ចាញ់នឹងកិរិយារបស់នាយ ខ្លាំងឡើងៗ ។

ថ្ងៃត្រង់ពេលបាយ...

នៅលើកន្ទេល ពូនងមីងមៀននិងកូនចៅជាច្រើននាក់ នាំគ្នាអង្គុយលើកន្ទេលបរិភោគអាហារ ។ មីងមៀនសួរមាលានីថា ៖

- កូននី! ហេតុអ្វីមិនហៅប្តីរបស់ឯងមកទទួលទានបាយ ?
- គឺ... គេមិនស្រួលខ្លួនណា៎ម៉ែ... គេកំពុងអស់កម្លាំង អោយគេ សំរាកសិនចុះ ។

មីងមៀនឃើញកូនមុខស្លាំង ហើយឃើញនាងមានភ្នែកក្រហម ទំនងដូចទើបតែពីយំហើយ ក៏បន្លឺវាចាទៅកូនស្រីថា ៖

- ជីវិតមានប្តី វាមិនសប្បាយដូចក្មេងៗខ្លះគិតនោះទេ ។ ការមាន គ្រួសារ គឺជាការទទួលបន្ទុកភារកិច្ចថ្មីក្នុងជីវិត ។ ដូច្នេះ កូនត្រូវ រៀនទទួលរក្សាហើយដោះស្រាយដោយសមត្ថភាពរបស់កូនហើយ! បើសិនមានបញ្ហាអី ត្រូវរៀនប្រឈមមុខរកកន្លែងចំណាងទាស់ចិត្ត ហើយរៀនស្រាយវាឡើង ដើម្បីកុំអោយជីវិតវាហ្មួហ្មង ។ ក្នុង៧ថ្ងៃ ដំបូងនៃជីវិតរៀបការ កូនមិនត្រូវអោយមានស្នាមទឹកភ្នែកស្រក់ ថ្ពាល់របស់កូនទេ ។ តាំងចិត្តអោយរឹងមាំណា៎កូន ទើបយើងអាច យកឈ្នះជីវិតដោយជោគជ័យបាន ។

មាលានីកំពុងតែមានអារម្មណ៍ល្អក់កករ កាលបើឮសំដីម្តាយ របស់នាងភ្លាម ស្រាប់តែមានកម្លាំងប្រឹសតែម្តង ។ នាងក៏ញញឹម កម្លាចិត្តម្តាយនាងឡើង ៖

- ខ្ញុំមិនអីទេ ម៉ែ! សូមម៉ែកុំព្រួយអី! អានីកូនម៉ែរឹងប៉ឹងណាស់!

មីងមៀនក៏ញញឹមតបវិញ ៖

- អញ្ចឹង! កូនត្រឡប់ទៅមើលប្តីវិញទៅ ។ ក្នុងមួយអាទិត្យនេះ មិនបាច់មកបំរើម៉ែពុកទេ ។ ត្រូវយកពេលនិយាយជាមួយប្តីអោយ ស្គាល់គ្នាបន្តិចសិនទៅណា៎ ហើយធ្វើយ៉ាងណាអោយគេមានអារម្មណ៍ កក់ក្តៅជិតដិតជាមួយកូន

CHANBOKEO.COM

រួចហើយចាំនាំគេអោយមកជិតដិត នឹង ពុកម៉ែព្រមទាំងប្អូន ដើម្បីអោយគេមានអារម្មណ៍ថាខ្លួនគេជា សមាជិកម្នាក់ក្នុងគ្រួសាររបស់យើងដែរ មិនមែនអ្នកក្រៅតទៅ ទៀតទេ ។

មាលានីស្តាប់ម្តាយពន្យល់ផង ជួយរៀបចំចានដួសអាហារបំរើ គ្រួសារថ្ងៃត្រង់ផង ។ ចំណែកឪពុករបស់នាងនៅអង្គុយក្បែរនោះ ដែរ ប៉ុន្តែមិនឃើញមាត់កអ្វីទេ ឃើញតែហៅកូនៗដទៃទៀតចូល បរិភោគបាយដូចទម្លាប់រាល់ថ្ងៃជាធម្មតា ។ បន្តិចមក មាណវីយើង ក៏លាងដៃលាងជើង ដើរចូលទៅបន្ទប់របស់នាងវិញ...

នៅចុងជើងកិត្យា...

មាលានីអង្គុយសម្លឹងមុខនរៈ ដែលកំពុងលង់លក់ក្នុងដំណេក ។ នារីល្អចជ្រួញចិញ្ចើម ស្រម័យនឹកទៅដល់អតីតកាលមួយរបស់នាង ដែលតែងតែមករំខានចិត្តមិនអស់មិនហើយ...

oooooooooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទីពីរ
# ជញ្ជីងដួងចិត្ត

ខែត្រព្រះត្រពាំង កម្ពុជាក្រោម...

ឆ្នាំ២០០៣...

នារីម្នាក់ អាយុប្រមាណ ១៨ឆ្នាំ ក្នុងសំលៀកអាវផាយសវែង ខោខ្មៅទើបជិះកង់ចេញពីសាលារៀន ដើរចូលក្នុងផ្ទះ ស្រាប់តែ ៖

- មាលានី! ពុករបស់ក្មួយមករង់ចាំទទួលទៅផ្ទះនែ៎ក!

នារីយើងងាកភ្លែត ឃើញឪពុកមារបស់នាង ឈ្មោះណាប់ ញញឹមដាក់នាង ថែមទាំងបួញមាត់ចង្អុលទៅបុរសចំណាស់ម្នាក់ ទៀតដែលអង្គុយរង់ចាំនៅក្នុងផ្ទះជាស្រេច ។

- ពុក! ជំរាបសួរ!

មាលានីចតកង់ទុកហើយប្រញាប់ស្ទុះរត់មកវន្ទាឪពុករបស់នាង ព្រមទាំងសួរថា ៖

- ពុកមកទទួលខ្ញុំធ្វើអ្វី ?

- គឺ ពួកយើងបានលើកដីស្រែអោយសាច់ញាតិយើង ហើយបំរុង នាំគ្នាទៅភ្នំពេញដើម្បីរកការធ្វើ ។

- ពុទ្ធោ ពុក! ខ្ញុំទើបតែបញ្ចប់ថ្នាក់ទី១១ មិនទាន់បញ្ចប់មធ្យម សិក្សាផង ធ្វើម៉េចនឹងខ្ញុំអាចមានតម្រេះរកការងារធ្វើបាននៅស្រុក គេទៅ ?

ការពិត មាលានីមករស់នៅជាមួយពូណាប់ដែលនៅធ្វើការឯទី ក្រុងដើម្បីទទួលការសិក្សា ។ បំណងរបស់នាង មានតែម្យ៉ាងទេ គឺរៀនអោយបានធ្វើជាវេជ្ជបណ្ឌិត

CHANBOKEO.COM

ដើម្បីត្រឡប់មកស្រុកជួយអ្នក ស្រុកក្រីក្រខ្វះខាត ដែលមិនមានសមត្ថភាពទៅព្យាបាលនៅទីក្រុង បាន ។ ដូច្នេះហើយ ទើបនាងចេញមករស់នៅឆ្ងាយម៉ែឪ តាំងពី តូចមក ។

ចំណែកឪពុកម្តាយរបស់នាងនៅស្រុកស្រែ រកស៊ីធ្វើ ស្រែចិញ្ចឹមមាន់ទា រស់នៅអត្តខាត់ណាស់ ។ ណាមួយកូនច្រើន ណាមួយមិនចេះអក្សរជ្រៅជ្រះ ។ ជីវភាពរបស់ពួកងមីងមៀន មានការខ្វះខាតក្រៃលែង ។

- ទោះជាយ៉ាងណា ម៉ែពុកបានសម្រេចចិត្តហើយកូន! ទៅរៀបចំ ឥវ៉ាន់មក ធ្វើដំណើរទៅផ្ទះវិញទាន់ភ្លឺនៅឡើយ ។

ឪពុកនាងមានប្រសាសន៍ប្រាប់នាងដោយសំដីស្រទន់ ប៉ុន្តែនារី បែរជាខកចិត្ត ស្ទើរតែស្រក់ទឹកភ្នែកទ្រហោយំនៅទីនេះតែម្តង ។ មាលាទីខំទប់ស្មារតី តាំងចិត្តក្លាហានមិនអោយឪពុករបស់នាងខក ចិត្តចំពោះនាងឡើយ ព្រោះនៅក្នុងចំណោមកូនទាំងអស់ គាត់មាន ជំនឿលើនាងច្រើនជាងគេក្នុងការជួយនាំមុខគ្រួសារសំដៅភាពចំរុង ចំរើន ។ ធីតាយើងក៏ឈ្ងោកមុខដើរស្ងៀមស្ងាត់ចូលទៅក្នុងបន្ទប់ ។

មាលានីបត់ឥវ៉ាន់ដាក់កន្ត្រកបណ្តើរ នឹកស្រណោះអាណិតខ្លួន បណ្តើរ ៖

- ឱ! សាលារៀនអើយ... ហេតុអ្វីខ្ញុំត្រូវឃ្លាតអ្នកទាំងតក្កហល យ៉ាងនេះ ? ខ្ញុំស្តាយណាស់... ដែលខ្ញុំគ្មានឱកាសស្គាល់អ្នកបន្តទៅ ទៀត... ឱ! មិត្តសម្លាញ់ទាំងឡាយ... សូមអភ័យទោសផង ដែលខ្ញុំ គ្មានឱកាសលាអ្នកជាចុងក្រោយ ។

ភ្លាមនោះ មាលានីស្រវាបានរូបថតយុវជនមួយរូប ក្នុងវ័យ ១៨-១៩ឆ្នាំ ដែលនាងសៀតទុកនៅក្នុងសៀវភៅចំណារប្រចាំថ្ងៃ របស់នាង ៖

- បងបែន! តើបងសុខទុក្ខយ៉ាងណាដែរ ប៉ុន្មានខែមកនេះ ? ខ្ញុំ ជិតត្រឡប់ទៅស្រុកវិញហើយ... ខ្ញុំនឹកបងណាស់ ដឹងទេ ? តើម៉ែ ពុកមានប្រាប់បងទេ ថាគាត់បំរុងនាំក្រុមគ្រួសារទៅរស់នៅភ្នំពេញ ទាំងអស់គ្នា រួមទាំងមាលានីផង ?

ធិតាលើកយករូបថតមកមើល រួចហើយក៏សៀតទុកទៅក្នុង សៀវភៅរបស់នាងវិញ ទើបប្រញិបប្រញាប់យួរកន្ត្រកខោអាវ ចេញមក ។

នៅមុខផ្ទះ មាលានីលើកដៃសំពះឪពុកមាររបស់នាង ព្រមទាំង ម្តាយមីង ដែលបានជួយទំនុកបំរុងអោយនាងរៀនសូត្ររហូតបាន ដល់ថ្នាក់ទី១១នេះ ថែមទាំងបានជួយបង្រៀនអក្សរខ្មែរនៅផ្ទះឲ្យ នាងចេះអានចេះសរសេរយ៉ាងច្រើនទៀតផង ។

CHANBOKEO.COM

- ពូ! ក្មួយជំរាបលាសិនហើយ!
មាលានីនិយាយទាំងសម្លេងរអួលៗរកកលនឹងយំ ។ ឪពុកមា របស់នាងឃើញដូច្នោះ
ក៏និយាយកម្លាចិត្តនាងថា ៖
- នៅភ្នំពេញ មានសាលារៀនទំនើបៗច្រើនណាស់ ។ អានីអាច ទៅចុះឈ្មោះរៀនបន្តបាន
មិនអីទេ! អោយតែក្មួយរស់នៅជួបជុំ គ្រួសារដោយសុខសប្បាយ
រឿងរៀនស្រួលដោះស្រាយទេ ។
- ចាស! លោកពូ!
បន្តិចមក ពូនងក៏នាំកូនស្រីឡើងរថយន្តឈ្នួលត្រឡប់ទៅស្រុក
វិញ ។ រំពេចនោះ ស្រាប់តែមានមិត្តនីរបស់មាលានីរត់មកពីខាង ណាមិនដឹង
ស្រាប់តែមកដល់ចំណតឡានដែរ ថែមទាំងលើកដៃ បបក់បបោយផ្តាំពីចម្ងាយមកថា ៖
- អានី! បើឃ្លាតទៅហើយ សូមចងចាំពួកយើងផង! បើជីវិត នៅភ្នំពេញមិនភ្លឺថ្លា...
ពួកយើងនៅទីនេះ នឹងស្វាគមន៍ការវិល ត្រឡប់របស់ឯងជានិច្ច ណាអានី!
យើងជាមិត្តនឹងគ្នារៀងរហូត ទៅ!
មាលានីក្រឡេកឃើញមិត្តនីពីលើរថយន្តឈ្នួលមក ហើយបាន
ស្តាប់ឮនូវពាក្យសំដីផ្ញើផ្តាំទាំងនោះគ្រប់ម៉ាត់ ។ បេះដូងនាងក៏រណ្តំ ឡើងដោយក្តីអាឡោះអាល័យ...
ទឹកភ្នែកពីរតំណក់ក៏លួចឆ្លៀតហូរ ចេញមកប្រឡៃងកែវភ្នែករបស់នាង...
ប៉ុន្តែមាលានីខំយកដៃផ្ទិត យ៉ាងរហ័ស មិនអោយឪពុករបស់នាងសង្កេតឃើញទាន់ទេ ។

ប៉ុន្មានម៉ោងក្រោយមក ពូនងនិងមាលានីក៏បានមកដល់ភូមិ កំណើតវិញ ។
ក្រុមគ្រួសាររបស់នាង បានរត់មកទទួលមាលានី យ៉ាងខ្សៀវខ្សា ។ ប៉ុន្តែ
ការស្វាគមន៍ដ៏កក់ក្តៅរបស់ពួកគេ មិនបាន ធ្វើអោយនារីយើងរីករាយសោមនស្សប៉ុន្មានឡើយ
ព្រោះពេលនេះ នាងកំពុងតែកាត់ផ្តាច់និស្ស័យជាមួយការសិក្សារបស់នាង ដែល
នាងធ្លាប់គេងគិតរំពឹងថានឹងរៀនចប់នៅឆាប់ៗខាងមុខនេះ ។
ក្រោយពីបរិភោគបាយជុំគ្រួសាររួចហើយ មាលានីក៏ដើរឆ្លង
វាលស្រែទៅដីភូមិមួយដែលនៅមិនឆ្ងាយពីផ្ទះនាងប៉ុន្មាន ។
- អូននី!
យុវជនម្នាក់កំពុងដឹកគោឡើងពីស្រែ ។ កាលបើក្រឡេកឃើញ

CHANBOKEO.COM

វត្តមានរបស់មាលានី គេក៏ស្រែកហៅទាំងភ្ញាក់ផ្អើល ។ មាលានី ឃើញបុរសហើយក៏ញញឹមស្ងួតតបទៅគេវិញ ។

- បងបែន សុខសប្បាយទេហ្អឹង ? ហេតុអ្វីបងមិនគង់ក្នុងផ្នួស តទៅទៀត អញ្ចឹង ? មានស្ដាយចំណោះចេះនឹងទេហ៍ ?

នរៈយើងយកគោទៅចងអោយស៊ីស្មៅ ទើបវិលត្រឡប់មករក ធិតាវិញ ហើយឆ្លើយថា ៖

- អានីនឹងហើយតើហ៍! ក្រុមគ្រួសាររបស់បងមានប្រុសតែម្នាក់ ។ កាលបើអត់ពីពុកទៅ គ្មាននរណាមានសមត្ថភាពរឹងប៉ឹងគ្រប់គ្រាន់ ធ្វើជាជំហរគ្រួសារទេ ទើបបងដាច់ចិត្តលាផ្នួស មកជួយប្អូននិងម៉ែ ធ្វើស្រែវិញ ដើម្បីផ្គត់ផ្គង់គ្រួសារ ។

អ្នកទាំងពីរដាក់ខ្លួនអង្គុយចុះនៅក្រោមដើមឈើមួយ ។ បែន អង្គុយស្ងៀម សម្លឹងមុខមាលានិយ៉ាងយូរទើប សួរថា ៖

- អានីមានឥរិយាបថប្លែកណាស់ មិនរីករាយដូចរាល់ដងទេ ។ អូន មានរឿងអ្វីរំខានចិត្ត មែនទេ ?

នារីងក់ក្បាល ៖

- ចាស់មែនហើយ! ក្ដីស្រម័យរបស់ខ្ញុំកំពុងមានដំណើរឈានចូល ទីងងឹតហើយ... ហើយរឿងរបស់យើង ក៏មិនដឹងថាមានដំណើរ យ៉ាងណា តទៅទៀតដែរ ។

- អូនចង់មានន័យថាយ៉ាងម៉េចហ្អឹង អានី ?

មាលានីធ្វើទឹកភ្នែករលីងរលោង ហើយឆ្លើយថា ៖

- បងបែន! បើសិនជាខ្ញុំផ្លាស់ទៅរស់នៅភ្នំពេញជាមួយពុកម៉ែ តើបងនៅរង់ចាំខ្ញុំដដែលទេ ?

- ថាម៉េច ? អូនផ្លាស់ទៅភ្នំពេញ ?

- ចាស! យើងនាំគ្នាទៅរកការធ្វើ ។ ចំណែកអូនវិញក៏ត្រូវឈប់ រៀនដែរ ។ មិនដឹងថា ខ្ញុំអាចចូលរៀនបន្តនៅស្រុកខ្មែរបានដែរឬ ក៏យ៉ាងណា ព្រោះកម្មវិធីសិក្សារបស់យើងខុសគ្នា ។

បែនដកដង្ហើមយូយ៉ាងវែងហើយឆ្លើយថា ៖

- បើនីនៅតែទទួលបង បងសន្យាថានឹងចាំទទួលអូនជាគូអនាគត រហូត មិនថាត្រូវចាំយូរប៉ុនណាទេ ។

- ពិតមែនហ្អេស ? ១០ឆ្នាំ ២០ឆ្នាំទៀត បងនៅចាំទេ ?

- ចាំ! បងសូមស្បថជូនអានីចុះ! មានតែអានីទេ ដែលបងត្រូវ ព្រួយ ព្រោះអានីមានឱកាសស្គាល់បុរសទីក្រុងដែលខ្ពង់ខ្ពស់ជាង បង មានឱកាសអាចរៀនសូត្រ

CHANBOKEO.COM

សាងជីវិតប្រសើរជាងបង... មិន ដឹងថា អានីនៅទទួលបងដែរឬទេ នៅរវាងប្អូនដប់ឆ្នាំខាងមុខ ទៀតនោះ... ព្រោះពេលនោះ បងក៏នៅតែជាបុរសស្រែចំការដ៏ សាមញ្ញមួយរូបនៅស្រុកផ្នូរលើនេះ មិនផ្លាស់ប្ដូរ ប៉ុន្តែអានីនិងក្លាយ ជាបញ្ញាវន្តឈ្លាសវៃ... មិនដឹងថា អូនគិតយ៉ាងណាចំពោះបង... ?

មាលានីនៅស្ងៀមមួយស្របក់ ទើបស្រដីវិញថា ៖

- តែអូនគិតថា ជូនពុកម៉ែនិងបងប្អូនទៅភ្នំពេញសិន ។ ពេល ដែលពួកគេបានការធ្វើ មានទីលំនៅសមរម្យហើយ ខ្ញុំនឹងត្រឡប់ មករៀនទីនេះវិញ ហើយយើងក៏មានឱកាសជួបជុំគ្នា ដូចដែល យើងធ្លាប់គ្រោងទុក ។ បងបែននៅចាំខ្ញុំណា! កុំធ្វើអោយនីខកចិត្ត ណាបង!
- បាទ! (បែនញញឹមឡើង) បងរង់ចាំអានីជានិច្ច ។
- មែនណា!
- ច្បាស់ហើយ! បងមិនអោយនីខកចិត្តទេ ។

ភ្លាមនោះ អ្នកទាំងពីរក៏ញញឹមដាក់គ្នាយ៉ាងចំព្រង បញ្ជាក់នូវ ជំនឿចិត្ត ចំពោះគ្នាទៅវិញទៅមក យ៉ាងជ្រាលជ្រៅក្រៃលែង ។

ព្រឹកស្អែកឡើង...

នៅចំណតឡានឈ្នួល...

ក្រុមគ្រួសាររបស់ពូនងក៏រៀបចំឥវ៉ាន់ដាក់ឡានឈ្នួល ។ នៅ ម្ខាងទៀត មីងមៀននិងកូនចៅកំពុងតែស្រវាអោបលាគ្នាជាមួយ ញាតិមិត្តក្នុងភូមិ ។ នៅក្រោយខ្នងពូនង មាលានីឈរស្ងៀមស្ងាត់ តែម្នាក់ឯង ភ្នែករំពៃរកមើលនាយបែន សង្សាររបស់នាង ។ ភ្លាម នោះ ឡានឈ្នួលក៏ស៊ីផ្លេអោយសញ្ញាចេញដំណើរ ។ ទាំងអស់គ្នាក៏ ស្ទុះស្រឡើងរថយន្តអស់ទុកអោយមាលានីឡើងក្រោយគេ ។

រថយន្តឈ្នួលវិលកង់ហើយ ។ មាណវីរេភ្នែករកមើលបែនម្ដង ទៀត ជាចុងក្រោយ ស្រាប់តែឃើញនរៈឈរទ្រោបមុខទៅលើដើម ឈើមួយ ទំនងលួចជូតទឹកភ្នែកតែម្នាក់ឯង ។ មាលានីក៏លើកដៃ បបក់បបោយឡើងទាំងទឹកភ្នែករលីងរលោង មិនដឹងថា នាយបែន បានឃើញសញ្ញាលាគ្នា របស់នាងជាចុងក្រោយនោះដែរឬក៏យ៉ាង ណាទេ ។ នារីក៏ចេញដំណើរទៅទាំងឱរាក្តុកក្តួលអួនណែននិយាយ មិនចេញ... ប៉ុន្តែ ធ្វើម៉េចបើនាងជាកូនស្រីហើយមិនទាន់ពេញវ័យ អាចគ្រប់គ្រងជីវិតដោយខ្លួនឯងបាន

CHIANBOKEO .COM

ដូច្នេះនាងត្រូវតែទទួលយក គ្រួសាររបស់នាង មុននាយបែនជាសង្សារហើយ ថ្វីបើបេះដូងរបស់នាងត្រូវរហែកឈឺចុកចាប់យ៉ាងណាក្តី ។

នៅភ្នំពេញ សង្កាត់ឬស្សីកែវ...

ពូនងរកបានផ្ទះតូចចង្អៀតមួយ ដែលមានតម្លៃពិបាកនឹងរៀប រាប់រួចហើយក៏បញ្ជូនកូនចៅធំៗអោយចេញដើររកការធ្វើ ។

មាលានីកាន់ធុងប្រអប់មួយដើរចូលផ្ទះទាំងទឹកមុខល្ហិតល្ហៃ ។

- បានចូលរៀនទេ មីអូន ?

ម៉ាឡា ជាបងស្រីរបស់នាង ស្រដីសួរ ។

- អត់ទេបង! ព្រោះគេថា ការសិក្សារបស់ខ្ញុំជាភាសាវៀតណាម ហើយពេលនេះខ្ញុំមិនមានកាន់បណ្ណ័គ្រួសារត្រឹមត្រូវនៅភូមិស្រុក គេនេះផង ។ ម្យ៉ាងទៀតវិជ្ជារបស់ខ្ញុំខាងអក្សរសាស្ត្រខ្មែរក៏នៅ ស្ទើរ លោកគ្រូថាប្រហែលជាមិនអាចរៀនទាន់គេនៅក្នុងថ្នាក់ទេ ។

- អញ្ចឹងមីអូនឯងគិតយ៉ាងម៉េចវិញ ? ទៅរកការងារនៅរោងចក្រ ដូចបងវិញហ្មែស ?

មាលានីដាក់ខ្លួនអង្គុយក្បែរបងស្រី ហើយស្រដីថា ៖

- បើសិនជាអាចចៀសបាន ខ្ញុំមិនចង់ធ្វើការរោងចក្រទេ បង! ខ្ញុំចង់ទៅរៀនវិញ ព្រោះថា...ក្តីស្រម៉័យរបស់ខ្ញុំគឺ មាលានីនឹងមាន មុខការជាពេទ្យថែរក្សាជំងឺ មិនមែនកម្មកររោងចក្រទេ ។

- តែជីវិតរបស់យើងត្រូវតែផ្លាស់ប្តូរតាមកាលៈទេសៈ ។ តើមីអូន ធ្វើពេទ្យយ៉ាងម៉េចនឹងកើត បើឯងចូលសាលាមិនបានយ៉ាងនេះ ?

- គឺខ្ញុំដើរធ្វើការខាងខាត់ក្រចក លាបក្រចកអោយគេ សំអិត សំអាងកាយអោយគេ តាមផ្សារ ឬតាមផ្ទះ តក់ៗរាល់ថ្ងៃទៅ ដើម្បី សន្សំកម្រៃសំរាប់ចូលរៀនវិញ ណា៎បង ។

- រៀននៅឯណា បើភ្នំពេញនេះ គេមិនទទួលឯងអោយចូលរៀន ផងនោះ ?

- គឺវិលត្រឡប់ទៅរៀននៅខែត្រព្រះត្រពាំងកម្ពុជាក្រោមវិញនោះ អី! ពេលណាខ្ញុំសន្សំលុយបានសមគួរ ខ្ញុំនឹងត្រឡប់ទៅវិញហើយ..

- ឯងហ៊ានដែរ បើទៅវិញម្នាក់ឯង ? ចំណែកពុកម៉ែវិញ ក៏ច្បាស់ ជាខឹងនឹងឯងស្លាប់ហើយ បើគាត់ដឹងថាឯងមានគម្រោងរត់ទៅនៅ ស្រុកកំណើតវិញ ។

CHANBOKEO.COM

- ខ្ញុំរត់ទៅរៀនទេតើហ៍ ហេតុអ្វីបានជាគាត់ត្រូវខឹងនឹងខ្ញុំផង ?
- ព្រោះគាត់នឹងគិតថា ឯងរត់ទៅរកនាយបែនសង្សាររបស់ឯង មិនមែនទៅរកសាលាទេ ។
- គាត់មិនបាននឹងរឿងបងបែននឹងខ្ញុំទេ! មានតែបងប៉ុណ្ណោះទេ ដែលដឹង ។
បើបងមិនជំរាបគាត់ ម៉ែពុកមិនខឹងនឹងខ្ញុំឡើយ ។

ម៉ាឡានៅស្ងៀម កាលបើឮដូច្នេះ ប៉ុន្តែក្នុងចិត្តនាង ហាក់ដូចជាមានការធុញថប់ព្រួយចំពោះប្អូនយ៉ាងណាមិនដឹង កាលបើដឹងថាមាលានីកំពុងរៀបចំផែនការត្រឡប់ទៅកម្ពុជាក្រោមវិញ ។

បន្តិចមក មាលានីក៏កាន់ធុងប្រអប់របស់នាង ដែលផ្ទុកនូវ ប្រដាប់ប្រដាសំរាប់សំអាងក្រចក សំអាងមុខ និងដៃជើង ដើរចេញ ទៅក្រៅ ដើម្បីបន្តការងាររបស់នាង ក្នុងការរកលុយសន្សំទុកទៅ រៀនបន្តវិញអោយចប់មធ្យមសិក្សា ។

ពីរបីខែក្រោយមក...

មាលានីកំពុងអង្គុយខាត់ក្រចក អោយភ្ញៀវម្នាក់នៅផ្ទះរបស់ គេ ដែលនៅឆ្ងាយពីផ្ទះជួលរបស់នាងប្រហែលជាមួយគីឡូម៉ែត្រ ស្រាប់តែមានបុរសសង្ហាម្នាក់ជិះម៉ូតូយ៉ាងថ្មីទំនើបមួយមកដល់ ។

- សួស្តី បងណោត! សុខសប្បាយទេ?

គេស្រដីទៅរកនារីម្ចាស់ផ្ទះដែលកំពុងអង្គុយអោយមាលានីខាត់ ក្រចក ។ ដាណោតក៏ងើបមុខឡើងញញឹម ៖

- ពុទ្ធោអើយ តារា! ទៅធ្វើការនៅសៀមរាប មិនដែលមកផ្ទះ រាប់ខែហើយ...
បងស្មានថាប្អូនភ្លេចផ្លូវមកផ្ទះយើងវិញហើយតើ!

តារាញញឹមហើយលើកដៃដោះវ៉ែនតាខ្មៅចេញពីភ្នែក រួច ហើយដើរចូលផ្ទះ ។ រំពេចនោះ គេក៏ទាក់ភ្នែកនឹងវត្តមានរបស់
មាលានីនៅក្នុងផ្ទះរបស់គេ ។

- គេជានរណាដែរ បងណោត ?

មាណពស្រដីផង លួចបូញមាត់ទៅរកមាលានី ដែលកំពុង ឈ្ងោកមុខ ខាត់ក្រចកជើងអោយដាណោតផង ។

CHANBOKEO.COM

- អូហ៍! គេមិនមែនជាអ្នករស់នៅក្នុងផ្ទះយើងទេ ។ គេគ្រាន់តែជាអ្នកសំអាងកាយអោយបងម្តងមួយយាមទេតើហ៎ ។ ល្ងាចនេះ បងត្រូវទៅញុំាការគេ ទើបហៅនាងអោយមកជួយបន្តិចទៅ ។

តារាដើរចូលទៅក្នុងផ្ទះ ប៉ុន្តែ កន្ទុយភ្នែកលួចបក់ឆាវៗភ្លិប ភ្លែត លើនារីយើង ។ ប៉ុន្តែ មាលានីមិនបានឃើញទេ ព្រោះ អាល័យអង្គុយធ្វើការសម្រិតសម្រាំងអោយដាណែត មិនបានចាប់ភ្លឹកនឹងក្រសែភ្នែករបស់បុរសសង្ហានោះឡើយ ។

បន្តិចមក មាលានីក៏លាចេញទៅ ។ តារាឈរមើលពីក្រោយ ឡើងភ្លឹកអារម្មណ៍ ។

- នែ! សម្លឹងគេម្លេះ តារា ? (ដាណែតខទាន)

តារាភ្ញាក់ព្រើត សើចខឹកៗហើយស្រដីថា ៖

- មកពីចាប់អារម្មណ៍នឹងសោភណ័នារីចម្លែកនោះអី បងណែត!

- ណើ្ហយ! តារាអើយ! វណ្ណៈដូចយើង ទៅចាប់ភ្លឹកអ្វីនឹងមនុស្ស អង្កាច់អង្កោចដើរខាត់ក្រចកលៀងជីវិតអញ្ចឹងនោះ ?

- គ្រាន់តែជាអ្នករកស៊ីខាត់ក្រចកសំអាងកាយអោយគេ តើមានអ្វី អន់ឬខូចខាតទៅបង ?

- គឺមនុស្សខ្វាត់ព្រាត់ណា៎... កុំសូវយកខ្លួនបៀតពេក ក្រែងប៉ះ មនុស្សមិនល្អទៅ ។

តារាជ្រួញចិញ្ចើមឡើងទំនងមិនយល់ស្របតាមការយល់ឃើញ របស់បងស្រីគេនោះឡើយ ។ ភ្លាមនេះ គេក៏ចាប់ម៉ូតូបញ្ឆេះ ។

- ទៅណាហ្នឹង តារា ?

- ទៅដើរលេងទីក្រុងភ្នំពេញនោះអី!

- ក្រែងប្អូនមកលេងផ្ទះហ្មែស ? ម៉េចក៏មិននៅផ្ទះ ? បន្តិចទៀត ប៉ាម៉ាក់ត្រឡប់មកវិញហើយ ។

- បាទ! ខ្ញុំទៅក្រៅម៉ាភ្លែត ចាំខ្ញុំត្រឡប់មកវិញអោយទាន់ពេល បាយជុំគ្នា ។

ថាហើយ គេក៏ហក់ឡើងម៉ូតូ បររឹងចេញទៅ ទុកអោយបងស្រីនៅឈរមើលពីក្រោយធ្វើភាំង ។ បន្តិចមក គេក៏បានមកទាន់មាលានីដែលកំពុងដើរយួរឆុងប្រអប់បំរុងចូលទៅផ្ទះមួយទៀត ។

- សួស្តី អ្នកសំអាង! (តារាហៅមាលានី)

នារីក៏ងាកមុខមករកតារាហើយឆ្លើយថា ៖

- លោកហៅខ្ញុំមែនទេ ?

- មែនហើយ! ខ្ញុំគ្រាន់តែចង់សួរថា អ្នកសំអាងទទួលសំអាត ក្រចកជើងក្រចកដៃបុរសដែរទេ ?

CHANBOKEO.COM

មាលានីញញឹម ៖

- ទទួលចាស! ប៉ុន្តែ មិនទទួលធ្វើតាមផ្លូវយ៉ាងនេះទេ ព្រោះមិន សមគួរ ណាមួយធូលីហុយផង ធ្វើមិនបានស្អាតឡើយ ។

- បើដូច្នោះ អ្នកសំអាងអោយខ្ញុំទៅកន្លែងណាដែរ ?

- គឺលោកត្រឡប់ទៅផ្ទះលោកវិញទៅ ចាំខ្ញុំទៅធ្វើជូនដល់ផ្ទះ ។

ភ្លាមនេះ តារានឹកឃើញដល់ដាណែតជាបងស្រី និងឪពុកម្តាយ ដែលបំរុងនឹងបរិភោគអាហារជុំគ្នា ដូច្នេះបើហៅទៅផ្ទះនាយពេល នេះ ដូចជាមិនសមកាលៈទេសៈទេ ។ គេក៏សួរវិញថា ៖

- ហើយចុះអ្នកសំអាងចូលផ្ទះមួយនេះ ដើម្បីធ្វើក្រចកដែហ៍ ?

- ចាស! គឺម្ចាស់ផ្ទះគេណាត់អោយមក ។

- ដូច្នេះ ខ្ញុំសូមចូលទៅផង ព្រោះខ្ញុំក៏មានមិត្តម្នាក់នៅផ្ទះនេះដែរ

ស្រីម្នាក់ក៏មកបើកទ្វាររបង ស្រាប់តែលាន់មាត់ឡើង ៖

- អូហ៍ សួស្តីតារា! ស្លាប់ហើយបាត់មុខបាត់មាត់យូរម្លេះ ?

- ទៅធ្វើការក្រៅខេត្រហ្នឹងណា៎ ទើបតែមកផ្ទះវិញថ្ងៃនេះ... ហើយ នឹកប្រានីពេកទើបឆៀងចូលលេង ។

ប្រានីញញឹមឡើង កាលបើឮដូច្នោះ ។

បន្តិចមក មាលានីក៏អង្គុយខាត់ក្រចកអោយប្រានីតាមភារកិច្ច របស់នាង ដោយទុកឱកាសឲ្យតារានិងប្រានីជជែកគ្នា ។ ចៃដន្យ តារាអង្គុយនិយាយលេងជាមួយប្រានី ដែលជាមិត្តធ្លាប់រៀនកាលពី នៅវិទ្យាល័យមែន ប៉ុន្តែភ្នែករបស់គេផ្តោតជាប់នឹងមាលានីមិនព្រិច សោះឡើយ ។ លុះខាត់លាបក្រចកអោយប្រានីហើយ មាលានីក៏ បែរមករកតារា ។

- ស្អីហ្នឹងតារា ? បុរសស្អីចង់អោយគេធ្វើក្រចកអោយ ? នែ៎.. កុំ ប្រាប់ខ្ញុំណា៎ថា តារាឯងជាខ្ទើយ! (ប្រានីឧទាន)

- ហើយសុំធ្វើជាបុរសខ្ទើយម្តងម្កាលផងមិនបានទេហ៍ ប្រានី ?

- មិនបានទេ..

- យី! មិត្តនីស្អី មិនចេះយោគយល់ស្គាល់ចិត្តមិត្តអញ្ចឹង ?

CHANBOKEO.COM

ការពិត ប្រានីមិនបានយល់ទេ ថាបុរសយើងកំពុងតែចង់មាន ទំនាក់ទំនងជាមួយមាលានី ។ ប៉ុន្តែទោះជាយ៉ាងណា តារាក៏ធ្វើមុខ ស្តីកអោយមាលានីកាន់ដៃកាន់ជើង កាត់ក្រចកខាត់សាច់ចុះឡើងៗ ទាំងទឹកមុខញញឹមពព្រាយ ។ គេសម្លឹងតាមម្រាមដៃរបស់នាង ដែលយកមកត្រងម្រាមរបស់គេដើម្បីកាត់ក្រចក... អូ៎យ! គួរឲ្យ រំភើបម្ល៉េះទេ ព្រោះគេមិនដែលមានស្រីណាហុចដៃអោយកាន់ ដូច្នោះ ម្តងណាសោះ មួយជីវិតមកហើយ ។

ពេលវេលានៃការរំភើបរំជើបរំជួលបេះដូងរបស់តារា បានត្រូវ កាត់យ៉ាងខ្លី ដោយពាក្យមួយម៉ាត់ថា ៖

- រួចរាល់ហើយលោក! (មាលានីស្រដីឡើង)
- អូហ៍ ហេតុអ្វីក៏ឆាប់ម្ល៉េះ ?
- ព្រោះលោកមិនត្រូវការលាបក្រចកដូចជានារីៗនោះអី!

តារានឹកឡើងស្តាយពេលណាស់ ដែលគេរកលេសអោយនារី កាន់ដៃកាន់ជើងរបស់ខ្លួនទៀតមិនបាន ។ ដោយទើសទាល់ គេក៏ ដកប្រាក់ហុចអោយនាង ស្រាប់តែមាលានីគ្រវីក្បាល ៖

- ក្រដាសប្រាក់ដល់ទៅ១០ម៉ឺនរៀល.. ? ខ្ញុំគ្មានប្រាក់រាយអាប់ទេ!
- បើអញ្ចឹង នាងយកទាំងអស់ទៅ (តារាតប)
- សូមទោស! ខ្ញុំសូមទទួលតែប្រាក់ថ្លៃកម្លាំងខ្ញុំចុះ លោក!

មាលានីស្រដីការពារជើងព្រួល ក្រែងលោបុរសយកប្រាក់ជន្ល ចិត្តនាង ។

- អញ្ចឹង ធ្វើម៉េចទៅ បើខ្ញុំគ្មានរាយ ?
- លោកជំពាក់សិនក៏បានដែរ ចាំថ្ងៃក្រោយលោកសងខ្ញុំវិញចុះ ព្រោះខ្ញុំស្គាល់ផ្ទះរបស់លោកហើយ ។
- ប៉ុន្តែតារាមិនចូលចិត្តជំពាក់ទេ ។ បើអញ្ចឹង អ្នកសំអាងឯងយក ទាំងអស់សិនចុះ ចាំថ្ងៃក្រោយ ចាំមកធ្វើការកាច់ជំពាក់វិញ យ៉ាង ម៉េចដែរ អ្នកសំអាង ?

មាលានីងក់ក្បាលយល់ព្រម ត្បិតយល់ឃើញថា នាងក៏ត្រូវការ លុយដែរ ហោចណាស់ពេលនេះ នាងមានម៉ូយប្រចាំ មិនបាច់ដើរ រកពេលក្រោយ ។ ភ្លាមនោះ ស្រាប់តែតារាលួចខ្សិប សួរនាងថា ៖

- ហើយចុះផ្ទះអ្នកសំអាងឯង នៅឯណាដែរ ?

មាលានីភ្ញាក់ព្រើត ហើយឆ្លើយថា ៖

- នៅជិតៗនេះឯង ។ ថ្ងៃក្រោយជួបគ្នាទៀត ចាំ៎ស!

ការពិត នារីយើងហាក់ដូចជាចាប់ភ្លឹកបន្តិចហើយថា តារាបានផ្តល់ចំណាប់អារម្មណ៍មកលើនាង យ៉ាងពិសេស ។ ដោយខ្លាចចិត្ត ម្ចាស់ផ្ទះផង ខ្លាចចិត្តតារាផង នារីក៏ដើរគេចយ៉ាងលឿនចេញពីផ្ទះ មួយនោះ ទាំងដួងចិត្តញាប់ញ័រចម្លែកខុសធម្មតា ។

រីឯបុរសយើងវិញ ក៏ឈរសម្លឹងតាមមើលនារីរហូតដល់នាងបាត់ស្រមោលទៅក្នុងហ្វូងមនុស្សនិងចរាចរទាំងឡាយ តាមដងផ្លូវ នោះទៅ ។

*ooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទីបី
# ងង៉ក់

ក្រុងភ្នំពេញ ឆ្នាំ២០០៧...

នៅក្នុងបន្ទប់ដ៏តូចចង្អៀតក្រៃលែង ដែលមានតែគ្រែមួយ និង មនុស្សពីរនាក់ គឺ មាលានី និងកិត្យា...

កិត្យាប្រែខ្លួនឡើង បើកភ្នែក ក៏ឃើញមាលានីអង្គុយត្របោម ជង្គង់ ផ្អែកខ្នងទៅនឹងជញ្ជាំង សម្លឹងមុខនរៈ ធ្វើមុខស្លូត បើកភ្នែកម៉ក់ៗ ។

- អូននី! (កិត្យាហៅនារីខ្សិបៗក្នុងមាត់)

គេស្ទុះងើបឡើងទាំងសើងមម៉ើង ស្រាប់តែមានអារម្មណ៍ថា នៅវិលមុខធីងធោងនៅឡើយ ។ គេក៏ដាក់ក្បាលទៅលើខ្នើយវិញ ហើយលើកដៃបបក់ហៅប្រពន្ធ ៖

- នី! មកជិតបងបន្តិចបានទេ អូន ?

មាលានីសម្លឹងមុខបុរសមួយស្របក់ ក៏រំកិលខ្លួនទៅជិត ស្រាប់តែកិត្យាស្រវាអោបនាងផ្ទាប់នឹងទ្រូងរបស់គេយ៉ាងណែន រួចហើយក៏សួរខ្សិបៗដាក់ត្រចៀកនាងថា ៖

- យប់មិញ មាននឹកបងខ្លះទេ នីអូន ?

ក្លិនស្រាដែលបង្ហើរមកតាមដង្ហើមរបស់កិត្យា ផ្សំនឹងការដែល បាត់រូបនាយពីផ្ទះពេញមួយយប់ក្នុងរាត្រីផ្សំដំណេក ដោយមិនដឹង ថាទៅណាមកណា បានធ្វើអោយមាលានីនឹកខ្នាញ់នៅក្នុងចិត្តឡើង សាជាថ្មីម្តងទៀតហើយ ។ មាណវីក៏បម្រះរឹង

CHANBOKEO.COM

ចេញពីរង្វង់ដៃរបស់ កិត្យា ស្វាមីរាត្រីទឹកឃ្មុះរបស់នាង រួចហើយដើបទៅអង្គុយនៅចុង ជើង ចងចិញ្ចើមទិប លែងរសាយតែម្តង ។

កិត្យាឃើញឫកពារបស់មាលានី ហាក់ដូចជាចង់តែគេចឆ្ងាយពី រូបគេ មិនព្រមមកនៅក្បែរសោះ សូម្បីតែគេបានរៀបការជាមួយ នាងត្រឹមត្រូវតាមប្រពៃណីទៅហើយក្តី ។ ពេលនេះ គេនឹកតូចចិត្ត កាន់តែខ្លាំងឡើងជាងម្សិលមិញទៅទៀត ។ កិត្យាបើកភ្នែកឡើង សម្លឹងភរិយា ដោយក្រសែភ្នែកសោកស្តាយ យ៉ាងណាមិនដឹងទេ ដែលគេស្រឡាញ់នារីអស់ពីបេះដូង ប៉ុន្តែមាលានីបែរជាមិនទទួល ស្គាល់នូវអារម្មណ៍របស់នរៈអ្វីបន្តិចទៅវិញ ។

ការពិត មាលានីគេងនឹកព្រួយបារម្ភពីកិត្យាពេញមួយយប់ ស៊ូ នៅរង់ចាំមិនហ៊ានធ្មេចភ្នែកគេង ប៉ុន្តែ ហេតុអ្វី ពេលនាងឃើញ គេមកដល់ចំពោះមុខទៅហើយ បែរជានឹកឃ្នាន់ខ្នាញ់មិនចង់នៅ ជិតគេ ថ្វីបើរូបគេខិតខំបង្ហាញនូវភាពរំជើបរំជួលក្នុងចិត្តរបស់គេ ចំពោះនាងយ៉ាងណាក៏ដោយ ។ មាលានីនៅតែនឹកខ្នាញ់នឹងបុរស យើងដែលដើរចោលនាងពេញមួយរាត្រី... ខ្នាញ់ដែលគេមិនផ្តល់ ឱកាសអោយនាងសម្របសម្រួលខ្លួនចំពោះជីវិតគូស្រករ... ខ្នាញ់ ដែលគេដោះស្រាយអារម្មណ៍អាប់អួរ ដោយការដើរចេញពីផ្ទះ... ខ្នាញ់ដែលគេមិនចេះយកពេលនិយាយគ្នាតាមសម្រួល ជាមួយនាង អោយយល់ចិត្តគ្នាទៅវិញទៅមក ។

កិត្យាគេងសណ្តូកជើង យកដៃគងថ្ងាសសម្លឹងមុខមាលានីមិន អស់មិនហើយ ប៉ុន្តែ ក៏មិនហ៊ាននិយាយស្តីអ្វី ព្រោះខ្លាចប៉ះពាល់ ដល់អារម្មណ៍របស់នាង ក្រែងលោនារីកាន់តែងឹក់ឡើងចំពោះ នាយសាជាថ្មី ។ ចំណែកមាលានីអង្គុយត្របោមជង្គង់ ធ្វើមុខស្លូត ចងចិញ្ចើម សម្តែងការខ្វល់ខ្វាយក្នុងចិត្ត ទម្លាយអារម្មណ៍មិនចេញ បានត្រឹមតែលួចចោលកន្ទុយភ្នែកដាក់កិត្យាវិញម្តងៗតែប៉ុណ្ណោះ ។

ពេលវេលាបានហោះទៅយឺតៗ នៅក្នុងបន្ទប់...

ទាំងពីរនាក់អាល័យតែលួចអង្គុយ លួចគេងពិចារណាអំពីជីវិត គូស្រកររបស់គេ មិនបាននឹកនារកអាហារថអែតពោះទេ ។ ភ្លាម នោះ កិត្យាក្ងរពោះគ្រូកៗ លាន់សូរមកក្រៅ តែគេបែរជាគេងធ្វើ មិនដឹង ព្រោះគេអាល័យតែចាប់អារម្មណ៍លើចិញ្ចើមជ្រួញរបស់ ប្រពន្ធ ។ ភ្លាមនោះ មាលានីក៏ស្ទុះដើបឡើង ៖

CHANBOKEO.COM

- បងកិត្យា ហៅបាយហើយ មែនទេ? បងងើបទៅលប់មុខសិន ទៅ! ចាំខ្ញុំទៅរៀបបាយជូនឥឡូវនេះ ។

និតាស្រដីផង បើកទ្វារបន្ទប់ចេញទៅផង ទុកអោយកិត្យាបែរ សម្លឹងតាមនាងដោយកិរិយាអស់អែកក្នុងចិត្ត ។

នៅលើកន្ទេលក្នុងផ្ទះបាយ កិត្យាទទួលអាហារយ៉ាងស្ងៀមស្ងាត់ បំផុត ។ យូរៗម្តង គេលួចចោលកន្ទុយភ្នែកដាក់នារី ក្នុងចិត្តបន់ អោយនាងសួរខ្លួនអំពីគេដែលបានគេចខ្លួនទៅដើរលេង យប់មិញ ប៉ុន្តែ គេបរិភោគបាយរួចហើយ នៅតែមិនឮនាងសួរនរ:អ្វីមួយ ម៉ាត់សោះ ។

ភ្លាមនោះ គេគិតក្នុងចិត្តថា ៖

- តើយើងគួរនិយាយជាមួយនាងពេលនេះ? ឬក៏ចាំស្អែក អោយ នាងត្រជាក់ចិត្តបន្តិចសិន?... ណ្ហើយ! ចាំស្អែកសិនក៏បានដែរ ព្រោះជជែកគ្នា ពេលមានអារម្មណ៍មិនល្អ នាំតែល្អក់កករចិត្តលើស ដើមទេ ។

អាស្រ័យហេតុនោះហើយ ទើបកិត្យានៅស្ងៀម មិនព្រមមាត់ក អ្វីដាក់មាលានីទេ គ្រាន់តែលួចមើលមុខនាងប៉ុណ្ណោះ ។

- នែ៎! ពីរនាក់នេះ គហើយទេដឹង បានជាថ្ងៃនេះ មិនឃើញ និយាយអ្វីជាមួយគ្នាសោះ?

ម៉ាឡាជាបងស្រីរបស់មាលានី ចំអន់ ។ នារីយើងឮហើយ ក៏ ចោលកន្ទុយភ្នែកដាក់កិត្យា ឃើញនាយសម្លឹងមុខនាងភ្លៀកៗវិញ ដែរ ។ នាងក៏ពើជាញញឹម ហើយឆ្លើយថា ៖

- មកពីឃើញបងកិត្យាអស់កម្លាំង ទើបមិនសូវហ៊ានស្តីអ្វីនោះ!

កិត្យាឃើញមាលានីនិយាយស្តី គេនឹកត្រេកអរក្នុងចិត្តមកវិញ បន្តិច ។ ពេលនោះ គេក៏និយាយកម្លាចិត្តប្រពន្ធវិញថា ៖

- ដល់ស្អែកមានកម្លាំង យើងនឹងជជែកគ្នាអោយធ្លង់ត្រចៀកបង មិនខានទេ មែនទេ អូននី?

គេងៀងភ្នែកទៅរកមាលានី ទំនងចង់អោយនាងតបមកវិញ ថានារីនឹងនិយាយជាមួយខ្លួនស្អែកនេះ ដូចធម្មតា មិនស្ងៀមស្ងាត់ តោះតើយដូចថ្ងៃនេះតទៅទៀត ។ ចៃដន្យ មាលានីគ្រាន់តែញញឹម ស្ងួតហើយក៏ល្ហោកមុខប្រមូលចានយកទៅលាង ដោយមិនមានស្តី តបអ្វីជាមួយនាយមួយម៉ាត់ ។

ដោយឃើញកិរិយាតោះតើយរវាងគូស្វាមីភរិយាថ្មី មីងមៀនក៏ ហៅកូនទាំងពីរមកប្រាប់ថា ៖

- នេះកូនរៀបការរួចហើយ មិនមែនអ្នកដទៃចំពោះគ្នាតទៅទៀត

CHANBOKEO.COM

ទេណ៎! នេះធូបទៀនបារីស្លាធម៌ នាំគ្នាទៅវត្តថ្វាយបង្គំលោកមួយ ភ្លែតទៅ
ដើម្បីសុំសុខសេរីសួស្តីដល់ជីវិតគ្រួសារថ្មីរបស់យើង ។

ការពិត មីងមៀនដេញអោយអ្នកទាំងពីរនាំគ្នាទៅវត្ត ដើម្បី
អោយកូនមានឱកាសស្និទ្ធស្នាលនឹងគ្នាជាប្តីប្រពន្ធ ដោយមិនមាន
ការរំខានពីក្រុមគ្រួសារដែលរស់នៅអ៊ូអែក្នុងផ្ទះជាមួយគ្នា ។ ពូនង
នៅអង្គុយដំសំបកកំប៉ុងដែលកូនៗរើសបានមក កាលបើឃើញមីង មៀនដេញកូនអោយទៅវត្ត
គាត់ក៏បន្ទរឡើង ៖

- អឺ! ល្អណាស់កូន! ចេះទៅវត្តថ្វាយបង្គំលោកស្តាប់ធម៌ខ្លះទៅ
ដើម្បីឲ្យចិត្តកូនស្ងប់ស្ងាត់ត្រជាក់នឹងគ្នា ។ បើមានអ្វីខុសឆ្គង កូន
នឹងចេះអត់អោនអធ្យាស្រ័យនឹងគ្នាជានិច្ច ។ ទៅចុះណ៎ាកូន!

កិត្យានិងមាលានីអោនសំពះឪពុកម្តាយ ឡើងម៉ូតូចេញទៅ ។ តាមផ្លូវ
កិត្យាស្រវាលូកចាប់ដៃប្រពន្ធអោយអោបចង្កេះរបស់នាយ ហើយស្រដីថា ៖

- អង្គុយអោយស្រួលណ៎ាអូន! ប្រយត្ន័ធ្លាក់! ម៉្លុំនេះ ចរាចរមិន សូវមានអំណោយទានទេ ។

មាណពកាន់ចង្កូតម៉ូតូដៃម្ខាង ហើយយកដៃម្ខាងទៀត កាន់ដៃ
មាលានីអោយអោបចង្កេះនាយរហូត ថ្វីបើនាងបានបម្រះបម្រុង ទាញដៃចេញប៉ុន្មានដងក៏ដោយ ។

បន្ទាប់ពីចេញពីកុដិលោកគ្រូចៅអធិការមក កិត្យាស្រដីថា ៖

- ចង់ទៅដើរលេងឯណាទេ អានី ? យើងទៅដើរលេងយកខ្យល់ អាកាសបន្តិចណ៎!

នារីគ្រវីក្បាល ឆ្លើយថា ៖

- មិនដឹងទេ ស្រេចតែបងចុះ!

- អញ្ចឹង យើងចេញទៅដើរលេងនៅត្រើយម្ខាងបន្តិច ។

រំពេចនោះ ស្រាប់តែមានបុរសម្នាក់ជិះម៉ូតូមកដល់ក្បែរអ្នក ទាំងពីរ ។ កិត្យាងាកបែរមើល
ស្រាប់តែលាន់មាត់ឡើង ៖

- យី! សំរោង ? ឯងគេងឆ្អែតហើយនៅហ្នឹង ? យប់មិញអត់
ឯងុយអង្គុយកំដរខ្ញុំរហូតជិតភ្លឺឯណោះ ?

- ឆ្អែតហើយ! ហើយចុះឯងវិញនោះ ? មានត្រូវដំបងទេ ដែល
ចេញដើរចេញពីផ្ទះជិតម៉ោយប់ ?

- គឺ... បើឯងចង់ដឹង សួរប្រពន្ធខ្ញុំទៅ!

CHANBOKEO.COM

សំរោងញញឹមឡើង ហើយបែរទៅមាលានី រួចស្រដីថា ៖

- នែ៎ ប្អូននី! ថ្ងៃក្រោយ មើលៗប្ដីផង! យប់មិញ ប្អូនធ្វើអ្វីអោយ កិត្យាអន់ចិត្តហ្នឹង បានជាគេចេញទៅឡើងស្ពានជ្រោយចង្វាររកកល នឹងសម្លាប់ខ្លួន នៅយប់ផ្សំដំណេក អញ្ចឹង ?

មាលានីភ្ញាក់ព្រើត សម្លឹងមើលមុខសំរោង ទំនងចង់ដឹងថា តើ គេនិយាយលេងឬនិយាយមែនជាមួយនាង ។ ឃើញទឹកមុខរបស់ មាលានី សំរោងយល់ភ្លាម ថាមាលានីសង្ស័យ ។ គេក៏ស្រដីឡើង ជំរះអារម្មណ៍របស់នារីយើង ៖

- គឺ បងមិនបានកុហកទេ អានីអើយ! នាយកិត្យាប្ដីឯងចំរុងចេញ ទៅលោតទឹកសម្លាប់ខ្លួនមែន ធ្វើអោយបងលោះព្រលឹងទាំងយប់ សុខចិត្តអត់ងងុយរត់មកអង្គុយលោមគេរហូតទើសភ្លឺ អោយគេផឹក អោយគេស្រែកទម្លាយអារម្មណ៍ហ្នួហ្នង នៅហាងការាអូខេស្រីខ្មើយ ទំរាំកិត្យាស្វាងពីភាពតប់ប្រមល់ ទើបបងនាំមកផ្ទះវិញ ។ នេ៎ះ! ប្ដីឯងមិនបាននិយាយប្រាប់ឯងទេហ៎ តាំងពីមកដល់ផ្ទះវិញ ?

ឮប្រយោគនេះ មាលានីនឹកអាណិតកិត្យាគ្រលួចក្នុងចិត្តតែម្ដង ត្បិតនាងបានគិតច្រឡំពីរូបគេអោយស្រឡះឆេង ។ ចំណែកកិត្យា វិញ ភ្ញាក់ផ្អើលណាស់ ដែលសំរោងហែកកេរ្តិ៍ចំណុចខ្សោយរបស់ នាយអោយមាលានីស្ដាប់ ។ ការពិត រឿងខ្លះៗដែលជាចំណុច ខ្សោយរបស់បុរស គេមិនចង់អោយនារីដឹងទេ ខ្លាចនាងប្រមាថចិត្ត គេរិតតែខ្លាំងឡើង ។ ម្យ៉ាងទៀត គេចង់ប្រាប់នាងដោយខ្លួនឯង បើសិនណាមាលានីសួរគេផ្ទាល់ ។ កិត្យាមិនចង់អោយអ្នកទីបីមក បកស្រាយប្រាប់មាលានីជំនួសនាយឡើយ ។ ចៃដន្យ សំរោងធ្លាយការសម្ងាត់មុនអស់ ធ្វើអោយនាយបាក់មុខអស់រលីង ។ ភ្លាមនោះ គេក៏ដេញសំរោងត្រង់ៗ ៖

- នែ៎ សំរោង! បើមានការអ្វីនៅឯណា ក៏ទៅៗ ។ ខ្ញុំសុំខ្លួនជូន ប្រពន្ធដើរលេងសិន ។

ថាហើយ គេក៏បន្ថែមល្បឿនម៉ូតូបរវឹងចេញទៅ ទំនងមិនចង់ អោយសំរោងដេញទាន់ជាន់កែងរឿងរបស់គេ តទៅទៀត ។ រីឯ សំរោងវិញ ក៏មើលតាមក្រោយអ្នកទាំងពីរ លួចញញឹមហើយគ្រវី ក្បាលតែម្នាក់ឯង បន្ទាប់មក ក៏បត់ក្បាលម៉ូតូចេញទៅទិសម្ខាង ទៀត បាត់ទៅ ។

ការពិត សំរោងជាមិត្តរបស់កិត្យាតាំងពីកុមារភាពម្ល៉េះ ហើយ សំរោងទើបតែស្គាល់មាលានី ពេលដែលនាងចូលធ្វើការនៅរោង ចក្រ ជាមួយនាយ កាលពីឆ្នាំទៅមិញ ។ គេរាប់អាននាងដូចជាប្អូន ស្រីម្នាក់ ព្រោះមាលានីធ្វើការហ្មត់ចត់ រហ័សរហួន ហើយទទួលខុសត្រូវកិច្ចការបានល្អផង ។ ជាពិសេស នៅកន្លែងការងារ នារី

CHANBOKEO.COM

យើងរួសរាយរាប់អានមិត្តគ្រប់ៗគ្នាដោយមិនឆ្មើងកន្ទ្រើង ថ្វីបើ ក្រោយមក មាលានីបានឡើងលំដាប់បុណ្យសក្តិជានាយកោយកម្មករ ម្នាក់ ដូចសំរោងហើយក៏ដោយ ។

នៅសួនច្បារក្បាលជ្រោយ...

កិត្យាចតម៉ូតូ ហើយក៏ដើរនាំមាលានីទៅអង្គុយនៅកៅអីថ្មមួយ ក្រោមម្លប់ដំបូលសាលាសំណាក់សំរាប់លំហែកាយ ទទួលខ្យល់ អាកាសបរិសុទ្ធពីផ្ទៃទន្លេខ្មែរ នៅមុខបរមរាជវាំង ។ នីតាយើងបែរសម្លឹងទឹករលកព្រិចៗ ក្រោមផ្ទៃមេឃស្រកានាគ ប្រដេញគ្នា ជាសោភណ័យ៉ាងស្រស់ត្រកាលមួយ... ធ្វើអោយនាងនឹកឃើញទៅ ដល់អ្វីៗទាំងឡាយក្នុងជីវិតរបស់នាង ដែលវិវត្តន៍ផ្លាស់ប្តូរខុសពី ចិត្តដែលនាងបានប៉ងទុកមកពីមុនទាំងអស់ ។ និតាដកដង្ហើមយូ យ៉ាងវែង បន្ធូរនូវភាពតានតឹងក្នុងចិត្ត ។

ឃើញកិរិយាស្រពោនរបស់ភរិយា កិត្យាយកដៃអង្អែលកេសា នាងថ្នមៗ ហើយស្រដីថា ៖

- នេះជាពេលវេលាសុភមង្គលរបស់យើងណា៎អូននី! យើងគួរតែ រីករាយសប្បាយចិត្ត មិនមែនទេហ៎ ? បើអូនមានអ្វីរំខានក្នុងចិត្ត យើងអាចពិគ្រោះគ្នាបាន... ក្រែងលោបានធូរស្រាលមកវិញ នោះ ដួងចិត្តរបស់អូននឹងយល់សេចក្តីសុខខ្លះៗជាងមុន ។

មាលានីបែរមើលមុខកិត្យាមួយស្របក់ ហើយក៏ដាក់មុខចុះ រួច ស្រដីថា ៖

- មិនដឹងថា ជាការសមរម្យឬទេ បើអូននិយាយប្រាប់បង ?
- មានរឿងអ្វីទៅដែលថាមិនសមរម្យនោះ អូននី ? យើងរៀបការ នឹងគ្នាហើយ មានន័យថា យើងមានដំណើរជីវិតតែមួយ រួមសុខ រួមទុក្ខជាមួយគ្នា ។ ទុក្ខសោករបស់អូន គឺជាទុក្ខសោករបស់បង ដែរ ។ បើសិនជាមានអ្វីរំខានចិត្ត អូនប្រាប់បងមក យើងនឹងជួយ គ្នាដោះស្រាយ ។
- តែរឿងរបស់អូនសាំញ៉ាំណាស់! បងច្បាស់ជាធុញទ្រាន់មិនខាន
- មិនទាន់និយាយប្រាប់បងផង ម៉េចក៏ដឹងថាបងធុញទ្រាន់ ?

មាលានីមិនឆ្លើយទេ បែរជាសម្លឹងទៅក្មេងកំពុងដើរយួរទ្រុង ចាបក្បែរនោះ ក៏ស្រដីបន្លប់ថា ៖

- គឺថា ពេលនេះអូនចង់ព្រលែងចាបពីរបី ដើម្បីបណ្តោះអារម្មណ៍ ហ្មួហ្មងចេញ ។ បងទៅព្រលែងជាមួយអូនទេ ?

CHANBOKEO.COM

- ទៅ! បងក៏ចង់រំដោះក្ដីតប់ប្រមល់ក្នុងចិត្តដែរ ។ តោះអូន!

មាលានីញញឹមឡើង កាលបើអ្នកទាំងពីរនិយាយត្រូវគ្នាវិញ ។

កិត្យាបានទិញកូនចាបមួយឡូ រួចហើយស្រដីថា ៖

- ម៉ោះ! យើងចែកគ្នាម្នាក់ពាក់កណ្ដាល ដើម្បីព្រលែង ។ ពេលនេះ អូននឹបន់ផ្សងទៅ តើអូនចង់ប្រាថ្នាយ៉ាងម៉េចខ្លះ ?

មាលានីញញឹមពព្រាយ លូកដៃទទួលចាបមួយពីកិត្យា ហើយក៏ដើរត្រសងទាំងគូសំដៅមាត់ទន្លេ ។ នារីលើកដៃប្រណម្យបន់ ក្នុងចិត្តតែម្នាក់ឯង ស្ងាត់ៗថា ៖

- សូមអោយអនាគតរបស់ខ្ញុំជួបតែភាពភ្លឺថ្លា កុំអោយខ្ញុំប្រទះតែ ការខកចិត្តទៅទៀត ចាប់ពីថ្ងៃនេះតទៅ!

រីឯកិត្យាវិញ បន់ស្រន់ថា ៖

- មិនថាត្រជាក់ក្ដៅយ៉ាងណា មិនថាក្រលំបាកឬយ៉ាងណា សូមអោយយើងរស់នៅជួបជុំគ្នាជាគ្រួសារតែមួយ ប្រកបដោយសេចក្ដីស្រឡាញ់យ៉ាងប្ដូរផ្ដាច់ស្មោះស្ម័គ្រភក្ដីចំពោះគ្នាទៅវិញទៅមក!

បន្ទាប់មក អ្នកទាំងពីរក៏បែរមុខញញឹមដាក់គ្នា ហើយក៏បើកទ្រុងឡើងព្រលែងចាបដំណាលគ្នា ។ កូនចាបតូចៗទាំងនោះក៏ហើរ ភិលឡើងទៅក្នុងអាកាស ។ កិត្យាស្រវាកាន់ដៃមាលានីហើយស្រដី ទៅកាន់នាងថា ៖

- សូមអោយយើងទាំងពីរបានទទួលសេចក្ដីសុខរៀងរហូតទៅ!

មាលានីសម្លឹងមុខមាណពដោយក្រសែភ្នែកភ្លឺថ្លាបំព្រង ។ រីឯភាពអាប់អួរតប់ប្រមល់ក្នុងចិត្ត តាំងពីព្រឹកព្រហាមមក ក៏រលាយ អស់រលីងពីបេះដូងរបស់នាង ។ ឃើញប្រពន្ធញញឹមដាក់យ៉ាង ស្រស់កិត្យារំភើបចិត្តណាស់ ក៏ឈ្ងោកខ្សិបដាក់ត្រចៀកនារីថា ៖

- ញញឹមអញ្ចឹងទៅ អូនស្រស់ស្អាតណាស់ ដឹងទេ ? ថ្ងៃក្រោយកុំភ្លេចញញឹមបែបនេះដាក់បងអោយបានញឹកញាប់ផងណា៎ ប្រពន្ធ សម្លាញ់!

មាលានីនឹកអៀនខ្មាសបុរស ថ្ពាល់ឡើងក្រហមទុំតែម្ដង ។

រំពេចនោះ កិត្យាដាក់ភ្នែកទៅម្ខាង ឃើញពួកអ្នកលក់កូនចាបកំពុងនាំកូនចៅរត់កន្ទ្រប់កូនចាបដែលហើរធ្លាក់ដីទាំងនោះមកវិញ ក៏ស្ទុះទៅឃាត់ពួកគេថា ៖

- មីង! កូនចាបទាំងនេះ គឺជាចាប ដែលពួកខ្ញុំបានទិញយកមក ព្រលែងអំបាញ់មិញនេះ ។ ហេតុអ្វីក៏ចាប់វាមកវិញដូច្នេះ ?

CHANBOKEO.COM

មីងម្នាក់នោះឮដូច្នោះ ក៏ឆ្លើយថា ៖

- លោកក្មួយបានទិញចាបទាំងនេះមែន តែក៏បានព្រលែងវាចោល ហើយ ហេតុដូច្នេះ គ្មានសិទ្ធិមកទាមទារទៅវិញទេ ។

- ប៉ុន្តែ វាមិនសមរម្យទេ ដែលមីងនាំកូនចៅទៅចាប់វាយកមក លក់សាជាថ្មី បែបនេះនោះ ។

- សមរម្យឬមិនសមរម្យ វាសម្រេចនៅលើក្រពះទេ លោកក្មួយ អើយ ។ បើមីងមិនធ្វើយ៉ាងនេះ តើបានចាបឯណានឹងអោយចាប់ លក់ទាន់ចិត្តនោះ ? ទោះនឹងចិញ្ចឹមវា ក៏ធំមិនទាន់សំរាប់លក់យក ប្រាក់លៀងជីវិតដែរ ។ កូនខ្ញុំច្រើននាក់ណាស់ ទារស៊ីរាល់ថ្ងៃ ហើយក៏មិនបានទៅរៀនទៅសូត្រនឹងគេដែរ ព្រោះយើងវាក្រ ។ គ្រាន់តែមីងរកស៊ីរបៀបៗនេះ វាមិនខុសទាស់អីទេ លោកក្មួយ ព្រោះមីងមិនបានធ្វើអ្វីទុច្ចរិត បង្កទុក្ខអោយអ្នកដទៃឯណា ?

- មែនហើយ មីង! មីងរកស៊ីនេះ សុចរិតមែនហើយ ព្រោះមីង មិនបានបង្កទុក្ខដល់នរណាទេ តែពេលនេះ ខ្ញុំគិតថា មីងកំពុងបង្ក ទុក្ខដល់គេខ្លះៗហើយ...

- នរណាគេទៅ ទទួលទុក្ខដោយសារមីងនោះ ?

- គឺ មីងកំពុងបង្កទុក្ខអោយកូនចាបនោះអី ព្រោះមីងយកវាជា ឈ្នាន់ ដើម្បីរកលុយចិញ្ចឹមកូន... ហើយមីងធ្វើអោយបំណាន់ប្រាថ្នា របស់ខ្ញុំមិនសំរេច ព្រោះខ្ញុំផ្សងព្រលែងចាបអោយគ្នាមានសេរីភាព តែគេមិនបានទទួលសេរីភាពដូចខ្ញុំផ្សងសោះ ។ ដូច្នេះបំណាន់ផ្សង របស់ខ្ញុំក៏មិនបានសំរេចដោយការព្រលែងសត្វទេ ព្រោះចាបទាំង នោះត្រូវមីងចាប់ដាក់ទ្រុងវិញដដែលជាដដែល ។ បើដូច្នេះមែន តើខ្ញុំគួរផ្សងព្រលែងចាបតទៅទៀតដែរទេ កាលបើខ្ញុំឃើញហេតុ ការណ៍យ៉ាងនេះទៅហើយ ? តើអោយបំណាន់របស់ខ្ញុំសក្តិសិទ្ធិម្តេច បាន កាលបើចាបដែលខ្ញុំព្រលែងទាំងនោះ មិនបានទទួលសេរីភាព ដូចដែលខ្ញុំបានផ្សងនោះ មីង ?

ភ្លាមនោះ មីងលក់ចាបធ្វើមុខស្រងូត បន្តិចមកក៏ឆ្លើយថា ៖

- មីងបានគិតថាមិនចង់ធ្វើដូច្នោះដែរ... ប៉ុន្តែ មីងក្រីក្រណាស់ លោកក្មួយអើយ! តើអោយមីងមានសមត្ថភាពអីនឹងរកលុយលៀង ជីវិតទៅ កាលបើមីងគ្មានតម្រេះវិជ្ជា ប្ដីក៏ស្លាប់ កូនៗក៏ល្ងង់អវិជ្ជា..

មាលានីឃើញទឹកមុខរបស់មីងលក់ចាប ដែលកំពុងយល់នូវ អំពើបាបរបស់ខ្លួនចំពោះសត្វ ក៏នឹករអាណិតគាត់ណាស់ ។ នាងនៅ ឈរគៀននោះ

CHIANBOKEO.COM

បានស្ដាប់ឮការសន្ទនារវាងអ្នកទាំងពីរយូរហើយ កាលបើឃើញ ស្ថានការណ៍ទំនងសោកសៅពេក ក៏ស្រដីថា ៖

- ណ្ហើយចុះមីង! ពួកខ្ញុំមិនហ៊ានជំរាបមីងទេ ថាគួររកស៊ីអ្វីដើម្បី លៀងជីវិត ។ ប៉ុន្តែ នៅកន្លែងទេសចរណ៍បែបនេះ មីងគួររកនឹក ធ្វើអ្វី ដែលទេសចរណ៍រីករាយនឹងជាវផង ហើយរក្សានូវសីលធម៌ វប្បធម៌ជាតិខ្មែរផង ហើយមីងក៏នឹងបានទទួលកម្រៃពីការលក់ដូរ នោះផង ។

- ដូចជាអ្វីខ្លះទៅ ក្មួយអើយ ?

មាលានីយកដៃឈ្លីថ្ងាសខំរកនឹក តែនឹកមិនឃើញ ក៏បែរទៅ រកកិត្យាអោយជួយ មួយស្របក់ស្រាប់តែគិតឃើញយោបល់មួយ ៖

- ចុះបើយើង បេះកំប្លោក ច្រៀកហាលថ្ងៃ ហើយរៀនកាច់ក្បាច់ ធ្វើជាកំប្រោង កន្ត្រាំង ស្នុក កន្ត្រកយួរ ជាអង្រឹង មានក្បាច់ មាន ម៉ូដប្លែកៗ យកមកលក់វិញ នោះយ៉ាងម៉េចដែរ មីង ? ខ្ញុំគិតថា ស្រុកយើងសំបូរកំប្លោកណាស់ ប្រហែលជាមិនពិបាករកទេ ។

ស្រាប់តែកូនស្រីជំទង់ម្នាក់ដែលនៅអង្គុយក្បែរនោះយូរហើយ ក៏ស្រដីឡើងថា ៖

- មែនហើយម៉ែ! នៅក្រោយផ្ទះតាយាយរបស់យើង មានបឹង កំប្លោកដែរតើហ៍ ។ បើសិនជាយើងធ្វើតាមបងស្រី ប្រហែលជា យើងអាចរកលុយបានខ្លះៗ មិនខាន!

មីងលក់ចាបក៏ងក់ក្បាល ហើយញញឹមដាក់កិត្យានិងមាលានី ៖

- អរគុណណាស់ដែលអ្នកទាំងពីរផ្ដល់ការណែនាំដល់ជីវិតរបស់មីង ចាំមើល ស្អែកៗ មីងសាកល្បងមុខរបរថ្មីនេះមើល៍ ក្រែងលោមីង កាក់កបនឹងគេ ។

- ចា៎ស!

- បាទ! មិនអីទេមីង!

អ្នកទាំងពីរឆ្លើយព្រមគ្នា ។ មុននឹងត្រឡប់ទៅផ្ទះវិញ កិត្យា បានដកប្រាក់ប្រាំពាន់ហុចទៅអោយមីងលក់ចាប ហើយស្រដីថា ៖

- ខ្ញុំក៏ជាអ្នកក្រដូចមីងដែរ ធ្វើការរោងចក្រ បានកម្រៃបន្តិចបន្តួច គ្រាន់នឹងលៀងក្រពះប៉ុណ្ណោះ ។ ប្រាក់នេះតិចតួចណាស់ ប៉ុន្តែ ខ្ញុំ សូមជូនមីងជាការលើកទឹកចិត្ត និងជាអនុស្សាវរីយ៍ដែលយើងមាន គំនិតដូចគ្នា ថាយើងមិនធ្វើបាបសត្វតទៅទៀត ហើយយើងនឹង ប្រកបមុខរបរអ្វីដែលសុចរិតជានិច្ច ដើម្បីភាពរុងរឿងក្នុងជីវិត របស់យើងទៅអនាគត ។ សង្ឃឹមថា ពេលខ្ញុំជួបមីងលើកក្រោយ

CHANBOKEO.COM

មីងនឹងក្លាយជាចៅកែលក់តវ៉ាន់អនុស្សាវរីយ៍ ធ្វើពីកំប្លោកក្នុងបឹង ក្រោយផ្ទះរបស់មីងមិនខាន មែនទេមីង ?

មីងក៏លើកដៃទទួលពរពីកិត្យា ថែមទាំងឧទានថា ៖

- ម៉ាជាតិ ម៉ាជីវិតមីងនេះ មិនដែលមាននរណាគេចិត្តល្អជួយផ្តល់ គំនិតរកស៊ីដល់មីងទេ អស់យ៉ាងត្រឹមជួយទិញចាបមីង ហើយក៏វិល ត្រឡប់ទៅវិញបាត់ទៅ ។ ពេលនេះ មីងសូមអរគុណក្មួយណាស់ ដែលជួយបំភ្លឺមីងអោយស្គាល់ផ្លូវរកស៊ី ហោចណាស់ក៏មីងបាន ទទួលគំនិត ទទួលមធ្យោបាយគួរចាប់អារម្មណ៍មួយដែរ ។ ចំណែក ប្រាក់ប្រាំពាន់របស់ក្មួយ ថ្វីបើមានតម្លៃតិចតួចពិតមែន ប៉ុន្តែ ទឹក ចិត្តនិងគំនិតរបស់ឯងដែលបានរំលឹកមីង ថ្ងៃនេះ ពិតជាមានតម្លៃ អស្ចារ្យវាស់មិនបានឡើយ ។

មីងលក់ចាបជូនពរអ្នកទាំងពីរម្តងហើយម្តងទៀត មិនចេះចប់ មិនចេះហើយ ព្រោះក្តីរំភើបចិត្ត ។

បន្ទាប់មក អ្នកទាំងពីរក៏លាមីងលក់ចាប ឡើងម៉ូតូត្រឡប់មក ផ្ទះ ។ តាមផ្លូវ អ្នកទាំងពីរមានអារម្មណ៍រីករាយស្រស់ថ្លាដួងចិត្ត ជាងមុនឆ្ងាយណាស់ ។ គេលួចញញឹមដាក់គ្នាជាញឹកញយ ហើយក៏ ស្រវាកាន់ដៃគ្នាយ៉ាងណែន តាំងពីក្បាលជ្រោយរហូតមក ដល់ផ្ទះ វិញ ដោយគ្មានរបេះ ទំនងហាក់ដូចជាមានជំនឿចិត្តចំពោះគ្នា ច្រើនជាងមុនឆ្ងាយណាស់ ។

នៅពេលបាយព្រលប់នោះ មីងមៀនលួចសង្កេតឃើញថា កូន ស្រីរបស់គាត់ ហាក់ដូចមានទឹកមុខញញឹមច្រើនជាងមុន មិនសូវ ចងចិញ្ចើម ធ្វើឫកហាក់ដូចជាទូលផែនដីម្នាក់ឯង ដូចកាលពីព្រឹក ទៀតឡើយ ។ បងប្រុសបងស្រីដែលរស់នៅជាមួយចេះតែនាំគ្នា បន្លំចំអន់ម្តងម្កាល ប៉ុន្តែមីងមៀនចេះតែលួចកេះអោយគេឈប់ ព្រោះខ្លាចនាំអោយមាលានីខ្មាស់ ហើយខ្ចក់ចិត្តខឹងនឹងប្តីរបស់នាង ដែលទើបនឹងរៀបការហើយ ។

នៅក្នុងបន្ទប់តែពីរនាក់...

នៅមុខកញ្ចក់ចាស់មួយផ្ទាំង មាលានីអង្គុយលើក្តារផ្ទះ យក ក្រមាច្បូតសក់អោយស្ងួតនឹងអាលសិតអោយស្អាត ព្រោះនាងមិន

CHANBOKEO.COM

ចង់ចូលដំណេកទាំងសក់មានសំណើម ។ ភ្លាមនោះ កិត្យាដើរចូល មកជិត
រួចហើយក៏ស្រវាចាប់ក្រមាពីដៃនាង ថែមទាំងវាចាថា ៖
- ម៉ោះ! អោយបងជូតសក់អោយអូនវិញណា៎!
មាលានីងើបមុខឡើងសម្លឹងមុខនរៈ ឃើញគេសម្លឹងមករក
នាងដោយកែវភ្នែកដែលមានទឹកដមយ៉ាងស្រទន់ផ្អែមល្ហែម ធ្វើឲ្យ
បេះដូងនារីរំជួលឡើងដោយក្ដីរំភើបស្នេហា ។ កិត្យាយកក្រមាច្បូត សក់នាងបន្តិចៗ
ហើយលួចញញឹមដាក់នាងតាមកញ្ចក់ភ្លៀកៗមិន ដាច់ ។ មាលានីញញឹមតបវិញ
ទាំងបេះដូងរំភើប ថែមទាំងលួច សួរខ្លួនឯងថា ៖
- តើខ្ញុំពិតជាស្រឡាញ់បងកិត្យា មែនទេ? ឬក៏ខ្ញុំកំពុងធ្វើពើជា ស្រឡាញ់បង?
តើខ្ញុំរំភើបចិត្តព្រោះកិរិយាទន់ភ្លន់របស់បង ឬក៏ខ្ញុំ
រំភើបព្រោះការជិតដិតផ្លូវកាយរវាងបុរសនិងស្ត្រី? ហើយចុះបង វិញនោះ កំពុងគិត កំពុងឆ្ងល់
កំពុងស្មុកស្មាញក្នុងចិត្តដូចខ្ញុំដែរឬ
ក៏យ៉ាងណា?
ឃើញនារីឈ្ងោកមុខស្ងៀមស្ងាត់ កិត្យាក៏ឈ្ងោកយកនាសាទៅ ផ្ដិតលើថ្ពាល់ប្រពន្ធយ៉ាងរហ័ស
ធ្វើអោយមាលានីភ្ញាក់ក្រញាង ។ គេ ក៏ញញឹមឡើង ហើយស្រដីថា ៖
- បើនឹងរង់ចាំការអនុញ្ញាត្តិពីម្ចាស់គេនោះ មិនដឹងកាលណាកិត្យា
បានថើបថ្ពាល់ដ៏ក្រអូបមួយគូនេះទេ ។ ទាល់តែថ្លើមធំធ្វើចោរឆ្មក់ ខ្លះហើយ ទើបបាន ។
មាលានីចោលកន្ទុយភ្នែកសម្លក់ កាលបើឮប្រយោគនេះ ។
នរៈឃើញដូច្នោះក៏ញញឹមឡើង ហើយស្រដីថា ៖
- កុំខឹងនឹងបងអីណា៎! ប៉ុន្តែ បើខឹងចង់សងសឹក បងក៏អត់ថាអី ដែរ! នេះថ្ពាល់បងនែ៎!
ថើបសងសឹកវិញទៅ... ម៉ាសាឡាញ់!
- ផ្ដាសមែន បងកិត្យា!
មាលានីស្រដីតបវិញទាំងអៀនប្រៀន ហើយយកដៃច្រានគេ ស្រាលៗ
ធ្វើអោយកិត្យានឹកខ្នាញ់ក្នុងចិត្តយ៉ាងណាមិនដឹង ។ បុរស
យើងក៏ទម្លាក់ក្រមាចោលហើយស្ទុះទៅលើមាលានីបីត្រកងឡើង ។ - បងកិត្យា! លែងមើស៍!
ខ្មាស់គេ!

CHANBOKEO.COM

- ពុទ្ធោអើយ! ខ្មាស់នរណា ? នេះជាបន្ទប់ផ្ទាល់ខ្លួនរបស់យើងពីរ នាក់ណា៎...
គ្មាននរណាគេឃើញទេ ។

មាលានីនឹករអើលខ្លួនបែកញើសខ្ទង់ស្រិបៗ នឹកខ្មាសកិត្យា ឡើងក្រហមថ្ពាល់ផ្ទុរដូចផ្លែទន្លាប់ទុំ ។ កិត្យាក៏ផ្តេកកាយនារីទៅលើ គ្រែស្រាលហើយក៏ដាក់ខ្លួនអង្គុយក្បែរនាង ស្រវាចាប់ដៃមាលានី ឡើង បន្ទាប់មកក៏ស្រដីថា ៖

- ថ្ងៃនេះ បងសប្បាយចិត្តណាស់ ដែលឃើញមាលានីញញឹមដាក់ បងយ៉ាងបំព្រង ។
- នីបានញញឹមដាក់បងតាំងពីដើមរហូតមកហើយតើហ៎!
- ញញឹមមែន តែមានន័យមិនដូចគ្នាទេ ។
- ម៉េចក៏បងដឹង ?
- ព្រោះ ភាពញញឹមលើផ្ទៃមុខរបស់អូន ថ្ងៃនេះ បានបង្កប់នូវក្លិន ស្នេហ៍សុភមង្គលរវាងយើងទាំងពីរនាក់នោះអី!
- មែនហ្ន៎ស ? ក្លិនស្នេហ៍ពីអង្កាល់ ? នីមិនដែលបានផ្តិតក្លិន ស្នេហ៍ជាមួយបងកិត្យាម្តងណាផង ?
- បើមិនទាន់មាន អញ្ចឹង យើងចាប់ផ្តើមអោយមានទៅណា៎!

ថាហើយ គេក៏ឈ្ងោកដាក់ច្រមុះលើថ្ពាល់នារី ស្រាប់តែនាង គេចចេញវឹង ហើយយកដៃទប់ខ្លួនបុរសមិនអោយទ្រោបលើកាយ របស់នាង រួចហើយស្រដីតបវឹងថា ៖

- អត់ទេ! បងកិត្យា! កុំលេងអញ្ចឹងមើស៍!
- ម៉េចមិនអោយបងប៉ះខ្លួនអញ្ចឹង ? នេះយើងរៀបការជាប្តីប្រពន្ធ នឹងគ្នាហើយណា៎!
- គឺ... អូនមិនទាន់ត្រៀមខ្លួន ត្រៀមចិត្តបាននៅឡើយទេ ។
- ពុទ្ធោ! ហើយចុះអង្កាល់ទៅ ទើបអូនត្រៀមចិត្តបាន ?
- ចាំស្អែកសិនទៅ ចាំអូនអោយចម្លើយថ្មីទៀត ណា៎! ណា៎!

កិត្យាខកចិត្តស្រឡេត ក៏ងើបអង្គុយឡើង ហើយស្រដីថា ៖

- ឬក៏អូននៅអាល័យចំណងអតីតកាលជាមួយបុរសណាម្នាក់ ក្នុង ជីវិត ហើយមិនទាន់បាននិយាយលាគ្នាពីរូបគេនៅឡើយ ?

មាលានីភ្ញាក់ព្រើតដែលកិត្យាវាចាដូច្នោះ ។ បេះដូងរបស់នាង ក៏កញ្ជ្រោលញាប់ញ័រឡើង ។ ដើម្បីបន្លប់បង្វែរក្តីសង្ស័យរបស់កិត្យា មាលានីប្រឹងញញឹមសាជាថ្មី ហើយនិយាយតបទៅនាយវិញថា ៖

CHANBOKEO.COM

- គិតអ្វីយ៉ាងនេះ បងកិត្យា! អូនមិនមានជាប់មាត់ជាប់សំដីនឹង
បុរសណាទេ! បងគឺជាបុរសតែម្នាក់ក្នុងជីវិតអូនហើយ ។

តែកិត្យាហាក់ដូចជាចាប់អារម្មណ៍ថា មាលានីមានកិរិយាប្លែក យ៉ាងណាមិនដឹងទេ ។ ភ្លាមនោះ គេក៏បែរមុខចេញ ហើយដក ដង្ហើមធំៗ មួយស្របក់ក្រោយមក ក៏ពោលទៅកាន់នារីវិញថា ៖

- ណ្ហើយចុះ! បងទុកពេលអោយអូនបានរំសាយនូវអ្វីៗដែល
កំពុងតែរំខានក្នុងបេះដូងរបស់អូន ។ ពេលណាអូនរំសាយចិត្តបាន ហើយ
សូមអូនបើកឱកាសថ្មីសម្លឹងប្តីខ្លះៗផងណា៎ ព្រោះកិត្យាក៏ ស្រឡាញ់អូន
មិនខុសពីបុរសណាៗដទៃទៀត ក្នុងជីវិតរបស់អូន នោះទេ...
ក្តីស្រឡាញ់មិនមែនកើតឡើងដោយការបង្ខំចិត្តឡើយ ។ ដូច្នេះ
បើអូនមិនទាន់ត្រៀមចិត្តទទួលរូបបងបាន បងក៏សុខចិត្ត រង់ចាំអូនតទៅទៀតចុះ...
រង់ចាំថ្ងៃស្នេហ៍របស់អូន... ចាំរហូតដល់ ថ្ងៃដែលអូនអាចឆ្លើយមកបងវិញបាន
ថាតើកិត្យាជាបុរសដែលអូន ត្រៀមចិត្តទទួលនោះមែនឬមិនមែន ។

បន្ទាប់មក គេក៏យកដៃអង្អែលកេសានារីដោយសេចក្តីស្រឡាញ់ រួចហើយក៏ស្រវាទាញផាហ៊ុំដណ្តប់អោយនាងថ្នមៗ ។ គេក៏ឈរ ឡើង សម្លឹងកែវភ្នែករបស់មាលានីយ៉ាងយូរ រហូតទាល់តែនាង ចាញ់ក្រសែភ្នែករបស់មាណព ទើបគេក៏ដើរថយចេញពីបន្ទប់នោះ ទៅ ។ មាលានីឃើញដូច្នោះ ក៏ស្លុតក្នុងចិត្តយ៉ាងណាមិនដឹងទេ.. ថា នឹងស្រែកហៅបុរសមកវិញ ក៏ហារមិនរួច... នឹងបណ្តោយអោយគេ ទៅតាមសម្រួល ក៏ដួងចិត្តរបស់នាងពិបាកទ្រាំទ្រនឹងការបាត់រូបគេ ពីបន្ទប់... តើនាងគួរធ្វើយ៉ាងណា ?

ទឹកភ្នែកពីរតំណក់ស្រក់ចាកនេត្រាទាំងគូរបស់នារី បន្ទាប់មក ពីរតំណក់ទៀត ក៏បន្តវេន... រួចហើយក៏ពីរតំណក់មកថែមទៀត... មាលានីយំទៀតហើយ... ជ្រួលច្របល់ចិត្តទៀតហើយ... ហេតុអ្វី ទៅ ? បើនាងស្រឡាញ់គេ ហេតុអ្វីនាងមិនឃាត់គេ តែបែរជា បណ្តោយអោយគេដើរចេញពីបន្ទប់ផ្ទំដំណេកយ៉ាងស្រួល ? ប៉ុន្តែ បើនាងមិនស្រឡាញ់គេ ហេតុអ្វីបានជានាងស្រក់ទឹកភ្នែក ពេលគេ បែរខ្នងដើរចេញទៅ ?

- ព្រះអើយ! តើនរណាទៅជាម្ចាស់ចិត្តខ្ញុំពិតប្រាកដ ?

CHIANBOKEO.COM

មាលានីស្រក់ទឹកភ្នែកផង សួរខ្លួនឯងផង មិនអស់មិនហើយ ក្នុងចិត្តនឹកទៅដល់ចំណងអតីតកាលខ្លះរបស់នាង ដែលចេះតែមក លងអារម្មណ៍របស់នាងរាល់ថ្ងៃមិនដាច់ស្រេច... ពេលនេះ តើនាង ត្រូវសម្រេចចិត្តយ៉ាងណា ? តើនាងមានរឿងរ៉ាវអ្វីខ្លះពីអតីតកាល ទើបធ្វើអោយនាងរារែកចំពោះកិត្យាយ៉ាងដូច្នោះ ? ឬមួយក៏កិត្យា ជាឈ្មោន់ជានុយប្រលោមចិត្តនាង ដើម្បីបំភ្លេចនរណាម្នាក់ ? តើបុរសនោះជានរណា ?

*oooooooooooooooooooo*

*ooooo*

*o*

CHANBOKEO . COM

# វគ្គទីបួន
# បាត់កូន

ក្រុងភ្នំពេញ ឆ្នាំ២០០៤...

នៅក្នុងផ្ទះពូនងមីងមៀន...

- ម៉ាឡា! កូននីវាដើរខាត់ក្រចកអោយគេយូរម្ល៉េះ មិនឃើញមក បាយផ្ទះពេលថ្ងៃត្រង់សោះ ? នេះម៉ោងបួនរសៀលហើយណ៎!

ពូនងសួរនាងម៉ាឡាជាបងស្រីរបស់មាលានីដែលរស់នៅរួមផ្ទះ ជាមួយនឹងឪពុកទោះបីជារៀបការហើយក្តី ។

- គឺ អានីមិនបានប្រាប់ខ្ញុំទេពុក! ព្រឹកមិញឃើញគេយួរកាតាប មួយហើយដើរចេញទៅ ដូចរាល់ដង មិនឃើញមាននិយាយអ្វីផ្តាំ ផ្ញើខ្ញុំទេ ។

ពូនងក៏សួរទៅកូនដទៃទៀត ។ ទាំងអស់គ្នាគ្រវីក្បាល ឆ្លើយ ដូចៗគ្នាថា គេមិនបានដឹងថា មាលានីទៅណាទេ ។ ពូនងដើរចូល ទៅឆែកហិបខោអាវកូនស្រី ឃើញដូចជានៅទាំងអស់មិនមានបាត់ អ្វីទេ ។ គាត់ក៏ដកដង្ហើមបន្ធូរទ្រូង ។

យប់ងងឹត... ម៉ោង៨ហើយ...

- ម៉ាឡា! ហើយកូននីគេទៅឯណាគេ បានថ្មើរនេះហើយមិនទាន់ មកផ្ទះទៀត ?

ម៉ាឡាកំពុងបោសសំអាតរៀបចំផ្ទះ មុននឹងចូលដំណេកធ្វើការ រោងចក្រនៅវេលាព្រឹកស្អែក ។ កាលបើឮពូនងសួរដូច្នោះ ក៏នឹក ភ្នកដល់មាលានីដែលតែងតែនិយាយថា នាងសន្សំលុយដើម្បីរត់ ត្រឡប់ទៅស្រុកវិញ រៀនបន្តយកសញ្ញាបត្រមធ្យមសិក្សា ។

- ស្លាប់ហើយពុកអើយ! (ម៉ាឡាលាន់មាត់)

CHANBOKEO.COM

- ស្លាប់រឿងអី ម៉ាឡា ? (ពូនងសួរ)
- ខ្ញុំគិតថា អានីវារត់ទៅព្រះត្រពាំងវិញហើយ!
- ហ្ហស៎! ថាម៉េច ? (មីងមៀនលាន់មាត់)
- គឺ ខ្ញុំធ្លាប់ឮ អានីវាតែងនិយាយថា វាចង់ត្រឡប់ទៅស្រុករៀន បញ្ចប់សាលា ។
ពូនងជួញចិញ្ចើមទំនងដូចជាជឿបន្តិច មិនជឿបន្តិច ។
- ច្បាស់ហើយហ្អែស ថាវាត្រឡប់ទៅស្រុកវិញនោះ ?
មីងមៀនសួរបញ្ជាក់ ។
- ច្បាស់ហើយពុក ។
ភ្លាមនោះ ពូនងធ្វើកិរិយាច្រាសច្រាលទំនងខឹងនឹងកូន ថែម ទាំងស្រដីគំហកខ្លាំងៗថា ៖
- នាងនីវាមិនមែនទៅស្រុកវិញដើម្បីរៀនបន្តទេ...ពុកថាវាច្បាស់ជានឹកអាបែនដេកមិនលក់ហើយ បានជារត់ទៅតាមទំនើងចិត្ត ដោយឥតប្រាប់ឪពុកយ៉ាងនេះ ។
ពូនងខឹងពេក ក៏ទាញអាវយកមកពាក់រឹង រួចហើយស្រែក ប្រាប់ម៉ាឡាថា ៖
- កូននៅផ្ទះជួយមើលម៉ែនឹងប្អូនផង!
- ពុកអញ្ជើញទៅណា ?
- ទៅតាមកូនស្រីក្បាលខូចរបស់ពុកឲ្យវាត្រឡប់មកផ្ទះវិញនោះអី
ឃើញពូនងខឹងខ្លាំងពេក មីងមៀនមិនហ៊ានឃាត់ ក៏បណ្ដោយអោយគាត់ស្រវាចាប់ដៃនាងមាល័យជាប្អូនបន្ទាប់របស់ម៉ាឡា យក ទៅជាមួយផង ។ ពូនងក៏ឡើងរថយន្តតាក់ស៊ីដិះទាំងយប់សំដៅ ទៅទល់ដែន ។

ស្រុកផ្ទះលើ ខេត្តព្រះត្រពាំង កម្ពុជាក្រោម...
- យី! នងអើយ! បាត់មុខជិតម៉ាឆ្នាំ សុខទុក្ខយ៉ាងណាហើយនៅ ភ្នំពេញនោះ ?
អ្នកស្រុកម្នាក់ជាញាតិជិតខាងរបស់ពូនងកូកពីចម្ងាយមកពេលឃើញពូនងនាំកូនមកដល់ភូមិ ។ ថៃដន្យពូនងបែរធ្វើមិនឮសម្លេង ពូម្នាក់នោះហៅគាត់ ហើយដើរប៉ាត់ញញ៉ាត់ដឹកដៃនាងមាល័យដើរ ហួសទៅយ៉ាងលឿនថែមទាំងធ្វើមុខដូចជាកំពុងឈឺពោះរកកន្លែង ដោះទុក្ខសត្វអញ្ចឹង ។

CHANBOKEO.COM

- យីអើវ៉ី! នាយនងកើតអីហ្នឹង បានជាវាធ្វើឫកប្លែកខុសពីមុន មកអញ្ចឹង ?
ឬក៏កំពុងពុលទឹកម៉ាស៊ីនក្រុងភ្នំពេញ បានជាធ្វើជា
វាយឫកធ្វើមិនដឹងមិនឮមិនស្គាល់ញាតិជិតខាងពីមុនមក ?

ពូម្នាក់នោះលាន់មាត់ហើយក៏បររទេះគោហួសទៅ ។ ពូនងមក ដល់ផ្ទះចាស់
ជួបនឹងប្អូនស្រីរបស់គាត់ឈ្មោះមីងនុត កំពុងចាប់ ជ្រូកថ្លឹងលក់អោយគេ ។

- យី! ល្បងនង! មកលេងស្រុកម្តង ម៉េចមិនអោយដំណឹងមុន យ៉ាងនេះ
សុខៗស្រាប់តែមកដល់ជ្រងោ!

ស្រាប់តែពូនងស្រែកអោយរ៉ូងរ៉ាំងថា ៖

- កុំភ័យពេក! យើងមកតែម៉ាភ្លែតទេ ទៅវិញហើយ មិននៅ បង្អុស់បាយឯងឡើយ ។
- មានន័យថាម៉េចហ្នឹង ល្បងនង ?
- គឺយើងមកតាមនាងនី អោយត្រឡប់ទៅភ្នំពេញវិញ ។
- តាមនាងនី ?(មីងនុតលាន់មាត់) នាងនីវាត្រឡប់មកស្រុកយើង នេះវិញពីអង្កាល់ ?
- កាលពីប៉ុន្មានថ្ងៃមុននេះឯង! តើឯងមានឃើញនាងនីមកទីនេះ ទេ ហ្ន៎ស ?

មីងនុតគ្រវីក្បាល ៖

- មិនឃើញទេ ល្បងអើយ! ប្រហែលជានាងនីទៅផ្ទះល្បងណាប់ ឯទីក្រុងទេដឹង
ព្រោះវាចូលចិត្តរៀនសូត្រណាស់ មិនចូលចិត្តជីវិត ស្រែចំការដូចពួកយើងទីនេះទេ ។

ពូនងឮដូច្នេះក៏ហក់រឹងត្រឡប់ទៅវិញ ។ ភ្លាមនោះ មីងនុត ក៏ស្រែកឃាត់ពីក្រោយមកថា ៖

- ពេលនេះ ព្រលប់ហើយ គ្មានឡានចេញទៅទីក្រុងទេ ។ ចាំ ស្អែកទៅល្បងអើយ
នៅពិសារបាយមួយពេលជាមួយខ្ញុំសិនទៅ!

តែពូនងមិនស្តាប់ទេ បែរជាដឹកដៃនាងម៉ាល័យបងស្រីរបស់
មាលានីអូសមីងណាត់មីងណោងតាមពីក្រោយគាត់ រហូតទៅដល់ ចំណតឡានឈ្នួល ។
ចៃដន្យពិតដូចពាក្យមីងនុតប្រាប់មែន ឡាន ឈ្នួលចុងក្រោយបានចេញដំណើរទៅបាត់
តាំងពីកន្លះម៉ោងមុនម្ល៉េះ ដូច្នេះហើយ ពូនងត្រូវបង្ខំចិត្តវិលមកស្នាក់ជាមួយនឹងក្រុមគ្រួសារ
របស់មីងនុតប្អូនស្រីរបស់គាត់វិញ ។

កំពុងអង្គុយពិសាបាយជាមួយក្រុមគ្រួសាររបស់មីងនុត សុខៗ
ស្រាប់តែពូនងគិតឃើញអ្វីមួយ ក៏អូសដៃនាងម៉ាល័យជាកូនស្រីរឹង
ចេញទៅ ។

CHANBOKEO.COM

- ល្បងនងទៅណាហ្នឹង ? (មីងនុតសួរ)
- ទៅឯណោះម៉ាភ្លែត បន្តិចមកវិញហើយ (ពូនងឆ្លើយ)

មីងនុតសម្លឹងតាមពូនងធ្វើស្រឡាំងកាំង ។

បន្តិចក្រោយមក ពូនងនិងម៉ាល័យក៏បានមកដល់ផ្ទះឈើចាស់ តូចមួយខ្នង ឃើញស្រីចាស់ម្នាក់ពិការភ្នែក កំពុងអង្គុយបុកស្លា ពិសា ។

- អ៊ំអើយ! នាយបែននៅទេ ? (ពូនងកូកសួរ)
- នៅ! វាកំពុងដឹកគោចូលក្រោល នៅខាងក្រោយផ្ទះឯណោះ ។ ហើយពីណាគេហ្នឹង មករកកូនបែនមានការអីដែរ ?

ពូនងមិនឆ្លើយទេ បែរជាប្រឹងដើរហួសទៅ ឃើញនាយបែន កំពុងបង្កាត់ភ្នក់ភ្លើងបំពក់មូសអោយសត្វគោ ។

- នាយបែន ?
- បាទ ពូ! ជំរាបសួរ!

នាយបែនលើកដៃសំពះទាំងភ្ញាក់ផ្អើល ដែលឃើញពូនងមក ដល់ផ្ទះនាយ ។

- នាងនីមានមកទីនេះជួបឯងទេ ?
- នី ? មកទីនេះ ? បាទ! មិនឃើញទេ!
- ច្បាស់ហើយហ្អែស ? ឯងកុំកុហកយើងណា៎!

បែនឈរភាំងដែលពូនងគំហកអោយខ្លាំងៗ ។

- បាទពូ! នីមិនបានមកទីនេះទេ ។

ពូនងដើរឆ្វែលដីភូមិនាយបែនមួយជុំ ឃើញស្ងាត់ច្រៀប មិន ឃើញស្រមោលនរណាម្នាក់សោះ ក៏ចេញទៅវិញយ៉ាងលឿនដោយ មិនស្រដីលាម្ចាស់ផ្ទះអ្វីមួយម៉ាត់ ។ ឃើញកិរិយាច្រាសច្រាលរបស់ ពូនង នាយបែនអូសដៃមាល័យទៅសួរខ្សិបៗថា ៖

- មានការអ្វីហ្នឹង ម៉ាល័យ ? ហេតុអ្វីពូនងតាមរកមាលានីយ៉ាង តក្កហលម្ល៉េះ ? មានគេដណ្ដឹងអូននីហ្អ៎ែស បានជានាងរត់ចេញ ពីផ្ទះ ?

ម៉ាល័យមិនទាន់ឆ្លើយផង ពូនងស្រែកពីចម្ងាយមកថា ៖

- អ៊ើយ ឆាប់ទៅផ្ទះនាងខ្មៀ!
- ចា៎សពុក!

CHANBOKEO.COM

រួចហើយនាងបែរមកខ្សិបនាយបែនវិញ ៖

- ខ្ញុំទៅសិនហើយ! បើឃើញអូននី សូមប្រាប់ផង ថាពុកមករក!

នាយបែនក៏រហន់សួរដដែលម្តងទៀតថា ៖

- ហេតុអ្វីអូននីរត់ចោលផ្ទះ ម៉ាល័យ ?
- ខ្ញុំមិនដឹងទេ ប្រហែលជាខ្លាចពុកបង្ខំអោយយកប្តីទេដឹង ?
- យកប្តី ? មានគេដណ្តឹងហ្ន៎ស ?
- មែនហើយ! ហើយខ្ញុំសូមផ្តាំតាមបែនឯងផង ថាបើសិនបាន ជួបអូននី សូមប្រាប់អោយគេទៅផ្ទះកុំខាន ព្រោះអីពុកខឹងខ្លាំង ណាស់ ដែលគេរត់គេចពីផ្ទះមិនប្រាប់នរណា ។

ថាហើយ ម៉ាល័យក៏រត់រឹងតាមពីក្រោយឪពុកនាងបាត់ទៅ ទុកអោយនាយបែនឈរមើលពីក្រោយទាំងស្លុតទឹកចិត្ត ដែលបាន ដំណឹងថា មាលានីមានគេដណ្តឹង...

- អូននី! តើពេលនេះ អូននៅឯណា ? អូនត្រឡប់មកស្រុក កំណើតយើង ឬក៏អូនគេចទៅខាងណាវិញ ?... មាលានីគេចផ្ទះ... មានន័យថា អូនជំទាស់នឹងការបង្ខំរបស់ពុកម៉ែអូនដែលអោយអូន រៀបការមែនទេ ? ឬក៏អូនមានគម្រោងជីវិតថ្មីទៀត ? នី! ផ្តល់ដំណឹងអោយបងដឹងផងណា៎អូន!

បែនអង្គុយលើដង្កត់ឈើក្បែរពាំនូកចំបើង យកដៃជ្រោងសក់ រួចហើយដកដង្ហើមធំៗតែម្នាក់ឯង រួចហើយរអ៊ូក្នុងមាត់តិចៗថា ៖

- តើអ្នកស្រែក្រីក្រដូចជានាយបែន មានសំណាងនឹងរៀបការ ជាមួយនឹងអូននីដែរឬទេ ? ឬក៏បានត្រឹមតែដេកស្រម័យរួចហើយ ក៏ត្រូវដេកខកចិត្តមួយជីវិតតែម្យ៉ាងប៉ុណ្ណោះ ?

ព្រឹកស្អែកឡើង...

នាយបែនបានស្កាត់មកជួបម៉ាល័យនៅផ្ទះមីងនុត ៖

- បែនមានការអីហ្នឹង បានជាតក្កហលមកជួបខ្ញុំទាំងព្រហាម ?
- គឺ... ចង់សួរថាតើពូនងកំពុងតាមចាប់មាលានី អោយទៅរៀប ការនៅភ្នំពេញវិញ មែនទេ ?
- មែនហើយ!
- ហើយចុះអានីគេថាម៉េចដែរ ?
- គេមានថាម៉េច ? គឺគេគេចខ្លួននេះអី!... ហើយគេមានសន្យាអ្វី នឹងបែនពីមុនមក ហ្ន៎ស!

CHANBOKEO.COM

- គឺ.. គឺ... ស្រដៀងៗហ្នឹងឯង...
- បើដូច្នេះ បែនឈប់គេងគិតសង្ឃឹមអ្វីទៀតទៅ ព្រោះពុកមិន ព្រមអោយនាងនីត្រឡប់មកស្រុកវិញទេ ។ គាត់ធ្វើអ្វីសព្វយ៉ាង ដើម្បីរក្សាកូនចៅអោយនៅជុំជាមួយគាត់ ។ បើបែនចង់ជួបនាងនី ដើម្បីសួរនាំ បែនត្រូវធ្វើដំណើរទៅជួបនាងដល់ភ្នំពេញហើយ ។
- ខ្ញុំទៅមិនបានទេ ម៉ាល័យ ព្រោះម៉ែខ្ញុំពិការភ្នែក ឯប្អូនៗចេញ ទៅធ្វើការបំរើគេនៅក្រុងអស់ហើយ គ្មាននរណានៅមើលម៉ែទេ ។
- បើដូច្នោះ កាត់ចិត្តទៅ ព្រោះពុកមានគំរោងការមុតមាំណាស់ ពី រឿងរៀបចំមាលានីអោយរៀបការជាមួយអ្នកទីក្រុងម្នាក់ ។

ថាហើយ ម៉ាល័យក៏គេចឡើងទៅលើផ្ទះវិញ ទុកអោយនាយ បែនឈររំជើបរំជួលចិត្ត លួចលេបទឹកភ្នែកតែម្នាក់ឯង ។

ព្រហាមថ្ងៃនដែល...

ពូនងនាំម៉ាល័យឡើងឡានឈ្នួលជើងដំបូងគេបង្អស់ ដើម្បីធ្វើ ដំណើរទៅផ្ទះពូណាប់ ។
- មិនឃើញនាងនីមកទីនេះទេ បងនង! (ពូណាប់និយាយប្រាប់)
- ម៉េចអញ្ចឹង ? មាលានីស្រឡាញ់ហើយគោរពឯងជាងគេបង្អស់ ហេតុអ្វី នាងបែរជាមិនមករកឯងសោះអញ្ចឹង ?
- មានន័យថាម៉េចហ្នឹង បងនង ? បងបង្ខំកូនរឿងអីមែនទេ ?
- មិនបានបង្ខំទេ តែជួនអីមានបុរសល្អគេមកដណ្តឹងនាងនី... បង មិនចង់អោយបាត់បង់ឱកាសល្អនោះទេ!
- ហើយបុរសល្អ ឱកាសល្អរបស់បងនោះមានន័យថា យ៉ាងម៉េច ដែរ ? សូមបកប្រែអោយប្អូនស្តាប់បន្តិចមក៍!

ការពិត ពូណាប់ជាគ្រូបង្រៀនម្នាក់ ជាមនុស្សហ្មត់ចត់ក្នុងការ ងារណាស់ សូម្បីពូនងក៏គង់គោរពប្អូនប្រុសបន្តិចដែរ ព្រោះពូ ណាប់រៀនសូត្របានជ្រៅជ្រះជាងគេទាំងអស់ក្នុងគ្រួសារ ។ ឮប្អូន ប្រុសសួរដូច្នោះ ពូនងក៏លេបទឹកមាត់ស្រដីម្តងទៀត ដើម្បីពន្យល់ អោយប្អូនដឹង ៖

CHIANBOKEO.COM

- គឺគេជាកូនម្ចាស់ផ្ទះឈ្នួលដែលយើងជួលគេរស់នៅ បានចូលមក សាកសួរនាងនីពីរដងហើយ តែនាងនីគេប្រកែក ។

- បើកូនប្រកែកទៅហើយ ម៉េចបានបងចូលចិត្តបង្ខំគេទៀត ?

- មិនមែនបង្ខំទេ ប៉ុន្តែបងមិនចង់បាត់បង់កូនប្រសារជាមនុស្ស មានទ្រព្យសមគួរ រូបសម្បត្តិសមគួរ ហើយនៅកម្លោះដូច្នោះទេ ។ ម្យ៉ាងទៀត បងមិនចង់បែកកូន... មិនចង់អោយវារត់មកស្រុក កំណើតចោលពុកម៉ែបងប្អូនវា ។ ឋាន:ប្រហែលយើង រូបប្រហែល យើង ពិបាកនឹងរកគូស្រករអោយសមល្អស្មើនឹងបុរសដែលចូលមក ស្ដីដណ្ដឹងនាងនីម្នាក់នេះណាស់ ។ ប៉ុន្តែនាងនីប្រកែកថា គេនៅ ក្មេងហើយចង់នៅរៀន... ម្ល៉ោះហើយបងចេះតែស្ដាយ ចំពោះការ ដែលកូនប្រកែកមិនទទួលយកបុរសម្នាក់នោះជាគូស្រករ ។

- ខ្ញុំគិតថា មាលានីចង់រៀននោះល្អហើយ ។ គេក៏នៅក្មេងណាស់! បងមិនគួរបង្ខំកូន រហូតដល់គ្នាភិតភ័យរត់ចោលផ្ទះយ៉ាងហ្នឹងទេ ។ យើងជាចាស់ទុំ គួរណាស់តែសម្លឹងទៅជីវិតអនាគតអោយបាន ឆ្ងាយជាងកូន ។ ពេលនេះមាលានីល្អប៉ុនហ្នឹង ក៏មានបុរសឋាន:ប៉ុន ហ្នឹងចូលដណ្ដឹង ។ ចុះទំរាំមាលានីរៀនបានខ្ពស់ជាងនេះ មានវិជ្ជា តម្រេះប្រសើរជាងនេះ មានការងារខ្ពស់ជាងនេះ លែងអ្វីមិនមាន មនុស្សល្អជាងនេះ មកសម្លឹងមកពិចារណានាងនោះ ? បងគួរតែ ផ្ដល់កម្លាំងចិត្តអោយគេខំរៀនតទៅទៀតទៅ ។ ឆ្នាំនេះ មាលានី ទើបតែមានអាយុ១៨ឆ្នាំទេ ជាវ័យនៅល្អសំរាប់ទទួលការសិក្សា នៅឧត្តមសិក្សាដើម្បីជ្រើសរើសការងារអាជីពសមរម្យ ប្រសើរជាង ធ្វើការជាកម្មកររោងចក្រ ឬក៏វិលមកស្រុកកំណើត ធ្វើស្រែដែរ ។ ខ្ញុំថាគេប្រកែកមិនរៀបការនោះសមរម្យហើយ ព្រោះខ្ញុំដឹងថានាង មាលានីចង់រៀនណាស់ មិនគួរនឹងទទួលចំណងដៃអាពាហ៍ពិពាហ៍ មុននឹងមានការសិក្សា មានការងារល្អប្រសើរនោះទេ ព្រោះថា បើនាងរៀបការពេលនេះ នាងនឹងក្លាយជាបន្ទុករបស់ប្ដី នឹងក្លាយ ជាមនុស្សអាសារឥតការ មិនអាចធ្វើអ្វីក្រៅពីធ្វើការនឹងកម្លាំងហើយ បង្កើតកូនឲ្យប្ដីប៉ុណ្ណោះ ។ តើជីវិតនាងមានតម្លៃអ្វីទៅ កាលបើនាង ក្លាយខ្លួនជាបញ្ញើក្អែកពឹងដង្ហើមប្ដីនោះ ? ចុះបើឧបមាថា ថ្ងៃណា មួយ ប្ដីបែកគំនិតមានស្រីរួចលែងលះគ្នាទៅ ឬក៏ប្ដីត្រូវស្លាប់ ធ្វើ អោយខ្លួនវិញក្លាយជាមេម៉ាយ តើនាងមានអ្វីជាជំហរជីវិត ដើម្បី ចិញ្ចឹមខ្លួនឬចិញ្ចឹមកូនដែរឬទេ ? ឬចាំស៊ីកេរ្តិ៍របស់ប្ដី មែនទេ ? បើរង់ចាំទទួលមរតកនោះ តើនាងនឹងបានទទួលកេរ្តិ៍នោះដោយ ងាយស្រួលដែរឬទេ

CHANBOKEO.COM

ឬក៏ត្រូវច្បាំងដណ្ដើមគ្នាពីសាច់ញាតិខាងប្ដី ? តើការច្បាំងនោះ នាំលាភឲ្យនាងនី ឬក៏នាំទុក្ខឲ្យនាងនិងកូនថែម ទៀត ? ម្យ៉ាងទៀត ការរៀបការកូនដោយទន្ទឹងរង់ចាំទទួលលាភ ពីសាច់ញាតិកូនប្រសារនោះ ជាការគិតខុសទាំងស្រុង ព្រោះកិរិយា នោះបញ្ជាក់ថា យើងស្រឡាញ់និងរាប់មនុស្សដោយតម្លៃទ្រព្យរបស់ ដែលគេមាន មិនមែនដោយសារគេជាមនុស្សល្អទេ ។ ហើយបើ សិនណា ថ្ងៃណាមួយ កូនប្រសារនោះធ្លាក់ខ្លួនក្រ យើងក៏ប្រែជា ស្អប់គេវិញព្រោះគេក្រ ហើយកូនរបស់យើងក៏នឹងត្រូវឃ្លាតមង្គល ដោយការលោភលន់របស់យើងជាឪពុកម្ដាយហើយ ។ ខ្ញុំថាបងនង គួរទៅសំរាន្តគិតវិញទៅ ហើយចាំមកនិយាយជាមួយកូនសាជាថ្មី ។ ចំណែកមាលានីវិញ នាងច្បាស់ជាមិនទៅណាទេ ច្បាស់ជានៅពួន ក្នុងក្រុងភ្នំពេញ កៀនៗផ្ទះរបស់បងនងឯងនោះឯង គ្រាន់តែនាង មិនហ៊ានមកផ្ទះវិញ ទីមួយខ្លាចការបង្ខិតបង្ខំរបស់ឪពុក ទីពីរ ធុញនឹងឮអ្វីដែលរំខានដល់គម្រោងការបន្តការសិក្សារបស់នាង ។

ពូនងអង្គុយស្ដាប់ពូណាប់ស្រដីរហូតចប់ចុងចប់ដើម ។ ពេល នេះ ពូហាក់ដូចជាមានអារម្មណ៍ស្ងប់បន្តិច តាំងពីបានស្ដាប់ពាក្យ វែកញែករបស់ពូណាប់យ៉ាងពិស្ដារមក ។ យប់នោះ គាត់សំរាន្តគង ថ្វាស គិតពិចារណាយ៉ាងច្រើនពេញមួយយប់ទើបសភ្លឺ ។

ទីក្រុងភ្នំពេញ...

ពីរថ្ងៃក្រោយមក...

ពូនងនាំម៉ាល័យមកផ្ទះវិញទាំងអស់កម្លាំងល្វិតល្វៃ ។ លុះចូល មកដល់ផ្ទះវិញ គាត់ភ្ញាក់ព្រើតព្រោះឃើញមាលានីនៅក្នុងផ្ទះជុំជា មួយក្រុមគ្រួសាររបស់គាត់ ។

- នាងនី! ឯងទើបតែមកពីណា ? ដឹងទេ ថាពុកដើររកឯងឡើង ជិតសោះខ្យល់ទៅហើយ ?

មាលានីនៅស្ងៀម ហើយចោលបភ្នែកទៅរកម្ដាយរបស់នាង ទំនងចង់អោយគាត់ជួយ ។ មីងម៉ៀនឃើញប្ដីមិនទាន់អស់ខ្យល់ ខឹងចំពោះកូនស្រី គាត់ក៏ឆ្លើយជំនួសថា ៖

- នាងនីមានគ្រោះថ្នាក់ចរាចរ ត្រូវម៉ូតូកៀរដួលពេលចេញមកពី ខាត់ក្រចកអោយគេ ហើយបានត្រូវសប្បុរសជនម្នាក់នាំទៅពេទ្យ ដេររបួសហើយ ទើបត្រឡប់មកដល់ផ្ទះវិញ ប្រហែល១០នាទី ក្រោយពេលពុកវាចេញទៅ ។ នេះបើសិនជាពុកវាឯងកុំច្រឡោត ខ្លាំងពេក

CHANBOKEO.COM

កុំតក្កហលខ្លាំងពេក ប្រហែលជាពុកវាឯងមិនបាច់ធ្វើ ដំណើរទៅដល់ស្រុក អស់បីបួនថ្ងៃ ចោលទទេៗនោះឡើយ ។ ថ្ងៃក្រោយ សូមគិតអ្វីល្អៗពីកូនខ្លះទៅណា៎ ទើបជីវិតមានសេចក្តីសុខខ្លះៗ ។

ពូនងក្រឡេកឃើញមាលានីរុំជើងស្តាំ ហើយមានស្នាមដាច់លើ ដៃទាំងសងខាង ក៏នៅស្ងៀមមិនហ៊ានមាត់កតបនឹងប្រពន្ធទេ ។ គាត់បែរដើរមកដាក់ខ្លួនជិតនាង ហើយយកដៃទះក្បាលកូនបន្តើរៗ ហើយមានប្រសាសន៍ថា ៖

- យ៉ាងណាក៏ពុកសប្បាយចិត្តដែរដែលឃើញកូនសុខសប្បាយ!

មាលានីញញឹម ហើយឆ្លើយថា ៖

- កូននីអាយុថ្លៃណាស់ មិនទៅណាមកណាចោលពុកងាយៗទេ ។

ពូនងញញឹម រួចហើយដកដង្ហើមយ៉ាងវែង បន្ទូរក្តីធុញថប់តប់ប្រមល់ ចេញពីទ្រូង កាលបើដឹងថា មាលានីមិនបានធ្វើអ្វីដូចគាត់ គិតពីមុនមកនោះឡើយ ។

ចាប់តាំងពីថ្ងៃនោះមក ពូនងដូចជាមិនសូវតឹងតែងមាត់ក ឬប្រកាន់ច្បាប់វិន័យអ្វីៗ ចំពោះមាលានីនិងកូនស្រីដទៃទៀតទាំង អស់ក្នុងផ្ទះប៉ុន្មានទេ ប្រហែលជាគាត់គិតពិចារណាច្រើនហើយ អំពីពាក្យសំដីដែលពូណាប់បាននិយាយពន្យល់គាត់ ។ ភាពរមនា ក្នុងគ្រួសារក៏ហាក់ដូចជាមានជីវិតរស់រវើកឡើងវិញ ។

ច្រើនខែកន្លងទៅ...

សព្វថ្ងៃនេះ មាលានីបានចូលហ៊ុនជាមួយមិត្តស្រីម្នាក់ ជួលផ្ទះ គេមួយល្វែង ដើម្បីបើកហាងធ្វើក្រចកដៃ ក្រចកជើង និងសំអាង មុខ ។ ឥឡូវនេះ នាងឈប់ដើរយួរធុងប្រអប់ទៅធ្វើក្រចកឲ្យគេ តាមផ្ទះហើយ ព្រោះនាងត្រូវចំណាយពេលធ្វើដំណើរច្រើនពេក មិនសូវមានពេលធ្វើក្រចកប៉ុន្មានទេ ។ ចំពោះភ្ញៀវដែលស្រឡាញ់ ស្នាដៃនាង តែងតែនាំគ្នាវិលមករកហាងដ៏តូចមួយនោះដើម្បីទទួល ស្នាដៃដុសខាត់លាបក្រចកដ៏ប៉ិនប្រសប់របស់នាង ។

នៅថ្ងៃមួយ...

សារេនមិត្តស្រីរបស់នាងដែលធ្វើការជាមួយ បានចេញទៅផ្ទះ មុនបាត់ ទុកអោយមាលានីនៅបោសសំអាតហាងម្នាក់ឯងបង្ហើយ មុននឹងបិទទ្វារទៅផ្ទះ ។ រំពេចនោះស្រាប់តែ ៖

CHANBOKEO.COM

- សួស្ដីថៅកែស្រី !

មាលានីងាកមើលឃើញ តារាចុះពីម៉ូតូដ៏សង្ហារបស់គេ ដើរចូល មកដល់ ។ នាងក៏ញញឹមឡើង ៖

- សួស្ដីលោកតារា ! ពេលនេះ ខ្ញុំបំរុងបិទហាងទៅផ្ទះហើយណា៎ !

តារាញញឹមឡើង ៖

- ឃើញភ្ញៀវពិសេសហើយនៅមិនចង់ទទួលទៀតឬ មាលានី ? នេះខ្ញុំជិះម៉ូតូតាំងពីសៀមរាបមកភ្នំពេញ មិនទាន់ចូលផ្ទះទេណា៎ សុខចិត្តមកទីនេះមុន ដើម្បីជួបម្ចាស់ហាង...

- អូហ៍ ! មកជួបម្ចាស់ហាងតើហ៍ មិនមែនមកធ្វើក្រចកឯណា ? អញ្ចឹង ខ្ញុំអាចបិទហាងបាន មែនទេ ?

- បើបិទហាងបាន នីមានពេលចេញទៅក្រៅជាមួយខ្ញុំ ម៉ាភ្លែត បានទេហ៍ ?

- ចង់ទៅណា៎ដែរទៅ លោកតារា ?

- ទៅជិតៗនេះ ដើម្បីនិយាយគ្នាលេងនោះអី ! ខ្ញុំអផ្សុក ចង់បាន គ្នីគ្នាកំដរអាហារមួយពេល ។

- ថៃងនេះ ខ្ញុំត្រូវត្រឡប់ទៅបរិភោគនៅផ្ទះជុំគ្រួសារ មិនអាចដើរ ហើរបរិភោគនៅក្រៅបានទេ ។

- បើអញ្ចឹង នីចាំទីនេះម៉ាភ្លែតទៅ មិនបាច់ទៅណាទេ ហើយសុំ ធ្វើម៉ូតូម៉ាភ្លែត ។

- លោកបំរុងអញ្ជើញទៅណាហ្នឹង ?

តារាញញឹមតបតែមិនព្រមឆ្លើយថាម៉េចទេ ហើយក៏ដើរឆ្លង ថ្នល់យ៉ាងរហ័ស ។ មួយស្របក់មក គេក៏ត្រឡប់មកវិញដោយមាន កាន់អាហារពីរបីកញ្ចប់មកផង ។

- ម៉ោះ ! បើមិនមានពេលទៅក្រៅ យើងបរិភោគនៅទីនេះជុំគ្នា តែម្ដងទៅ ។ ឯណាចាន ? សុំខ្ចីពីរបីមកណា៎ !

មាលានីឈរធ្វើភាំង កាលបើតារាសំដែងឫកពាស្និទ្ធស្នាលដាក់ នាងហាក់ដូចជាមិត្តរាប់ឆ្នាំមកហើយអញ្ចឹង ។ បន្ទាប់មក គេក៏អូស ដៃនារីអោយអង្គុយ ។

- ម៉ោះ ! ឃ្លានមិនឃ្លានក៏ដាក់មួយម៉ាត់ពីរកំដរភ្ញៀវទៅណា៎ ! ព្រោះអីខ្ញុំហេវបាយណាស់ អត់តាំងពីព្រឹកមកម្ល៉េះ !

- អូហ៍ ? ហេតុអ្វីចាំធ្វើដូច្នោះផង ?

CHANBOKEO COM

- គឺចង់អោយមកដល់ភ្នំពេញឆាប់នោះអី ព្រោះតារានឹកគេម្នាក់ ចង់អោយឆាប់ដល់ នឹងអាលឃើញមុខគេ ។

មាលានីនឹកអៀនក្រហមមុខ កាលបើឮសំដីរបស់តារាបែប នោះ ។ ឃើញនាងធ្វើកិរិយាអៀនប្រៀន តារាក៏ស្រដីឡើងថា ៖

- ហើយនីមាននឹកដល់តារាខ្លះទេ ?

ស្រស់ស្រីមិនឆ្លើយទេ បែរជានៅអង្គុយស្ងៀមស្ងាត់ទៅវិញ ។ ការពិតទៅ នាងកំពុងញាប់ញ័រក្នុងចិត្តយ៉ាងចម្លែកយ៉ាងណាមិន ដឹងទេ ដែលបានទទួលចំណាប់អារម្មណ៍ពីបុរសទីក្រុងលើដំបូង ។ ការពិត គេមានរូបសង្ហា សំដីពិរោះ ឬកពាក៏មានអំណោយទាន ប៉ុន្តែ នាងទើបតែស្គាល់គេប៉ុន្មានដង ពេលគេមកលេងភ្នំពេញ ហើយហៅនាងអោយទៅសំអាតក្រចកអោយ ។ ការពិត គេគ្រាន់ តែយកលេសអោយនាងទៅធ្វើក្រចកនោះ ដើម្បីអោយតែបានជួប មុខនឹងបានប៉ះម្រាមដៃរបស់នាងតែប៉ុណ្ណោះ ។ មាលានីមិនទុកចិត្ត បុរសនោះទេ ថាមិនស្គាល់ថាគេជានរណា... នៅលីវឬក៏មានម្ចាស់ ទៅហើយ... នារីតែងប្រយត្ន័ប្រយែងខ្លួនជានិច្ច ។

ឃើញនារីនៅស្ងៀម គេក៏ឈប់បរិភោគអាហារហើយដើបដក ខ្លួនឡើង ផ្អែកកៅអី រួចនិយាយថា ៖

- មានរឿងអ្វីដែលមាលានីសង្ស័យពីខ្ញុំមែនទេ ? តើចង់សួរខ្ញុំអ្វី ទេ ? ខ្ញុំសន្យាថានឹងឆ្លើយដោយពាក្យស្មោះត្រង់បំផុត ។

មាលានីគ្រវីក្បាល ៖

- មិនមានទេ ចាស! គ្រាន់តែមានអារម្មណ៍ថា លោកជាមនុស្សល្អ ម្នាក់គួរអោយរាប់អាន ។

ភ្លាមនោះ តារាញញឹមឡើង ៖

- បើដូច្នោះ រៀនស្គាល់តារាជាងនេះបន្តិចទៅ នោះមាលានីនឹង ស្រឡាញ់តារាជាងនេះមិនខាន ព្រោះតារាជាបុរសបេះដូងបរិសុទ្ធ!

- ពុទ្ធោអើយ! ហេតុអ្វីក៏អួតខ្លួនម្ល៉េះ ? (មាលានីនឹកក្នុងចិត្ត)

តារាក៏ពោលបន្តទៀតថា ៖

CHANBOKEO.COM

- ខ្ញុំបានទទួលច្បាប់ផ្លាស់មកភ្នំពេញវិញហើយ ដូច្នេះ ខ្ញុំនឹងមានពេលមកលេងមាលានីបានញឹកញាប់ជាងមុន ។ តើមាលានីគិតយ៉ាង ណាដែរ បើខ្ញុំសុំមកលេងទីនេះញឹកញាប់ ?

មាលានីសម្លឹងមុខនរៈ មួយភ្លែត ក៏ស្រដីតបថា ៖

- បើសិនមកជាភ្ញៀវ លោកអាចអញ្ជើញមកពេលណាក៏បាន ។ ប៉ុន្តែបើមកជាមិត្ត សូមអញ្ជើញមកក្នុងពេលសំរាកប្រសើរជាង នោះយើងអាចនិយាយអ្វីៗបានទូលាយ ដោយមិនខ្លាចចិត្តភ្ញៀវ ដទៃដែលមកទីនេះ ។

- អឺយ៉ា មាលានី! មានច្បាប់ទម្លាប់វិន័យហាងល្អដល់ហើយហ្ន៎!

នារីញញឹមចេញធ្មេញរាបស្មើ ធ្វើអោយតារាលួចគយគន់ឡើង ភ្លឹកអារម្មណ៍តែម្តង ។

ចាប់តាំងពីថ្ងៃនោះមក តារាក៏មកលេងមាលានីជាប្រចាំ ហើយបានរិតចំណងមិត្តភាពជាមួយនាងក៏កាន់តែជិតដិតឡើង រាល់ថ្ងៃ...

*ooooooooooooooooo*

*ooooo*

*o*

CHANBOKEO .COM

# វគ្គទី៥
## ឈាមរក្ស

ក្រុងភ្នំពេញ ឆ្នាំ២០០៧...

នៅក្នុងបន្ទប់ដំណេក...

មាលានីប្រែខ្លួនចុះឡើងៗយ៉ាងរសាប់រសល់...

- តើគេទៅណា ?

មាលានីសួរខ្លួនឯងដដែលជាដដែល ។ ភ្លាមនោះ នាងក៏នឹកភ្នកទៅដល់សំដីដែលសំរោងបាននិយាយប្រាប់នាងថ្ងៃមិញ ពេល ជិះម៉ូតូជួបគ្នាតាមផ្លូវ ស្រាប់តែនាងភ្ញាក់ព្រើត នឹកថា ៖

- បងកិត្យា ? ម្សិលមិញបងខឹងនិងខ្ញុំរហូតចង់លោតទឹកសម្លាប់ ខ្លួន ? ពិតមែនឬបង ? ហើយចុះពេលនេះ បងនៅគិតដូច្នោះ ដដែលទៀតទេ ? មិនបានទេ ? នីមិនអោយបងស្លាប់ចោលនីទេ! នីត្រូវការបង...! បងកិត្យា...!

មាលានីរលាស់ផាហ៊ំចេញពីខ្លួន ហើយស្ទុះចុះពីគ្រែយ៉ាងរហ័ស រួចបើកទ្វារចេញទៅក្រៅរកមើលកិត្យាភ្លាម ។ នាងដើរលបៗរក ស្រមោលកិត្យានៅក្នុងផ្ទះ តែមិនឃើញនាយសោះ ។ រំពេចនោះ នារីឃើញបងស្រីរបស់នាងនៅចង្ក្រានបាយកំពុងរៀបចំខ្ចប់អាហារ សំរាប់ទៅធ្វើការព្រឹកស្អែក ។ លុះសួរបងស្រីនាងទៅ ម៉ាល័យគ្រវី ក្បាលប្រាប់ថា នាងមិនបានឃើញកិត្យាចេញពីបន្ទប់ទេ ។

ពេលនោះ យប់បន្តិចហើយ... អ្នកនៅក្នុងផ្ទះទាំងអំបាលម៉ានក៏ចូលនិទ្រាអស់រលីងគ្មានសល់ ។ មាលានីមិនហ៊ានដាស់ម្តាយឪពុក របស់នាងសួររកកិត្យាទេ

CHANBOKEO.COM

ព្រោះខ្លាចក្រុមគ្រួសារទាំងមូលភ្ញាក់ផ្អើល ដើររកនាយទាំងយប់ខានដេកខានពួន ។ ទីបំផុត នាងសំរេចចិត្ត បើកទ្វារចេញមកក្រៅ តាមរកកិត្យា ក្រែងលោគេនៅសំកុកនៅ តាមតូបទំនេរណាមួយតាមផ្លូវម្តុំៗនោះ ។ ចរាចរតាមផ្លូវស្ងប់ស្ងាត់ ទៅហើយ នៅសល់តែពន្លឺភ្លើងគោមសម្លួយៗតាមផ្លូវថ្នល់ បំភ្លឺដី ទីក្រុងយ៉ាងទន់ខ្សត់ខ្សោយ ។

មាលានីដើរចុះដើរឡើងទាំងចិត្តក្រហល់ក្រហាយកន្ទះរា រកថា មិនត្រូវ ។ លុះដើរយូរៗទៅ ស្រាប់តែនាងមានអារម្មណ៍ថាឈឺ បាតជើងហើយលាមកឆ្កួលីក៏កាន់ជើងនាងស្អិតៗយ៉ាងក្រាស់ឃ្មឹក ។ ពេលនាងឈ្ងោកមើលទៅ ទើបដឹងថា នាងភ្លេចពាក់ស្បែកជើង ពេលចេញពីផ្ទះមក ព្រោះតែក្តីបារម្ភរបស់នាងចំពោះសុខទុក្ខកិត្យា ខ្លាំងពេក ។ មាលានីបែរចុះបែរឡើង រំពៃរកមើលស្រមោលស្វាមី របស់នាង ប៉ុន្តែស្ងាត់ច្រៀប មិនឃើញស្រមោលមនុស្សណាមួយ គួរអោយកត់សំគាល់ទេ ។

អស់ចិត្តហើយ នាងក៏ដាក់ខ្លួនអង្គុយចុះ ផ្អែកនឹងសសររោង លក់ចេកចៀនដំឡូងចៀនមួយដែលនៅទំនេរស្ងាត់ ។ រំពេចនោះ មាលានីក៏យំខ្សឹកខ្សួលឡើង ព្រោះតែនាងគ្មានមធ្យោបាយថានឹងទៅ តាមរកកិត្យានៅទីណាអោយឃើញឡើយ ។

ចៃដន្យ ស្រាប់តែមានដៃមួយមកចាប់ស្មានាងអង្រួនឡើង ធ្វើអោយមាលានីភ្ញាក់ព្រើតបែររកមើល ក៏ប្រទះនឹងតាចាស់ម្នាក់ ៖

- ដើររកពីណាគេមីនាង ? តាដេកនៅក្រោមសំយាបផ្ទះខាងក្រៅ ឃើញមីនាងឯងដើរចុះដើរឡើងយ៉ាងខ្វល់ខ្វាយ ទើបចេញមកសួរ នេះមីនាងឯងបាត់កូនមែនទេ ?

មាលានីគ្រវីក្បាល តែមិនហ៊ានឆ្លើយទេ ថានាងកំពុងបាត់ប្តី ។ ភ្លាមនោះ នាងក៏យកដៃជូតទឹកភ្នែកឡើង ហើយស្រដីតបវិញថា ៖

- ប្រហែលជាខ្ញុំមមើដើរហើយតា! សូមអរគុណដែលតាបានដាស់ ខ្ញុំអោយភ្ញាក់! អញ្ចឹង ខ្ញុំសូមលាទៅវិញសិនហើយ ។ សូមតាចូល សំរាន្តវិញចុះ ។

ថាហើយ នាងក៏សំពះលាតាចាស់នោះ ដើរថយក្រោយត្រឡប់ ទៅផ្ទះនាងវិញ ក្នុងចិត្តបន់ស្រន់ថា ៖

- បើសិនយើងជាគូនឹងគ្នាពិតប្រាកដ សូមបារមីវត្ថុសក្តិសិទ្ធិជួយ តម្រែតម្រង់នាំចិត្តបងកិត្យាអោយត្រឡប់មកផ្ទះ ពេលឥឡូវនេះផង ព្រោះខ្ញុំបារម្ភពីគាត់ណាស់ ។

CHANBOKEO.COM

កំពុងតែដើរឈ្លោកៗ ស្រាប់តែនាងមានអារម្មណ៍ថា មាន ស្រមោលមនុស្សម្នាក់ដើរតាមនាងពីក្រោយ ។ មាលានីដើបមុខ ឡើង បែរក្រោយក៏ប្រទះឃើញកិត្យាអោយជ្រងោតែម្តង ៖

- បងកិត្យា ?
- បាទ!

គ្រាន់តែឮសំដីឆ្លើយតបនេះភ្លាម មាលានីស្ទុះរឹងរត់ទៅស្រវា អោបកិត្យាយ៉ាងណែន ហើយក៏យំខ្សឹកខ្សួលឡើង ៖

- បងកិត្យា! បងមកពីណាហ្នឹង ? ដឹងទេ ថាមាលានីភ័យព្រួយ ហើយបារម្ភពីបងប៉ុនណា ?

កិត្យាភ្ញាក់ព្រើត លូកដៃស្រវាអោបនារីផ្ទាប់នឹងលង្វែកទ្រូង របស់គេទាំងបេះដូងរំដើបរំជួលរកទីបំផុតគ្មាន កាលបើឃើញនារី ស្រក់ទឹកភ្នែកដោយសាររូបគេ ៖

- អូននី! បងមកវិញដោយសុខសប្បាយហើយតើហ៍ ដូច្នេះ យើងគួរញញឹមដាក់គ្នាវិញ ណាអូន!

មាណពស្រដីផង យកដៃអង្អែលខ្នងនារីបន្តើរៗយ៉ាងថ្នមៗផង ហាក់ដូចជាប្រាថ្នាលួងលោម អោយចិត្តនាងរសាយកង្វល់ពីការភិត ភ័យដែលបាត់រូបគេទាំងកណ្តាលយប់ ។

បន្តិចមក គេក៏កាន់ដៃមាលានី ដើរត្រឡប់មកផ្ទះវិញ ។

- នី! ជើងអូនកើតអីហ្នឹង ?

កិត្យាសួរ ព្រោះឃើញប្រពន្ធដើរបុំងខ្ញើតៗ ។

- គឺប្រហែលជាមុតបន្លា ឬអំបែងដបអីហើយ ព្រោះនីភ្លេចពាក់ ស្បែកជើង (មាលានីឆ្លើយ)

កិត្យានឹកអាណិតមាលានីជ្រួចក្នុងឱរា កាលបើដឹងថា នារីខ្វល់ ខ្វាយពីសុខទុក្ខរបស់ខ្លួនរហូតដល់ភ្លេចពាក់ស្បែកជើង មុននឹងរត់ ចេញមកតាមរកនាយនៅខាងក្រៅផ្ទះ ។ គេក៏ទុចដំណើរដើក់ហើយ ងាកបែរមកត្រកងប្រពន្ធលើកបីឡើង ៖

- អញ្ចឹង នីមិនបាច់ដើរទេ ខ្លាចមុតអំបែងកែវថែមទៀត... ចាំបង បីអូនទៅផ្ទះវិញ ។

មាលានីនៅស្ងៀម សម្ងំអោយកិត្យាបីនាងរហូតដល់ផ្ទះ ព្រោះ នាងក៏មានអារម្មណ៍ថា ជើងរបស់នាង កំពុងពើតផ្សាពិបាកទ្រាំ ណាស់ទៅហើយ ។ ម្យ៉ាងទៀត នាងមានអារម្មណ៍ថា ខ្លួនកំពុងមាន សេចក្តីសុខណាស់ដែលបានទទួលការបីត្រកងពីស្វាមី ។

ពេលលអ្នកទាំងពីរបើកទ្វារចូលមក គេក៏ប្រទះម៉ាល័យដែល

CHANBOKEO.COM

កំពុងដើរចេញពីផ្ទះបាយមកដែរ ។ មាល័យភ្ញាក់ក្រញាំងសួរថា ៖
- ប្អូនទាំងពីរទើបនាំគ្នាមកពីណាហ្នឹង ?
កិត្យាញញឹម ហើយឆ្លើយថា ៖
- បាទ! មកពីនាំគូស្នេហ៍ទៅអង្គុយមើលលោកខែនៅខាងក្រៅ!
- អូហ៍ ?... អញ្ចឹងហ្ស៎ ? ចេញទៅមើលលោកខែ ដូចតួឯក
ក្នុងកុនចិនបុរាណដល់ហើយហ្ន៎!... ឡូយផង់គេមែន!
ម៉ាល័យញាក់ស្មាហើយដើរគេចទៅចូលគេងបាត់ទៅ ។

នៅក្នុងបន្ទប់គេង...
កិត្យាយកទឹកក្តៅមកលាងសំអាតជើងអោយប្រពន្ធ រួចហើយ
យកថ្នាំមកលាបអោយតាមស្នាមមុតប៉ុន្មានកន្លែងនោះ បន្ទាប់មកក៏
យកស្បៃមករុំជើងអោយនាងព្រមទាំងស្រដីថា ៖
- នី! ថ្ងៃក្រោយអូនកុំចេញទៅក្រៅផ្ទះពេលយប់ទៀតណា៎! នៅ
ខាងក្រៅមិនមានសុវត្ថិភាពដូចក្នុងផ្ទះយើងទេ ជាពិសេស ចំពោះ អូនជាស្រី
ចេញក្រៅយប់ព្រលប់ ខ្លាចចោរខ្ពញវាប្រមាថជីវិត ។
មាលានីសម្លឹងមុខកិត្យាយ៉ាងយូរទើបឆ្លើយវិញថា ៖
- បើសិនបងកិត្យាមិនចេញទៅណាមកណាពេលយប់ នោះមាលានី
មិនចេញទៅក្រៅពេលយប់ទៀតឡើយ...
ឮដូច្នោះ មាណពក៏ស្រវាចាប់ដៃមាលានីមកកាន់ ហាក់ចង់ផ្តល់
នូវភាពកក់ក្តៅក្នុងចិត្តចំពោះនារី រួចហើយពោលតបថា ៖
- បងមិនទៅណាទេ អូននី! ប្រពន្ធរបស់បងនៅទីនេះ! បងត្រូវ តែត្រឡប់មកទីនេះវិញ
ជានិច្ច ។
- ប៉ុន្តែ ពេលខ្លះ បងក៏ដើរចោលអូនទៅ...
- នោះ ព្រោះបងមិនចង់អោយអូនមានអារម្មណ៍ទើសទាល់ចង្អៀត
ចង្អល់ ចំពោះវត្តមានរបស់បងនោះអី ។
- នរណាថាអូននីទើសទាល់ចង្អៀតចង្អល់ចំពោះរូបបងនោះ ?
- គឺ... មកពីបងឃើញអូនមានកិរិយាហាក់ដូចជាមិនចង់អោយបង នៅជិតៗក្បែរៗអូនទីនេះ ។

CHANBOKEO.COM

រំពេចនោះ មាលានីរំកិលខ្លួនទៅជិតកិត្យា ហើយយកដៃលូក ក្រសោបចង្កេះនរៈ រួចយកកេសាផ្អែកទៅលើទ្រូងរបស់គេ បន្ទាប់ មកក៏ស្រដីថា ៖

- យល់ខុសហើយ បងកិត្យា! ការពិត.. នីចង់នៅជិតបងណាស់! ហើយ... នៅពេលដែលបងដើរចេញពីបន្ទប់យើងទៅ អូនតែងតែ មានអារម្មណ៍ថា បេះដូងរបស់អូនរងាក្រៃលែង... ពេលនោះអូនក៏ បន់ក្នុងចិត្តអោយបងវិលត្រឡប់មកផ្តល់ភាពកក់ក្តៅ...ដល់រូបអូន...

កិត្យាមានការភ្ញាក់ផ្អើលនឹងកិរិយានារីចំពោះរូបគេ ពេលនោះ អ្វីម្ល៉េះទេ! គេរំភើបចិត្តណាស់... រំភើបក្រៃលែងស្ទើរតែហើបជើង ពីដី ។ ភ្លាមនោះ គេក៏លាតដៃស្រវាក្រសោបអោបកាយមាលានីវិញយ៉ាងណែនពេញរង្វង់ដៃរបស់គេ រួចហើយដាក់ថ្ពាល់នរៈផ្តិតផ្ទិប នឹងថ្ពាល់របស់មាណវី ដើម្បីអោយបេះដូងទាំងទ្វេហា មានឱកាស បន្ទរចង្វាក់ឆ្លើយឆ្លងគ្នាទៅវិញទៅមក សម្តែងនូវទឹកចិត្តមេត្រី ចំពោះគ្នាយ៉ាងជាក់ច្បាស់ជាលើកដំបូងយ៉ាងយូរ...

ការពិត នរៈរង់ចាំពេលនេះយូរហើយ... រង់ចាំទទួលនូវសេចក្តី ស្នេហាដ៏បរិសុទ្ធដែលមាលានីព្រមប្រគល់មករូបគេ ដោយសេចក្តី ពេញចិត្តពេញថ្លើមបំផុត ។

បន្តិចមក គេក៏ស្រដីខ្សិបៗដាក់ត្រចៀកនារីថា ៖

- បងស្រឡាញ់អូនណាស់ មាលានី! បងស្រឡាញ់អូនយូរហើយ ហើយក៏រង់ចាំថ្ងៃដែលអូនស្មគ្រ័ចូលខ្លួន មករស់នៅក្នុងលង្វែកទ្រូង របស់បងជានិច្ច ដូចគ្នាដែរ! ស្នេហារបស់បងគ្មានការបង្ខំចិត្តទេ... គឺបងមានតែដួងចិត្តស្រឡាញ់សំរាប់ប្រគល់អោយអូន គ្រប់វិនាទី ទាំងអស់ ។ ពេលនេះ បងរំភើបចិត្តណាស់ដែលបានទទួលនូវ ចម្លើយដួងចិត្តរបស់អូន យ៉ាងទន់ភ្លន់ផ្អែមល្ហែមចំពោះបងវិញ...! នី! បងស្រឡាញ់អូន! បងស្រឡាញ់អូនណាស់ ម្ចាស់ដួងចិត្តបង!

រួចហើយ គេក៏ដាក់នាសាថៃថើបថ្ពាល់នារី ទាំងបេះដូងរន្ធត់ ញាប់ញ័ររកទីបំផុតគ្មាន ។ មាលានីក៏ញញឹមឡើង ទទួលយកការ ថ្នាក់ថ្នមរបស់ស្វាមីដោយពេញចិត្តពីក្នុងបេះដូង លែងមានបញ្ចេញ តិរិយាបថណាដែលបង្ហាញថា នាងមានការទើសទាល់នៅក្នុងចិត្តដូច ពេលមុនៗទៀតឡើយ ។ រាត្រីនោះ គូគាប់ទាំងទ្វេហាបានផ្តេកចិត្ត ផ្តិតកាយ ជាគូស្វាមីភរិយានឹងគ្នា យ៉ាងផ្អែមល្ហែមសុខដុមរមនា ក្រៃលែង ។

ភ្លឺស្រាងៗ... មេឃក៏ចាប់មានពន្លឺសាជាថ្មី...

CHANBOKEO.COM

- ដើបទៅណាហ្នឹង អូននី ?

- គឺទៅដណ្តាំបបរពេលព្រឹកជូនបងពិសានោះអី !

- តែបងមិនទាន់ឃ្លានទេ... នៅគេងក្បែរបងនេះសិនហើយ ព្រោះបងនៅចង់ថ្នាក់ថ្នមប្រពន្ធរបស់បងបន្តិចសិន...

មាលានីញញឹម ហើយស្រដីថា ៖

- នីមិនទម្លាប់ក្រោកក្រោយថ្ងៃរះទេ នាំតែជាគំរូអាក្រក់ដល់ប្អូនៗ...

- តែនេះជាពេលវេលាសុភមង្គលរបស់គូស្រករថ្មី គ្មាននរណាគេ មើលបំណាំយើងទេ អូន !

នារីយកដៃអង្អែលទ្រូងស្វាមី ហើយស្រដីតបថា ៖

- ពេលវេលារបស់យើងនៅសល់សែសិប ហាសិបឆ្នាំតទៅមុខ ទៀតឯណោះណាំបង ! តោះក្រោកឡើង រកលប់លាងមុខណាំ ទាន់នៅព្រហាមព្រឹកមានទឹកសន្សើមបរិសុទ្ធ ដើម្បីទទួលពរពី ទេវតាចំពោះយើងទាំងពីរផង ។

តែកិត្យាមិនសុខចិត្តទេ គេបែរជាទាញដៃនាងផ្ដួលទៅលើទ្រូង របស់គេវិញ ហើយស្រវាអោបកាយនាងសាជាថ្មី ៖

- អញ្ចឹង ! សុំថើបមួយសិនណាំ មុននឹងក្រោកចេញទៅ !

ថាហើយ គេថើបថ្ពាល់ប្រពន្ធខ្សឹត ធ្វើអោយនាងខ្មាញ់ លួចក្តិច សាច់ស្វាមាណពលេង រួចហើយក៏សើចកខឹកឡើង ៖

- លេងខូចណាស់ បងឯងនេះ ។

ថាហើយ មាលានីក៏ទាញក្រមាក្រសោបខ្លួន រួចដើបដើរចេញ ពីបន្ទប់របស់នាង ទៅរកងូតទឹកជំរះខ្លួននៅក្នុងបន្ទប់ទឹក ។

នៅខាងក្រោយផ្ទះ មាលានីឈរពូតខោអាវហាលតែម្នាក់ឯង ។

- អរុណសួស្តី មាលានី !

និតាបែរមុខយ៉ាងរហ័សរកម្ចាស់សម្លេង ក៏ប្រទះឃើញបុរស សង្ហាម្នាក់ ឈរអើតពីម្ខាងរបងមក ។ មាលានីញញឹមស្ងួតតបវិញ រួចហើយបែរចេញធ្វើមិនដឹង ។ ភ្លាមនោះ បុរសស្រដីថា ៖

- នៅខឹងនឹងបងទៀតហ្ន៎ស នារីរូបស្រស់ ? ខឹងរហូតដល់សុខ ចិត្តរៀបការយ៉ាងឆក់ឆៀត ដោយឥតមានប្រាប់ញាតិណាមួយ ម៉ាត់ អញ្ចឹងហ្ន៎សអូន ?

CHANBOKEO.COM

ភ្លាមនោះ នារីក៏ជ្រួញចិញ្ចើម ហើយស្ទុះដើរចេញពីទីនោះ យ៉ាងលឿន ស្រាប់តែបុរសនោះលោតរឹង ឆ្លងរបងមកចាប់ដៃនាង យាត់អោយឈប់យ៉ាងរហ័ស ៖
- នី! កុំអាលទៅណា! មើល៍ បងសុំនិយាយពីរបីម៉ាត់អោយនឹង ស នឹងខ្មៅបន្តិចមើល៍!

មាលានីស្រវាបេះដៃបុរសចេញពីដៃនាង ហើយឆ្លើយថា ៖
- សូមទោស ស៊ុនហេង! យើងគ្មានអ្វីត្រូវនិយាយគ្នាទេ ។
- តែបងមាន!... មានច្រើនណាស់ ដែលបងចង់និយាយជាមួយ អូននី!
- សូមទោស! ខ្ញុំរៀបការមានប្ដីសីហើយ សុំមេត្តាកុំរំខានជីវិត របស់ខ្ញុំតទៅទៀត!

មាលានីក៏បែររឹងបោះជំហានចូលទៅក្នុងផ្ទះវិញ ស្រាប់តែបុរស ស្រែកពីក្រោយទៅថា ៖
- រៀបការហើយ ក៏អាចលែងលះវិញបានដែរ! យ៉ាងណាក៏បង នៅតែស្រឡាញ់មាលានីជានិច្ច!

និយាយពីកិត្យាដែលនៅក្នុងបន្ទប់វិញម្ដង...

កិត្យាក៏សម្លឹងតាមប្រពន្ធដែលដើរចេញទៅ ទាំងទឹកមុខញញឹម រីករាយដាក់នាង ។ បន្ទាប់មក គេក៏ស្រវាទាញផាហ៊ឹមកអោបថើប ដោយក្ដីរំភើបក្នុងចិត្តតែម្នាក់ឯង រួចស្រាប់តែ គេនឹកឃើញអ្វីម្យ៉ាង ក៏ស្រវាលាតផាហ៊ឹរបស់គេទាំងពីរលាតមើលម្ដងទៀត ។ បន្តិចមក កិត្យាបែរខ្លួនយកដៃស្ទាបអង្អែល ពិនិត្យមើលកន្ទេល ដែលក្រាល ទទួលការរួមរក្សមេត្រី រវាងគេនិងមាលានី កាលពីយប់មិញ ។ ភ្លាមនោះ គេជ្រួញចិញ្ចើមក្រញូវភ្លិបតែម្ដង ៖
- មាលានី ? តើអូនជាក្រមុំបរិសុទ្ធឬទេ ? ឬក៏អូនធ្វើពើជាក្រមុំ បរិសុទ្ធ ដើម្បីបន្លំភ្នែកបង ? អូន... មានធ្លាប់ឆ្លងកាត់ជីវិតជាមួយ បុរសណាម្នាក់ពីមុនមកមែនទេ អូននី ? ហេតុអ្វីក៏...គ្មានឈាមរក្សា បញ្ជាក់នូវព្រហ្មចារីយ៍របស់នារីក្រមុំសោះអញ្ចឹង ? បងមិនយល់ទេ អូននី ? ហេតុអ្វីក៏ដូច្នេះទៅវិញ ?

ពេលនោះ កិត្យាមានអារម្មណ៍ថា បេះដូងរបស់គេកន្ត្រាក់ភឹង ឡើង ធ្វើអោយឈាមរត់ច្រាលពេញភ្នែក រកមើលអ្វីមិនឃើញទេ ឃើញតែដំណក់ទឹកភ្នែកនៃក្ដីអាមាសឆាបឆ្លួលក្នុងចិត្ត ដែលគេមិន បានទទួលចំណង់ដៃជាព្រហ្មចារីយ៍បរិសុទ្ធរបស់នារីក្រមុំម្នាក់... ដូច ដែលគេបានប៉ងទុកពីមុនពេលរៀបការមាលានី ។

CHANBOKEO.COM

ទប់អារម្មណ៍មិនបាន គេក៏ឈ្លើផាហ៊ឺបោះចេញទៅក្រៅបន្ទប់ រួច
ហើយក៏ចាប់បោចកន្ទេលទម្លាក់ពីលើគ្រែ ។

- មានរឿងអ្វីហ្នឹង កិត្យាកូន ?

កិត្យាបែរមើលទៅមាត់ទ្វារ ឃើញមីងម៉ៀនឈរធ្វើស្រឡាំង
កាំងដែលឃើញនាយស្រវាទាញកន្ទេលបោចទម្លាក់ពីគ្រែ ។ ដោយ ខ្លាចចិត្តចាស់ៗ
គេក៏ទម្លាក់ដៃចុះ ស្រវាកន្ទេលមកក្រាលលើគ្រែ របស់គេវិញ ហើយឈ្ងោកមុខស្រដីថា ៖

- សូមទោសម៉ែ! គឺ...ខ្ញុំយល់សប្តិមិនល្អ!

ឮដូច្នោះ មីងម៉ៀនក៏គ្រវីក្បាល ហើយមានប្រសាសន៍ថា ៖

- រៀនពន្លត់ចិត្តខ្លះទៅ ណាកូន! សូម្បីតែយល់សប្តិអាក្រក់ ទប់ ចិត្តមិនបានទៅហើយ
ចុះទំរាំបើមានរឿងនៅក្នុងគ្រួសារទៀត តើកូននឹងទប់អារម្មណ៍យ៉ាងណាបានទៅ កូនប្រុសម្តាយ ?
រៀនទប់ រំងាប់ចិត្តបន្តិចទៅណាកូន!

ពោលចប់ គាត់ក៏ដើរចេញទៅ ។ កិត្យាឈរក្តាប់ដៃខាំធ្មេញ មួយស្របក់ក៏ចាប់អាវពាក់
ហើយដើរចេញពីបន្ទប់ទៅតាមប្រពន្ធ ស្រាប់តែជល់គ្នាម៉ាំងជាមួយមាលានី
ដែលកំពុងរត់ចូលមកក្នុងផ្ទះ វិញ ។ ភ្លាមនោះ គេបានឮសម្លេងបុរសស្រែកពីក្រោយខ្នងនារី
មកថា ៖

- រៀបការហើយ ក៏អាចលែងលះវិញបានដែរ! យ៉ាងណាក៏បង
នៅតែស្រឡាញ់មាលានីជានិច្ច!

គេភ្ញាក់ព្រើត លូកស្រវាចាប់ដៃប្រពន្ធជាប់ ហើយដាក់មុខអើត ចេញទៅក្រៅ
ស្រាប់តែប្រទះបុរសសង្ហាមួយរូបកំពុងឈរស្រែក ដាក់មាលានីពីចម្ងាយមក ។
កិត្យាភ្ញាក់ផ្អើលណាស់ ជាពិសេស ចំពោះពាក្យដែលបុរសនោះស្រដីខ្លាំងៗអំបាញមិញនេះ ។ គេក៏
ចាប់ដៃមាលានីយ៉ាងណែនហើយសួរថា ៖

- តើបុរសម្នាក់នោះជានរណា ? ហេតុអ្វីផ្លោះរបងមកស្រែកអុង អាត់ស្អី នៅទីនេះ
ដោយមិនខ្លាចរអែងចិត្តប្តីរបស់គេ ?

មាលានីកន្ត្រាក់ដៃចេញហើយនិយាយថា ៖

- បងកុំច្របាច់ដៃបង្ខំអោយខ្ញុំឆ្លើយ មើលតែខ្ញុំនេះជាអ្នកទោស
អញ្ចឹងមើស៎! បើចង់ដឹងថាគេជានរណា ម៉េចមិនទៅសួរគេទៅ ?

CHANBOKEO.COM

និតាគំហាកហើយជ្រួញចិញ្ចើមដាក់កិត្យា បន្ទាប់មកក៏រត់គេចវឹង ចូលបន្ទប់បាត់ទៅ ។ តែកិត្យាមិនបានរត់ទៅតាមមាលានីទេ ។ គេ បែរជាមកប្រឈមមុខនឹងស៊ុនហេង ដែលកំពុងសម្លឹងទឹកមុខ កន្ទុះរា យ៉ាងចម្លែកបំផុត ។

- នែ៎ លោក! ទីនេះជាផ្ទះរបស់យើង! សូមមេត្តាយោគយល់ព្រំ ដែនផងបាទ!

កិត្យានិយាយទំនងចង់បណ្តេញបុរសនោះ អោយផុតពីរបងផ្ទះ របស់ខ្លួន ។ ចៃដន្យបុរសនោះបែរជាសើច ហើយឆ្លើយវិញថា ៖

- នរណាថា ទីនេះជាផ្ទះរបស់លោក ? ការពិត ទីនេះជាដែនដី របស់ខ្ញុំទេ គ្រាន់តែខ្ញុំអោយគ្រួសារមាលានីជ្រកនៅបណ្តោះអាសន្ន តែប៉ុណ្ណោះ ។ ពេលនេះ ល្មមដល់ពេលហើយទេដឹង ដែលគ្រួសារ មួយនោះត្រូវបង់ថ្លៃឈ្នួលផ្ទះ ឈ្នួលដី អោយសមនឹងតម្លៃទីផ្សារ បច្ចុប្បន្ន ព្រោះខ្ញុំនេះដូចជាយោគយល់គ្រួសារមាលានី យូរខែយូរ ឆ្នាំ ជ្រុលបន្តិចហើយ ។ ការពិត... គឺមកពីខ្ញុំនេះវាឆ្កួត... ឆ្កួតនឹង ស្នេហា ទើបជីវិតរបស់ខ្ញុំវាឡាំឆាអស់រលីងយ៉ាងនេះ !

គេនិយាយផង ធ្វើទឹកភ្នែករលីងរលោងផង រួចក៏លោតឆ្លោះ របងចេញទៅវិញ ទុកអោយកិត្យាឈរស្រឡាំងកាំង មើលតាម កិរិយាបុរសទាំងងឿងឆ្ងល់ផង ខ្លាញ់ផង ហើយក៏ខឹងប្រចណ្ឌប្រពន្ធ ពេញដើមទ្រូងផង ស្ទើរតែទ្រាំមិនបាន រហូតចង់តែស្រែកអោយ ផ្អើលអ្នកជិតខាងទាំងព្រឹកតែម្តង ។

- មាលានី! តើអូនមានចំណងចិត្តស្នេហាជាមួយបុរសនេះយ៉ាងណា ដែរ ទើបម្នាក់ៗមានកិរិយាមានសំដីប្រកបដោយពិរុទ្ធយ៉ាងនេះ ? (កិត្យាគិតក្នុងចិត្តតែម្នាក់ឯង) បងមិនយល់ទេ មាលានី! បងមិន យល់ទេ! ហេតុអ្វីបងក្លាយជាក្របីកម្លៅអោយប្រពន្ធពាក់ស្នែងចង កន្ទុះអូសច្រមុះបានយ៉ាងងាយបែបនេះ ? តើហេតុអ្វី បងក្លាយជា មនុស្សធ្លាក់ក្នុងសំណាញ់ស្នេហាត្រីកោណផង ? ពេលនេះ បងគួរ តែស្រឡាញ់អូនតទៅទៀតទេ ឬក៏យើងត្រូវចែកផ្លូវគ្នាត្រឹមនេះ ?

ភ្លាមនោះ មីងមៀននិងពូនងរត់ចេញមកអើតមើល ព្រោះគាត់ បានឮសម្លេងស៊ុនហេងស្រដីខ្លាំងៗនៅក្រោយផ្ទះ ។ ប៉ុន្តែ លុះ ឃើញស៊ុនហេងត្រឡប់ទៅវិញ ហើយឃើញកិរិយាចម្លែករបស់ កិត្យា គាត់ក៏កេះគ្នាមិចភ្នែក នាំគ្នាដើរចេញទៅ ។

CHANBOKEO.COM

បែរមកមាលានីវិញ...

គ្រាន់តែនារីដើរមកដល់មាត់ទ្វារបន្ទប់របស់នាងភ្លាម ស្រាប់តែប្រទះនឹងផាហ៊ំរបស់នាងធ្លាក់ជ្រុះនៅមាត់ទ្វារ ។ មាលានីភ្ញាក់ព្រើត អោនស្រវារើសឡើងយកមកអោបផ្ទាប់នឹងទ្រូង ដោយក្ដីរន្ធត់ចិត្ត រួចហើយក៏ដើរចូលក្នុងបន្ទប់ ស្រាប់តែភ្ញាក់ក្រញាងលើសមុនទៅ ទៀត ដោយឃើញខ្សែមង្គលរបស់នាងនិងកិត្យាធ្លាក់ជ្រុះរប៉ាត់ រប៉ាយពាសពេញបន្ទប់ ។ ចំណែកឯកន្ទេលក្រាលទទួលពរមង្គល រវាងនាងនិងកិត្យាក្លាយជាបកត្រឡប់ឡើង ក្រាលទទឹងគ្រែយក ខាងខុសក្រាលមកលើវិញ ខុសពីបែបបទដើមអស់រលីង ។

- មានរឿងអីហ្នឹង បងកិត្យា ? (មាលានីស្រដីខ្សិបៗតែម្នាក់ឯង)

ពេលនោះ នារីយើងរន្ធត់ចិត្តចម្លែកយ៉ាងណាមិនដឹងទេ ដែលសុខៗជីវិតគ្រួសារដ៏ថ្មីស្រឡាងរបស់នាងប្រែក្រឡាប់ចក្រដោយមិន ដឹងហេតុផល ។ នាងក៏ស្ទុះទៅបកកន្ទេលរៀបជាថ្មី ហើយរើស ខ្សែមង្គលមកដាក់លើគ្រែវិញ... បន្ទាប់មកក៏អង្គុយអោបផាហ៊ំ សម្លឹងខ្សែ គិតតែម្នាក់ឯងទាំងអារម្មណ៍ច្របូកច្របល់ ។

ស្នូរសូរជើងបានឈានចូលមកដល់បន្ទប់ ។ មាលានីយកដៃ ជូតទឹកភ្នែកចេញពីផ្ទៃមុខហើយបែរក្រោយ ស្រាប់តែឃើញកិត្យា ធ្វើមុខក្រញូវដាក់នាង ថែមទាំងគំហកដោយកំហឹងថា ៖

- បុរសម្នាក់នោះជាសង្សារ ឬជាប្ដីដើមរបស់អូន ? ហេតុអ្វីគេថ្លើម ធំហ៊ានឈ្លានពានប្រមាថកិត្តិយសរបស់បងជាប្ដីទាំងព្រឹកព្រហាម បែបនេះ អូននី ? ឆ្លើយមក់! ឆ្លើយប្រាប់បងមក់!

មាលានីលេបទឹកមាត់ក្អឹក រំងាប់ភាពពុះកញ្ជ្រោលនៅក្នុងចិត្ត រួចហើយក៏តប ថា ៖

- រំលត់ភាពតក្កហលនៅក្នុងបេះដូងសិនទៅ បងកិត្យា! អូនមិន និយាយជាមួយបងទេកាលបើបងកំពុងមានកំហឹងពេញខ្លួនយ៉ាង ដូច្នេះ ព្រោះបើនិយាយ ក៏យើងស្ដាប់គ្នាមិនបានដែរ ។

តែកិត្យាទប់ចិត្តមិនបានទេ ។ គេបែរជាឆ្លើយថា ៖

- យ៉ាងម៉េច ? សុំពេលដើម្បីគិតរកល្បិចមកភូតកុហកបងមែនទេមាលានី ? នែ៎ះ អូនយល់ថាបងល្ងង់ដូចក្របីណាស់មែនទេ បានជាធ្វើមារយាទបែបនេះដាក់បង ? ឬក៏អូននៅអាល័យបុរសម្នាក់នោះ ណាស់ទៅឬទើបធ្វើឫកពាស្អប់ខ្ពើមប្ដី ដល់ថ្នាក់ហ្នឹង ? ឬព្រោះតែ អូនចង់បញ្ឆោះគេទើបអូនប្រញាប់យល់ព្រមរៀបការនឹងបងទាំង តក្កហល ដោយឥតប្រកែកមួយម៉ាត់ដូច្នេះ ?

CHIANBOKEO.COM

- កុំនិយាយបែបនេះ បងកិត្យា! បងស្រដីបែបនេះ ដូចជាមើល ងាយកិត្តិយសអូនពេកហើយ!

គ្រាន់តែឮប្រយោគនេះភ្លាម កិត្យាក៏ច្រត់ចង្កេះឡើង ៖

- អូហ៍! អូននៅស្គាល់ពាក្យថា កិត្តិយសដែរហ្អ៎ស មាលានី? បើ ដូច្នេះ សូមអូននិយាយប្រាប់បងផងមើល ថានារីក្រមុំដែលរៀបការ ផ្សំដំណេកជាមួយប្ដី ដោយគ្មានព្រហ្មចារីយ៍ជាចំណងដៃរាត្រីមង្គល នោះ តើគួរទទួលកិត្តិយសយ៉ាងម៉េចដែរ?

- បងនិយាយអ្វីហ្នឹង បងកិត្យា?

- មនុស្សយើងអស់ធំហើយ ល្អអាក្រក់ ខុសត្រូវ យើងអាចយល់ ដឹងដោយខ្លួនឯង ដោយមិនបាច់គេប្រាប់ផ្ទួនអោយឮច្រំដែលច្រើន ដងទេ ។ បងនិយាយប៉ុនហ្នឹង អូនល្មមយល់ហើយ មាលានី!

ថាហើយ គេក៏ស្រវាវ៉ាលីសចេញមក ហើយរូសខោអាវញ៉ុក យ៉ាងរហ័ស ។ មាលានីភ្ញាក់ផ្អើលណាស់ ចំពោះកិរិយារបស់គេ ។

- គិតទៅណាហ្នឹង បងកិត្យា?

- ទៅណាក៏ដោយ ស្រេចតែបងទេ ។

- តែអូនមិនអោយបងទៅទេ!

- តើអូនមានអំណាចអីមកឃាត់បងនោះ?

- នីមិនមានអំណាចទេ តែនីជាប្រពន្ធបង មានសិទ្ធិឃាត់ប្ដីមិនឲ្យ ទៅក្រៅ ។

- បើបងជាប្ដីមែន ចូរពន្យល់បងបន្តិចមក ថា បុរសដែលស្រែក ឡូងៗនៅខាងក្រៅអំបាញមិញនោះជានរណា? ហេតុអ្វីគេបន់ អោយអូនលែងលះពីបង ដើម្បីគេ?

- គេនិយាយតែគេ ហេតុអ្វីក៏ដាក់ទោសអូនផង បងកិត្យា? អូន មិនមានគម្រោងអ្វីដូចគេនិយាយនោះទេ...

តែទ្រូងកិត្យាកំពុងក្ដៅខ្លាំងណាស់ ។ គេស្ដាប់ការពន្យល់របស់ ប្រពន្ធមិនឮទេ ។ ភ្លាមនោះ គេក៏កញ្ឆក់វ៉ាលីសយួរចេញទៅ ។

- ទៅណា បងកិត្យា?

កិត្យាមិនឆ្លើយទេ បែរជាកាន់តែដើរលឿនជាងមុន ។ មាលានី ស្ទុះរត់តាមពីក្រោយ ធ្វើអោយឪពុកម្ដាយនិងបងប្អូនរបស់នាងនៅ ក្នុងផ្ទះរត់មើលឈូនរពីក្រោយដែរ ។

- បងកិត្យា! (មាលានីស្រដីហៅទាំងទឹកភ្នែករលីងរលោង)

CHANBOKEO.COM

- មិនបាច់តាមបងទៅទេ មាលានី!

កិត្យាលើកវ៉ាលីសដាក់ម៉ូតូ តែគេមិនហ៊ានបែរក្រោយមើល ប្រពន្ធវិញទេ ព្រោះខ្លាចឃើញទឹកភ្នែករបស់នាងណាស់ ។ ថ្វីបើ ពេលនេះ គេខឹងនឹងមាលានីយ៉ាងណាក៏ដោយ ក៏គេមានអារម្មណ៍ថា បេះដូងរបស់គេទន់ជ្រាយជាងស្រីទៅទៀត ។ គេខ្លាចមាលានីយកទឹកភ្នែកមកលួងបន្ទន់ចិត្តរបស់គេ អោយលង់ក្នុងល្បិចកលរបស់ នាងសាជាថ្មី...

- បងកិត្យា... បងទៅហើយ... តើថ្ងៃណាបងត្រឡប់មកផ្ទះវិញ ? អូននៅចាំបងណា បងកិត្យា... សូមត្រឡប់មកវិញឆាប់ៗ !...

មាលានីស្រែកហៅស្ទើយៗ ។ កិត្យាក៏ស្រដីតបខ្សិបៗថា ៖

- មិនដឹងពេលណាត្រឡប់វិញទេ មាលានី... ចាំស្អែក បងមាន អារម្មណ៍ល្អ... បងនឹងគិតសាថ្មី... តែពេលនេះ... បងទ្រាំធ្វើក្របី អោយអូនដាក់កន្លុះដឹកច្រមុះតទៅទៀតមិនបានទេ... ព្រោះបងមិន មែនជាក្របីសំរាប់ជួយបិទបាំងឈ្មោះផ្កាបាក់ទង របស់អូនឡើយ ។ បងពិតជាខ្មាសលោកីយ៍ណាស់ បើសិនជាបងក្លាយជាក្របីសម្រាប់ អោយអូនជិះចម្លងភក់ ដើម្បីបាំងបិទភ្នែកសង្គមទូទៅ...

កិត្យាទប់ចិត្តណាស់ ថាគេមិនអាឡោះអាល័យមាលានីទេ ហើយ ក៏មិនញាប់ញ័ររន្ធត់ដោយការបោះបង់នាងដែរ ប៉ុន្តែពេលនេះ ទ្រូង របស់គេហាក់ដូចជាញាប់ញ័រឡើងៗ ទប់មិនបានសោះ ។

នៅឯមុខផ្ទះរបស់មីងមៀនពូនងវិញ...

មាលានីឈរធ្មឹងដូចរូបចម្លាក់... យំក៏មិនចេញ និយាយក៏មិន ចេញ បានត្រឹមតែឈរសម្លឹងតាមមើលកិត្យាដែលបរម៉ូតូចេញទៅ រហូតបាត់ស្រមោលកប់ទៅក្នុងហ្វូងចរាចរដ៏ខ្ជាន់ខ្ជប់...

មិនដឹងជាអស់ពេលប៉ុន្មានទេ ស្រាប់តែប្អូនប្រុសជំទប់របស់ នាងម្នាក់ ឈ្មោះចាន់ណាត រត់មកកេះ ខ្សិបថា ៖

- បងនី! ម៉ែពុកមានប្រសាសន៍ហៅអោយចូលទៅផ្ទះវិញ ។

មាលានីភ្ញាក់ព្រើត ងក់ក្បាលហើយដើរចូលផ្ទះវិញ ឃើញម្ដាយ ឪពុកនៅអង្គុយជុំគ្នា ក្នុងផ្ទះ ។ ពេលនោះ បងៗរបស់នាងចេញ ទៅធ្វើការរោងចក្រអស់ហើយ ។ ចំណែកប្អូនក៏បានចេញទៅរៀន អស់ដែរ នៅសល់តែឪពុកម្ដាយរបស់នាងតែប៉ុណ្ណោះ ។ មាលានី ស្ទុះទៅស្រវាអោបចង្កេះម្ដាយ ទ្រោបមុខលើស្មារបស់គាត់ ហើយ

CHANBOKEO.COM

ល្អួចសម្រក់ទឹកភ្នែកចេញមកស្ងៀមស្ងាត់ ។ មីងម៉ៀនលើកដៃឡើង បបោសខ្នងនាងបន្តិចៗ ទំនងជួយលួងលោមនាង ។ ពូនងដែល នៅក្បែរនោះ ក៏នៅស្ងៀម មិនពូនិយាយអ្វី សួរអ្វីឡើយ ។

*oooooooooooooooooo*

*oooooo*

CHANBOKEO . COM

# វគ្គទី៦

## ខកបំណង

ក្រុងភ្នំពេញ...

ឆ្នាំ២០០៥...

- ឯងកំពុងរៀបចំវ៉ាលីសទៅណា មាលានី ?
- ទៅលេងស្រុកម្តងណា៎ បងម៉ាល័យ! បងទៅជាមួយប្អូនទេ ?
- មិនទៅទេ ព្រោះពិបាកសុំច្បាប់ពីរោងចក្រណាស់ ខ្លាចមកវិញ អត់ការធ្វើ ព្រោះដើរទៅស្រុកយូរថ្ងៃពេក ។ ហើយនេះ ប្អូនទៅ ជាមួយពុក ឬក៏ម៉ែ ?
- អត់ទេ! ទៅតែម្នាក់ឯងតើហ៏! ពុកម៉ែមិនបានទៅជាមួយទេ!
- អូហ៏! ហើយគាត់អនុញ្ញាត្តិអោយឯងធ្វើដំណើរម្នាក់ឯងដែហ៏ ?
- ស្លាប់ហើយបង! នេះខ្ញុំមានអាយុ២០ឆ្នាំហើយ ណា៎ មិនមែនកូន ក្មេងឯណា ដែលតម្រូវឲ្យមានចាស់ៗចាំឃ្លាំយាមមើលខ្លាចវង្វេង បាត់នោះ ?
- តែឯងជាស្រីក្រមុំណា៎! មិនគួរដើរដំណើរតែម្នាក់ឯងទេ ។
- នរណាទៅដឹងថា ខ្ញុំក្រមុំឬមិនក្រមុំ ? ដើរដំណើរ កុំតែងខ្លួន ហ៊ឺហា វាយប្ញកកោងកាចអោយគេចាប់អារម្មណ៍នោះ ខ្ញុំបានសុខ ហើយ មិនអីទេ បង!

មាល័យញាក់ស្មាដើរចេញទៅ ។ រំពេចនោះ ស្រាប់តែនារីងាក មុខមកសួរប្អូនស្រីវិញ ៖

- ហើយចុះបើប្អូនអាល័យតែទៅស្រុកនោះ តើបាននរណាមើល ហាងសំអាងកាយរបស់ឯង ?
- គឺសេងអោយមិត្តភក្តិបណ្តោះអាសន្នសិនទៅ ព្រោះសព្វថ្ងៃនេះ មានអ្នកធ្វើការទីនោះដល់ទៅបួននាក់ហើយ អត់ខ្ញុំម្នាក់ ក៏មិនអី ដែរណា៎បង ។

CHANBOKEO.COM

មាល័យងក់ក្បាលហើយក៏ស្លៀកពាក់ចេញទៅធ្វើការបាត់ ។

ថ្ងៃនោះ ពូនង មីងមៀនមិននៅទេ អាល័យទៅលើកអង្ករមកពី តាមខែត្រ យកមកលក់ ។ មាលានីក៏សរសេរសំបុត្រមួយទុកអោយ ឪពុកម្តាយហើយក៏ធ្វើដំណើរចេញទៅ ។

លុះពេលព្រលប់ឡើង ពូនងនាំប្រពន្ធមកដល់ផ្ទះវិញ ក៏ប្រទះ សំបុត្រយ៉ាងខ្លីរបស់មាលានីដែលសរសេរថា ៖

- ជំរាបពុកម៉ែ! ខ្ញុំទៅព្រះត្រពាំងវិញហើយ មិនដឹងថ្ងៃណាមក ភ្នំពេញវិញទេ ។ ខ្ញុំបានផ្ញើប្រាក់មួយចំនួនទុកនឹងបងម៉ាឡាសំរាប់ ជូនពុកម៉ែ ។ សូមពុកម៉ែបានសុខសប្បាយជានិច្ច... មាលានី!

ពូនងបើកភ្នែកធំៗ សួរមីងមៀនថា ៖

- ហើយនេះ នាងនីមានប្រាប់អូនទេ ថាគេទៅព្រះត្រពាំង ?

មីងមៀនគ្រវីក្បាល ៖

- ចាស! អត់ទេ!

- សង្ស័យតែវាត្រឡប់ទៅរកនាយបែនទេដឹង ?

មីងមៀនជ្រួញចិញ្ចើម ៖

- បើដូច្នោះ យើងគិតយ៉ាងណាទៅ ?

- បងគិតទៅតាមកូនយកមកវិញហើយ ។

- ប៉ុន្តែ យើងនៅជំពាក់អង្ករម៉ូយប៉ុន្មានជើងទៀតឯណោះ ។ បើ ចង់ទៅតាមមាលានី ចាំដឹកអង្ករអោយម៉ូយតាមសន្យាអោយអស់ សិនទៅ ។

- ចាំយូរពេក តិចលោខក ចាប់មាលានីមិនទាន់... បងព្រួយខ្លាច កូនជ្រុលដំណើរជាមួយនាយបែន កែកុនលែងកើតណា៎!

កំពុងតែជជែកគ្នា ស្រាប់តែមានបុរសសង្ហាម្នាក់ជិះម៉ូតូទំនើប មួយមកដល់មុខផ្ទះ ។

- ជំរាបសួរលោកអ៊ំ!

ពូនងមីងមៀនលើកដៃទទួលសំពះរបស់បុរសហើយក៏មើលមុខ គ្នាឡើង ព្រោះគាត់មិនស្គាល់បុរសនោះជានរណាទេ ។ ឃើញពូនង មីងមៀនធ្វើមីងមាំង បុរសនោះក៏ញញឹមឡើង ហើយស្រដីថា ៖

CHANBOKEO.COM

- ខ្ញុំឈ្មោះតារា ជាភ្ញៀវប្រចាំហាងមាលានី ។ ថៃដន្យ ថ្ងៃនេះ ខ្ញុំ ទៅហាង ឃើញគេដូរផ្លាកដាក់ឈ្មោះថ្មី ក៏នឹកពិភាល់ក្នុងចិត្ត ចង់ ដឹងថា តើមាលានីគេបើកហាងថ្មីនៅខាងណា ទើបខ្ញុំចូលមកសួរ ដំណឹងពីអ្នកផ្ទះ ។

ភ្លាមនោះ មីងមៀនពូនងបើកភ្នែកម្ញូលក្រឡង់ដាក់បុរសសង្ហា ហើយស្រដីថា ៖

- ហាងមាលានីដូរឈ្មោះ ? ហេតុអ្វីទៅ ?

ប៉ុន្តែ ទាំងពូនង ទាំងមីងមៀន គ្មាននរណាដឹងទេ ថាហាង មាលានីដូរឈ្មោះ ។ ភ្លាមនោះ ពូនងជ្រួញចិញ្ចើម ហើយស្រដីថា៖

- សង្ស័យតែមាលានីត្រឡប់ទៅស្រុក លែងមកវិញហើយ ។

- ត្រឡប់ទៅស្រុក ? (តារាលាន់មាត់ហើយជ្រួញចិញ្ចើមផង)

ប៉ុន្តែ ទាំងពូនង ទាំងមីងមៀន មិនបានចាប់ភ្លឹកនឹងកិរិយា របស់តារាទេ ។ គាត់បែរជាសម្តែងចិត្តខ្វល់ខ្វាយទៅលើតែមាលានី ម្នាក់ប៉ុណ្ណោះ ។ ភ្លាមនោះ ពូនងស្រដីឡើងថា ៖

- មៀនអើយ! ទៅរកពីងគេឯងអោយនាំទៅជួយដឹកអង្ករពីខេត្ត មកលក់ហើយ ។ ពេលនេះបងបារម្ភពីកូនណាស់ មិនអាចនៅ ស្ងៀម ចាំស្អែកបានទេ ។ បងនឹងចេញដំណើរទៅនៅពេលនេះ ។

ថាហើយ គាត់ក៏ទាញអាវហាក់ឡើងម៉ូតូឌុបសំដៅចំណតរថយន្ត ឈ្នួលវីង យ៉ាងលឿន ដោយមិនមានលាភ្ញៀវសង្ហានោះមួយម៉ាត់ ណាឡើយ ។ ចំណែក មីងមៀននិងបុរសសង្ហាឈ្មោះ តារា ក៏ ឈរសម្លឹងមើលមុខគ្នាទៅមក ធ្វើឡឹងឡង់ៗ...

និយាយពីមាលានីវិញម្តង...

- ជំរាបសួរមីងនុត!

- យី! នាងនីតើហ៎! ស្លាប់ហើយ! ទៅនៅភ្នំពេញពីរឆ្នាំ មកវិញ ពេញក្រមុំស្រស់ស្អាតណាស់! មីងមើលសឹងតែមិនស្គាល់ ។

មាលានីស្ទុះរត់អោបម្តាយមីង ដែលកំពុងទទាក់ចុងអង្ករអោយ ចំណីមាន់ ។

- មកជាមួយនរណាដែរ ក្មួយនី ? (មីងនុតសួរ)

- គឺមកតែម្នាក់ឯងទេ មីង!

CHANBOKEO.COM

- ហ្អ៎ស ? ឥឡូវនេះ បងនឹងធូររលុងបណ្ដោយអោយកូនក្រមុំដើរ
ហើរធ្វើដំណើរឆ្ងាយតែម្នាក់ឯងឯងផងហ្អ៎ស ?
- អត់ទេ! ខ្ញុំមកនេះ មិនបានសុំគាត់ឯណា ។
- អូហ៍ ? ម៉េចអញ្ចឹង ?
- ព្រោះសុំនឹងឯណា គាត់ប្រកែកដងហ្នឹង ទើបខ្ញុំលួចរត់មកនេះអី!
- ពុទ្ធោ! នេះបើពុកឯងដឹង ច្បាស់ជាខឹងដាច់ក្បាលដាច់កន្ទុយ មិនខាន
ជាពិសេសកាលបើដឹងថា ឯងរត់មកទីនេះ ដើម្បីនរណា ម្នាក់នោះ ។

មីងនុតនិយាយព្រលយពាក្យ ទំនងហាក់ចង់បង្អើបរឿងនាយ បែន ។ ប៉ុន្តែ
មាលានីបែរជាញញឹមហើយស្រដីថា ៖
- មីងមិនបាច់ភ័យទេ ខ្ញុំគ្រាន់តែឆៀងចូលទីនេះ ដើម្បីសួរសុខទុក្ខ មីងម៉ាភ្លែត តែប៉ុណ្ណោះ ។
បន្តិចទៀត ខ្ញុំនឹងចេញដំណើរទៅផ្ទះ ពូណាប់ឯទីក្រុងហើយ ។ យ៉ាងណាក៏ពុកគោរពពូណាប់
មិនហ៊ាន ជេរវាយខ្ញុំឡើយ ណ៎ាមីង ។

មីងនុតក៏ញញឹមឡើង ៖
- អី បើអញ្ចឹង មីងឈប់ខ្វល់ហើយ ម៉ោះ មីងខ្ចប់បាយអោយឯង ទុកបរិភោគតាមផ្លូវ ។

មាលានីមិនបាននៅលេងជាមួយមីងនុតនិងក្រុមគ្រួសារ យូរទេ
ព្រោះនាងត្រូវប្រញាប់ចេញពីភូមិ អោយទាន់ពេលត្រូវឡើងឡាន
ឈ្នួលចុងក្រោយទៅផ្ទះពូណាប់ ។ បន្ទាប់ពីទទួលបង្វិចបាយនិង
អាហារក្រៀមក្រោះពីម្ដាយមីងហើយ នាងក៏សំពះលាមីងនុតធ្វើ ដំណើរចេញទៅ ។ ចៃដន្យ
នាងមិនបានធ្វើដំណើរទៅរកចំណត ឡានទេ តែបែរជាគេចធ្វើដំណើរកាត់ភ្លឺស្រែសំដៅដីភូមិមួយ
ដែល មានផ្ទះឈើចាស់មួយខ្នង ។ នៅក្រោមផ្ទះ មានដូនចាស់ម្នាក់កំពុង
សំរាន្តលើអង្រឹងស្វាត់ស្ញៀម ។ រំពេចនោះ មាលានីបានឃើញនារី ស្រុកស្រែក្មេងច្រឡឹងម្នាក់
ដែលមានវ័យក្មេងជាងនាងបន្តិច កំពុង ទប់ខ្លួននឹងដងទំពក់បេះផ្លែឈើ ឈរនៅក្នុងកៀនផ្ទះ ។
មាលានី សម្លឹងមើលនាងមួយស្របក់ នៅតែមិនចំណាំមុខនារីនោះសោះថា ជានរណា ។
មាលានីក៏នៅឈរស្ងៀមទ្រឹងមួយកន្លែង ក្នុងចិត្តហាក់ ដូចជាជ្រួលច្របល់ចម្លែកយ៉ាងណាមិនដឹង
៖
- តើនាងជានរណា ? (មាលានីខ្សិបសួរខ្លួនឯង)

មាលានីសង្កេតឃើញថា នារីនោះមានផ្ទៃពោះទំនងជិតគ្រប់ខែ ផង ។ ភ្លាមនោះ នារីនោះយកដៃទប់ពោះធ្វើមុខជូរ ទំនងសៀត ពោះ ។ មាលានីក៏ដើរទៅជិតសួរថា ៖

- ចង់អោយខ្ញុំជួយគ្រាហ៍ទៅក្រោមផ្ទះវិញទេ ប្អូនស្រី ?

នារីងក់ក្បាលទាំងបែកញើសសស្រាក់ ។ គ្រាន់តែមាលានីទប់ខ្លួននារីដល់គ្រែឫស្សីនៅក្រោមផ្ទះ ស្រាប់តែបុរសម្នាក់ដើរចុះពីលើ ផ្ទះមកដី ហើយស្រដីព្រមមកផងថា ៖

- បេះស្វាយបានហើយឬនៅ អូនសាឯម ? នេះ បងយកទឹកត្រី ស្ករមកអោយអូនជ្រលក់...!

ស្រាប់តែមាលាណាពភ្ញាក់ក្រញាងនឹងវត្តមានរបស់មាលានីដែលនៅឈរជាមួយនារីដែលមានផ្ទៃពោះ ទីនោះដែរ ។

- នី ? (បុរសលាន់មាត់ខ្សិបៗ)

មាលានីភ្ញាក់ក្រញាង កាលបើឃើញមុខរបស់គេ ៖

- បងបែន ? (មាលានីលាន់មាត់)

រំពេចនោះ ស្រាប់តែនាងសាឯម ស្រដីថា ៖

- អូនសៀតពោះណាស់ បងបែន! ប្រហែលជាដល់ពេលសំរាល កូនហើយទេដឹង! សូមបងរត់ទៅតាមយាយហ្មបបន្តិចមក!

មាលានីកាន់តែភ្ញាក់ឡើងថែមទៀត ក៏ឧទានសួរឡើងថា ៖

- នាងជាប្រពន្ធរបស់បងឬ បងបែន ?

នាយបែនឈរភាំង ញ័របបូរមាត់និយាយមិនចេញ ។ ចំណែក មាលានីវិញក៏រន្ធត់ចិត្តយ៉ាងខ្លាំងដូចគ្នាដែរ ។ កាលបើឃើញអ្នកទាំងពីរឈរសម្លឹងមុខគ្នាមិនព្រិច នាងសាឯមក៏លាន់មាត់សួរថា ៖

- មានរឿងអ្វីហ្នឹង បងបែន ? ហើយបងស្រីម្នាក់នេះជានរណា ?

ប៉ុន្តែ បែនមិនបានឮសំដីរបស់សាឯមសួរទេ ។ គេបែរជាឈរ សម្លឹងមាលានីយ៉ាងភ្លឹក ហើយក៏ឈរកកគាំងមួយកន្លែងនិយាយ មិនចេញ ។ ភ្លាមនោះ មាលានីលេបទឹកមាត់រំលត់ភាពញាប់ញ័រ នៅក្នុងខិភ ហើយ ក៏បន្លឺវាចាឡើងថា ៖

- ប្រពន្ធកំពុងឈឺពោះរកឆ្លងទន្លេហើយ ប្រញាប់ទៅតាមយាយ ហ្មបភ្លាមមក បងបែន!

បែនសម្លឹងមុខមាលានីជាចុងក្រោយ ហើយក៏ស្រវាកង់ឡើង ធាក់យ៉ាងលឿនតាមភ្លឺស្រែសំដៅផ្ទះយាយហ្មប ។

CHANBOKEO.COM

- នរណាគេហ្នឹង មាត់ឰៗ ដូចជាសំដីនាងនី!

មាលានីងាកក្រោយឃើញដូនចាស់ដើបអង្គុយក្នុងអង្រឹង ក៏ស្ទុះ ទៅជិត លុតជង្គង់លើកដៃសំពះ ៖

- ជំរាបសួរម៉ែចាស់! គឺខ្ញុំមាលានី ពិតមែនហើយចាស!

- យី! នីមែនតើហ៎! ហើយឯងសុខសប្បាយទេហ៎? ចុះឯណា ប្តី សីរបស់ឯងមានមកជាមួយទេ?

មាលានីភ្ញាក់ព្រើត ដែលដូនចាស់សួរនាងដូច្នោះ ។ នាងក៏គ្រវី ក្បាលហើយឆ្លើយថា ៖

- ខ្ញុំនៅលីវ មិនទាន់រៀបការឯណា ម៉ែចាស់! ធ្វើម៉េចនឹងមានប្តី យកមកបង្ហាញម៉ែចាស់បានទៅ?

- អូហ៎ ហើយចុះម៉េចបាននាងម៉ាល័យបងស្រីរបស់ឯង វាប្រាប់ អាបែនថាឯងរៀបការជាមួយបុរសទីក្រុងទៅហើយនោះ? ដឹង ទេ ថាអាបែនវាឆ្កួតចិត្តជិតស្លាប់ ទើបម៉ែចាស់ដាច់ចិត្តទៅដណ្តឹង នាងសាឯមអោយវានេះអី ។

មាលានីស្តាប់ដូនចាស់ស្រដីផង នឹកខកចិត្តផង នឹកស្តាយផង ខឹងផង... យ៉ាងណាមិនដឹង... ថានឹងចង់ស្រក់ទឹកភ្នែក ក៏ខ្មាស់មិន ហ៊ានយំនៅចំពោះមុខនាងសាឯមភរិយារបស់នាយបែន ថានឹង ញញឹមអួតខ្លួនសម្តែងភាពក្លាហាន ក៏អួតមិនរួច ។ នាងឈរញ័រដៃ ញ័រជើងទទ្រើកតែម្នាក់ឯង ។ នៅម្ខាងទៀតឯនោះ នាងសាឯម កំពុងតែអង្គុយទប់ផ្ទៃពោះរបស់នាង ធ្វើមុខជូរហ្មួញ មិនដឹងថា នាងកំពុងឈឺផ្ទៃ ឬក៏នាងកំពុងឈឺចិត្ត ដែលបានឃើញសង្សារ របស់នាយបែននៅឈរជ្រងោនឹងមុខ...

មាលានីលើកដៃមើលនាឡិកា ឃើញពេលវេលាប្រថុចញ៉ុច ណាស់ទៅហើយ ។ នាងក៏សំរេចចិត្តលើកដៃសំពះដូនចាស់ ដើរ ចេញមកវិញទាំងសោកសៅ ៖

- សូមទោស ម៉ែចាស់! កូននីដល់ម៉ោងត្រូវឡើងឡានឈ្នួលពេល នេះហើយ ។ សូមជូនពរអោយម៉ែសុខសប្បាយ ។ ប្រាប់បងបែន ផងថា ខ្ញុំលាហើយ!

ថាហើយនាងបែរមករកនាងសាឯម ហើយស្រដីថា ៖

- សូមជូនពរអោយនាងនិងកូនបានសុខសប្បាយ!

ថាហើយ មាលានីក៏ឈ្ញោកមុខរត់ចេញទៅយ៉ាងលឿន ។

នៅចំណតរថយន្តឈ្នួល...

CHANBOKEO.COM

មាលានីបង់ថ្លៃសំបុត្រជិះហើយ ក៏ស្រវាទាញសំពៀតឃ្នួរឡើង ឡាន ស្រាប់តែមានដៃមួយមកទាញសំពៀតរបស់នាង អោយនាង ថយក្រោយវិញ ៖

- ឈប់សិនអូននី!

មាលានីងាកក្រោយឃើញនាយបែនទម្លាក់កង់ចោលហើយអូស ដៃនាងចេញមក ។

- លែងដៃ បងបែន! ខ្ញុំនល់ម៉ោងឡើងឡានហើយ!

- គឺ... បងចង់មកប្រាប់នី ថាបងមិនបានក្បត់ចិត្តអូនទេ! (នរ: ស្រដីទាំងរលីងរលោងទឹកភ្នែក) សូមអូនកុំយល់ច្រឡំអី! គឺមកពី បងបានដំណឹងពីម៉ាល័យថា អូនរៀបការ... ទើបបង...

- មិនបាច់ពន្យល់ទេ បងបែន! ពេលនេះ ទោះយើងបកក្រោយ វិញ ក៏មិនអាចផ្លាស់ប្តូរស្ថានការណ៍អោយប្រសើរបានដែរ... មាន តែបោះជំហានទៅមុខទៀតតែប៉ុណ្ណោះ ។

- ប៉ុន្តែ... បងនៅស្រឡាញ់នី ហើយ... ក៏... នៅរង់ចាំ...

- ឈប់រង់ចាំទៅ... ពេលនេះ បងមានប្រពន្ធកូនហើយ ។ សូម វិលទៅរក្សាគេអោយល្អត្រឹមត្រូវផង ព្រោះពេលនេះគេកំពុងត្រូវ ការបងជាចាំបាច់ណាស់ ។ នីសូមជំរាបលា...!

ថាហើយ មាលានីក៏ឆក់សំពៀតរឹង ស្ទុះរត់ឡើងរថយន្តឈ្នួល យ៉ាងលឿន មិនអោយនាយបែនឃើញទឹកភ្នែករបស់នាងឡើយ ។ ចំណែកនាយបែនវិញក៏ឈរទ្រឹងដូចមនុស្សគ្មានវិញ្ញាណតែម្នាក់ឯង ក្នុងសំណុំធូលីហុយពីក្រោយរថយន្តឈ្នួល ដែលកំពុងដឹកមាលានី ចេញទៅ...

នៅលើរថយន្ត មាលានីខាំមាត់លេបទឹកភ្នែកតែម្នាក់ឯង ប្តេជ្ញា ក្នុងចិត្តដាច់ណាត់ថា នាងនឹងឈប់នឹកនាយបែន... ប៉ុន្តែ ពេលនាង កាន់តែខំធ្មេចពន្លត់ចិត្តនឹកប៉ុនណា រូបនាយបែនអណ្តែតឆ្ពោ មក លងអារម្មណ៍របស់នាងកាន់តែញឹកញាប់ប៉ុននោះដែរ ។ នារីនឹក ស្តាយណាស់ ដែលនាងខំរក្សាចិត្តបរិសុទ្ធអស់យូរឆ្នាំ ដើម្បីអនាគត មួយដែលនាងនឹងនាយបែនក្លាយជាគូជីវិតនឹងគ្នា ។ ប៉ុន្តែអ្វីៗប្រែ ប្រួលមិនដូចការគ្រោងទុករបស់នាងឡើយ ។ ទឹកភ្នែកច្រើនដំណក់ ចេះតែលួចប្រជ្រៀតគ្នាមករំខានផ្ទៃមុខរបស់នាងចប់តាមផ្លូវ រហូត ដល់ផ្ទះពូណាប់ ។

- ព្រះអើយ ក្មួយនី! នេះឯងនឹកពូរហូតយំហើមភ្នែកយ៉ាងនេះ មែនទេ?

CHANBOKEO.COM

ពូណាប់យកដៃអង្អែលក្បាលក្មួយស្រីដែលរត់យំអោបគាត់យ៉ាង សស្រិកសស្រាក់ ។ ការពិត ពូណាប់និយាយបន្លប់ទេ ។ ថ្វីបើក្មួយ ស្រីមិនបានប្រាប់ក៏ដោយ ក៏គាត់អាចកាត់យល់រឿងពិតបានខ្លះដែរ ព្រោះមាលានី ទើបតែវិលត្រឡប់មកពីផ្ទះមីងនុត ។

- ណៃ! ឈប់យំទៅ! យើងធំហើយណា! តាំងចិត្តអោយរឹងប៉ឹង ឡើង! ចុះឯណាក្រែងថា ឯងមានបំណងមករៀនបញ្ចប់មធ្យម សិក្សាវិញ មិនមែនទេ?

មាលានីងក់ក្បាល ។

មែនហើយ! ការពិត មាលានីខំធ្វើការពីរឆ្នាំមកនេះ គឺដើម្បី សន្សំលុយត្រឡប់មករៀនបញ្ចប់ការសិក្សា ឯកម្ពុជាក្រោមវិញ ។ នាងតែងតែគេងយល់សប្តិ ចង់ធ្វើគ្រូពេទ្យណាស់ ។ នារីសង្ឃឹម ថា មានតែពូណាប់ទេ ដែលអាចជាបង្អែករឹងប៉ឹងជួយនាងឆ្លងដល់ ត្រើយបានយ៉ាងជោគជ័យ ។ បើរំពឹងលើឪពុកនាងនោះ នាងនឹង ក្លាយជាកម្មកររោងចក្រមួយជីវិតហើយ ។

នៅរាត្រីនោះ ពូណាប់និងប្រពន្ធរបស់គាត់ បាននៅនិយាយ លេង លើកទឹកចិត្តមាលានី ដែលមានគំនិតវិលមករករៀនបញ្ចប់ ការសិក្សា ។ ប៉ុន្តែ ទោះជាយ៉ាងណា គ្មាននរណាដឹងទេ ថាឪពុក ម្តាយរបស់មាលានីនឹងគិតយ៉ាងណាចំពោះរូបនាង ។

នៅរាត្រីដដែល...

មាលានីគេងយំមួយយប់ទល់ភ្លឺ នឹកឈឺចិត្ត ចំពោះនាយបែន ដែលសម្រេចចិត្តរៀបការដោយមិនផ្តែផ្តាំអ្វីប្រាប់នាងមួយម៉ាត់ ទុក បណ្តោយអោយនាងគេងស្រម័យ រង់ចាំគេអស់ជាយូរឆ្នាំ ។ នាង ក៏គេងនឹកខឹងនឹងបងស្រីដែលទៅភូតនាយបែន ថានាងបានរៀប ការចោលគេ... ខឹងនឹងព្រេងវាសនា ដែលបំបែរផ្លូវជីវិតរបស់ នាង អោយខុសពីបំណងដែលនាងបានប៉ងទុក...

ទីបំផុត មាលានីបានសម្រេចចិត្តយ៉ាងដាច់ណាត់ ថានាងនឹង ទម្លាក់រឿងរបស់នាយបែនចោល ហើយឈោងចាប់យកការសិក្សា របស់នាងជាជំនួសវិញ ។

ស្អែកឡើង ពូណាប់មកគោះទ្វារប្រាប់នាងថា ៖

- ក្មួយនី! ពុកឯងបានមកតាមឯងយកទៅភ្នំពេញហើយ ។

មាលានីភ្ញាក់ព្រើត រត់ចុះពីលើផ្ទះទៅដី ឃើញឪពុកឈរនៅ ចាំនៅមាត់ជណ្តើរ ៖

- ពុក! (មាលានីលាន់មាត់ខ្សិបៗ)

នាងក៏រត់ចុះទៅសំពះសួរពូនងជាឪពុក ។

CIANBOKEO.COM

- ម៉េចក៏កូនមិនសុំពុកស្រួលបួល មាលានី ? ហេតុអ្វីចាំរត់ពួនគេច មុខពុកដូចកណ្ដុរអញ្ចឹង ? បើត្រឹមតែត្រឡប់មករៀនវិញ ហើយអ្វី បានចាំលួចរត់ពីផ្ទះ ?

មាលានីឈ្ងោកមុខមិនឆ្លើយទេ ព្រោះថា ទោះបីជានាងឆ្លើយ យ៉ាងណា ក៏ពូនងនៅតែគិតថា គាត់គិតត្រូវជានិច្ចតែរហូតហ្នឹង! ពូណាប់ឃើញពូនងសំដីធ្ងន់ដាក់មាលានីពេក ក៏មានប្រសាសន៍ធ្វើ អន្តរាគមន៍ឡើង ៖

- ណ្ហើយចុះ បងនង! ទុកនាងនីអោយរៀនម៉ាឆ្នាំសិនទៅ! ដល់ នាងរៀនចប់មធម្យមសិក្សាហើយ ចាំបងមកទទួលកូនទៅផ្ទះវិញ ចុះ ។ ក្មេងកំពុងចង់រៀន យើងមិនគួរឃាត់គេទេ ហើយគេក៏មិន បានទៅធ្វើអ្វីអោយខុសឆ្គងបាក់មុខឪពុកម្ដាយដែរ ។ ទុកអោយខ្ញុំ ជាអ្នកឃុំគ្រងអប់រំគេចុះ ។ បើសិនជាខ្ញុំទាល់ច្រក ចាំខ្ញុំចាប់ បញ្ជូនគេផ្ញើជូនបងវិញ!

ដោយទាល់ច្រក ពូនងក៏សំរេចចិត្តអោយមាលានីស្នាក់នៅឯ កម្ពុជាក្រោមជាមួយឪពុកមា ។ ចំណែកគាត់ក៏ឡើងរថយន្តវិល ត្រឡប់ទៅភ្នំពេញវិញទាំងខកចិត្ត ។

មិនយូរប៉ុន្មាន មាលានីក៏បានចូលរៀនវិញ ដោយមានពូណាប់ ជួយណែនាំផ្លូវយ៉ាងហ្មត់ចត់ផង ព្រោះគាត់ចង់អោយក្មួយស្រីបាន ទទួលការសិក្សាខ្ពង់ខ្ពស់ ដូចកូនចៅរបស់គាត់ពីរនាក់ទៀត ។

សំណាងមិនល្អ មាលានីរៀនមិនបានប៉ុន្មានខែផង នាងក៏បាន ទទួលសំបុត្រពីភ្នំពេញ ថាឪពុកនាងមានគ្រោះថ្នាក់នៅពេលចេញ ទៅដឹកអង្ករតាមខេត្រ ហើយពេលនេះ នៅសំរាន្តពេទ្យមិនដឹងជា ស្លាប់រស់យ៉ាងណា ។ ដោយបារម្ភពីឪពុកពេក មាលានីក៏ដាច់ចិត្ត ឈប់ពីសាលាវិលត្រឡប់ទៅភ្នំពេញ បំរើឪពុកវិញ ព្រោះមិនដឹង ថា នោះជាវេលាចុងក្រោយរបស់គាត់ឬក៏យ៉ាងណា ។ ឯការសិក្សា របស់នាងក៏ត្រូវកាត់ខ្លីតែត្រឹមនោះទៅ ។ រីឯពូណាប់និងប្រពន្ធ របស់គាត់វិញក៏មានការសោកស្ដាយជាខ្លាំង ដែលក្មេងស្រីឆ្លៀវឆ្លាត ដូចមាលានីក្លាយជាខកខានមិនបានរៀនសូត្រ ព្រោះបញ្ហាគ្រួសារ ។ ប៉ុន្តែ ធ្វើម៉េចទៅ បើគាត់មានឋានៈត្រឹមជាឪពុកមាម្ដាយមីង ទោះ ជាយ៉ាងណា ក៏រត់ក្រោយឪពុកម្ដាយរបស់ក្មេងដែរ ។ ពូណាប់មិន អាចជួយអីបានទេក្រៅពីឈរគ្រវីក្បាលអាណិតមាលានីតែប៉ុណ្ណោះ...

oooooooooooooooo

CHANBOKEO.COM

# វគ្គទី៧
# បែកសំបុក

ក្រុងភ្នំពេញ...

ឆ្នាំ២០០៧...

មាលានីមិនអស់ចិត្ត ដែលកិត្យាឡើងម៉ូតូបរចេញពីផ្ទះទៅយ៉ាង តក្កហល ក៏ឡើងម៉ូតូឌុបតាមរកនាយរហូតដល់ផ្ទះឪពុកម្ដាយក្មេក ប៉ុន្តែ គាត់បានក៏គ្រវីក្បាលប្រាប់ថា កិត្យាមិនបានត្រឡប់មកផ្ទះទេ ហើយគាត់ក៏ភ្ញាក់ផ្អើលណាស់ដែល ដែលកិត្យារត់គេចពីមាលានីមក ព្រោះនៅគ្រាមួយពីអតីតកាល គេធ្លាប់ប្រកែកមិនព្រមទទួលយក នារីដែលឪពុកម្ដាយប្រុងដណ្ដឹងឲ្យ ហើយស្មគ្រ័ទទួលយកមាលានី ដោយចិត្តឯង មិនតែប៉ុណ្ណោះថែមទាំងបង្ខំគាត់អោយចូលស្ដីនាង មាលានីរៀបការយ៉ាងប្រញិបប្រញាប់ទៀតផង ។

- បើសិនជាកិត្យាមកផ្ទះ ចាំម៉ាក់ប៉ាជួយណែនាំគេអោយទៅរកកូន វិញណា៎! ពេលនេះកូនទៅផ្ទះវិញសិនចុះ ។

- ចា៎ស! សូមអរគុណម៉ាក់ប៉ាណាស់ ។

មាលានីជំរាបលាឪពុកម្ដាយក្មេកចេញមកវិញ ទាំងឱរារឡេះ រលួយដោយក្ដីបារម្ភចំពោះកិត្យា ។ ពូកេតឪពុកកិត្យាសម្លឹងមុខមីង រត្ន ជាប្រពន្ធរបស់គាត់ ហើយគ្រវីក្បាល ៖

- ហ៊ឺ! ក្មេងៗសម័យឥឡូវគេឆេវឆាវណាស់! ចង់ការក៏ការប្រុយ ចាប់មិនជាប់! ចង់បែកក៏បែកប្រុយ ចាប់មិនជាប់ទៀត... ហើយ នេះ តើគេគិតថា

CHANBOKEO.COM

អាពាហ៍ពិពាហ៍ជាហ្គេមបាយឡុកបាយឡឬអី បាន ជាធ្វើបែបនេះ ? ប្រហែលជាគេមិនដឹងថា គេកំពុងលេងល្បែង ហ្គេម ដាក់ជីវិតរបស់គេទេហ្អីហ្នឹង ម៉ាក់វា ?

- ព្រោះគេស្ថិតនៅក្នុងវ័យឈាមរាវនោះអី ប៉ាវាអើយ! កិត្យាទើប តែអាយុជាងម្ភៃ តើអោយគេមានឈាមខាប់ដូចយើងម៉េចកើត ?

- ហ្នឹងបានថា! បើដឹងថា គេឈាមរាវដែរ ម៉េចក៏បណ្ដោយអោយ កូនរៀបការ អញ្ចឹង ម៉ាក់វា ? ដឹងទេ ជីវិតយុវវ័យ ជាវ័យ ដែលត្រូវរៀនសូត្រ ត្រូវលូតលាស់ទាំងស្មារតីប្រាជ្ញ ទាំងការសិក្សា និងទេពកោសល្យអាជីព ជាវ័យដែលត្រូវធ្វើការសន្សំលុយ ជាវ័យ ដែលមិនគួរចងខ្លួនក្នុងអាពាហ៍ពិពាហ៍ទេ ព្រោះថាគេនៅឆេវឆាវ មានចិត្តមិននឹងន ហើយចូលចិត្តសង្ស័យច្រើនណាស់ ។ ដូច្នេះ គេ គួរតែរង់ចាំដល់អាយុខ្ទង់៣០ មានការសិក្សាជ្រៅជ្រះ មានការងារ ធ្វើគត់មត់ មានប្រាក់ចំណូលគ្រប់គ្រាន់សិន សឹមរៀបការទើបហាក់ ដូចជាសមរម្យ ព្រោះពេលនោះគេក៏លែងឈាមរាវភ្លើតភ្លើនតទៅទៀតហើយ ។ បើសិនគេរៀបការនៅវ័យចំណាស់បន្តិច គ្រួសារគេ នឹងមានសេចក្ដីសុខច្រើនជាងមុន ព្រោះគេចេះនិយាយគ្នាស្ដាប់បាន មិនឆេវឆាវឆុងឆាំង យកឈ្នះ តាមកម្លាំងឈាមរាវរបស់គេទេ ។

- ប៉ុន្តែ ចំពោះកិត្យាកូនរបស់យើង វាខុសគ្នា ។ កាលហ្នឹង បើ យើងមិនព្រមតាមគេ គេនឹងប៉ុនប៉ងធ្វើអត្តឃាដ ។ ពេលនោះ យើងនឹងបាត់បង់កូនប្រុសកម្លោះម្នាក់យ៉ាងអាសារឥតការ ។

- ថៃដន្យ យើងធ្វើតាមគេហើយ ក៏មិនឃើញគេបានទទួលជោគជ័យក្នុងជីវិតស្នេហារបស់គេឯណា ? ឃើញតែឆេវឆាវរត់រកលោត ទឹកសម្លាប់ខ្លួនដដែល... អូនមិនចាំទេ ថាសំរោងគេទូរសព្ទ័មក ប្រាប់យើងរឿងនោះដែរ ? មិនដឹងថា លើកនេះ កិត្យាគេរត់គេច ទៅខាងណាទេ.. គិតទៅ យុវជនដែលមានជំងឺវិបត្តិដួងចិត្ត ពិតជាពិបាកនឹងអោយមនុស្សធម្មតាដូចយើងនេះ ជួយគេណាស់ ព្រោះយើងពុំមានឯកទេសគ្រប់គ្រាន់ នឹងជួយអប់រំចិត្តកូនអោយគេ ទន់ភ្លន់ ចេះគិតវែងឆ្ងាយហើយឈប់ឆេវឆាវតទៅទៀត ។ បង គិតថា បើសិនជានៅស្រុកយើងមានបើកមន្ទីរពេទ្យចិត្តសាស្ត្រ ព្យាបាលរោគចិត្តវិបត្តិ និងកិរិយាវិបត្តិ សំរាប់យុវជននិងយុវបុរស ដូចជានៅបស្ចឹមប្រទេសនោះ បងប្រហែលជាដឹកដៃកិត្យាដើរចូល អោយពេទ្យព្យាបាលមុនគេហើយ ។

CHANBOKEO.COM

- ហើយពេលនេះ បងមានគិតទេ ថាកិត្យា គេកំពុងរត់គេចទៅ ណាដែរទៅ ?
- បងថា កិត្យាស្រឡាញ់សំពោងណាស់ ព្រោះមានតែមិត្តរបស់គេ ម្នាក់នេះទេ
ដែលចេះយោគយល់កិត្យា មិនថា ពេលកិត្យាមួម៉ៅឬ សប្បាយរីករាយទេ ។ បើមិនដូច្នោះទេ
កិត្យាច្បាស់ជាត្រឡប់មក រកយើងជាឪពុកម្ដាយ ។
- តែអំបាញ់មិញ យើងទូរសព្ទ័ទៅក្មួយសំពោងហើយ ។ គេឆ្លើយ ថា
មិនបានឃើញកិត្យាទៅរកគេទេ ។
- បើដូច្នោះ បងចាល់តម្រិះហើយ ព្រោះកិត្យារស់រវើករត់ចុះរត់ ឡើងយ៉ាងនេះ
យើងមិនអាចតាមរកគេឃើញទេ មើលទៅ ទាល់ តែរង់ចាំអោយគេទាក់ទងមកយើងហើយ ។

ពូកេតមីងរត្នសម្លឹងមុខគ្នា សម្ដែងនូវក្ដីបារម្ភចំពោះកិត្យាជាកូន
ជាអតិបរមា ។

និយាយអំពីមាលានីវិញ...

ពេលនាងដើរចេញពីផ្ទះរបស់ឪពុកម្ដាយក្មេកមក នាងមាន អារម្មណ៍ថា
ជង្គង់របស់នាងញ័រខុសប្លែកធម្មតា ។ ចំណែកពិភព លោកក៏វិលផ្ទៀងផ្ទងខុសកន្លែង ។
មាលានីប្រឹងដើរទប់ខ្លួនមករក ហៅម៉ូតូឌុប ឡើងជិះចេញទៅ ក្នុងចិត្តនឹកគិតមិនអស់មិនហើយ
ចំពោះចរិតដ៏សែនចម្លែករបស់កិត្យាចំពោះនាង ម្ដងល្អ ល្អហួស ម្ដងបែរខ្នង ក៏បែរហួស
រកតែនិយាយគ្នាអ្វីមិនបានមួយម៉ាត់...

បន្តិចមក មាលានីក៏ប្រាប់អោយម៉ូតូឌុបដឹកនាងទៅសួនច្បារ ក្បាលជ្រោយ
រំពឹងក្រែងលោបានជួបកិត្យានៅទីនោះ ។ ពេលនោះ នាងបានជួបនឹងមីងលក់ចាប
ព្រមទាំងកូនទាំងបួនរបស់គាត់ ។ គ្រាន់តែក្រឡេកឃើញមុខនាងភ្លាម មីងក៏ស្រែកវ៉ាងមកថា ៖
- យី ! អ្នកនាងអើយ ! មីងកំពុងចាំមើលផ្លូវណា៎ !

មាលានីអរភើត នឹកថា ប្រហែលជាគាត់បានជួបកិត្យាហើយ ស្រាប់តែពូគាត់ស្រដីបន្តទៀតថា
៖
- ម្សិលមិញ មីងនាំកូនទៅផ្ទះតាយាយ ចុះបឹងអូសកំប្លោកច្រៀក ហាលហើយ
តែមិនចេះក្បួនកាច់ធ្វើជាកន្ត្រក ជាអង្រឹងស្អីនោះអ្វី បន្តិចសោះ ។
តើអ្នកនាងអាចធ្វើជួយបង្រៀនគម្រូខ្លះៗ ដល់មីង និងកូនៗបានទេ ?

មាលានីញញឹមហើយស្រដីថា ៖

CHANBOKEO.COM

- មានអីមីង! តែមីងកុំហៅខ្ញុំថាអ្នកនាងអី ហៅខ្ញុំថា អានីៗទៅ បានហើយ ព្រោះខ្ញុំក៏ជាអ្នកក្រីក្រដូចតែមីងដែរទេ ។

- អឺ! អរគុណណាស់ក្មួយនី! ហើយចុះឯណាប្តីរបស់ក្មួយ មិនមកជាមួយទេ ? ពីព្រហាមមិញ មីងឃើញគេមកម៉ាក្លែត ទិញចាប ព្រលែងហើយក៏ចេញទៅវិញទៅ រកតែមីងសួរអីក៏មិនទាន់ ។

មាលានីភ្ញាក់ព្រើតដែលបានដឹងថា កិត្យាមកទីនេះដែរ ។ នាង ញញឹមបន្លប់ ៖

- អញ្ជឹង មីងនាំខ្ញុំទៅផ្ទះតាយាយទៅ ចាំខ្ញុំបង្រៀនមីង ។ ការពិត ខ្ញុំមិនសូវចេះស្ទាត់ទេ តែអាចធ្វើបានខ្លះ ។ បើសិនប្អូន ៗ គេឆ្លាត ប្រហែលអាចបំបែកក្បួន ថែមគំនិត រាវរកម៉ូដថែមទៀត នោះ នឹងអាចក្រងបានច្រើនបែបហើយ ។

ថ្ងៃនោះ មីងលក់ចាបបានយកសំណុំខ្សែកំប្លោកហាលមកអោយ មាលានីណែនាំ ។ ថ្ងៃជិតត្រង់ នារីក៏លាត្រឡប់ចេញទៅផ្ទះវិញ ។ ពេលនោះ មាលានីនឹកចង់ទៅរកសំរោង ដើម្បីសាកសួរដំណឹង កិត្យា ។ តែលុះគិតចុះគិតឡើង នាងក៏សំរេចចិត្តមិនតាមរកប្តីរបស់ នាងតទៅទៀតឡើយ ៖

- បើគេស្រឡាញ់យើងពិតមែន ហេតុអ្វីគេបោះបង់ចោលយើង ដោយឥតអាល័យ យ៉ាងនេះ ? ចំណែកយើងវិញ ម៉េចក៏ធ្វើខ្លួនជា ស្រីហេមរហាមដើរតាមរកប្តីផង ? ដឹងដល់ណាខ្មាស់គេដល់នោះ ថាយើងជាស្រីមិនកើត ការមិនបានបីថ្ងៃផង ប្តីវេចសំពាយរត់ចោលផ្ទះគ្មានដំណឹង ។ ហេតុអ្វី មាលានីដែលជានារីស្រស់ស្អាត មួយរូបបែរជាមានជីវិតអភព្វយ៉ាងនេះ ? អ្វីៗហាក់ដូចជាត្រូវ បណ្តាសាធ្មប់បិសាច... ចង់រៀន រៀនមិនចប់... មានសង្សារ... សង្សាររៀបការចោល... មានប្តី...ប្តីរត់ចោលទៀត... តើពេលនេះ យើងត្រូវរំពឹងលើអ្វី ? រំពឹងព្រះមែនទេ ? តើព្រះនៅឯណា ? ហេតុអ្វីមិនឃើញលោកយាងចុះមកប្រោសយើងអោយផុតបណ្តាសា នេះទៅ ? ពេលនេះ យើងគួរពឹងនរណា ? ពឹងពុកម៉ែឬ ? អត់ទេ យើងមិនអាចពឹងគាត់បានទេ ព្រោះគាត់ជួយខ្លួនគាត់មិនរួចផង តើ អោយជួយយើងយ៉ាងម៉េច ? ពឹងបងៗ ? គេសុទ្ធតែមានគ្រួសារ ហើយធ្វើការរោងចក្រ រកតែពេលបរិភោគអាហារជុំប្តីប្រពន្ធមិន បានផង តើអោយគេមានពេលឯណាមកគិតរឿងយើង ? ពឹងបង សំរោង ? គេមានប្រពន្ធ មានកូនចៅដែលត្រូវថែរក្សា គេគ្មាន ពេលអោយមាលានីទេ... ដូច្នេះ គ្មាននរណាអាចជួយមាលានីបាន ក្រៅពីខ្លួនមាលានីតែប៉ុណ្ណោះ ។

CHANBOKEO.COM

ភ្លាមនោះ នារីដកដង្ហើមមួយយ៉ាងវែង ទម្លាយភាពសៅហ្មង ក្នុងចិត្ត រួចហើយក៏ហៅម៉ូតូឌុបជិះត្រឡប់ទៅផ្ទះ ។

ថ្ងៃដន្យ ពេលដែលមាលានីមកដល់មុខផ្ទះ ស្រាប់តែនាងប្រទះ នឹងថៅកែស្រីម្នាក់កំពុងឈរស្រែកចេកចាច ដាក់ឪពុកម្ដាយរបស់ នាង ។

- មានរឿងអ្វីហ្នឹង អ៊ីហួយ ? (មាលានីសួរ)

- គឺយើងត្រូវការអោយក្រុមគ្រួសារនាងរើចេញឆាប់ៗនេះ ។

ថៅកែចិននោះឆ្លើយ ។ មាលានីក៏តបវិញថា ៖

- ម៉េចអញ្ចឹងទៅវិញ អ៊ី ? គ្រួសារយើងមានកុងត្រាជួលផ្ទះនេះ ជាប់រហូតដល់ឆ្នាំក្រោយឯណោះ ទើបត្រូវរើចេញ ។

- តែស្ថានការណ៍ផ្លាស់ប្ដូរហើយ ព្រោះមានគេដេញថ្លៃយកដីធ្វើផ្ទះ ល្វែងលក់គ្រឿងម៉ូតូ ។ កាលបើត្រូវថ្លៃហើយ យើងត្រូវតែលក់ យកលុយរកស៊ីទៀត ។ ចំណែកឯងគ្រួសាររបស់នាង ក៏ត្រូវរើ ចេញអោយបានឆាប់ដែរ បើមិនដូច្នេះ យើងនឹងអោយពួកត្រាក់ទ័រ មកឈូកចូកចោលទាំងមនុស្សទាំងផ្ទះហើយ ។

មាលានីស្ងួតបំពង់ក នឹកអាណិតក្រុមគ្រួសាររបស់នាងណាស់ ។ តាំងពីឪពុកនាងមានគ្រោះថ្នាក់មក គាត់ក៏ក្លាយខ្លួនពិការ មិនអាច ធ្វើការអ្វីបាន ពឹងតែមីងម៉ៀននិងកូនៗ ដើម្បីជួយធ្វើការផ្គត់ផ្គង់ គ្រួសារប៉ុណ្ណោះ ។ ពេលនេះ ជីវភាពរបស់គ្រួសារនាង ក៏មិនទាន់ ធូរធារនឹងអាចដើររកផ្ទះល្អនៅបានទេ មានតែរកផ្ទះកណ្ដុរកន្លាត ជួលនៅតែប៉ុណ្ណោះ ។

កំពុងតែឈ្ងោកគិត ស្រាប់តែនាងដាក់ភ្នែកចោលទៅម្ខាងរបង ក៏ប្រទះនឹងនាយស៊ុនហេង កូនកម្លោះអ៊ីហួយ កំពុងឈរអោបដៃ ផ្អែកមាត់ទ្វារផ្ទះរបស់គេ សម្លឹងមុខនាងពីចម្ងាយ ធ្វើទឹកមុខយ៉ាង ចម្លែកដាក់នាង ។ ពេលនោះ មាលានីយល់ស្ថានការណ៍ភ្លាម ៖

- ការពិត គឺជាអ្នកទេតើហ៏ ដែលពន្យុះម្ដាយអោយមកដេញពួក យើងអោយរើផ្ទះ ! ហេតុអ្វីនាយចិត្តសាមាន្យចំពោះខ្ញុំម្ល៉េះ ? តាំង ពីថ្ងៃដែលខ្ញុំស្គាល់អ្នកលើកដំបូង រហូតដល់ថ្ងៃអ្នកសារភាពចំពោះខ្ញុំ ថាស្រឡាញ់មាលានី អ្នកមិនដែលបង្ហាញនូវសមានចិត្តចំពោះក្រុម គ្រួសាររបស់ខ្ញុំទេ... សេចក្ដីស្រឡាញ់របស់អ្នក មានតែការបង្ខិត បង្ខំអោយពួកខ្ញុំធ្វើតាមចិត្តអ្នកតែម្យ៉ាងប៉ុណ្ណោះ... ធ្វើម៉េចខ្ញុំជាអ្នក ក្រ ខ្ញុំពិតជាចាញ់ឥទ្ធិឫទ្ធិរបស់អ្នកមែនហើយ ប៉ុន្តែខ្ញុំមិនចាញ់ទឹក ចិត្តអ្នកទេ... ខ្ញុំមិនចាញ់ទេ..

CHANBOKEO.COM

ខ្ញុំមិនចុះចាញ់អ្នកជាដាច់ខាត ។ ខ្ញុំ មិនអោយអ្នកបំផ្លាញជីវិតខ្ញុំ ឬជីវិតពុកម៉ែបងប្អូនរបស់ខ្ញុំបាន ឡើយ ។

ភ្លាមនោះ មាលានីក៏ស្ទុះចូលទៅក្នុងផ្ទះ ស្រវាយកប្រាក់ដែល នាងសន្សំទុកទាំងអំបាលម៉ាន ចេញទៅរកជួលផ្ទះមួយភ្លាម ។ សំណាងល្អ ប្រហែលពីរម៉ោងក្រោយមក នារីក៏មកហៅបងប្អូននាំគ្នាប្រមូលឥវ៉ាន់តាមតែអាចធ្វើទៅបានតាមកម្លាំងសម្មាជីវោ រើយក សំបុកសម្បត្តិតាមខ្លួន ដើរសំដៅទៅផ្ទះថ្មីដែលនាងទើបជួលបាន ដែលនៅឆ្ងាយពីនោះ ប្រហែល៣០០ម៉ែត្រ ។

- ផ្ទះនេះតូចហើយគ្មានបន្ទប់យ៉ាងនេះ តើយើងរស់នៅយ៉ាងម៉េច ទៅអូននី ? (ម៉ាល័យសួរ) ពួកយើងខ្លះមានគ្រួសារហើយ ខ្លះក៏ នៅលីវ ខ្លះក៏កូនក្មេង...

- ស៊ូទ្រាំសិនទៅបង ចាំយើងមានលុយទិញផ្ទះនៅខ្លួនឯង ។

មាលានីនិងបងប្អូនប្រុសស្រីរបស់នាងពីរបីនាក់ទៀត ក៏មិន មើលបំណាំគ្នាដែរ ។ គេក៏នាំគ្នាជួយរើអីវ៉ាន់ពីផ្ទះចាស់មកផ្ទះដែល ទើបជួលបានដោយមិនមាននរណារអ៊ូរទាំអ្វីទេ ព្រោះគេឃើញពូ នងមីងម៉ៀនមានទឹកមុខមិនសូវស្រស់បស់ ។ ទោះជាយ៉ាងណា គេបានសម្រេចចិត្តថា រស់នៅជាគ្រួសាររួមសុខរួមទុក្ខនឹងគ្នាទៅ ហើយ ។ ពួកគេក៏នាំគ្នាតស៊ូប្រឹងខំមាត់ប្រយុទ្ធនឹកការលំបាកតទៅ ទៀត តាមដែលគេអាចធ្វើបាន ។

ថ្ងៃនេះ មាលានីអស់កម្លាំងណាស់ ប៉ុន្តែ នាងនៅតែប្រឹងជួយ ដៃបងប្អូនរបស់នាងដោយមិនត្អូញត្អែរសោះឡើយ ។ កំពុងតែរៀប ចំផ្ទះ ស្រាប់តែមាលានីមានអារម្មណ៍ថា ពិភពលោកផ្អៀងវិលខ្វាល់ រួចហើយនាងក៏ដួលបាត់ស្មារតីទៅ ។

លុះភ្ញាក់ស្មារតីមកវិញ មាលានីឃើញឪពុកម្តាយរបស់នាង និងបងប្អូនទាំងអស់អង្គុយដំកង់ជុំវិញខ្លួននាង ក្នុងផ្ទះ ។

- ពុក! ម៉ែ! បង...!

មាលានីប្រឹងក្រោកឡើង ត្បិតមិនចង់អោយម្តាយឪពុកភិតភ័យ ចំពោះអាការៈរបស់នាង ស្រាប់តែឪពុករបស់នាងមានប្រសាសន៍ ឡើងថា ៖

- គេងទៅវិញសិនទៅកូន! កុំប្រញាប់ក្រោកឡើងមកធ្វើអី! រក្សាសុខភាពកូនអោយរឹងប៉ឹងសិនទៅ ។ កុំបារម្ភពីពុកម៉ែនិងបងប្អូន ពេក ។ ពួកយើងមិនអីទេណា!

ការពិត នរណាៗក្នុងផ្ទះក៏ដឹងដែរថា មាលានីមានអារម្មណ៍មិន ល្អ តាំងពីកិត្យាគេចចេញទៅ ។ ភ្លាមនោះ មាណវីយើងក៏ដាក់ខ្លួន ទៅលើខ្នើយវិញ បិទភ្នែកសម្ងំស្ងៀមស្ងាត់ ។ មីងម៉ៀនយកដៃ អង្អែលក្បាលកូនបន្តើរៗ ហើយស្រដីថា ៖

CHANBOKEO.COM

- ថ្វីបើគេគេចខ្លួនមិនទទួលខុសត្រូវជីវិតរបស់កូនមែន ប៉ុន្តែកូន
នៅមានពុកម៉ែនិងបងប្អូនពេញផ្ទះ ដែលរង់ចាំផ្តល់កម្លាំងចិត្តអោយ កូនជានិច្ច...
កុំគិតខ្លីអ្វីអោយសោះណ៎ាកូនណ៎ា! យើងនឹងរក្សាគ្នា ទៅវិញទៅមកដោយសេចក្តីស្រឡាញ់!
យើងមិនបោះបង់ចោលគ្នា ទេ ។ មាលានីជាកូនរបស់ពុកម៉ែ! ហើយពុកម៉ែស្រឡាញ់កូន គឺ
ស្រឡាញ់កូនគ្រប់គ្នាទាំងអស់ ។ កូនកុំតូចចិត្តនឹងព្រេងវាសនាអី!
ជីវិតរបស់យើងនៅមានផ្លូវដើរច្រើនណាស់ មិនមែនមានតែផ្លូវ មួយសម្រាប់ដើរទេ ។
បើផ្លូវមួយណា វាទាល់ច្រក វាមានគន្លុក មានពស់អសិរពិស នៅមានផ្លូវផ្សេងទៀត
ដែលកូនអាចដើរបាន ដោយសុខសប្បាយ ឆ្ពោះទៅរកជោគជ័យក្នុងជីវិតជាថ្មី ។ កុំអស់
សង្ឃឹមណ៎ាកូនណ៎ា! តាំងស្មារតីឡើង! កុំចុះចាញ់ជីវិត ហើយកុំ
ចុះចាញ់ចិត្តបុរសដែលមិនស្គាល់តម្លៃពិតរបស់យើង ។ បណ្តោយ គេទៅ...
ទុកអោយគេគេងគិតម្នាក់គេចុះ ។ ចំណែកកូនវិញ ត្រូវ រៀបចំខ្លួន
ធ្វើយ៉ាងណាអោយខ្លួនមានតម្លៃ ហើយអោយបុរសគេ ដេកនឹកស្តាយចំពោះរូបកូន
ស្តាយនូវអ្វីដែលគេបានធ្វើមកលើកូន.. បើសិនបុរសស្គាល់តម្លៃពិតប្រាកដរបស់កូន
គេនឹងវិលមករួមជីវិត ជាមួយកូនសាជាថ្មី ដោយគ្មានការប្រកាន់រើសអើងអ្វីតទៅទៀត ឡើយ ។
ពេលនោះ ជីវិតរបស់កូននឹងមានសុភមង្គលល្អជាមិន ខាន ។

មាលានីលូនទៅជិតឪពុកម្តាយរបស់នាង ហើយលើកដៃសំពះ
ប្រណម្យឡើង ៖

- កូនស្រឡាញ់ពុកម៉ែណាស់! ពេលនេះ បើសិនជាជីវិតរបស់កូន គ្មានពុកម៉ែនិងបងៗទេ
ប្រហែលជាកូនគិតខ្លីផងក៏មិនដឹង ។ តែពេលនេះ កូនគិតថា កូនកាត់ចិត្តបានហើយ
ថាមិនងាកក្រោយ មើលទៅអតីតកាលទៀតទេ ។ កូននឹងខំកសាងខ្លួនសាជាថ្មី មិន
អោយបុរសមកប្រមាថកូនជាលើកទីពីរបានឡើយ ។

ពូនងមីងមៀននិងបងប្អូនមាលានីទាំងអស់ ក៏ញញឹមដាក់នាង ឡើង ជាសញ្ញាលើកកម្លាំងចិត្ត
និងក្តីសោមនស្សដែលមាលានីមិន បណ្តោយអោយទុក្ខព្រួយដណ្តប់ចិត្តនាងអោយគិតខ្លី
ដូចជានារីក្មេង ខ្លះៗក្នុងសង្គមខ្មែរបច្ចុប្បន្ន ដែលតែងតែគិតច្រឡំថា ជីវិតមាន
តែផ្លូវមួយគត់សំរាប់ដើរ មិនដឹងថា ពិភពលោកធំធេង ហើយមាន
ផ្លូវសំរាប់ជ្រើសរើសច្រើនណាស់ បើសិនជាគេព្រមបើកភ្នែកបើក
ចិត្តបែរសម្លឹងមើលពិភពជុំវិញខ្លួន អោយបានយូរជាងមុនបន្តិច....

CHANBOKEO.COM

ពោលគឺសម្លឹងពិភពលោកដោយសតិប្រាជ្ញ មិនមែនដោយអារម្មណ៍ ខឹងហួហ្មងអំពល់ក្នុងចិត្តនោះឡើយ ។

០០០០០០០០០០០០០០០០០០០០

០០០០០

០

CHANBOKEO . COM

# វគ្គទី៨
# មិត្តប្រុស

ក្រុងភ្នំពេញ...

ឆ្នាំ២០០៦...

មាលានីធ្វើដំណើរមកពីកម្ពុជាក្រោម ត្រឡប់មកភ្នំពេញទាំង អន្ទះសា ព្រោះត្បិតព្រួយបារម្ភពីស្ថានភាពជំងឺរបស់ឪពុកនាង ។ សំណាងល្អណាស់ ដែលពេទ្យបានជួយសង្គ្រោះពូនងទាន់ពេល វេលា ។ ពេលនោះ ពូបាក់ភ្លៅស្ដាំហើយបាក់ឆ្អឹងជំនីរបីកាំ ដូច្នេះ ហើយក៏ត្រូវទទួលការព្យាបាលយ៉ាងយូរទំរាំជាសះស្បើយមកវិញ ។ ចំណែកឯលុយកាក់ដែលមាលានីសន្សំបានសំរាប់ទុករៀនសូត្រនោះ នាងបានយកទៅប្រគល់ជូនម្ដាយ មើលថែជំងឺឪពុករបស់នាង អស់ រលីង ។ ចាប់ពីថ្ងៃនោះមក មាលានីក៏ត្រូវចេញរកការធ្វើសាជាថ្មី ដើម្បីជួយក្រុមគ្រួសារជំនួសដៃជើងឪពុករបស់នាង ដែលពិការ ធ្វើការលែងកើត ។ ចំណែកមីងមៀន ក៏ឈប់នៅផ្ទះរក្សាពូ នង ខានរកស៊ីអស់ម្នាក់ទៀត ។ ម្ល៉ោះហើយជីវភាពរបស់គ្រួសារ ពូនង មានសភាពតឹងតែងជាងមុន តាំងពីពូទទួលគ្រោះថ្នាក់នោះ មក ។

មាលានីគិតថានឹងទៅធ្វើការជាអ្នកខាត់ក្រចកសំអាងមុខសំអាង សក់នារីសាជាថ្មី ក៏វិលត្រឡប់ទៅរកសារេនមិត្តស្រីរបស់នាង ។

CHANBOKEO.COM

- អោយខ្ញុំសូមទោសផងទៅមាលានី ពេលនេះ ខ្ញុំបានសេងហាង ទាំងមូលអោយគេហើយ ព្រោះប្ដីរបស់ខ្ញុំចង់បើកហាងផ្ដិតរូបថត ហើយឲ្យខ្ញុំ ទៅជួយគេនៅទីនេះ ទើបសម្រេចចិត្តឈប់ធ្វើមុខរបរ នេះ ។

មាលានីធ្វើមុខស្ងួត រកនឹកថា តើនាងត្រូវចាប់ផ្ដើមដើរខាត់ ក្រចកតាមផ្ទះសាជាថ្មី ឬយ៉ាងណា ។ សារេនឃើញនារីយើងមាន ឬកពាសោកសៅ គេក៏ហៅមាលានីអោយទៅជួបបងប្រុសគេម្នាក់ ដែលធ្វើការនៅរោងចក្រមិនឆ្ងាយពីហាងសំអាងកាយចាស់របស់គេ ទាំងពីរនាក់ប៉ុន្មានទេ ។

- អានី! នេះបងសំរោង បងប្រុសរបស់ខ្ញុំ ។

- ជំរាបសួរបង!

សំរោងញញឹមលើកដៃសំពះតបវិញ ។ នៅក្នុងផ្ទះសំរោងដែល ត្រឹមតែជាកូនផ្ទះតូចផ្ទាល់ដីមួយខ្នង មាលានីអង្គុយមើលនាងប៉ិច ប្រពន្ធរបស់សំរោងរកស៊ីលក់នូរកំប៉ិកំប៉ុកមុខផ្ទះ ដើម្បីជួយសំរាល បន្ទុករបស់សំរោងដែលធ្វើការរោងចក្រយ៉ាងនឿយហត់បំផុត ។

- ឮថាប្អូនចង់ធ្វើការនៅក្នុងរោងចក្រមែនទេ? (សំរោងសួរ)

មាលានីងក់ក្បាល ៖

- ចាំសបង! ខ្ញុំពិតជាពឹងបងជួយណែនាំផ្លូវខ្លះ ព្រោះក្រុមគ្រួសារ របស់ខ្ញុំមានសភាពទីទាល់បន្តិច ព្រោះយើងជាមនុស្សចំណូលថ្មី ។

សំរោងនិងភរិយាហាក់ដូចជាមាននិស្ស័យនឹងមាលានីណាស់ ។ គ្រាន់តែជួបគ្នាភ្លាម ក៏រាប់អានស្គាល់គ្នាជិតដិតតែម្ដង ។ មិនយូរ ប៉ុន្មាន សំរោងក៏បានជួយនាំមាលានីអោយចូលធ្វើការក្នុងរោងចក្រ ជាមួយគ្នា ប៉ុន្តែកាន់ការងារផ្នែកផ្សេងគ្នាពីសំរោង ។

ប៉ុន្មានខែក្រោយមក...

ដោយបងៗរបស់មាលានីមានការធ្វើគ្រប់គ្នាផង ហើយណាមួយ កូនចៅរបស់ពូនងកាន់តែលូតលាស់ធំៗផង ពូនងនិងមីងមៀន បានសំរេចចិត្តលើកដំបូលតូបតូចមួយមុខផ្ទះ គ្រាន់នឹងរកស៊ីបន្ថែម

CHANBOKEO.COM

តិចតួចគ្រាន់នឹងទប់ទល់ការខ្វះខាតក្នុងគ្រួសា ព្រោះនៅផ្ទះគាត់ អ្នកធ្វើការមានតិចចំនួនជាងអ្នកដេកស៊ី ។

បងប្អូនរបស់មាលានីទាំងអស់មិនបានធ្វើការជុំគ្នាទេ ព្រោះមិនអាចប្រជ្រៀតសុំគេចូលព្រមគ្នាបាន ទើបបណ្តោះគ្នាធ្វើនេះធ្វើនោះ តាមតែដំណើរ ។ តាំងពីសង់តូបមុខផ្ទះនោះមក មាលានី បងស្រី និងបងថ្លៃរបស់នាង រួមដៃគ្នាបើកតូបសំអាងក្រចក សំអាងមុខ និង សំអាងសក់នារី សាជាថ្មី ហើយផ្លាស់វេននាំគ្នាកាន់ការ ក្រោយ ពេលម៉ោងរោងចក្រ ព្រោះពួកគេកាន់វេនការងារខុសៗគ្នា ។

ក្រោយមក ជីវភាពរបស់ក្រុមគ្រួសារពូនងក៏កាន់តែវិវត្តន៍មក ប្រសើរវិញម្តងបន្តិចៗ ។ មាលានីក៏បានកាត់ចិត្ត ឈប់នឹកនាពីការ វិលត្រឡប់ទៅកម្ពុជាក្រោម ដើម្បីបន្តការសិក្សាដែរ ព្រោះនាងបាន អស់ទឹកចិត្តតាំងពីដឹងថា នាយបែនបានរៀបការចោលនាងទៅ ។ ពេលនេះនាងបានរៀបខ្លួនត្រៀមចិត្តទទួលជីវិតនៅភ្នំពេញជាមួយ ឪពុកម្តាយរបស់នាងវិញហើយ ។

ព្រឹកថ្ងៃអាទិត្យមួយ...

ម៉ាឡាជាបងស្រីកំពុងកាត់សក់ធ្វើសក់អោយភ្ញៀវនារីម្នាក់ នៅក្នុងតូបមុខផ្ទះឈ្នួលរបស់មីងមៀន ។ មាលានីកំពុងអង្គុយជូត សំអាតគ្រឿងសំអាង ស្រាប់តែ ៖

- សួស្តីមាលានី!

មាណវីងាកវឹង ឃើញបុរសសង្ហាម្នាក់ដើរចូលមក ។

- ភ្លេចខ្ញុំហើយប្ញ៉ស ? បានឈរធ្វើភាំងអញ្ចឹង ?

បុរសនោះសួរ ។ ស្រាប់តែមាលានីលាន់មាត់ឡើង ៖

- លោកតារា ?

- បាទ មែនហើយ!

មាលានីញញឹមឡើង ៖

- បាត់មុខលោកយូរ ដល់ឃើញវិញ សង្ហាឡើងមើលមិនស្គាល់តែ ម្តងហើយនេ៎ះ!

តារាញញឹមឡើងដែរ ៖

- ស្លាប់ហើយ! មិនដឹងសោះថា មាលានីចេះក្បួនបញ្ជោរភ្ញៀវដល់ ថ្នាក់ហ្នឹង!

CHANBOKEO.COM

អ្នកទាំងពីរក៏ញញឹមដាក់គ្នាសាជាថ្មី ។ ពេលនោះ មាលានីមាន អារម្មណ៍ហាក់ដូចជារំភើបចិត្តប្លែកតែម្តង ដែលនាងបានជួបតារា ។

- លោកតារា! នេះ ម៉ាឡាបងស្រីរបស់ខ្ញុំ!

មាលានីឃើញបងស្រីលួចសម្លឹងតារាភ្លៀកៗ ក៏ណែនាំអោយ ស្គាល់គ្នា ។

- សួស្តីបងស្រី! មិនប្រាប់ក៏នឹងថា ជាបងប្អូននឹងគ្នាដែរ ព្រោះអី មុខមាត់ស្រដៀងគ្នាណាស់ ។

ម៉ាឡាញញឹមដាក់តារា រួចហើយក៏បែរទៅបំរើភ្ញៀវរបស់នាង វិញ ។ ភ្លាមនោះ តារាស្រដីថា ៖

- តើមាលានីអាចទៅសំអាងភ្ញៀវនៅតាមផ្ទះបានដែរទេ ?
- គឺ.. ខ្ញុំធ្វើតែនៅក្នុងតូបតូចរបស់យើងនេះ មិនដែលចេញតាម ផ្ទះទេ ។ ម្យ៉ាងទៀត ខ្ញុំមិនដែលមានភ្ញៀវមកហៅអោយទៅតុប តែងសំអាងអោយគេនៅតាមផ្ទះរបស់គេផង ។
- ថៃដន្យ ព្រឹកនេះ ខ្ញុំមានសាច់ញាតិច្រើនគ្នាដែលត្រូវសំអាងសក់ សំអាងមុខ ដើម្បីទៅញ៉ាំការល្ងាចនេះ ហើយពិបាកឌុបគេមករក មាលានី តើមាលានីអាចទៅសំអាងអោយគេបានទេ ?

មាលានីងាកទៅបងស្រី ទំនងសួរយោបល់ ស្រាប់តែម៉ាឡា ឆ្លើយថា ៖

- បើមានគ្នាច្រើនអញ្ចឹងក៏ម្យ៉ាងដែរ ណា៎អូននី! ទៅជួយសំអាង ម៉ាភ្លែតទៅ កុំអោយគេថាយើងឆ្មើងមិនចេះគួរសមជាមួយភ្ញៀវ ប្រចាំរបស់យើង ។

មាលានីឮហើយក៏ប្រញិបប្រញាប់រៀបឥវ៉ាន់ ឡើងជិះម៉ូតូពី ក្រោយតារាអោយគេឌុបចេញទៅ ។ ថៃដន្យ មាលានីសង្កេតឃើញ ថា តារាមិនបានឌុបនាងទៅផ្ទះរបស់គេទេ បែរជាបត់ទៅផ្លូវផ្សេង ទៅវិញ ។

- នាំខ្ញុំទៅណាហ្នឹង លោកតារា ?
- បន្តិចទៀត មាលានីនឹងដឹងហើយ!

នារីយើងក៏នៅស្ងៀមទៅវិញ ។ លុះជិះម៉ូតូកាន់តែឆ្ងាយទៅៗ មាលានីនឹកពិភាល់យ៉ាងណាមិនដឹង ក៏សួរម្តងទៀត ៖

- លោក! នាំខ្ញុំទៅខាងណាដែរ លោកតារា ?

តារាញញឹមហើយងាកបែរមកឆ្លើយថា ៖

- កុំភ័យអី! ខ្ញុំមិននាំមាលានីទៅចូលរូងក្តាមទេណា៎!

មកដល់អាហារដ្ឋានផែប្រក់ស្បូវមួយ នាមាត់ទន្លេ...

CHANBOKEO.COM

មាលានីជ្រួញចិញ្ចើម ៖

- ហេតុអ្វីក៏ភ្ញៀវទាំងនេះ គេមកនៅចាំខ្ញុំនៅក្នុងអាហារដ្ឋានទៅ វិញ អញ្ចឹង ?

តារាចតម៉ូតូ ហើយលូកស្រវាជួយយួរធុងប្រអប់របស់មាលានី ហើយស្រដីថា ៖

- ម៉ោះ! ខ្ញុំជួយកាន់!

- មិនសមរម្យទេនឹងលោកតារា ព្រោះលោកជាភ្ញៀវរបស់ខ្ញុំណា៎!

- តារាមិនបានគិតថាសមមិនសមទេ ព្រោះតារាកំពុងសប្បាយចិត្ត

- សប្បាយចិត្តរឿងអ្វីទៅ ?

តារាមិនឆ្លើយទេ បែរជានិយាយបន្លប់ទៅវិញថា ៖

- ចូលទៅក្នុងសិនទៅ មាលានី ។

ភ្លាមនោះ អ្នកបំរើបានក្រាលតុយ៉ាងស្អាតមួយទទួលអ្នកទាំង ពីរនៅក្នុងរោងផៃមួយ ដាច់ឆ្ងាយពីគេឯងបន្តិច ។

- ហេតុអ្វីក៏គ្មានភ្ញៀវម្នាក់សោះអញ្ចឹង លោក ?

មាលានីសួរ ។

- ប្រហែលជាគេមិនទាន់មកដល់ទេនឹង! (តារាឆ្លើយឆ្វេហី)

មាលានីជ្រួញចិញ្ចើម នឹកពិភាល់ក្នុងចិត្តយ៉ាងណាមិនដឹង ។ ឃើញដូច្នោះ តារាក៏ពោលកម្លាចិត្តនារីឡើង ៖

- កុំភ័យអី មាលានី! យើងជាមិត្តស្គាល់គ្នាយូរហើយ មិនទុកចិត្ត ខ្ញុំទេឬ ?

- គឺ ខ្ញុំគ្រាន់តែឆ្ងល់ ថាលោកកំពុងលលេងនឹងខ្ញុំរឿងអ្វី ?

- ពុទ្ធោ! នរណាគេលលេងនឹងមាលានីនោះ ? ការពិត តារាកំពុង នឹកមាលានីសឹងស្លាប់ ។ បើទៅបបួលដើរលេងស្រួលៗ ម៉េចនឹង មាលានីព្រមចេញមកជាមួយខ្ញុំទៅ ?

- មានន័យថា យ៉ាងម៉េចហ្នឹង លោកតារា ?

- មើល៍! ឈប់ហៅខ្ញុំថា លោកតារាទៀតទៅ! ស្តាប់ទៅដូចជា មិនស្និទ្ធស្នាលគ្នាសោះ ។

មាលានីឈ្ងោកមុខនៅឈរស្ងៀម ។ តារាក៏ទាញដៃអោយនាង អង្គុយចុះទៅក្នុងកៅអីផ្តៅដ៏ប្រណិតមួយក្បែរនោះ ។ ពេលនោះ មាលានីមានអារម្មណ៍ចម្លែកយ៉ាងម៉េចមិនដឹង រកថាមិនត្រូវ ។ លុះ ឃើញកិរិយាទើសទាល់របស់នារី តារាក៏ញញឹមឡើង ស្រដីថា ៖

- ធ្វើមុខជ្រួញៗអញ្ចឹង សង្ស័យតែចូលចិត្តញុំាក្រសាំងទាំងសំបក ហើយមើលទៅ!

CHANBOKEO.COM

- ស្លាប់ហើយ! នរណាគេញ៉ាំក្រសាំងទាំងសំបកនោះ ?
- គឺសម្លម្ជូរគ្រឿងចាស់បុរាណនោះអី គេដាក់ទាំងសំបកអោយសម្ល មានក្លិនឈ្ងុយនោះអី! នីដែលភ្លក្សទេ ?

មាលានីគ្រវីក្បាល ។ តារាក៏ស្រដីថា ៖

- តែថ្ងៃនេះ យើងមានគ្នាតែពីរនាក់ទេណា៎! ដូច្នេះតារាសូមប៉ាវ អាហារប្លែកម្តង មិនអោយមានសម្លម្ជូរក្រសាំង ជូរតាំងពីសម្លរហូត ដល់អ្នកបរិភោគសម្លទៀតទេ ។

មាលានីងើបមុខឡើងសម្លឹងតារាដោយក្រសែភ្នែកភ្លឺថ្លា ៖

- គ្រាន់តែហៅមាលានីមកប៉ាវបាយ ម៉េចចាំមានល្បិចភូតផងហ្ន៎ ?

តារាសើចខឹកៗឡើង ៖

- បើមិនភូត ធ្វើម៉េចគេនឹងព្រមមកតាមតារាយ៉ាងប្រញិបប្រញាប់ បែបនេះ ? នឹងទេថា តារានឹកមាលានីប៉ុនណាដែរ ? យើងមិន ដែលបានជួបគ្នាយូរខែហើយណា៎ គឺតាំងពីមាលានីឈប់ធ្វើការនៅ ហាងជាមួយសារេននម៉្លេះ! តើនីមានដែលនឹកតារាដែរទេហ៎ ?

ឃើញក្រសែភ្នែកដ៏មានទឹកដមមន្តស្នេហ៍របស់តារា មាលានីក៏ ងាកចេញភ្លាម ត្បិតខ្លាចចាញ់ព្រួញស្នេហ៍របស់គេ ។ ដោយមិន ឃើញមាលានីឆ្លើយតបមកនាយវិញ តារាក៏អូសកៅអីទៅអង្គុយជិត នាងហើយស្រវាចាប់ដៃនារីកាន់ឡើង ៖

- ទោះបីជាយ៉ាងណា ក៏តារាចង់អោយមាលានីដឹងថា តារាលួចគេង នឹករាល់ថ្ងៃ មិនដែលខានវេលាណាទេ ។

មាលានីព្រឺព្រួចក្នុងចិត្តយ៉ាងចម្លែក ដែលបានទទួលចំណាប់ អារម្មណ៍យ៉ាងពិសេសពីតារា ។ ថៃដន្យ នាងមិនទាន់ជាសះស្បើយ ដំបៅបេះដូង ដែលនាយបែនបានក្បត់ចិត្តទៅរៀបការនោះនៅ ឡើយទេ ។ នាងមិនទាន់គិតថា តើគួរសម្លឹងបុរសជាគូជីវិតរបស់ នាងនៅឡើយ ថ្វីបើតារាជាបុរសសង្ហាគួរចាប់ចិត្តបេតីក៏ដោយ ។

ភ្លាមនោះ តារាក៏ស្រដីបន្តទៅនារីយើងថា ៖

- បើខ្ញុំសុំមាលានីធ្វើសង្សារ ដើម្បីសម្លឹងចិត្តគ្នាទៅវិញទៅមក មុន នឹងយើងរៀបការ តើមាលានីគិតយ៉ាងណាដែរ ?

នីតាយើងភ្ញាក់ព្រើតដែលបុរសសួរចិត្តនាងត្រង់ៗ យ៉ាងចំហ ដូច្នោះ ។ នាងគិតមួយស្របក់ ក៏ឆ្លើយថា ៖

CHANBOKEO.COM

- ដូចជារហ័សពេកនឹង លោកតារា ? សុំធ្វើត្រឹមជាមិត្តបានទេ ?
ខ្ញុំមិនទាន់ត្រៀមខ្លួនទទួលបុរសណាជាសង្សារទេ ព្រោះខ្ញុំមានអ្វីៗ
ក្នុងជីវិតច្រើនណាស់ដែលត្រូវដោះស្រាយសិន ។
- មិនឆាប់ពេកទេ មាលានី! នេះ យើងស្គាល់គ្នាជិតមួយឆ្នាំហើយ តើហ៍! នីមិនចាំទេ ?
- អត់ទេ (មាលានីគ្រវីក្បាល) យើងស្គាល់គ្នារបៀបជាភ្ញៀវនិង អ្នកធ្វើការ
មិនបានស្គាល់ជិតដិតផ្លូវចិត្តឯណា ?
- បើអញ្ចឹង យើងចាប់ផ្តើមពីពេលនេះទៅណា៎! បងគិតថា បង ពេញចិត្តមាលានីណាស់
ហើយមានបំណងសាងអនាគតជាមួយគ្នា ផង នឹងទេ ?

មាលានីរឹតតែភ្ញាក់ផ្អើលជាងមុនទៅទៀត ដែលតារាចេះតែនាំ
មុខព្រួញនៃការសន្ទនាកាន់តែជ្រាលជ្រៅទៅក្នុងជីវិត ។

- ប៉ុន្តែ... ខ្ញុំទើបតែមានវ័យមិនទាន់គ្រប់២០ឆ្នាំស្រួលបួលទេ ។ ខ្ញុំ
មិនទាន់ចង់គិតពីអនាគតឡើយ ។
- នៅចាស់យូរពេក មិនល្អទេណា៎ នី!
- ម៉េចថា មិនល្អទៅវិញ ? មាលានីចង់ត្រឡប់ទៅរៀនវិញ... ព្រោះខ្ញុំធ្លាប់ស្រម័យចង់ធ្វើពេទ្យ
ចង់ធ្វើការការិយាល័យ...
- រៀបការហើយ ក៏នីអាចត្រឡប់ទៅរៀនបានដែរតើហ៍ !
- អត់ទេ! សព្វថ្ងៃនៅលីវផង នៅរកពេល រកលុយទៅរៀន មិនបានផង
ចុះទំរាំមានគ្រួសារមានកូនចៅ តើនឹងអាចឆ្លៀតពេល ឯណា ដើម្បីអោយបានទៅរៀនទៅ ?
- ទោះជាយ៉ាងណា តារានៅតែប្រាថ្នាអោយមាលានីសម្លឹងបងខ្លះៗ បានទេ នី ?

មាលានីសម្លឹងមុខនរៈដោយក្រសែភ្នែកភ្លឺថ្លា ៖

- ខ្ញុំមិនទាន់អាចឆ្លើយបានទេ ស្រេចនៅលើគុណសម្បត្តិនិង
ការប្រព្រឹត្តរបស់លោកអោយនីជឿជាក់ច្បាស់ក្នុងចិត្តថា ខ្ញុំអាចទុក ចិត្តលោកបានសិន ។
ពេលនេះ យើងរាប់គ្នាជាមិត្តធម្មតាៗសិនទៅ បានទេ ?
- អញ្ចឹង សុំលើសពីមិត្តបន្តិចណា៎! តារាសុំការចាប់អារម្មណ៍ពី មាលានីពិសេសបន្តិច
លើសមិត្តរបស់នីទូទៅ នីធ្វើបានទេ ?

មាណពទទូច ។ មាលានីអត់មិនបានក៏សើចខឹកៗ ហើយឆ្លើយ តបវិញថា ៖

CHANBOKEO.COM

- អញ្ជឹង ប្រាប់នីផង ថា តើការផ្តល់ចំណាប់អារម្មណ៍យ៉ាងពិសេស លើសពីមិត្តទូទៅនោះ មានអ្វីខ្លះដែរ ?

- គឺមានដូចជា...

តារាក៏ស្រវ៉ាម្រាមដៃនារីយកថើប ។ មាលានីភ្ញាក់ព្រើតដកដៃ វិញយ៉ាងរហ័ស ។

- ពុទ្ធោ! យ៉ាប់មែន! (មាលានីលាន់មាត់)

តារាញញឹមយ៉ាងស្រស់កាលបើបានថើបដៃមាលានី ។ រំពេច នោះ អ្នកបំរើក៏យកអាហារមកដល់ ។ អ្នកទាំងពីរក៏នាំគ្នាបរិភោគ ទាំងដួងចិត្តរំភើបរីករាយ ។ យូរៗម្តង គេចោលភ្នែកលួចមើលគ្នា ទៅវិញទៅមក ហើយញញឹមលាក់គំនួចក្នុងចិត្តរៀងៗខ្លួន ។

ថ្ងៃនោះ តារាបានឌុបម៉ូតូនាំមាលានីដើរលេង ពេញមួយថ្ងៃតែ ម្តង ។ គេនិយាយសាសងគ្នា រាងទូលាយជាងមុន មិនសូវជាខ្លាច ក្រែងរអែងចិត្តគ្នាប៉ុន្មានទេ ។

ចាប់តាំងពីថ្ងៃនោះមក តារាតែងតែមកទទួលមាលានីទៅដើរ កំសាន្តជារឿយៗ ជាពិសេសនៅថ្ងៃអាទិត្យតែម្តង ។ ថ្វីបើគេមាន កិរិយាទន់ភ្លន់ហើយថ្នាក់ថ្នមមាលានីណាស់ ប៉ុន្តែ អ្វីដែលធ្វើអោយ មាលានីនារីមិនទាន់ទុកចិត្តតារានោះគឺ... គេមិនដែលណែនាំក្រុម គ្រួសាររបស់គេអោយនាងស្គាល់ទេ មិនដឹងថាមកពីហេតុអ្វី ។ ទោះបីជាយ៉ាងណា មាលានីនៅតែរីករាយទទួលមិត្តភាពរបស់តារា ជានិច្ច ហោចណាស់ នាងក៏បានចេញដើរទៅឃើញពិភពក្រៅផ្ទះ ខ្លះៗ ស្គាល់ជីវិតរស់នៅប្លែកៗ និងភូមិសាស្ត្រភ្នំពេញកាន់តែ ច្បាស់ជាងមុនដែរ គឺនាង មិនរស់ក្នុងស្នូកក្តាមស្គាល់តែរោងចក្រ និងផ្ទះជួលនោះតែប៉ុណ្ណោះ ឡើយ ។

ប្រហែល៦ខែក្រោយមក...

នៅរោងចក្រដែលមាលានីធ្វើការ បានប្រារព្ធពិធីបុណ្យចូលឆ្នាំ ខ្មែរ ដោយអោយកម្មករសំរាកកន្លះថ្ងៃ ដើម្បីជួបជុំគ្នាជប់លៀង នំចំណីនិងទឹកភេសជ្ជៈបន្តិចបន្តួច ដល់កម្មករទាំងឡាយ ថែមទាំង មាន លេងល្បែងប្រពៃណី និងការសម្តែងអាយ៉ៃអត់ភ្លេងអម ប្រកួតគ្នារវាងកម្មករនិងកម្មករទៀតផង ។

មាលានីឈរទះដៃសើចក្អាកក្អាយជាមួយមិត្តរបស់នាងក្នុងរោង ចក្រ ត្បិតមានកម្មករម្នាក់ឡើងនិយាយរឿងកំប្លែងស្នូត ។ ភ្លាម នោះ

CHANBOKEO.COM

ស្រាប់តែឮសម្លេងលាន់ប្រាវឡើង ។ ទាំងអស់គ្នាបែរភ្នែក
ទៅឃើញកម្មករក្មេងម្នាក់អាយុប្រហែល២២ឆ្នាំ លីដុំទឹកកកជំពប់ ជើង ដួលទៅដីប្រួស
ធ្លាក់ទឹកកកបែកខ្ចាត់ខ្ចាយពាសពេញដី ។

- យី! នាយឯងនោះ ធ្វើការធ្វេសប្រហែសម្ល៉េះវុី! បែកទឹកកក អស់
បានអីកាប់ចែកកម្មករផឹក ? ឆាប់ទៅប្រមូលកំទេចទឹកកកនោះ មកលាងទឹក ដាក់ធុងវិញ
ឮហើយនៅ ?

នាយកោយម្នាក់ឡូឡាស្ដីអោយកម្មករក្មេងនោះខ្លាំងៗដដែលៗ ពីរបីសា
ទំនងស្ដាយដុំទឹកកកដែលធ្លាក់បែកនោះណាស់ ។ រីឯ
កម្មករម្នាក់នោះក៏មានកិរិយាហាក់ដូចជាខ្លាចគេ ខ្លាំងណាស់ដែរ ។
នរៈស្ទុះធ្វើតាមពាក្យដែលមេកម្មករបញ្ជា ដោយឥតមានស្ដីតបអ្វី មួយម៉ាត់ឡើយ ។
មាលានីឈរកៀននោះយូរហើយ កាលបើឮ សំដីច្រំដែលរបស់នាយកោយនោះទ្រាន់ត្រចៀកពេក
នាងក៏ឆ្លើយ អត់ឈ្មោះ ជំនួសនាយម្នាក់នោះថា ៖

- គេមានចិត្តមកជួយលីទឹកកក ទុកអោយយើងគ្រប់គ្នាផឹកស្រណុក ស្រួលខ្លួនហើយ
នៅពើមានមុខមកជេរស្ដីអោយទៀត ? ការពិត
គេមិនចាំបាច់មកជួយលីទឹកកកមួយដុំនេះក៏បានដែរ... មានចិត្ត
ធ្វើការហត់ហើយមានគេជេរយ៉ាងនេះ លើកក្រោយគ្មាននរណាមាន
ចិត្តមកជួយធ្វើការរហេមរហាម អត់លុយប៉ូវដូច្នេះឡើយ ។ គេសុខ
ចិត្តយកពេលទៅឈរមើលអ្នកស្រុកច្រៀងអាយ៉ៃវិញ សប្បាយជាង ផង
មិនបាច់ខ្វល់អោយនរណាគេជេរ ។

ស្រាប់តែនាយកោយម្នាក់នោះ បែរមកគំហក ៖

- នែ៎! ចង់ថាអោយនរណាគេដែរ នាងនី ?

មាលានីញាក់ចិញ្ចើម ៖

- គឺថាអោយខ្លួនខ្ញុំនេះអី! វាខ្ជិលអើយសែនខ្ជិល អត់មានចិត្ត មានថ្លើមអីបន្តិចសោះ
ពេលមានរវល់ម្ដងៗ ចង់តែយកពេលទៅ ឈរមើលគេលេងអាយ៉ៃ
តែមិនដែលមានចិត្តទៅជួយលីទឹកកកចែក ញាតិណាផឹកទេ ព្រោះខ្ញុំនេះមានទម្លាប់រមិលគុណណាស់
មិនមាន មារយាទចេះអរគុណអ្នកដែលមានសន្ដានចិត្តចំពោះខ្លួនអីបន្តិចទេ!

- ជើ! មាត់បានណាស់ នាងល្អ!

CHANBOKEO.COM

មេកោយកម្មករនោះគំហកតែប៉ុននេះក៏បាត់មាត់ទៅ ព្រោះដឹងថាមាលានីកំពុងនិយាយដៀមដាមអោយខ្លួន ។ កម្មករដទៃដែល នៅម្តុំៗនោះក៏លួចសើចញឹមៗដាក់គ្នា ដែលឃើញមាលានីហ៊ាន ចាក់ផាមេកោយ ការពារកម្មករដូចគ្នា ។

រីឯបុរសកម្មករក្មេងមួយរូបនោះវិញ កំពុងលូកដៃស្រវាកើប កំទេចទឹកកកបណ្តើរលួចមើលមាលានីភ្លៀកៗបណ្តើរ ។ លុះនាង បែរដាក់ភ្នែកចំរូបគេ មាណពក៏ដាក់មុខចុះវិញ មិនហ៊ានសម្លឹងតប ទៅនាងវិញទេ ទំនងខ្លាចចិត្តនារីយើង ។ លុះឃើញកិរិយារបស់មាណពនោះទំនងឆ្អើលៗ មាលានីក៏កេះមិត្តរបស់នាងម្នាក់សួរថា ៖

- បងខុម! ស្គាល់កម្មករលីទឹកកកម្នាក់នោះដែរទេ? មើលទៅគេ ដូចជាកម្មករចំណូលថ្មី ។
- បងមិនស្គាល់ទេ (សុខុមឆ្លើយ) ទើបតែឃើញមុខគេ ប្រហែល ពីរបីថ្ងៃនេះឯង ។
- មើលទៅឫកពារបស់គេ ហាក់ដូចជាខ្លាចនាយកោយដល់ហើយ!
- ឮថា បងសំរោងជាអ្នកនាំចូលមកធ្វើការទីនេះ ដូចកាលគាត់នាំ នីឯងចូលមកដែរអញ្ចឹង ។ ការពិត គេមានបញ្ហាជីវិត ទទួលជួប បងសំរោងដែលជាមិត្តចាស់តាំងពីនៅរៀន គេក៏ចង់ផ្លាស់ប្តូរផ្លូវ ជីវិត បែរមករកផ្លូវសុក្រិតវិញ ។
- មានន័យថាម៉េចទៅ បងខុម?
- ឮថាពីមុនមក គេធ្លាប់ញៀនអាភៀន ហើយធ្លាប់មានទោសជា ទណ្ឌិតទៀតផង ។ ប៉ុន្តែដល់បានជួបបងសំរោងនិងប្រពន្ធគាត់ មក
គេក៏កែប្រែចិត្តគំនិតឈប់វិលត្រឡប់ទៅជីវិតពាលវង្វេងនោះ ទៀត ។ បងក៏ធ្លាប់ឮដែរថា ឪពុកម្តាយគេធ្លាប់ខឹងកាត់កាល់ មិន អោយគេចូលផ្ទះវិញផង ។
- ពុទ្ធោ! ដល់ប៉ុនហ្នឹងផង? អញ្ចឹងមានន័យថា គេបានប្រព្រឹត្តអ្វី ទុច្ចរិតធ្ងន់ធ្ងរហើយ ។
- បងមិនដឹងច្បាស់ទេ ប៉ុន្តែធ្លាប់ឮថា ធ្លាប់បានចូលហ្វូងក្មេងស្ទាវ មួយស្របក់ដែរ ក្រោយមកមិនដឹងហេតុអ្វីទេ គេត្រូវប៉ូលីសចាប់ឃុំ ប៉ុន្មានអាទិត្យ ទើបតែចេញមកវិញថ្មីៗនេះ ។
- អីយ៉ា! បងខុមដូចជាដឹងរឿងបុរសក្មេងម្នាក់នេះច្រើនណាស់ តើហ៎! សង្ស័យតែចាប់អារម្មណ៍លើភាពសង្ហារបស់គេទេដឹង បាន ជាតាមដានស៊ើបដឹងប្រវត្តិខ្មៅខ្មីរអស់យ៉ាងនេះ?
- យីអើ! ម៉េចមកចំអន់គ្នាអញ្ចឹងមើស៍! អូហ៍...នែ៎! នែ៎! ពេល នេះ បងដឹងហើយថា ឯងកំពុងចាប់អារម្មណ៍ពីរូបគេដែរមែនទេ បានជាប្រចណ្ឌ័ដាក់បងអញ្ចឹង? មើលហ្ន៎! មិនទាន់ស្ទើផង ចេញ មុខការពារគេយ៉ាងខែងរ៉ែងទៅហើយ...

CHANBOKEO.COM

សុខុមចំអន់ផង សើចកក្អឹកផង ធ្វើអោយមាលានីអៀនឡើង
ក្រហមថ្ពាល់តែម្តង ។

- និយាយតែផ្តាស បងខុមឯងនេះ!
- ឃើញទេ! មុខក្រហមហើយ! បងថា មែន! មែន!

មាលានីអត់មិនបានក៏លូកដៃក្តិចមិត្តនី ធ្វើអោយសុខុមរិតតែ
បានចិត្តរិតតែលលេងនាងថែមទៀត ។ ចំណែកកម្មករក្មេងនោះ
ក៏លួចសម្លឹងមាលានីនិងសុខុមភ្លៀកៗវិញមិនដាក់ភ្នែកដែរ ទំនង ហាក់ដូចជាចង់ដឹងថា
តើនារីទាំងពីររូបនោះខ្សិបគ្នារឿងអ្វីបានជា
ចោលកន្ទុយភ្នែកដាក់នាយហើយលួចសើចកខឹកតែពីរនាក់អត់ឈប់ យ៉ាងហ្នឹង ។

នៅរសៀលនោះ កម្មករទាំងឡាយនាំគ្នាលេងល្បែងកំសាន្ត យ៉ាងសប្បាយ ។ ខ្លះច្រៀង
ខ្លះទះដៃ ខ្លះអង្គុយមើល ឈរមើល ខ្លះស្រែកហ៊ោរខ្ញៀវខ្ញាអឺងកង ។
មាលានីអង្គុយកៀនជញ្ជាំងពីរ នាក់សុខុមជាមិត្តនីរួមការងារ កំពុងហែកក្រូចចែកគ្នា ស្រាប់តែ
មាលានីនិយាយថា ៖

- ខ្ញុំស្រេកទឹកណាស់ គិតទៅរកទឹកត្រជាក់មួយកែវសិន!
- ញ៉ាំទឹកកកសាបទេ បាទ?

មាលានីនិងសុខុមភ្ញាក់ព្រើត ងើយមុខបែរមើល ឃើញបុរស
ម្នាក់នោះលើកទឹកកកសាបពីរកែវហុចអោយគេទាំងពីរ ។ មាលានី បែរសម្លឹងមុខសុខុម
ធ្វើកិរិយាអេះអុញ ។ សុខុមឃើញដូច្នោះ ក៏លូកដៃទទួលទាំងពីរកែវ ហើយឆ្លើយថា ៖

- ពុទ្ធោអើយ! អីក៏យល់ចិត្តគ្នាម្ល៉េះហ្ន៎! ម្នាក់រអ៊ូថាស្រេកទឹក មិន ទាន់អីផង មានម្នាក់ទៀត
គេចាក់ទឹកមកហុចដល់ដៃទាន់ចិត្តភ្លាម តែម្តង ។

មាលានីព្ទសុខុមចំអន់ ក៏ចោលកន្ទុយភ្នែក លួចសម្លក់មិត្ត រួច
ហើយអង្គុយស្ងៀម ញញឹមស្មើធ្វើហាក់ដូចជាគ្មានអារម្មណ៍អ្វីអញ្ចឹង ប៉ុន្តែ នៅក្នុងពោះវិញនោះ
នាងហាក់ដូចជានឹកខ្មាស់ក្រសែភ្នែក បុរសម្នាក់នោះយ៉ាងណាមិនដឹងទេ
ព្រោះគេតាមសម្លឹងរូបនាងមិន
ព្រមដាក់ភ្នែកសោះ ។

- អរគុណណាស់ មហាមិត្ត...! ឈ្មោះអីដែរហ្នឹង សុំស្គាល់ផងបាន ទេ បុរសសង្ហា?

CHANBOKEO.COM

សុខុមស្រដីសួរទៅបុរសកម្មករមួយរូបនោះ ។ ស្រាប់តែគេ
ញញឹមឡើងយ៉ាងបំព្រងហើយវាចាតបវិញថា ៖

- ឈ្មោះកិត្យា បាទ!
- កិត្យា! យី! ពិរោះណាស់! ឈ្មោះល្អហើយសង្ហាដូចតួកុនទៀត ឃើញហើយ
ចង់តែសុំស្នេហាទេនេះ! អូហ៍ និយាយអញ្ចឹង មាន គូស្រករហើយឬនៅ កិត្យាឯងហ្នឹង ?

ឮដូច្នោះ កិត្យាញញឹមក្រប្លួចមាត់ បែរមុខចេញធ្វើអៀនៗ មិន ហ៊ានឆ្លើយទៅសុខុមវិញទេ ។
មើលទៅ សុខុមកំពុងស៊ើបប្រវត្តិ អោយមាលានីហើយ
ព្រោះនាងចាប់កន្ទុយភ្នែកមាលានីដែលបាន លួចសម្លឹងទៅកម្មករក្មេងមួយរូបជាច្រើនដង
ថ្វីបើមាលានីមិនបាន ស្រដីចេញមួយម៉ាត់ថា នាងកំពុងតែចាប់អារម្មណ៍អំពីបុរសនោះក៏ ដោយ ។
សុខុមក៏និយាយបន្តថា ៖

- ណេ៎ះ! ខ្ញុំសុំណែនាំខ្លួនបន្តិចណា៎! ខ្ញុំនេះឈ្មោះសុខុម ធ្វើការ នៅរោងចក្រនេះ បីឆ្នាំហើយ ។
ចំណែកមិត្តដ៏ស្រស់ស្អាតសោភា របស់ខ្ញុំម្នាក់នេះ ឈ្មោះមាលានី
ទើបតែចូលធ្វើការថ្មីៗប្រហែលជិត មួយឆ្នាំនេះទេ ។ ហើយបើសិនកិត្យាឯងនៅលីវទេ
គួរសុំទាក់ទង មាលានីជាសង្សារទៅ ព្រោះរូបសម្បត្តិរបស់អ្នកទាំងប្រដំប្រសងគ្នា មែនទែន ។
មើលទៅ  សមគ្នាតតខ្វះតែម្តង ។ ចំណែកខ្ញុំវិញ..
ចាំសំបុកក្រោយទៅណា៎ ឮហើយឬនៅ កិត្យា ?

មាលានីនឹកខ្មាញ់នឹងការចំអន់របស់មិត្តរហូតក្រហាមមុខក្រហាម ស្លឹកត្រចៀកអស់
ព្រោះនឹកខ្មាស់បុរសសង្ហានោះណាស់ ។ មិនដឹង ជាហេតុអ្វីទេ តាំងពីប្រទះឃើញគេភ្លាម
មាលានីហាក់ដូចជាមាន អារម្មណ៍ប្លែកយ៉ាងណាមិនដឹង ចេះតែអៀនៗខ្លួន ពេលគេសម្លឹង
មកចំកែវភ្នែករបស់នាងម្តងៗ ។ កាលពីដើម នាងធ្លាប់ស្គាល់នាយ បែន ប៉ុន្តែ
នាងមិនដែលនឹករំភើបញាប់ញ័រក្នុងចិត្ត ម្តងណាទេ ។ ចំណែកឯតារាវិញ
នាងបានស្គាល់ហើយរាប់អានគ្នាទៅវិញទៅមក តែនាងក៏មិនដែលមានអារម្មណ៍រំភើបអៀនខ្មាស់អ្វី
ដូចពេលនេះ ដែរ ។ លើកនេះ ភាពរួសរាយរបស់នាងបែរជាផ្លាស់ប្តូរអស់រលីង
រហូតរកនឹកពាក្យនិយាយលេងមិនឃើញមួយម៉ាត់ ទុកអោយសុខុម ចាប់ទីវាយផ្ចួលនាង
ដោយពាក្យចំអន់លេងយ៉ាងជោគជ័យ ។

នៅក្បែរនោះ កិត្យាឈរអៀនធ្វើអេះអុញៗ ដាក់មាលានីដូចគ្នា
ហើយក៏មិនឃើញគេដើរគេចទៅណាដែរ ឃើញតែនៅឈរក្បែរៗ មាលានីនិងសុខុម

CHANBOKEO.COM

ធ្វើកិរិយាស្ងៀមៗរហូតដល់ពេលបញ្ចប់កម្មវិធី ជប់លៀងកម្មករ
ទំនងប្រហែលជានរៈមិនមានស្គាល់នរណានៅក្នុង រោងចក្រនោះហើយ ។

ព្រលប់ចប់ពិធី មាលានីក៏លាសុខុមដើរត្រឡប់មកផ្ទះវិញតែ ម្នាក់ឯង ។ ស្រាប់តែ..

- នី!

មាលានីងាកក្រោយ ឃើញកិត្យាដើរយួរធុងបាយតូចមួយចេញ ពីមាត់ទ្វាររោងចក្រ ។
នារីញញឹមតបទៅនាយវិញ ។ ឃើញដូច្នោះ
កិត្យាក៏ស្រដីបន្តថា ៖

- នៅផ្ទះជិតនេះទេហ៎ ទើបមិនជិះរ៉ឺម៉ក ឫម៉ូតូឌុប ?
- ចា៎ស ប្រហែល៥០០ម៉ែត្រប៉ុណ្ណោះ មិនឆ្ងាយទេ ។
- អញ្ចឹង ខ្ញុំសុំដើរជាមួយផងណា៎ ដើម្បីអោយបានជាគ្នា ។
- ចា៎ស! ហើយចុះផ្ទះរបស់បងប្រុសនៅខាងណាដែរ ?
- មិនឆ្ងាយពីនេះប៉ុន្មានទេ ប្រហែលជិតមួយគីឡូ ដើរទៅដើរមក ហាត់ប្រាណល្មមស្រួលខ្លួន ។
- អញ្ចឹងក៏ល្អដែរ យើងដើរទៅជាមួយគ្នា បានគ្នាដើរកំដរ មាន សុវត្ថិភាពផង ។

កិត្យាញញឹមឡើង បន្តិចមកក៏សួរនាងថា ៖

- ចុះបើព្រឹកៗឡើង ខ្ញុំទៅទទួលនីពីផ្ទះហើយដើរជាមួយគ្នាទៅធ្វើ ការ នីយល់យ៉ាងណាដែរ ?
- អឺ... ដូចជាអំពល់បងប្រុសទេដឹង ?
- មិនអំពល់ទេ រឿងតិចតួចប៉ុនហ្នឹង (កិត្យាគ្រវីក្បាល)
- អញ្ចឹង ស្អែកខ្ញុំចាំនៅមាត់ផ្លូវណា៎ ។

កិត្យាងក់ក្បាល ហើយលើកដៃបក់បោយលាទៅ ។ មាលានីបែរ ញញឹមដាក់មាណពយើងបន្តិច
ហើយក៏ដើរបត់ចូលទៅផ្ទះជួល របស់នាង ។

ចាប់តាំងពីថ្ងៃនោះមក កិត្យាតែងតែក្រោកពីព្រឹកមកឈរចាំ មាលានីនៅមាត់ផ្លូវ
ដើម្បីដើរទៅធ្វើការនៅរោងចក្រជាមួយគ្នា ។

0000000000000000

00000

0

CHANBOKEO.COM

# វគ្គទី៩
# រលកវិលច្រាំង

CHANBOKEO.COM

ក្រុងភ្នំពេញ

ឆ្នាំ២០០៧...

ពេលកិត្យាកញ្ឆក់វ៉ាលីសយួរចេញពីផ្ទះមាលានីមក...

នរ:ជិះម៉ូតូបណ្ដើរ ទូរសព្ទ័ទៅសំរោងបណ្ដើរ តែប្រពន្ធសំរោង ប្រាប់ថា គេទៅធ្វើការឯរោងចក្របាត់ទៅហើយ ទាល់តែព្រលប់ ទើបត្រឡប់មកវិញ ។ កិត្យាមិនបានរំខាន ក៏បរម៉ូតូទៅដល់ផ្ទះ ឪពុកម្ដាយរបស់ខ្លួននៅម្ដុំពេទ្យលោកសង្ឃ ។ លុះទៅដល់មាត់ទ្វារ ផ្ទះ គេបែរជាមិនហ៊ានចូលទៅជួបគាត់ ខ្លាចលោកដេញដោលសួរ នាំក្បាលកន្ទុយចុះឡើង ខ្លាចរកពាក្យឆ្លើយតបមិនរួច ។ គិតចុះ គិតឡើង គេក៏ឡើងម៉ូតូទៅរកមីងលក់ចាប ទិញចាបពីរបីព្រលែង ចោលអោយអស់អារម្មណ៍តប់ប្រមល់ ។ ប៉ុន្ដែ លុះព្រលែងចាបរួច ហើយ ចិត្តរបស់គេនៅតែធុញថប់មួម៉ៅដដែល មិនឃើញធូរស្រាកស្រាន្តអ្វីសោះ ។ រូបភាពរបស់មាលានីនៅតែអណ្ដែតលេចឆ្លោក្នុង អារម្មណ៍របស់គេ មិនស្រាកស្រាន្ត... ទោះបីគេឆ្មេចចង់បំភ្លេចយ៉ាង ណាក៏មិនមានប្រសិទ្ធិភាពឡើយ ។

មីងព្រេមលក់ចាប ហាក់ដូចជាចាប់ភ្លឹកអំពីកិរិយារបស់កិត្យា ដែរ ប៉ុន្ដែមីងអាល័យមានភ្ញៀវមករកទិញចាបច្រើន ម្ល៉ោះហើយ មិនបានសន្ទនាអ្វីជាមួយកិត្យាទេ ។ មួយស្របក់ក្រោយមក គេក៏ ហាក់ឡើងម៉ូតូជិះត្រឡប់ចេញទៅវិញបាត់ទៅ ។

កិត្យាជិះម៉ូតូវិលវល់ចុះឡើងពេញភ្នំពេញ រហូតដល់អស់សាំង ម៉ូតូ នៅតែមិនដឹងថា ចង់ទៅណាសោះឡើយ ។ គេនឹកឃើញទៅ ដល់មិត្តភឿនរបស់គេពីអតីតកាល

នឹកភ្នកចង់ទៅរកមិត្តទាំងនោះ តិចៗដែរ ប៉ុន្តែ លុះគិតពីរបីសាទៅ គេក៏ដូរចិត្ត មិនព្រមទៅរកពួកគេទាំងនោះ ព្រោះមិនចង់អោយមិត្តសួរនាំរឿងរបស់នាយ
ចុះចេញពីប្រពន្ធដែលខ្លួនទើបរៀបការបានពីរយប់ ។ ទីបំផុត គេ ចាក់សាំងម៉ូតូ
ហើយក៏បរទៅសំកុកនៅមាត់ផែ មើលមនុស្សម្នា
ធ្វើដំណើរឡើងចុះសាឡាងយ៉ាងអ៊ូអរកុះកររហូតទល់ព្រលប់ ។

ពេលនោះ សតិមួយបានមកដាស់គេថា ៖

- ហេតុអ្វីកិត្យាចុះចាញ់ជីវិតគួយ៉ាងងាយបែបហ្នឹង ? បើកិត្យាដើរ
ចេញពីជីវិតរបស់មាលានីងាយៗមកយ៉ាងនេះ មិនខុសពីបើកដៃ អោយបុរសដទៃ
ដណ្ដើមយកនាងដោយមិនបាច់ប្រឹងនោះឡើយ ។ ពេលនេះ កិត្យាបានក្លាយជាគូគាប់របស់មាលានី
ត្រឹមត្រូវតាម ប្រពៃណីទៅហើយ ហេតុអ្វីបែរជាព្រលែងអោយរបូតងាយៗបែប ហ្នឹង ?
កិត្យាមិនព្រមទេ... កិត្យាមិនគួរអោយបុរសណាមានសិទ្ធិ មានឱកាសជួបមាលានី
កាត់មុខនាយងាយៗបានទេ ។ ហេតុអ្វី មាលានីត្រូវមានឱកាសជ្រើសបុរសដទៃទៀតផង
កាលបើកិត្យាគ្មាន នរណាម្នាក់រង់ចាំខ្លួនសោះនោះ ? កិត្យាមិនព្រមចាញ់មាលានីទេ!
កិត្យាត្រូវតែឈ្នះ... ឈ្នះមាលានីដាច់ខាត!

ទីបំផុត គេនឹកប្រចណ្ឌ ខ្លាចមាលានីមានឱកាសច្រើនក្រោយ ខ្នងរបស់គេ
ក្នុងការណាត់បុរសសង្ហាឈ្មោះស៊ុនហេងនោះ ឬក៏ បុរសណាដៗទៃទៀត បើសិនគេមិននៅផ្ទះ...
ភ្លាមនោះ កិត្យាក៏ ចាប់ដៃម៉ូតូ ហក់ឡើង បរចេញត្រឡប់ក្រោយ ទៅរកមាលានីវិញ
យ៉ាងលឿនដូចព្រួញ ។

លុះមកដល់មុខផ្ទះ គេឃើញនាយចាន់ណាត ប្អូនរបស់មាលានី កំពុងឈររេរានៅទីនោះ ។

- ប្អូនណាត! ម៉េចបានជាផ្ទះបិទចាក់សោះផង ? បងប្អូនយើង ទៅណាអស់ហើយ ?

កិត្យាសួរទៅប្អូនថ្លៃ ។ កុមារជំទង់ក្រឡេកឃើញកិត្យា ក៏ឆ្លើយ ឡើងថា ៖

- គឺពួកយើងត្រូវម្ចាស់ផ្ទះនេះគេបណ្ដេញព្រឹកមិញនេះណាំបង!
ទើបពួកយើងនាំគ្នារើតវាន់ទៅនៅកន្លែងថ្មី ។ ហើយពុកប្រើអោយ ខ្ញុំមកចាំទីនេះ
ចាំបងៗដែលចេញពីធ្វើការ ដើម្បីនាំគាត់ទៅផ្ទះថ្មី វិញ ។

- ហើយ ហេតុដូចម្ដេចបានជាគេត្រូវបណ្ដេញយើងផង កាលបើ
យើងជួលផ្ទះបង់ប្រាក់ត្រឹមត្រូវទៅហើយនោះ ?

CHANBOKEO.COM

- អ្នកភ្នំពេញគឺដូច្នេះឯង បងប្រុសអើយ! ពួកអ្នកមានធ្វើអ្វីក៏សម ក៏ត្រូវតែរហូតហ្នឹង! ចំណែកពួកប៉ូលីសវិញ ក៏ស្តាប់លុយដែរ មិនស្តាប់ច្បាប់ទេ ។ អ្នកក្រតូចតាចដូចពួកយើងនេះ រស់សម្រាប់ តែធ្វើឈ្នាន់ពួកអ្នកមានតែប៉ុណ្ណោះ ។ គិតៗទៅ ពួកអ្នកមាន មាន រូបកាយស្រោបមាសប្រាក់ពិតមែន តែពួកគេមានបេះដូងមាន ចិត្តថ្លើយស្អុយដូចគម្រង់... គួរអោយខ្ពើមរអើមណាស់ ។

រំពេចនោះ ស្រាប់តែមានសម្លេងស្ត្រីម្នាក់ស្រែករាំងមកថា ៖

- ជើ! អាល្អិត! មាត់បានម្ល៉េះ ឯងនេះ ?

ខ្លួស! ចាន់ណាតត្រូវស្រីនោះខោកក្បាលមួយក្រញ៉ាំដៃ យ៉ាង ធ្ងន់ ។ កិត្យាបែរមើលឃើញស្ត្រីចិនចំណាស់ហាប្លយ កំពុងយារដៃ បំរុងនឹងទះនាយចាន់ណាតបន្ថែមទៀត ។ គេក៏ស្ទុះរឹងយកដៃទៅ ចាប់ដៃស្ត្រីនោះជាប់ហើយវាចាគំហកអោយវិញថា ៖

- និយាយតែមាត់បានហើយ ម៉េចចាំបាច់វាយធ្វើបាបក្មេងផង ?

ស្ត្រីនោះកញ្ឆក់យកដៃចេញ ហើយចង្អុលក្បាលកិត្យាចង់ផ្ងាក ថែមទាំងស្រដីឡូឡាថា ៖

- ហើយចុះឯងជាស្អីដែរ បានជាមកខែងរ៉ែងលើដីកម្មសិទ្ធិរបស់ យើង ?

- ជាស្អីមិនសំខាន់ទេ ដែលសំខាន់នោះ គឺអ៊ីកំពុងរំលោភសិទ្ធិធ្វើ បាបក្មេង!

- យើងវាយនរណាស្រេចតែយើង! វានេះជាកូនអ្នកជួលផ្ទះរបស់ យើង... ជាក្មេងអង្កាច់អង្កោចអត់ត្រកូល មាត់ធំហ៊ានស្រដីឈ្លើយ អត់ពូជអំបូរ ដៀលប្រមាថដល់យើង ទើបយើងប្រដៅវាខ្លះ ។

ស្រាប់តែ ចាន់ណាតឆ្លើយខ្លាំងៗតបវិញថា ៖

- នែ៎អ៊ីហ្វួយ! កុំជេរដៀលពូជអំបូរខ្ញុំណា៎ តិចថា ខ្ញុំមិនបានប្រាប់!

ឮដូច្នេះ អ៊ីហ្វួយនោះស្រវាចាប់ដងអំបោសដេញវាយនាយ ចាន់ណាត យ៉ាងលឿនដូចព្យុះ ៖

- នែ៎ ចេះដឹងអី! តិច! អញនឹងវាយឯងអោយងាប់!

កិត្យាឃើញហើយ ក៏ស្ទុះទៅចាប់អំបោសចេញពីដៃអ៊ីហ្វួយភ្លាម មិនអោយគាត់វាយចាន់ណាតបាន ជាហេតុធ្វើឲ្យអ៊ីហ្វួយរិតតែខឹង សម្បារខ្លាំងឡើង ហើយក៏ស្រវាទាញអំបោសពីកិត្យាឡើងអស់ ទំហឹង ។ ឃើញដូច្នោះ កិត្យាក៏ព្រលែងអំបោសអោយអ៊ីហ្វួយវិញ ស្រាប់តែអ៊ីនោះភ្លាត់ជំហរដួលគ្រាំងទៅលើគំនរសម្រាមក្បែរផ្ទះ ។

CHANBOKEO.COM

- អាងាប់អើយ ! ហ៊ានធ្វើបាបអញផងហ្ន៎ស ? (អ៊ីហួយស្រែក) អាស៊ុនហេង ! អាស៊ុនហៀង ! អាសៀកហ៊ារ ! ទៅណាអស់ហើយ វើយ ! មកជួយប្រដៅអាម្នាក់អោយអាម៉ាបន្តិចមើល៍ ! !

ភ្លាមនោះ បុរសពីរនាក់ស្ទុះចេញពីក្នុងផ្ទះជាប់គ្នានោះ យ៉ាង លឿន ហើយក៏គ្រវីដៃជើងដាក់កិត្យាយ៉ាងរហ័សមើលមិនទាន់ ។ ចំណែកបុរសទីបី ក៏លើកទូរសព្ទ័ឡើងហៅគ្នីគ្នាថែមទៀត...

នៅឯផ្ទះថ្មីរបស់ពូនង...

- ម៉ែ ! ពុក ! បង ! ឆាប់ទៅជួយបងកិត្យាផង !

ចាន់ណាតរត់មកហៅបងប្អូនអោយទៅជួយកិត្យា ដែលត្រូវកូនប្រុសទាំងបីរបស់អ៊ីហួយវាយតប់ ។ មាលានីកំពុងឆ្ងេចសំងំគេង ដោយក្តីសោកសៅ ។ កាលបើឮសូរសម្លេងប្អូនប្រុសកូកហៅបង ប្អូនអោយទៅជួយកិត្យា មាលានីភ្ញាក់ព្រើតស្ទុះក្រោកយ៉ាងរហ័ស ស្រវាដៃនាយចាន់ណាត ក្តាប់រត់សំដៅកន្លែងកើតហេតុភ្លាម ទុក អោយបងប្រុសបងស្រីរបស់នាង រត់តាមពីក្រោយរហង់ ។

មកដល់ដីធ្លាមុខផ្ទះជួលចាស់របស់នាង...

- នែ៎ ! ឈប់វាយគេភ្លាមទៅ ស៊ុនហេង ! ស៊ុនហៀង !

មាលានីស្រែកផង យកខ្លួនប្រឡូករងដៃជើងរបស់បុរសទាំង ពីរនោះផង ។ រំពេចនោះ ក្រុមប៉ូលីសសង្កាត់ក៏បានមកដល់ដែរ ។ កាលបើឃើញមានមនុស្សចូលមកដល់ធ្វើអន្តរាគមន៍ នាយទាំងពីរ នោះក៏ដកកណ្តាប់ដៃយ៉ាងរហ័ស ។

- បងកិត្យា !

មាលានីស្ទុះទៅលើកកិត្យាឡើង ឃើញរាងកាយរបស់គេទ្រុឌទ្រោមដោយការវាយដំថែមទាំងមានឈាមហូរពីមាត់ពីច្រមុះផង ។ នាងក៏ជួយគ្រាហ៍កិត្យាអោយឈរឡើង រួចហើយក៏បែរសម្លក់បុរសបីនាក់នោះដោយក្រសែភ្នែកប្រកបដោយការខកចិត្ត ។ បន្ទាប់មក មាលានីក៏ស្រដីយ៉ាងត្រជាក់ស្រេបទៅបុរសទាំងនោះ នៅចំពោះមុខហ្វូងអ្នកស្រុកនិងក្រុមប៉ូលីសទាំងនោះថា ៖

CHANBOKEO.COM

- ស៊ុនហេង! ភាពយង់ឃ្នងរបស់លោកមកលើសមាជិកគ្រួសារខ្ញុំ
មិនអាចជួយបង្កើនអោយខ្ញុំពេញចិត្តរូបលោកថែមទៀតទេ មានតែ
ស្រកស្រុតទឹកចិត្តជាមិត្តភាពកាន់តែធ្ងន់ធ្ងរថែមទៀត ព្រោះកិរិយា កម្រោលនេះធ្វើឲ្យខ្ញុំរិតតែខ្លាច
រិតតែស្អប់មុខស៊ុនហេង មិនចង់ ឃើញ មិនចង់រាប់ជាញាតិនឹងគ្នាតទៅទៀតឡើយ ។
ស៊ុនហៀង! សៀកហ៊រ! ការដែលអ្នកចេញមុខការពារម្តាយរបស់អ្នកនោះ ពិត
ជាត្រឹមត្រូវហើយ ប៉ុន្តែ ការដែលអ្នកប្រើកំរោលហឹង្សាលើមនុស្ស បែបនេះមិនសមរម្យអ្វីបន្តិចទេ
ព្រោះអ្នកមានគ្នាច្រើនវាយគ្នាតិច អាងកម្លាំងបាយ អាងបក្សពួក...
វាយគេអោយរបួសយ៉ាងធ្ងន់ធ្ងរ លើសកំរិតទោស ដែលគេគួរទទួលពីអ្នកគ្រប់គ្នា ។ ពេលនេះ
បើសិនជាសមាជិកគ្រួសាររបស់ខ្ញុំ មានសំដីលើសខ្វះទៅលើគ្រួសារ របស់អ្នកទាំងពីរ
ខ្ញុំសូមទោសជំនួសគេទាំងពីរនាក់នោះផង ។ សូមមេត្តាខន្តីអធ្យាស្រ័យ ព្រោះ
ពួកយើងជាជនក្រីក្រល្ងិតល្ងង់ មិនស្គាល់របៀបរបបរបស់អ្នកមាន ទើបបានជាមានកិរិយាជ្រុល
ជ្រួស មិនសមរម្យ ។ ចាប់ពីថ្ងៃនេះទៅ ខ្ញុំសង្ឃឹមថា ស៊ុនហៀង សៀកហ៊រ
និងបងប្រុសរបស់អ្នក នឹងប្រព្រឹត្តបង្ហាញនូវកិរិយា របស់អ្នកមានអោយគេឯងបានឃើញផងថា
តើពពួកអ្នកមានថ្លៃថ្នូរ គួរសម្តែងឥរិយាបថឬកពាបែបណា ទើបសមនឹងភ្នែកអ្នកផង
ដើម្បីកុំឲ្យអ្នកស្រុក គេលួចសើចយំតិះដៀលភាពមិនប្រពៃរបស់ អ្នកតទៅទៀត ។

ពោលចប់ នារីក៏គ្រាហ៍សត្យាដើរចេញទៅ ទុកអោយអ្នកទាំង
ឡាយដែលឈរនៅទីនោះធ្វើមុខភាំង ទំនងពិចារណាពាក្យពេចន៍ របស់មាលានីយ៉ាងល្អិតល្អន់ ។
រីឯស៊ុនហេងវិញ ក៏បែរមើលតាម នារីដោយក្រសែភ្នែកសោកស្តាយ ។

ផាច់! ស៊ុនហេងត្រូវដៃមួយទះកំភ្លៀងសឹងធ្លាក់ក្រោយ ។

- តាមសម្លឹងវាម៉េះហ្ន៎ស ? វាមានប្តីហើយ ទៅមើលវាស្អីទៀត ?

ស៊ុនហេងងាកមក ឃើញអ៊ីហួយជាម្តាយកំពុងឈរច្រត់ចង្កេះ ចង្អុលមុខនាយ ។
គេក៏ឈ្ងោកដើរចេញទៅ ក្នុងចិត្តនៅអាល័យ មាលានីមិនអស់មិនហើយ ។
ព្រោះតែក្តីស្រឡាញ់នេះហើយដែល ធ្វើអោយគេនឹកប្រចណ្ឌ នឹកខឹងនឹងកិត្យា
ទើបឆ្លៀតឱកាសយក លេស ពេលឃើញអ៊ីហួយដួលលើគំនរសម្រាម ក៏ហាក់ទៅទាត់
កិត្យាទាំងកម្រោល ដើម្បីទម្លាយកំហឹងប្រចណ្ឌរបស់ខ្លួន អោយ ធ្លាយអស់ពីពោះ ។ ថៃដន្យ
កិរិយានោះមិនបានធ្វើអោយមាលានី អាណិតស្រណោះឬស្រឡាញ់រូបគេថែមជាងមុនឡើយ ។
ពេលនេះ គេមានអារម្មណ៍ថាមាលានីកំពុងលារូបគេទៅរហូតហើយ... បេះដូង

CHANBOKEO.COM

របស់គេក៏ហួលពើតឡើងយ៉ាងឈឺផ្សា... តើហេតុអ្វីរូបគេបែរជាមក ចុះចាញ់សេចក្ដី
ស្នេហាចំពោះនារីមួយរូបនេះផង ? ហេតុអ្វីទៅ ?

បែរមកកិត្យានិងមាលានីវិញ...

នារីផ្ដេកកិត្យាលើកន្ទេលក្រហមមួយ រួចហើយក៏ជូតលាងមុខ របួសអោយបុរសយើងថ្នមៗ ។
មើលទៅកិត្យាហាក់ដូចជាទ្រោម
ខ្លួនខ្លាំងណាស់ដែលត្រូវបុរសពីរបីនាក់នោះទាត់ធាក់មិនលែងដៃ ។
ដោយចង់អោយកិត្យានិងមាលានីមានពេលវេលា និយាយរឿងផ្ទាល់ ខ្លួន
ពូនងមីងមៀនក៏កេះកូនចៅអោយគេចចេញពីទីនោះអស់ មិន
អោយនៅរំខានអ្នកទាំងពីរទេ ។

កិត្យាបើកភ្នែកឡើងសម្លឹងមាលានីយ៉ាងយូរ ទើបស្រដីថា ៖

- បងអរគុណណាស់ នី ដែលមកជួយបងទាន់វេលា!

មាលានីញញឹមទាំងទឹកភ្នែករលីងរលោង ហើយតបវិញថា ៖

- នីក៏អរគុណបងដែរ ដែលបងវិលត្រឡប់មកផ្ទះវិញ!

មែនហើយ! មាលានីរំភើបចិត្តរកថាមិនត្រូវទេ ពេលនាង បានឃើញប្ដីត្រឡប់មកផ្ទះវិញ ។
ចិត្តធុញថប់តប់ប្រមល់ពេញមួយ ថ្ងៃកន្លងមកនោះ ក៏រសាយអស់រលីង ពីបេះដូងរបស់នាង ។
ធីតា យកដៃជូតរបួសថ្នមៗ ដោយដួងចិត្តរន្ធត់ញាប់ញ័រ ព្រោះត្រេកអរ
សោមនស្សដែលកិត្យាត្រឡប់មកវិញផង និងដោយព្រោះក្ដីព្រួយ បារម្ភ
ចំពោះភាពទុរន់ទុរារបស់នាយផង ។

- ត្រូវការអោយគេទៅហៅពេទ្យមកមើលបងទេហ៎ ?

មាលានីសួរ ។

- បងមិនអីទេ នី!

កិត្យាគ្រវីក្បាលបណ្ដើរ លួចសម្លឹងមុខភរិយាបណ្ដើរ ។ ពេល នោះ
គេមានអារម្មណ៍ចម្លែកយ៉ាងណាមិនដឹងទេ ។ គេហាក់ដូចជា ញាប់ញ័រក្នុងបេះដូង
រកថាមិនត្រូវសោះ ។ ព្រឹកមិញនេះ គេខឹង គេស្អប់មាលានីណាស់
ប្រឹងរត់គេចទៅអោយបាត់កុំអោយឃើញមុខ នាងសាជាថ្មី
ហើយគេបានបើកម៉ូតូគេចខ្លួនពេញភ្នំពេញរកទីលាក់ ខ្លួនអោយឆ្ងាយកុំអោយឃើញមុខនាងទៀត

CHANBOKEO.COM

ប៉ុន្តែ នៅទីបំផុត គេ បែរជាវិលត្រឡប់មករកនាងវិញដោយខ្លួនឯងទៅវិញ ។ គេមិនយល់ចិត្តខ្លួនឯងទេ ថាហេតុអ្វីគេមានចិត្តជំពាក់លើមាលានីយ៉ាង ជ្រាលជ្រៅបែបនេះ ? ភ្លាមនោះ កិត្យាសង្កេតឃើញថារង្វង់កែវ ភ្នែករបស់មាលានីមានដក់ដលនេត្រវឹមៗ ថ្វីបើនារីខំញញឹមបន្លប់យ៉ាងណាក៏ដោយ ។

- ស្រក់ទឹកភ្នែកព្រោះខឹងនឹងបង មែនទេ អូននី ? (កិត្យាសួរ)

 មាលានីនៅស្ងៀម មួយស្របក់មកក៏ឆ្លើយថា ៖

- ចា៎ស ! អត់ទេ ! គឺមកពីនីភ័យខ្លាំងពេក ដែលឃើញបងទទួល រងការវាយទាត់របស់គេ ។

 កិត្យាឮហើយ ក៏ប្រែខ្លួន រួចប្រឹងងើបអង្គុយឡើង បន្ទាប់មកក៏លើកដៃទៅផ្តិតទឹកភ្នែកចេញពីរង្វង់មុខមាលានី ហើយក៏ស្រដីថា ៖

- បងសុំទោសណា៎ ដែលបងនាំកង្វល់មកអោយអូន !

 មាលានីងើបមុខឡើងសម្លឹងកែវភ្នែកកិត្យាយ៉ាងយូរ ទើបវាចា តបវិញថា ៖

- បងមិនបាននាំកង្វល់អោយនីទេ ការពិត.... បងកំពុងនាំសេចក្តីសុខអោយដួងចិត្តអូនវិញទេតើ ។

 កិត្យាលូកចាប់ដៃភរិយាមកកាន់យ៉ាងណែន ៖

- បើអូនមានសេចក្តីសុខពិតមែន ហេតុអ្វីអូនស្រក់ទឹកភ្នែក ?

 មាលានីលើកដៃផ្តិតទឹកភ្នែក រួចហើយញញឹមឡើង ៖

- បើសិនផ្ទះយើងមានរូបបងនៅផ្ទះរៀងរហូតទៅ នីសន្យាថាមិន ស្រក់ទឹកភ្នែកទៀតទេ...

- មែនឬ អូននី... !

 កិត្យារំភើបចិត្តអ្វីម្ល៉េះទេ កាលបើឮមាលានីស្រដីដូច្នោះ ។ គេសម្លឹងមុខនាងដោយឱភាញញាប់ញ័រ ។ មែនហើយ ! ពេញមួយថ្ងៃ ដែលគេគេចពីមាលានីទៅ គេគិតស្មានថា គេអាចបំភ្លេចនាងបាន ដោយងាយ.. ចៃដន្យ គេបែរជាតាំងចិត្តមិនបានសោះ ។ កិត្យា បែរជានឹកមាលានីលើសមុនខ្លាំងឡើង មិនស្រាកស្រាន្ត ។ ពេល នេះ គេបានមកអង្គុយគយគន់រង្វង់ភក្ត្រដ៏ស្រទន់របស់ប្រពន្ធខ្លួន សាជាថ្មី កាន់តែគយគន់យូរ កាន់តែចាប់បេតីចេតនាឡើង ស្ទើរតែ ទប់អារម្មណ៍ស្រើបស្រាលមិនបាន ។ គេមិនយល់ទេ ថាហេតុអ្វីក៏ នារីមួយរូបនេះមានឥទ្ធិពលមកលើបេះដូង របស់គេខ្លាំងក្លាដល់ ម្លឹង... ។

 ទ្រាំនឹងអារម្មណ៍រំភើបប្រតិពទ្ធ័ក្នុងបេះដូងមិនបាន កិត្យាក៏ដាក់នាសាទៅផ្តិតលើថ្ពាល់មាលានីដោយសេចក្តីស្នេហាយ៉ាងធំធេង រួច

CHANBOKEO.COM

ហើយក៏ស្រវាអោបនាងយ៉ាងណែនបំផុត សំដែងកិរិយាហាក់ដូច
ជានឹករលឹកហើយស្រឡាញ់នាងក្រៃលែង ។ នេះ គេទើបតែបែក ពីនាង
កាលពីព្រឹកមិញនេះទេតើហ៍ ហេតុអ្វីគេបែរជាមានអារម្មណ៍ ថា គេនឹកនាងខ្លាំងម្ល៉េះ ?...
ខ្លាំងរហូតប្រាថ្នាចង់លេបនាងលាក់ទុក ក្នុងឱកាពេលនេះតែម្តង ។
រីឯមាលានីក៏ផ្តលខ្លួនទទួលភាពកក់ក្តៅ ពីលង្វែកទ្រូងរបស់នរៈ
ជាស្វាមីទាំងដួងច័យរំភើបរំជួលរកពាក្យថ្លែងមិនបាន ស្ទើរតែស្រក់ ទឹកភ្នែកជាថ្មី ។
គូស្នេហ៍ទ្វេហានៅសម្ងំក្នុងរង្វង់ដៃរបស់គ្នាទៅវិញ ទៅមកយ៉ាងយូរ ទើបកិត្យាស្រដីឡើងថា ៖
- នី! បងអរគុណណាស់ ដែលនីចេញមុខការពារបង មិនអោយ
បុរសម្នាក់នោះនិងសាច់ញាតិរបស់គេវាយធ្វើបាប ។
គេនិយាយផង អង្អែលខ្នងភរិយាបន្តើរៗផង ។ មាលានីក៏បន្លឺ វាចាតបវិញថា ៖
- បងឈប់ប្រចណ្ឌខឹងអូនជាមួយស៊ុនហេងនោះហើយមែនទេ ?
- នរណាថា បងខឹងប្រចណ្ឌនឹងអូនជាមួយគេម្នាក់នោះ ?
- ហើយចុះព្រឹកមិញនេះ បងមួម៉ៅខឹងនឹងអូនរឿងអី ?
កិត្យាភ្ញាក់ព្រើត កាលបើឮមាលានីសួរនាយដូច្នោះ ។ ភ្លាម នោះ
គេហាក់ដូចជានឹកខ្ទក់ខ្ទាញ់ក្នុងចិត្តទៀតហើយ... គេនៅតែនឹក
មិនអស់ចិត្តដែលគេបានរួមមេត្រីជាមួយប្រពន្ធនៅរាត្រីដំបូង ប៉ុន្តែ
បែរជាគ្មានស្នាមដានឈាមរក្សព្រហ្មចារីយ៍ជាភស្តុតាង ។ គេនៅតែ សង្ស័យមិនអស់មិនហើយថា
មាលានីមិនមែនជាក្រមុំបរិសុទ្ធ ។ មាណពក៏សម្តែងកិរិយាអល់ឯក
ព្រោះគេកំពុងមានអារម្មណ៍ច្របូក ច្របល់ ពិបាកនឹងសម្រេចចិត្ត ។ គេស្រឡាញ់មាលានី
ស្រឡាញ់រក អ្វីប្រៀបមិនបានទេ ប៉ុន្តែ គេក៏ខកចិត្តព្រោះមិនដឹងថាតើរូបគេជា
បុរសទីមួយក្នុងជីវិតរបស់មាលានី ឬក៏បុរសទីប៉ុន្មានទៅវិញ ។ អ្វីដែលគួរអោយខ្ទាញ់បំផុតនោះគឺ
នារីមិនដែលនិយាយអ្វីពីអតីត កាលរបស់នាងអោយគេបានស្តាប់ បានដឹង បានយល់ ម្តងណា
ឡើយ ។ ថែមទៀត កិត្យាពុំមានសេចក្តីក្លាហានមុតមាំ នឹងសួរចិត្ត មាណវីទេ ។ តាមការពិត
កិត្យាចង់អោយនាងនិយាយប្រាប់ខ្លួន ណាស់ អំពីចិត្ត អំពីអារម្មណ៍ពិតៗរបស់នាងចំពោះរូបគេ ។
ប៉ុន្តែ មាលានីបែរជាបិទមាត់ជិតឈឹងរៀងរហូត ធ្វើអោយ មាណពរិតតែ ធុញថប់កន្ទះរាក្នុងចិត្ត
ពិបាកក្រៃណានឹងរៀបរាប់ចេញមក ។

CHANBOKEO.COM

ចំណែកមាលានីវិញ កាលបើឃើញស្វាមីនៅស្ងៀម នាងក៏មិន ហ៊ានសួរកិត្យាថែមទៀត ខ្លាចគេខ្ចក់ចិត្តខ្ចក់អារម្មណ៍ ខឹង ហើយ រត់គេចពីនាងបាត់ទៅវិញ ម្ល៉ោះហើយ នាងក៏ឈ្ងោកមុខសម្ងំ នៅស្ងៀមក្នុងរង្វង់ដៃក៏កក់ក្តៅរបស់មាណព ។

មួយសន្ទុះធំក្រោយមក នារីក៏វាចាទន់ភ្លន់ទៅកាន់កិត្យាថា ៖

- ថ្ងៃនេះ បងមិនស្រួលខ្លួន មិនបាច់និយាយអ្វីប្រាប់អូនក៏បានដែរ ចាំស្អែក បងមានកម្លាំង មានអារម្មណ៍ល្អ ចាំយើងនិយាយគ្នាណា៎ បងកិត្យា!

- បាទ៎!

កិត្យាឆ្លើយស្លូតថៃស ទំនងរកនឹកមិនឃើញថា តើគេគួរ និយាយជាមួយប្រពន្ធថាម៉េចហើយនិយាយយ៉ាងណា ដើម្បីកុំអោយ ទាំងសង ខាងមានអារម្មណ៍ល្អក់កករចំពោះគ្នាដូចព្រឹកមិញសាជាថ្មី ទៀត ។ តាមការពិតទៅ គេក៏ទទួលស្គាល់ដែរ ថាគេមានចិត្តឆេវ ឆាវបន្តិចមែន ប៉ុន្តែ ក៏ប្រកាន់ចិត្តរឹងត្អឹងដែរថា គេជាបុរសម្នាក់ ដែលរក្សាដួងចិត្តបរិសុទ្ធចំពោះមាលានីដោយស្មោះសបំផុត ដូច្នេះ គេមិនគួរនឹងបានទទួលភាពសៅហ្មងត្រឡប់មកពីមាលានីវិញទេ ។ ប៉ុន្តែ តើអោយធ្វើម៉េចទៅ នឹងដឹងការពិត ? បើគេសួរនាងត្រង់ៗ តើមាលានីហ៊ានបារមាត់ទម្លាយការពិតដល់រូបគេទេ ? ចុះបើនាង ជានារីដែលអស់ភាពបរិសុទ្ធនៅ មុនពេលនាងរៀបការនឹងរូបគេ តើគេត្រូវគិតយ៉ាងណាទៅវិញ ? លែងលះគ្នា មែនទេ ?

- ទេ! ខ្ញុំមិនអាចទទួលបានទេ បើសិនជាយើងត្រូវចែកផ្លូវគ្នា (កិត្យាគិតក្នុងចិត្តម្នាក់ឯង) ប៉ុន្តែ ខ្ញុំក៏មិនអាចទទួលបានដែរ បើ មាលានីជានារីមិនបរិសុទ្ធមុនពេលនាងរៀបការជាមួយខ្ញុំ... ពេល នេះ តើខ្ញុំត្រូវគិតយ៉ាងណា ធ្វើយ៉ាងណា ?

ពេលវេលាក៏កន្លងទៅយឺតៗ... ទុកឱកាសអោយបេះដូងរបស់ អ្នកទាំងពីររណ្តំបទភ្លេងក្នុកក្នាក់ៗ ខុសចង្វាក់ផង ត្រូវចង្វាក់ផង ដោយក្តីកន្ទះរាក្នុងចិត្តរៀងៗខ្លួន ពេញមួយរាត្រី...

OOOOOOOOOOOOOOO

OOOOO

O

# វគ្គទី១០
# ពន្លកស្នេហ៍

ក្រុងភ្នំពេញ...

បីខែមុនមាលានីរៀបការជាមួយកិត្យា...

- សួស្តីនី! ចាំបងយូរហើយហ្ន៎ស ?
- នរណាថា នីចាំបងតារានោះ ?
- អូហ៍ ក្រែងយើងណាត់គ្នាត្រូវចេញទៅណាថ្ងៃនេះ មែនទេ ?
- នីមិនចាំទេ សុំទោសចាស!

មាលានីសើចក្អឹក លលេងតារាដែលមកទទួលនាងចេញទៅ ក្រៅ ។ ការពិត ពូនងមីងមៀន មិនបានដឹងទេ ថា មាលានីទៅ ណាមកណាជាមួយតារា ព្រោះគាត់នឹកស្មានថា តារានាំមាលានីទៅធ្វើក្រចកនៅផ្ទះភៀវ ដូចពីដើមដែលនាងធ្លាប់ធ្វើ ។ ការពិត គាត់ ក៏លួចសម្លឹងតារាបន្តិចៗដែរ ព្រោះគេជាបុរសសង្ហាគួរអោយចាប់ ភ្នែកណាស់ គ្រាន់តែគាត់ទាំងពីរមិនដឹងប្រវត្តិថា តារាជានរណា ហើយណាមួយ គាត់មិនហ៊ានសួរផង ខ្លាចតារាគិតថា គាត់ជាមនុស្សចង់ដឹងរឿងច្រើនមិនសមរម្យ ។

ការពិត មាលានីធ្វើការនៅតូបមុខផ្ទះរបស់នាងជាមួយបងៗតែ មួយកំណាត់ថ្ងៃទេ ។ នៅរវាងម៉ោងប្រហែលបីរសៀល ថ្ងៃអាទិត្យ តារាតែងតែយកម៉ូតូមកទទួលនាងចេញទៅជារឿយៗ មិនសូវខាន ឡើយ ។ គេនាំមាលានីទៅនេះទៅនោះតាមបែបយុវវ័យ ជួនកាល គ្រាន់តែការជិះម៉ូតូកំសាន្តទីក្រុង ក៏ជាការសប្បាយរបស់គេទាំង ពីរដែរ ។

ថ្ងៃនេះ តារាបានឱបនារីសំដៅកន្លែងថ្មីមួយ...

CHANBOKEO.COM

- ទៅណាហ្នឹង បងតារា ?
- មិនដឹងទេ... ចេះតែបើកដើរលេងទៅ !

នាងក៏នៅស្ងៀម ចេះតែរំពៃមើលទេសភាពតាមដងផ្លូវ យ៉ាង សប្បាយប្លែកភ្នែក ។ មួយស្របក់មក អ្នកទាំងពីរក៏បានមកដល់ ផ្ទះល្វែងមួយខ្នងនៅសង្កាត់ស្ទឹងមានជ័យ ។

- ផ្ទះនរណាហ្នឹង បងតារា ?
- ផ្ទះរបស់ប៉ាម៉ាក់បង ។ ពីដើមយើងជួលអោយគេយកកម្រៃ ។ លុះគេដាច់កុងត្រាទៅ ប៉ាម៉ាក់គិតថា នឹងដាក់លក់វិញ ។ ពេលនេះ គាត់កំពុងរកជាងមកជួលជុលកែកុនអោយស្អាតដើម្បីលក់ ។

មាលានីចុះពីម៉ូតូ ដើរចូលទៅក្នុងផ្ទះ ឃើញផ្ទះនោះទំនេរ ចោលគ្មានគ្រឿងសង្ហារឹមទេ មានតែក្តារដឿចាស់មួយនៅបន្ទប់ គ្រួសារ ក្រៅពីនោះទទេស្អាត ។

- បងនាំខ្ញុំមកទីនេះ ធ្វើអីហ្នឹង ?

មាលានីសួរ ។ តារាញញឹម មិនឆ្លើយទេ បែរជាចតម៉ូតូហើយ ដើរចេញទៅទាញទ្វារមុខបិទ ។

- ម៉េចចាំបិទទ្វារផង ?

នារីយើងសួរបន្ថែម ព្រោះចម្លែកចិត្ត ។ តារាញញឹមមិនឆ្លើយ ទេ បែរជាទៅអូសកន្ទេលមួយពីក្រោមក្តារដឿមកក្រាលអង្គុយ រួច ហើយ ទើបស្រដីថា ៖

- យើងស្គាល់គ្នាយូរហើយ តែយើងមិនដែលមានពេលវេលាផ្ទាល់ ខ្លួនស្ងាត់ៗ និយាយគ្នាទេ ។ ថ្ងៃនេះ បងគិតថាបងចង់និយាយ ជាមួយអូននី បន្តិច បានទេអូន ?

មាលានីជ្រួញចិញ្ចើម នឹកឆ្ងល់ ៖

- បងតារាចង់និយាយពីអ្វីទៅ ?

តារាដាក់ខ្លួនចុះលើក្តារដឿ ហើយទាញដៃនារីអោយអង្គុយចុះ ក្បែរខ្លួនគេ រួចហើយក៏ពោលទៅនារីដោយវាចាទន់ភ្លន់ថា ៖

- យើងស្គាល់គ្នាប៉ុន្មានឆ្នាំហើយ មាលានី ?
- គឺ... ប្រហែលជាងពីរឆ្នាំហើយទេដឹង !
- ហើយចុះ នីគិតយ៉ាងណាពីរឿងយើងទាំងពីរ ?
- រឿងយើង ? មានន័យថាម៉េចទៅបងតារា ?
- មាលានី ! នេះអូនធ្វើពើ ឬក៏អូនមិនដឹងពិតមែន ថាយើងជាគូ ស្នេហ៍នឹងគ្នា ?
- គូស្នេហ៍ ? ថាម៉េចហ្នឹង បងតារា ? យើងជាគូស្នេហ៍តាំងពី អង្កាល់ ?

CHANBOKEO.COM

តារាបើកភ្នែកមូលក្រឡង់ ៖

- អញ្ចឹង អូននីមិនដែលស្រឡាញ់បងទេ មែនទេ ?
- ស្រឡាញ់បង ? អត់ទេ! ខ្ញុំគ្រាន់តែរាប់អានបងត្រឹមជាមិត្តទេ តើហ៎!
- បើអូនមិនស្រឡាញ់បង ហេតុអ្វីអូនធ្វើកិរិយាស្និទ្ធស្នាលបញ្ឆោត ចិត្តបងធ្វើអ្វី ?
- បញ្ឆោត ? នរណាគេបញ្ឆោតបង ? គឺបងទេតើហ៎ ដែលគិតតែ ខ្លួនឯង ម្នាក់ឯងនោះ ។
- នី! អូនកុំលេងចិត្តបងរបៀបនេះណា៎! ព្រោះពេលនេះ បង គិតថា បងលង់ស្នេហ៍របស់អូនហើយ ។
- ប៉ុន្តែ នីស្រឡាញ់បងត្រឹមជាមិត្ត មិនមានគំនិតវែងឆ្ងាយជាង ហ្នឹងទេ ។ ខ្ញុំនៅក្មេងណាស់បង ចង់ធ្វើការជួយម៉ែពុកបន្តិចសិន ហើយក៏ចង់ចូលរៀនវិជ្ជាជីវៈល្អៗខ្លះសំរាប់អនាគត មិនចង់មានគូ ស្នេហ៍ពេលនេះទេ ។

មែនហើយ មាលានីចង់ត្រឡប់ចូលរៀនវិញណាស់ ។ នាង ស្រឡាញ់ការសិក្សា... សំណាងមិនល្អ នាងមិនអាចបន្តការសិក្សា នៅមហាវិទ្យាល័យបាន ទើបមានគំរាងចង់រៀនខាងបច្ចេកទេស វិជ្ជាជីវៈអ្វីផ្សេងវិញ ។

- ចុះបើបងស្រឡាញ់នី សុំអូនរៀបការតាមច្បាប់ តាមប្រពៃណី តើនីគិតយ៉ាងណាដែរ ?
- ខ្ញុំនៅតែឆ្លើយដដែលហ្នឹងថា មិនទាន់ត្រៀមខ្លួនទេ ។ អោយខ្ញុំ សុំពេលវេលាគិតបន្តិចសិនបានទេ ? ម្យ៉ាងទៀត... យើងក៏មិន ដែលណែនាំគ្រួសារយើងអោយស្គាល់គ្នាទៅវិញទៅមកដែរ មិនដឹង ថាចាស់ទុំគាត់មានអារម្មណ៍យ៉ាងណាចំពោះរឿងយើងទាំងពីរ ។

តារាឈ្ងោកមុខនៅស្ងៀមមួយស្របក់ក៏និយាយថា ៖

- ចុះបើយើងចាប់ដៃគ្នាធ្វើសង្សារពីថ្ងៃនេះទៅ តើនីព្រមឬទេ ?

មាលានីសម្លឹងក្រសែភ្នែករបស់តារា ទំនងចង់យល់នូវជំរៅ ចិត្តរបស់នាយ មួយស្របក់មកក៏គ្រវីក្បាល ៖

- អត់ទេ! ធ្វើជាមិត្តស្និទ្ធស្នាលចំពោះគ្នាទៅវិញទៅមកបែបនេះ សមរម្យហើយ ។ មាលានីមិនចង់បានអោយលើសពីនេះទៀតទេ ។

តារាក៏បែរសម្លឹងកែវភ្នែករបស់នាងដោយក្រសែភ្នែកស្នេហា៖

- មានន័យថា នីមានម្ចាស់ចិត្តហើយមែនទេ ។

CHANBOKEO.COM

មាលានីងាកមុខចេញ គេចក្រសៃភ្នែករបស់គេ ត្បិតខ្លាចចាញ់ឥទ្ធិពលមន្តស្នេហ៍ដែលគេកំពុងបញ្ជូនមកសណ្ដំអារម្មណ៍និងដួងចិត្ត របស់នាង ៖

- នីសុំមិនឆ្លើយបានទេ បងតារា ? (ស្រស់ស្រីយើងឆ្លើយ)

តារាយកដៃជ្រោងសក់ ទំនងគិតវែងឆ្ងាយ ៖

- តែបងពិបាកទប់ចិត្តណាស់ មាលានី ថាបងអាចរាប់អានត្រឹមជា មិត្ត ព្រោះពេលនេះ បងគិតថា នីជាម្ចាស់បេះដូងបងរួចទៅហើយ - ថៃដន្យ មាលានីមិនបានត្រៀមខ្លួនចូលមកធ្វើជាម្ចាស់បេះដូង របស់បុរសណាបាននៅឡើយទេ ។ សូមបងតារាអភ័យទោសផង! តារាអង្គុយឈ្ងោកមុខយ៉ាងយូរ ។

មួយសន្ទុះធំក្រោយមក មាលានីក៏ស្ទុះក្រោកឡើងទៅបើកទ្វារ៖

- ល្មមជូនខ្ញុំទៅផ្ទះវិញហើយបង! ដើរយូរពេកខ្លាចពុកម៉ែគាត់ បារម្ភ ។

តារាងើបឈរឡើង ដើរតាមពីក្រោយនារី រួចហើយក៏ស្រវា អោបនាងពីក្រោយ ៖

- បងសុំថើបមួយបានទេ នី ?

មាលានីភ្ញាក់ព្រើត ស្រវាបេះដៃតារាចេញ ហើយស្ទុះថយ ក្រោយខ្វាក យ៉ាងរហ័សដូចព្រួញ ៖

- កុំធ្វើបែបនេះ បងតារា! ខ្ញុំនឹងស្អប់បងមិនខាន បើសិនបងមាន គំនិតល្មក់កករមកលើមាលានី ។

តារាទុចង៉ក់ ធ្វើមុខស្ងួត ។ បន្តិចមក គេក៏បើកទ្វារឱបនារី ចេញទៅ ទាំងដួងចិត្តសៅហ្មង ។

មកដល់មុខតូបសំអាងនារីរបស់គ្រួសារមាលានី ស្រាប់តែតារាប្រទះឃើញបុរសក្មេងម្នាក់ កំពុងជួយបោសសំអាតតូបជាមួយបងប្អូនស្រីរបស់មាលានីពីរបីនាក់ទៀត ។ រំពេចនោះ តារាហាក់ ដូចជាចាប់ភ្លឹកថាបុរសក្មេងនោះ លួចចោលកន្ទុយភ្នែកមកគេនិង មាលានី រួចហើយលួចជ្រួញចិញ្ចើមហើយបែរមុខចេញទៅ ។ តារាដឹងភ្លាមថា នរៈម្នាក់នោះកំពុងចោលចំណាប់អារម្មណ៍ទៅលើមាលានី គ្រាន់តែគេមិននិយាយស្ដី ។ ការពិត តារាមិនដែលឃើញ មាណពម្នាក់នោះពីមុនមកទេ ថ្វីបើគេទៅមកមាលានី ជាញឹកញាប់ ក៏ដោយ ។

- គេជានរណា អូននី ? (តារាលួចខ្សិបសួរ)
- នរណាគេ ? (មាលានីឆ្លើយ)
- គឺបុរសសង្ហាម្នាក់នោះ !
- អូហ៍ គេជាអ្នកជិតខាង មានសន្ដានចិត្តមកជួយដៃជើងបងស្រីខ្ញុំ បន្តិចបន្តួច ។

CHANBOKEO.COM

- តែបងគិតថា គេផ្តល់ចំណាប់អារម្មណ៍លើអូននីជាពិសេសយ៉ាង ណាមិនដឹងទេ ។

- កុំគិតផ្តេសផ្តាសយ៉ាងហ្នឹង បងតារា! មាលានីជាមនុស្សសាមញ្ញ យ៉ាងនេះ គ្មាននរណាគេមកចាប់អារម្មណ៍ទេ ។

- តែក៏មានម្នាក់ហើយ ហើយចាប់អារម្មណ៍អូននីយ៉ាងពិសេសទៀត ផង ។

- យី! នរណាគេទៅ ?

- គឺ បងនេះអី!

- ចេះតែថាហើយ បងតារា! បងគឺជាបងប្រុសដ៏ល្អរបស់ខ្ញុំ មិន មែន អ្នកលួចស្ញើចសរសើរសោភ័ណរបស់ខ្ញុំទេ ។

តារាធ្វើមុខស្ងួត ដែលមាលានីមិនព្រមទទួលអារម្មណ៍ប្រតិព័ទ្ធ របស់រូបគេ ។ បន្តិចមក គេក៏បត់ម៉ូតូត្រឡប់ទៅវិញ ទាំងចិត្ត សង្ស័យមិនអស់មិនហើយ ។

- អូននី! នេះប្អូនកិត្យា គេមករកប្អូនតាំងពីរសៀល តែប្អូន អាល័យចេញទៅក្រៅ វិះតែមិនបានជួបគ្នា ។

ម៉ាឡានិយាយប្រាប់ប្អូនស្រីដែលកំពុងដើរចូលទៅក្នុងតូប ។ ឮបងស្រីស្រដីដូច្នេះ នាងក៏បែរទៅកិត្យាហើយញញឹម ៖

- មានការអ្វីឬ បងប្រុសរូបស្អាត ?

គេញញឹមតបមករកនាងវិញ តែមិនឮគេស្តីតបអ្វីទេ ។ នារី យើងក៏សួរបន្តទៀតថា ៖

- យើងជួបគ្នាកន្លែងធ្វើការមួយអាទិត្យ៦ថ្ងៃទៅហើយ មានអីត្រូវ នឹកគ្នា តាមរកគ្នានោះ មែនទេ បងកិត្យា ?

មាលានីញាក់ស្មា ធ្វើកិរិយាហាក់មិនចាប់អារម្មណ៍នឹងវត្តមាន របស់មាណពប៉ុន្មានឡើយ ។ ភ្លាមនោះ នាងក៏ស្រវាជួយបងស្រី រៀបចំបិទហាងដែរ ។ បន្តិចមក ពួកគេក៏ចូលទៅក្នុងផ្ទះអស់ ទុកឲ្យមាលានីបង្ហើយការងារតែពីរនាក់កិត្យា ។ ភ្លាមនោះ នរៈដើរ មកជិតមាលានី ហើយស្រដីខ្សិបៗថា ៖

- ចុះបើកិត្យានឹកមាលានី ហើយចង់ជួបមុខរាល់ថ្ងៃវិញនោះ នីមាន អារម្មណ៍យ៉ាងម៉េចដែរ ? អនុញ្ញាត្តិអោយបងមកលេងនៅផ្ទះខ្លះ ផងបានទេ ? នៅកន្លែងធ្វើការ យើងបានត្រឹមតែឃើញមុខគ្នាមែន តែយើងមិនអាចនិយាយគ្នាបានទេ ព្រោះយើងត្រូវបំពេញមុខការ ងារអោយត្រឹមត្រូវ ។ ចំណែកការដើរនិយាយគ្នាតាមផ្លូវទៅមក ធ្វើការរាល់ថ្ងៃ ក៏មិនសមនឹងជជែកពីរឿងផ្ទាល់ខ្លួនដែរ មែនទេ មាលានី ?

CHANBOKEO.COM

មាលានីភ្ញាក់ក្រញាង ។ នេះជាលើកទីមួយហើយដែលមាលានី
ឮបុរសម្នាក់នេះនិយាយមានប្រយោគយ៉ាងវែងអស់ពីចិត្ត ជាមួយ នាង ។ ការពិត
ចាប់តាំងពីថ្ងៃដែលនាងចាប់ស្គាល់គេមក គេស្រដី តិចណាស់ជាមួយនារីៗ
ថ្វីបើគេជាមនុស្សរួសរាយ បានមាត់បានក
ជាមួយបុរសជាមិត្តភឿននៅរោងចក្រជាមួយគ្នាក៏ដោយ ។ ភាគ ច្រើន គេច្រើនតែញញឹម
ហើយដើរស្ងៀមៗជាមួយនាងតាមផ្លូវ ទៅធ្វើការ ឬពេលចេញត្រឡប់មកផ្ទះវិញ ។

- តើមានរឿងផ្ទាល់ខ្លួនអ្វីទៅ ដែលបងកិត្យាចង់និយាយជាមួយខ្ញុំ នោះ ?

(មាលានីសួរធ្វើពើជាមិនយល់សំដីបុរសយើង)

គេញញឹម ហើយឆ្លើយវិញដោយសម្លេងស្រទន់ ៖

- កាលពីរសៀល បងនឹកថាចង់និយាយស្អីទេ ជាមួយមាលានី តែ ពេលនេះ
បងភ្លេចបាត់ទៅហើយ... ចាំស្អែក នឹកឃើញ ចាំបង ប្រាប់ណា៎!
តើនីអោយពេលបងនិយាយជាមួយទេ ?

- អោយតែរឿងល្អៗ ខ្ញុំស្តាប់ទាំងអស់ហ្នឹង ។

មាណពក៏ញញឹមបំព្រងឡើងដាក់មាលានី កាលបើឮនាងតប វិញដូច្នោះ ។
គេក៏រួសរាន់ជួយបិទទ្វារតូប ចាក់សោរតូប ស្រាប់តែ
ឃើញប្អូនស្រីជំទង់ម្នាក់របស់មាលានីរត់មកហៅអ្នកទាំងពីរ ៖

- បងយ៉ា! បងនី! ពុកម៉ែមានប្រសាសន៍ហៅអោយទៅពិសារ បាយជាមួយគាត់ ។

មាលានីឮហើយ ក៏ងាកមើលមុខកិត្យា ធ្វើកិរិយាទំនងចម្លែក
ចិត្តដែលឪពុករបស់នាងទទួលភ្ញៀវកម្លោះ អោយនៅទទួលទាន
អាហារជាមួយគ្រួសាររបស់នាង ។

នៅជុំវិញស្តុកអាហារ មាលានីមានអារម្មណ៍ថាបងប្អូនរបស់ នាងទាំងអស់លួចគយគន់កិត្យា
និងរូបនាងមិនដាក់ភ្នែកសោះ ទំនងហាក់ដូចជាកំពុងផ្ទៀងផ្ទាត់គុណសម្បត្តិរបស់អ្នកទាំងពីរក៏មិន
ដឹង ធ្វើអោយមាលានីរអៀសខ្លួន បែកញើសខ្នងឡើង រងាចង់រណ្តំ ចង្កា ។
ណាមួយនាងនឹកអៀនខ្មាសឪពុកម្តាយ ណាខ្មាស់ប្រុស កម្លោះដែល
ហ៊ានយកខ្លួនដើរចូលមកអោយឪពុកម្តាយនឹងក្រុម គ្រួសាររបស់នាង
ពិចារណាដោយត្រង់ៗដូច្នេះ ។

CHANBOKEO.COM

កាលពីមុនពូនងដែលធ្លាប់មានចិត្តរឹងត្អឹងចំពោះកូនគ្រប់ៗគ្នា ប៉ុន្តែ តាំងពីគាត់រងគ្រោះពិការមក ពូក៏បានក្លាយខ្លួនជាបន្ទុករបស់ កូនៗគ្រប់គ្នា ម្ល៉ោះហើយ គាត់បានផ្លាស់ប្តូរចរិតកំណើតរបស់គាត់ ជាច្រើន មិនសូវហ៊ានមាត់កអោយល្អក់ទឹកចិត្តកូនរបស់គាត់ទៀត ទេ ជាពិសេសចំពោះមាលានី ត្បិតតែងតែហុចអ្វីៗទាំងអស់ ជូន ឪពុកម្តាយគ្រប់គ្រងគ្រួសារ អោយតែនាងរកបាន គឺមិនដែលលាក់ ទុកចាយផ្ទាល់ខ្លួនទេ ។ ចំណែកបងៗរបស់នាង គេមានគ្រួសារ មានកូនចៅដែរ អាចជួយផ្តល់មកពូនងនិងមីងមៀន តាមតែ លទ្ធភាពប៉ុណ្ណោះ ព្រោះគេត្រូវសន្សំសំរាប់កូនចៅរបស់គេដែរ ។ មាលានីគិតថា នាងនៅក្មេង នៅមានពេលច្រើននឹងស្វែង រកវិជ្ជា រកអនាគតភ្លឺស្វាង ។ ដូច្នេះ នាងក៏សំរេចចិត្តធ្វើការពេលនេះ ដើម្បីទ្រទ្រង់ឪពុកម្តាយនិងប្អូនៗសិន ។

នៅព្រលប់នោះ...

ពូនងនៅអង្គុយសំណេះសំណាលជាមួយកិត្យាតែពីរនាក់ បន្ទាប់ ពីពេលបាយរួច ។

- ក្មួយមានឪពុកម្តាយទេ ហើយបងប្អូនប៉ុន្មាននាក់ដែរ ?
- បាទ! ប៉ាម៉ាក់នៅភ្នំពេញនេះឯង ជាអ្នករកស៊ីបន្តិចបន្តួច ហើយ មានកូនតែមួយទេ គឺខ្ញុំនេះតែម្តង ។
- អូហ៍ អញ្ចឹងមានន័យថា កិត្យាឯងជាកូនទំរើសប្រាកដណាស់ ។

កិត្យានៅស្ងៀម បន្តិចមក ក៏ឆ្លើយថា ៖

- ការពិត ខ្ញុំជាក្មេងមិនមានសំណាងល្អទេ ដែលបានកើតមកជាកូន ទោលក្នុងគ្រួសារ អោយឪពុកម្តាយទំរើសនោះ ។
- ហេតុអ្វី បានជាក្មួយនិយាយដូច្នោះ ?
- ព្រោះខ្ញុំជាក្មេងរងាគ្មានបងប្អូន គ្មានការកក់ក្តៅក្នុងចិត្ត ដូចក្មេង ទូទៅ ម្ល៉ោះហើយ តែងទាមទារចំណាប់អារម្មណ៍ពីឪពុកម្តាយមិន លែងឡើយ ។ លុះធំឡើង ពេលគាត់មិនអាចផ្តល់ចំណាប់អារម្មណ៍ ឲ្យបានតាមការទាមទាររបស់ខ្ញុំ ខ្ញុំក៏បែររកមិត្តភក្តិ... ហើយក៏ដើរ ឃ្លាតពីឪពុកម្តាយកាន់តែឆ្ងាយទៅៗ... រហូតដល់យកមិត្តធ្វើជា ឪពុកម្តាយជំនួសវិញ ព្រោះគេផ្តល់ការកក់ក្តៅអោយខ្ញុំនូវអ្វីដែល យុវជនភ្លើតភ្លើនត្រូវការ...
- ដូចជាអ្វីខ្លះទៅ ?

CHANBOKEO.COM

- ដូចជាសេរីភាពដើរហើរមិនមានព្រំដែន ជក់ ផឹក ច្រៀង ការាអូខេ គេចរ៉េះសាលា ចាក់បាល់
ចូលហាងហ្គេម លេងល្បែង ភ្នាល់... ។ល ។...
- ហើយក្មួយបានប្រព្រឹត្តវង្វេងបែបហ្នឹងផងហ្ន៎ស ?
  កិត្យាងក់ក្បាល ៖
- បាទ! ព្រោះកាលនោះ ខ្ញុំមិនបានដឹងថា ភាពឈាមរាវនឹងផ្ដល់
លទ្ធផលអាក្រក់ដល់ជីវិតរបស់ខ្ញុំបែបណាទេ រហូតទាល់តែ ខ្ញុំបាន
ទទួលរងវិបត្តិយ៉ាងធ្ងន់ពីការសេពគប់មិត្តប៉ោឡៃ បានត្រូវជាប់ឃុំ រាប់ខែ អស់សិទ្ធិសេរីភាព
ទើបភ្ញាក់ខ្លួន...
- មានដល់ថ្នាក់ហ្នឹងផង ? មើលមុខក្មួយដូចមិនសមជាមនុស្សខូច
សោះតែម្ដងហើយ ។ តើកាលនោះ មានរឿងហេតុអីទៅ បានជានាំ
អោយក្មួយជាប់ទោសអញ្ចឹងនោះ ?
  កិត្យាឈ្ងោកមុខយ៉ាងយូរ ទើបគេងើបមុខឡើងសាជាថ្មី ហើយ
ពោលបន្តទៅទៀតថា ៖
- គឺទៅរាំវង់ចូលឆ្នាំតន្ត្រីធុងបាស់ មានគេស៊ីផឹកស្រវឹងវាយគ្នា ។
នៅក្នុងនោះមានពួកម៉ាករបស់ខ្ញុំដែរ ។ ពេលខ្ញុំស្ទុះទៅជួយគេ ក៏ ត្រូវក្មេងងទៃវាយ
ម្លោះហើយត្រូវតដៃដើម្បីដោះខ្លួន ។ ក្រោយ មកក៏មានហ្វូងប៉ូលីសទៅធ្វើអន្តរាគមន៍ ។ កាលនោះ
មានមនុស្ស របួសជាច្រើននាក់ ហើយមានបែកបាក់ទ្រព្យសម្បត្តិអ្នកស្រុកផង
ទើបពួកយើងត្រូវគេកាត់ទោសអោយជាប់ឃុំរាប់ខែ ជាពិសេសអ្នក
ដែលគ្មានអាណាព្យាបាលមកបង់ប្រាក់លោះខ្លួន ។
- ហើយចុះឪពុកម្ដាយក្មួយមិនរវល់អើពើនឹងសុខទុក្ខរបស់ឯង ទេ ឬអីក្មួយ ?
- បាទ! គាត់បារម្ភពីខ្ញុំជានិច្ច ប៉ុន្តែគឺខ្ញុំទេតើដែលខ្មាស់ឪពុកម្ដាយ មិនហ៊ានផ្ដល់ដំណឹងជូនគាត់ទេ
ខ្លាចគាត់ភ័យភ្ញាក់ផ្អើល ទទួលទុក្ខ ដោយសារកូនអកតញ្ញូដូចខ្ញុំនេះ
ទើបសុខចិត្តសំងំនៅក្នុងមន្ទីរឃុំ យាំងរាប់ខែទំរាំគេព្រលែងអោយមានសេរីភាពឡើងវិញ ។
- មានន័យថា ឪពុកម្ដាយមិនបានដឹងរឿងប៉ោឡៃរបស់ក្មួយទេ ?
- ដឹងបាទ! ខ្ញុំបានសារភាពចំពោះគាត់នូវកំហុសរបស់ខ្ញុំហើយ...
- ហើយពេលនេះ ក្មួយយល់យ៉ាងម៉េចដែរ អំពីជីវិតបច្ចុប្បន្នរបស់ ខ្លួន ?

CHANBOKEO.COM

- គឺស្តាយ... ស្តាយកំហុសដែលបានប្រព្រឹត្តខក ប្រព្រឹត្តខុស មិន បានរៀនចប់មហាវិទ្យាល័យ មិនបានទទួលសេចក្តីស្រឡាញ់និងការ កក់ក្តៅពីឪពុកម្តាយដែលគាត់រង់ចាំតែប្រគល់អោយខ្ញុំ តែខ្ញុំបែរជា រត់គេចមិនព្រមទទួល មិនបានយកពេលទៅរកស៊ីធ្វើការរកលុយ ជួយគ្រួសារឬជួយខ្លួនឯង... មានតែបំផ្លាញអស់ទាំងទ្រព្យឪពុក ម្តាយ អស់ទាំងអនាគតរបស់ខ្លួន ។ នៅពេលដើរចេញពីគុកមក វិញ សង្គមក៏លែងរាប់រកខ្ញុំទៀត ព្រោះគេគិតថា ខ្ញុំជាទណ្ឌិតដ៏ ឧក្រិដ្ឋ មិនគួរនឹងជួយជ្រោមជ្រែងអោយមានការធ្វើ មានជីវិតភ្លឺថ្លា មកវិញទេ ព្រោះគេខ្លាចខ្ញុំមិនកែខ្លួន តែបែរក្លាយជាឧក្រិដ្ឋជន ដូច ដើមវិញ ។

- អញ្ចឹង ក្មួយមានដែលគិតទេ ថាខ្លួនចង់វិលទៅប្រព្រឹត្តឧក្រិដ្ឋ តាមបែបយុវជនឈាមរាវសាជាថ្មី ?

- បាទ! អត់ទេ! ខ្ញុំបានកែខ្លួនជាងមួយឆ្នាំហើយ តាំងពីបានវិល ត្រឡប់ទៅសុំទោសឪពុកម្តាយខ្ញុំទាំងពីរនាក់រួចមក ។

- ពូត្រេកអរណាស់ដែលក្មួយបានដឹងកំហុស ហើយកែប្រែខ្លួនមក ល្អវិញទាន់ពេលវេលា ។ ចាប់ពីពេលនេះទៅ សូមកុំអោយដើរធ្លាក់ ផ្លូវចាស់ទៀតទៅបានហើយ ។

- បាទ ពូ!

ព្រលប់នោះ កិត្យាមិនបាននិយាយប្រស្រ័យអ្វីជាមួយមាលានី ទេ ព្រោះគេអាល័យតែជជែកលេងជាមួយពូនឯទៅ ក៏យប់ជ្រៅ ល្មម ។ គេក៏សំពះលាចាស់ៗត្រឡប់ទៅសំរាកវិញ ដើម្បីធ្វើការងារ នៅថ្ងៃស្អែក ។

ព្រឹកព្រហាមឡើង...

មាលានីរៀបចំខ្លួនហើយក៏យួរបាយស្រោក់ចេញទៅមាត់ផ្លូវ រង់ ចាំ កិត្យាដើរមកដល់ នឹងអាលបានដើរមានគ្នាទៅរោងចក្រ ស្រាប់ តែ...

- ឥឡូវនេះ គេវាយឬកដល់ហើយ តាំងពីមានអង្គរក្សសង្ហាៗ តាមយាម ព្រឹកល្ងាចៗមក ។ សូម្បីតែមនុស្សស្គាល់គ្នា ក៏គេឆ្មើង ឆ្មៃ លែងនិយាយស្តីរាប់អានគ្នា អស់រលីង ។

ឮសំដីនេះ មាលានីក៏ងាកមើល ឃើញបុរសម្នាក់អង្គុយលើ កែបម៉ូតូ មុខងើយទៅលើមេឃ តែភ្នែកលួចដៀងកន្ទុយដាក់ មាលានី ។ គ្រាន់តែឃើញដូច្នោះ នារីក៏ស្រដីឡើង ថា ៖

- នែ៎! ស៊ុនហេង! ចង់ដៀមដាមអោយនរណាគេហ្នឹង ?

CHANBOKEO.COM

ស៊ុនហេងងាកមុខមករកនាង ហើយធ្វើភ្ញាក់ ៖

- អូហ៍! មកពីណាហ្នឹង ? នីលួចស្តាប់ខ្ញុំនិយាយរកមេឃហ្មែស ?
- មិនបានលួចស្តាប់ទេ តាមពិត មានគេចាក់មេក្រូថ្លង់ពេក ទើប ភ្ញាក់ផ្អើលនោះអី ។

ថាហើយ មាលានីក៏ដើរចេញទៅ ស្រាប់តែបុរសនោះ ចុះពី លើ កែបម៉ូតូ ស្រវាចាប់ដៃមាលានី ៖

- ឈប់សិនមើល៍ នី! បងនិយាយលេងតើហ៍ ។ ការពិត យើង នៅផ្ទះជាប់គ្នា គួរណាស់តែមានការជិតដិតនឹងគ្នាជានរណាៗទាំង អស់...! ប៉ុន្តែ ហេតុអ្វី នីធ្វើកិរិយាហាក់ដូចជាបងនេះ ជាមនុស្ស ចម្លែកចំពោះនីម្ល៉េះ ?

មាលានីបេះដៃស៊ុនហេងចេញពីកំភួនដៃនាង ហើយគេចថយ ក្រោយពីរបីជំហាន ទើបស្រដីថា ៖

- ស៊ុនហេងនឹងហើយតើហ៍ ថាអ៊ីហួយមិនចូលចិត្តអោយស៊ុនហេង មកនិយាយស្តីទាក់ទងអ្វីជាមួយខ្ញុំទេ ។
- នោះព្រោះតែគាត់អន់ចិត្ត ដែលកាលមួយនោះ គាត់ចូលស្តីអូននី អោយបង ហើយអូនរត់គេចទៅកម្ពុជាក្រោមបាត់ ធ្វើអោយគាត់ អាមាសមុខញាតិនោះអី ។
- ខ្ញុំមិនបានរត់គេចទេ គឺខ្ញុំទៅលេងស្រុក ហើយចង់ទៅរៀនផង
- តែឥឡូវមាលានីឈប់រៀនហើយតើហ៍ យើងអាចនិយាយគ្នាម្តង ទៀតបានតើហ៍ ។
- តែខ្ញុំមិនទាន់ត្រៀមខ្លួនទទួលសំដីនរណាទេ ស៊ុនហេង ។ ម្យ៉ាង ទៀត គ្រួសាររបស់ខ្ញុំក្រីក្រណាស់ មិនសមនឹងទទួលពាក្យកូនថៅ ថៅកែណាឡើយ ។
- តែអាម៉ាខ្ញុំ ពេញចិត្តអូននី ហើយបងក៏ពេញចិត្តអូនដែរ ទើប...
- កុំនិយាយតាមផ្លូវអញ្ចឹងអី ស៊ុនហេង... មិនពិរោះស្តាប់ ហើយ ក៏មិនសមរម្យទៀតផង ។ ពេលនេះ ខ្ញុំដល់ម៉ោងទៅធ្វើការហើយ សូមលាសិនហើយណា៎!

ថាហើយមាលានីក៏គេចខ្លួនរឹងទៅ ដោយមិនរង់ចាំអោយកិត្យា មកទទួលនាងទេ ព្រោះនាងមិនមានអារម្មណ៍ល្អនឹងទទួលសន្ទនា ជាមួយស៊ុនហេង ។ ការពិត បុរសម្នាក់នេះបានតាមនាងច្រើនឆ្នាំ ហើយ ។ កាលពីលើកមុន គេធ្លាប់អោយអ៊ីហួយជាម្តាយមកស៊ើប សួរឪពុកម្តាយនាងម្តងហើយ ។ តែលុះមាលានីគេចមិនព្រមទទួល ពាក្យរបស់គេ អ៊ីហួយក៏បានទៅដណ្តឹងកូនចិនម្នាក់ផ្សេងអោយ

CHIANBOKEO.COM

ស៊ុនហេង ។ សំណាងមិនល្អ គេរៀបការមិនបានពីរខែផង ក៏លែង លះគ្នាទៅវិញ ដោយសារតែក្រុមគ្រួសារទាំងសងខាងមានជម្លោះ រឿងរកស៊ីកេងប្រវញ្ច័គ្នាពេក ណាមួយដោយសារប្រពន្ធក្មេងនោះ មិនស្រឡាញ់នាយស៊ុនហេងផង ព្រោះត្រូវចាស់ៗបង្ខំអោយនាងរៀបការ ។

ក្រោយពីបែកបាក់ប្រពន្ធមក ស៊ុនហេងនៅតែតាមមាលានី យ៉ាងស្អិត ហើយតែងតែលបតាមដាននាងសឹងគ្រប់ជំហានក្នុងជីវិត សូម្បីតែរឿងដែលនាងជិះម៉ូតូដើរលេងជាមួយតារា ក៏គេបានដឹង ទាំងអស់ដែរ ។ ថែដន្យមាលានីមិនមាននិស្ស័យនឹងបុរសចិនម្នាក់ នេះទេ ។ បេះដូងរបស់នាងដែលធ្លាប់នឹកសង្ឃឹមថានឹងប្រគល់ ជូននាយបែនពេលរៀបមង្គលការ ក៏ប្រែក្លាយជាបេះដូងកកឈាម ព្រោះនាយបែនបានរៀបការនាងសាឯមចោលនាងទៅ ។ ពេល នេះ មាលានីហាក់ដូចជាបានស្គាល់មេរៀនជីវិត ហើយមានស្មារតី ភ្លឺថ្លាជាងមុន ម្ល៉ោះហើយក៏ប្រយ័ត្នប្រយែងខ្លួនជាងមុនដែរ មិនសូវ ចង់ចងចិត្ត ចងបេះដូងនឹងបុរសណាទេ ព្រោះខ្លាចត្រូវកកឈាម ដូចកាលលើកមុនទៀត ។

នៅពេលសំរាក សំរាប់ទទួលទានអាហារថ្ងៃត្រង់...

មាលានីឈ្ងោកមុខបរិភោគស្ងៀមស្ងាត់តែម្នាក់ឯង ព្រោះអីថ្ងៃ នេះ សុខុមមិត្តរបស់នាងបានសុំឈប់ទៅធ្វើបុណ្យឈាបនកិច្ចរបស់ សាច់ញាតិម្នាក់ ។

- នី! សុំញ៉ាំជាមួយផង បានទេ?

មាលានីងើបមុខឡើងឃើញកិត្យាដើរមកដល់ ដាក់ខ្លួនអង្គុយ ក្បែរមាណវី ហើយក៏ស្រាយអាហារកញ្ចប់ហុចអោយនាង ៖

- នេះ សាច់ជ្រូកប្រឡាក់ចៀន បងធ្វើយកមកផ្ញើនី!

នរៈស្រដីទៅរកមាលានីទាំងទឹកមុខញញឹម ។

- អរគុណ បងកិត្យា!

មាលានីទទួលយកដោយមិនប្រកែក ។

- សូមទោស ព្រឹកមិញ បងដើរមកទទួលនីយឺតបន្តិច ព្រោះ អាល័យចង់ចៀនសាច់ផ្ញើសំរាប់នីញ៉ាំបាយថ្ងៃត្រង់ ។

CHANBOKEO.COM

កិត្យាស្រដីប្រាប់នាង ។ មាលានីងើបមុខឡើង នឹករំភើបចិត្ត
ដែលមាណពផ្ដល់ចំណាប់អារម្មណ៍ដល់នាង ។ ថ្វីបើសាច់ជ្រូកអាំង
នោះគ្រាន់តែជាសាច់បន្ទះមួយចំណិត ប៉ុន្ដែទឹកចិត្តដែលគេនឹកមក ដល់នាង
ហើយខំក្រោកពីព្រឹកទៅទិញសាច់ជ្រូកមកប្រឡាក់ចៀន
ផ្ញើនារីនោះ ពិតជាមានតម្លៃចំពោះនាងណាស់ ។
- ឆ្ងាញ់ណាស់ បងកិត្យា! ថ្ងៃក្រោយ ផ្ញើផ្ញើនីទៀតណា៎!
មាណពយើងញញឹមពព្រាយកាលបើនឹងថា នារីយើងមិនមាន
ការទើសទាល់ចង្អៀតចិត្តចំពោះរូបគេ ។
- មានអី! ប៉ុន្តែ បងអាចធ្វើបានតែអាហារងាយៗទេ ព្រោះទើប តែរៀនដាំស្លថ្មីៗនេះឯង ។
- អូហ៏ ហេតុអ្វីទៅ! បងឈប់នៅជាមួយប៉ាម៉ាក់ហើយហ្ន៎ស ?
- មិនមែនទេ! បងនៅជាមួយគាត់ដដែល តែបងខំរៀនធ្វើម្ហូប ខ្លួនឯង
ព្រោះចង់ធ្វើផ្ញើគេម្នាក់នោះ កុំអោយគេពិបាកក្រោកពីព្រឹក ធ្វើអាហារយកមកធ្វើការ...
បងចង់ថ្នមគេ មិនចង់អោយគេនឿយ ហត់មិនបានសំរាក ខ្លាចខូចសោភ័ណអស់ ។
មាលានីស្ដាប់យល់ភ្លាម ក៏នឹកអៀនក្នុងចិត្តតិចៗ តែក៏ហាក់ដូច ជារីករាយរំភើបចិត្តណាស់ដែរ
ដែលបុរសម្នាក់នេះយកចិត្តយក ថ្លើម ។ តាមការពិត
ក្នុងចំណោមបុរសបីនាក់ដែលទាមទារចំណាប់ អារម្មណ៍ពីនាង ដូចជាស៊ុនហេង តារា និងកិត្យា
ម្នាក់ៗមានគុណ សម្បត្តិប្លែកៗគ្នា ហើយមានគុណវិបត្តិក៏ប្លែកគ្នាដែរ ។ កាលពីបួន ឆ្នាំមុន
ពេលនាងទើបស្គាល់ស៊ុនហេងដំបូង នាងគិតថាគេសង្ហាគួរ អោយចាប់អារម្មណ៍ ។ ក្រោយមក
នាងបាននឹងថា ក្រុមគ្រួសារ របស់អ៊ីហួយជាអ្នករកស៊ីគៃបំបាត់គេឯងបន្តិច មាលានីក៏រសាយក្ដី
ស្រម័យក្នុងចិត្តទៅវិញ ។ ចំណែកតារាវិញ ក៏សុភាពទន់ភ្លន់ ប៉ុន្តែ គេលាក់ប្រវត្តិរបស់គេណាស់
មិនដែលអោយមាលានីស្គាល់ក្រុម គ្រួសាររបស់គេម្ដងណាទេ ។ គេតែងតែនាំនាងពង្វាង
និយាយពី នេះពីនោះរហូត ពេលណាដែលនាងសាកសួរពីក្រុមគ្រួសាររបស់ គេ ។
ចំណែកកិត្យាវិញ មានប្រវត្តិមិនសូវស្អាតសោះ ថ្វីបើពេល នេះ គេប្រឹងដើរផ្លូវសុក្រិតវិញក៏ដោយ
ក៏នៅមិនទាន់ អាចទុក ចិត្តបានដែរថា តើគេនឹងកែប្រែរហូតឬយ៉ាងណា ។ គេជាមនុស្ស
ឆាប់ខឹងណាស់ ប៉ុន្តែ ក៏ឆាប់រសាយទៅវិញ ហើយមិនសូវចេះគុំគួន ក្នុងចិត្តយូរទេ ។
គេធ្លាប់ខឹងងរ៉ក់ដាក់មាលានីនិងសុខុមជាញយ ដង ព្រោះអ្នកទាំងពីរចូលចិត្តចំអន់គេខ្លាំងពេក ។

CHANBOKEO.COM

សំណាងល្អ គេ ជាមនុស្សត្រង់ សួរពេលណា ប្រាប់ពេលហ្នឹងមិនសូញសាញ មិន សូវចេះលាក់អារម្មណ៍ទេ ។

ឃើញមាលានីកំពុងរៀបចានស្រាក់ទុក កិត្យាក៏សួរថា ៖

- នី! អោយបងសុំសួរអ្វីបន្តិចបានទេ?
- ចាស! សួរមកចុះ!
- អញ្ចឹងនីសន្យាសិនមក ថាមិនខឹងនឹងបងទេ បើសិនបងសួរ...
- ហេតុអ្វីចាំខឹងផង?
- ព្រោះបងចង់សួររឿងផ្ទាល់ខ្លួន...
- រឿងផ្ទាល់ខ្លួន?

មាលានីបើកភ្នែកមូលក្រឡង់ ហាក់ចង់ដឹងថា តើកិត្យាចង់សួរ នាងពីអ្វី ។ បេះដូងរបស់នាងក៏រណ្តំភិបៗឡើង... បន្តិចមក នាង ក៏ញញឹម ហើយពោលបន្តថា ៖

- សួរសិនមក... ចាំនីគិត ថាគួរខឹងឬមិនគួរខឹង ។
- គឺ... បងចង់សួរថា... តើបុរសដែលបរម៉ូតូឌុបអូនមកផ្ទះ កាលពី ម្សិលមិញនោះជានរណាដែរ? បងឃើញគេឌុបអូនរាល់ដំណាច់ សប្តាហ៍... គេជាសង្សាររបស់នីមែនទេ?

មាលានីបើកភ្នែករិតតែធំជាងមុន ៖

- ហើយ... ហេតុអ្វីក៏បងចង់ដឹងផង?
- គឺ... គឺ...

កិត្យានិយាយបន្តទៅទៀតលែងរួច ក៏ឈ្ងោកមុខនៅស្ងៀម ។

- ចុះបើគេជាសង្សាររបស់នីមែន បងកិត្យាយល់យ៉ាងណាដែរ?

កិត្យាភ្ញាក់ក្រញាង កាលបើឮចម្លើយដូច្នេះភ្លាម ៖

- គឺ... បងគិតថា... គេជាបុរសសង្ហា ហើយសក្តិសមនឹងនីណាស់! ព្រោះអ្នកទាំងពីរមានរូបសម្បត្តិប្រដំប្រសងនឹងគ្នា ។
- នេះបងគិតថា យើងសក្តិសមគ្នាដោយសារតែរូបសម្បត្តិតែម្យ៉ាង ទេ មែនទេ?
- បងស្គាល់ត្រឹមតែរូបសង្ហារបស់គេ មិនស្គាល់គុណសម្បត្តិអ្វីផ្សេង ទៀតទេ... ដូច្នេះ បងមិនអាចឲ្យយោបល់លើសពីហ្នឹងបានឡើយ ។
- ហើយចុះបងវិញនោះ មានសង្សារហើយឬនៅ?

CHANBOKEO.COM

កិត្យាឈ្ងោកមុខនៅស្ងៀមមួយស្របក់ ក៏ស្រដីថា ៖
- មនុស្សដូចបង រូបក៏មិនបាន ប្រវិត្តក៏មិនល្អ ជីវភាពក៏តានតឹង តើនារីណាទៅគេមកសម្លឹងបងនោះ ?
- បើគេមិនសម្លឹងបង តើបងមានដែលសម្លឹងគេវិញទេ ?
- គឺ... គឺ... មិនហ៊ានសម្លឹងគេទេ... បានត្រឹមតែលួចគិតម្នាក់ឯង...
- មានន័យថា បងមានចាប់អារម្មណ៍នរណាម្នាក់ហើយ មែនទេ ?

កិត្យានៅស្ងៀម... រកនឹកចម្លើយឆ្លើយមិនទាន់ផង កណ្ដឹងក៏ រោទិ៍ឡើង ជាសញ្ញាដល់ម៉ោងចូលធ្វើការវិញ ។ អ្នកទាំងពីរក៏ត្រូវ បំបែកជួរគ្នាភ្លាម ។
- ល្ងាចនេះ កុំទៅផ្ទះមុនបងណា៎! ចាំបងផង បងចង់ដើរត្រឡប់ ទៅផ្ទះវិញជាមួយនី!
- ចា៎ស!

មាលានីងក់ក្បាល ។ កិត្យាញញឹមដាក់នាង ហើយក៏ដើរត្រឡប់ ទៅកន្លែងធ្វើការរបស់ខ្លួនវិញ ។

ព្រលប់ចេញពីធ្វើការ មាលានីក៏ប្រទះឃើញកិត្យាមកឈរចាំ នាងនៅមាត់ទ្វាររោងចក្រទាំងទឹកមុខញញឹម ។
- ទៀងទាត់ម៉ោងម្ល៉េះ បងកិត្យា ? (មាលានីសួរ)
- ព្រោះព្រឹកមិញ បងមកយឺត មិនទាន់ដំណើររបស់នី ទើបមិន ចង់អោយខកល្ងាចនេះទៀត ។
- មិនមែនជាកំហុសបងទេ ការពិត មកពីនីចេញពីផ្ទះមកឆាប់ជាង ធម្មតាទេតើហ៍!
- ហេតុអ្វីទៅ ? នីប្រាថ្នាគេចមុខបងមែនទេ ?
- នរណាថា ? នីគេចអ្នកផ្សេងទៀតទេ!
- អូហ៍! មានអ្នកផ្សេងអោយនីដើរគេចផងហ្ន៎ស ?
- សួរច្រើនម្ល៉េះ បងកិត្យា ? (មាលីនីដូរប្រយោគបន្លប់ មិនអោយ កិត្យាដឹងចិត្ត) ម៉ោះ! ទៅផ្ទះ!

ថាហើយ នាងក៏ស្រវាកាន់ដៃនរៈ អូសចេញទៅយ៉ាងលឿន ។ ភ្លាមនោះ កិត្យាញញឹមឡើងដាក់នាងយ៉ាងត្រកាល ។
- ល្អចញញឹមអីហ្នឹង បងកិត្យា ?

មាណពមិនឆ្លើយទេ គិតតែពីដើរញញឹមស្ងៀមៗ ។ រំពេចនោះ មាលានីចាប់ភ្លឹកថា ខ្លួននាងកំពុងកាន់ដៃកិត្យា ក៏នឹកខ្មាស់ក្នុងចិត្ត ក្ដៅមុខភាយតែម្ដង

CHANBOKEO.COM

ហើយក៏រលាស់ដៃចេញយ៉ាងរហ័ស ។ ថៃដន្យ កិត្យាមិនព្រមព្រលែងដៃនាងចេញទេ ។ គេបែរជាក្ដាប់ដៃនាងដើរ ធ្វើមិនដឹង ។ តាមផ្លូវ អ្នកទាំងពីរលួចញញឹមអៀនៗដាក់គ្នា រហូតដល់ផ្ទះពូនង....

oooooooooooooooooo
oooo

CHANBOKEO . COM

# វគ្គទី១១
## កំសួលប្រច័ណ្ឌ

ខណ្ឌឫស្សីកែវ ភ្នំពេញ...

ឆ្នាំ២០០៧...

ស្ត្រីម្នាក់ជិះម៉ូតូឌុបមកដល់មុខផ្ទះថ្មីរបស់ពូនង ។

- ជំរាបសួរពូ !
- អូហ៍! នាងខុមតើហ៍! ហើយម៉េចក៏មករកពួកយើងឃើញ ?
- គឺខ្ញុំបានជួបក្មេងៗកូនពូតាមផ្លូវអំបាញមិញ ប្រាប់ថាពូផ្លាស់មក នៅផ្ទះថ្មីនេះកាលពីម្សិលមិញ ។
- មែនហើយ! គ្រួសាររបស់យើងបានទទួលការកៀបសង្កត់ពី ម្ចាស់ផ្ទះឲ្យផ្លាស់ចេញប្រញិបប្រញាប់ ទើបយើងចេញមកដោយ មិនបានប្រាប់ញាតិណាម្នាក់ទេ ។

រំពេចនោះ មាលានីដើរចេញពីក្នុងផ្ទះមកវិញ ក្នុងសម្លៀកជា កម្មកររោងចក្រ ៖

- បងខុម !
- អូហ៍ អូននី! ដល់ថ្ងៃត្រឡប់ចូលធ្វើការវិញហើយណ៎!
- គឺខ្ញុំសុំច្បាស់ឈប់ដើម្បីរៀបការបានតែបួនថ្ងៃទេបង! ថ្ងៃនេះ ដល់ពេលចូលវេនវិញហើយ ។
- ហើយចុះកិត្យានោះ ?
- គាត់មិនស្រួលខ្លួន ប្រហែលជាត្រូវសំរាកមួយថ្ងៃពីរហើយ ។
- ស្លាប់ហើយ! បើឈប់ហួសថ្ងៃ វីវរគេបណ្ដេញចោលរហូតទៅ ?

CHANBOKEO . COM

- គឺ... គាត់មិនស្រួលមែនណា៎បង! ខ្ញុំមិនហ៊ានបណ្តោយអោយ គាត់ទៅធ្វើការទេ ក្រែងលាប់ជំងឺឈឺជាងមុន ។

សុខុមក៏ដើរចូលទៅក្នុងផ្ទះមើលកិត្យា ។

នៅក្នុងផ្ទះ... សុខុមឃើញកិត្យាដើបអង្គុយលើកន្ទេល មាន ស្នាមរបួសជាំពេញខ្លួន ។

- ណ្ហើយចុះ កិត្យាអើយ! នៅផ្ទះមើលខ្លួនសិនទៅ កុំទាន់ទៅធ្វើ ការអី ។ ចាំខ្ញុំមើលប្រពន្ធអោយចុះណា៎ សន្យាថាមិនអោយមាន ខ្លែងឆាបបាត់ទេ ។ ពេលនេះយើងទៅធ្វើការសិនហើយ!

កិត្យាងក់ក្បាល ហើយបែរសម្លឹងមុខមាលានី ក្នុងក្រសែភ្នែក ហាក់ដូចជាមិនទុកចិត្តនាងអ្វីបន្តិច ។ ឃើញកិរិយានោះ មាលានី ក៏ឈ្ងោកខ្សិបដាក់ត្រចៀកបុរសតិចៗ ទំនងចង់ផ្តល់នូវក្តីកក់ក្តៅ ដល់បេះដូងរបស់គេដែលកំពុងរងា ព្រោះភាពសង្ស័យ ៖

- នឹកអូនផងណា៎ ប្តីសម្លាញ់! នីសូមផ្ញើអារម្មណ៍និងបេះដូងរបស់ នីជាមួយបងផង! ល្ងាចនេះយើងជួបគ្នាវិញហើយ!

ថាហើយ នាងក៏ញញឹមដាក់កិត្យាហើយក៏ដើរចេញទៅ ។ ភ្លាម នោះ មាណពយើងហាក់ដូចជារំភើបចិត្តយ៉ាងណាមិនដឹង ដែលគេ បានឮវាចាដែលភរិយាខ្សិបយ៉ាងទន់ភ្លន់ដាក់ត្រចៀក ។ គេក៏មើល តាមនាងមិនដាក់ភ្នែករហូតបាត់ស្រមោលទៅ ។

ពេញមួយថ្ងៃនោះ កិត្យាមានអារម្មណ៍ថា ពេលវេលាដើរយឺត អើយសែនយឺត បន់អោយតែមាលានីឆាប់វិលត្រឡប់មកដល់ផ្ទះ វិញ ។ គេមិនយល់សោះថា ថ្វីបើគេមានចិត្តល្អក់កករចំពោះនារី ដល់ម្លឹងទៅហើយ គេនៅតែនឹកនាង ទ្រាំមិនបានសោះ ។ ការពិត គេនៅតែមានចិត្តធុញថប់ចំពោះនារីមិនទាន់បាត់នៅឡើយទេ អំពី រឿងដែលថា តើមាលានីជានារីបរិសុទ្ធឬក៏យ៉ាងណា ។ គេពិតជា សង្ស័យ... សង្ស័យនាងណាស់... មិនជ្រះស្រឡះក្នុងចិត្ត ប៉ុន្តែ គេ ក៏ស្រឡាញ់នាង... ស្រឡាញ់រកអ្វីប្រៀបស្មើមិនបានឡើយ ។

ពេលនេះ ព្រលប់ហើយ...

កិត្យាខំដើបដើរចេញទៅក្រៅ ។

- ទៅណា៎ហ្នឹងកូន ? បើមិនទាន់ស្រួលខ្លួន កុំទាន់អាលប្រញាប់ ចេញទៅក្រៅអី ។

CHANBOKEO.COM

មីងមៀនស្រដីឃាត់កូនប្រសារដោយក្ដីបារម្ភ ។

- គឺខ្ញុំចង់ចេញទៅយកខ្យល់អាកាសបន្តិច បាទ!

- ទៅចាំផ្លូវប្រពន្ធ មែនទេ ? បន្តិចទៀត គេមកវិញហើយ ។

ឮមីងមៀនមានប្រសាសន៍ដូច្នេះ កិត្យានឹករអៀសខ្លួនភ្លាម ក៏ធ្វើពើជាដើរត្រឡប់ទៅរកសំរាកវិញ ប៉ុន្តែក្នុងចិត្តរបស់គេចង់ចេញ ទៅក្រៅនោះដល់កំរិតហើយ ។

មិនបានដប់នាទីផង មាលានីក៏ត្រឡប់មកពីធ្វើការវិញ ។ កិត្យាក៏ធ្វើពុតជាសម្ងំហាក់មិនបានចាប់ភ្លឹកអំពីប្រពន្ធទេ ប៉ុន្តែក្នុងចិត្ត វិញនោះ ត្រេកអររំភើបក្រៃណាដែលនាងមកដល់ឆាប់ដូចបំណង របស់គេបែបនេះ ។

ស្នូរសិរិបជើងរបស់នារីក៏បានមកដល់ក្នុងរង្វង់ បន្ទប់របស់គេទាំងពីរ ដែលចងបាំងរំលែកពីក្រុមគ្រួសារ ដោយ វាំងននពណ៌ខៀវចាស់ពីរផ្ទាំង ។

រំពេចនោះ កិត្យាមានអារម្មណ៍ថា មានដៃមួយមកស្ទាបថ្ងាស ហើយស្ទាបខ្លួនរបស់នាយ ។ បន្តិចមក កិត្យាក៏ទទួលអារម្មណ៍ថា មានច្រមុះមួយមកអង្អែលថើៗលើសៀតផ្ការរបស់នាយ នាំយកក្លិន កាយដ៏ក្រអូបប្រហើរមកប្រឡ្លងនឹងនាសារបស់មាណពយើង ធ្វើអោយគេនឹករំភើបស្រើបស្រាលនៅក្នុងចិត្តយ៉ាងណាមិនដឹង ក៏បើក ភ្នែកឡើង លាតដៃស្រវាអោបម្ចាស់នាសានោះយ៉ាងណែនពេញ ទំហឹង ៖

- អូននី!

កិត្យាបើកភ្នែកឡើង ឃើញមាលានីភ្ញាក់ក្រញាង ប្រឹងស្ទុះដើប ឡើងយ៉ាងរហ័ស ៖

- ចង់ដើបទៅណាហ្នឹង នី ?

- ពុទ្ធោ បងកិត្យា! អំបាញ់មិញ បងធ្វើពើជាគេងលក់ មែនទេ ?

- បើមិនពើជាគេងលក់ ធ្វើម៉េចនឹងចាប់ចោរបាន ?

- ចោរឯណា មិនឃើញ ?

- ចោរដែលលួចថើបបងអំបាញ់មិញនោះអី អូនមានឃើញទេ ?

- មិនបានឃើញទេ,,, បងកិត្យាឃើញតែម្នាក់ឯងទៅ ។

CHANBOKEO.COM

មាលានីនឹកអៀនប្ដីណាស់ដែលកិត្យាដេញទាន់ជាន់កែង ក៏ងើប បែរមុខទៅម្ខាង ធ្វើពើជារកខោអាវមកផ្លាស់ ដើម្បីបន្លប់អារម្មណ៍ អៀនខ្មាស់ ។
កិត្យាតាមសម្លឹងមើលនាងដោយក្រសែភ្នែកប្រកប ដោយដួងចិត្តស្នេហា ។

ពេលប់នោះ មាលានីបានទទួលរៀបចំអាហារអោយឪពុកម្ដាយ និងប្អូនៗរបស់នាងហើយ ក៏វិលបែរមកបំរើកិត្យាក្នុងបន្ទប់វិញ ។ ទើបតែលើកនេះទេ
ដែលគេទាំងពីរហាក់ដូចជាថ្នាក់ថ្នមគ្នាជាងសព្វ ដង ។ គេញញឹមដាក់គ្នា...
គេបញ្ចុកអាហារអោយគ្នាទៅវិញទៅ មក...
គេប្រើក្រសែភ្នែកស្រទន់ផ្អែមល្ហែមសាសងគ្នាជំនួសពាក្យ សំដីសព្វយ៉ាង ។ កិត្យាមានអារម្មណ៍ថា គេមានសេចក្ដីសុខណាស់.. អារម្មណ៍ល្អក់កករដោយភាពសង្ស័យរបស់គេចំពោះមាលានីក៏ហាក់ ដូចជាថមថយអនុភាពទៅវិញឯងៗ ព្រោះគេកំពុងទទួលសេចក្ដី
សុខដោយការថ្នាក់ថ្នមរបស់ប្រពន្ធជាលើកដំបូង ។ មែនហើយ! គេពេញចិត្តណាស់
បើសិនមាលានីបញ្ចេញភាពទន់ភ្លន់ដាក់រូបគេ ។ កាលដើមឡើយ
គេបានទន់ភ្លន់យកចិត្តនាងសព្វយ៉ាង ប៉ុន្តែនារីមិន
ដែលសំដែងកិរិយាអើពើឬចាប់អារម្មណ៍អីប៉ុន្មានអោយគេរំភើបចិត្ត ទេ ឃើញតែធ្វើហ៊ឺៗ ញឹមៗ មិនតបមិនស្ដី ថែមទាំងចូលចិត្ត និយាយពង្វាងសាច់រឿងទៀតផង ។

CHANBOKEO.COM

នៅលើខ្នើយមង្គលមួយពីរនាក់...

- អូននី!
- ចា៎ស!
- បើសិនបងសួរអូនរឿងមួយ... តើអូនឆ្លើយប្រាប់បងដោយត្រង់ បានទេហ៎?
- បងចង់សួររឿងអ្វីទៅ ?
- គឺ រឿងផ្ទាល់ខ្លួនពីអតីតកាលខ្លះៗ...
- រឿងរបស់នី មិនមានអ្វីគួរអោយរំភើបចិត្តនឹងស្ដាប់ទេ បង!
- ប៉ុន្តែ បងចង់ស្ដាប់ណាស់... បងចង់ស្គាល់អូនណា៎ មាលានី!
- ចុះពេលនេះ បងស្គាល់អូនហើយតើហ៎... ស្គាល់លើសនរណា ទាំងអស់ក្នុងជីវិតរបស់នី ។
- ប៉ុន្តែ បងស្គាល់តែបច្ចុប្បន្នរបស់អូន... ចំណែករឿងអតីតកាល
បងមិនទាន់ស្គាល់អូនទេ ។

- តើបានប្រយោជន៍អ្វីដែលនីត្រូវរិលទៅអតីតកាលសើរើរឿងទាំងឡាយនោះ អោយស្រក់ទឹកភ្នែកសាជាថ្មី ?

- មានន័យថា អូនធ្លាប់ទទួលរងការឈឺចាប់ក្នុងចិត្ត ដោយសារ បុរសណាពីមុនមក មែនទេ ? តើគេបានធ្វើអ្វីទៅលើអូនខ្លះ ?

កិត្យាសួរបែបនោះ ចំនងចង់ដឹងអំពីដំណើរជីវិតស្នេហារបស់មាលានីមុនពេលរៀបការជាមួយគេ ។ ថែដន្យ មាលានីបែរជាមិន ឆ្លើយ ហើយលូកដៃទៅបិទកុងតាក់ភ្លើង រួចផ្ដេកកេសាលើខ្នើយ ផ្ទែកនឹងស្មារបស់កិត្យា បន្ទាប់មកក៏ស្រដីថា ៖

- ចាំស្អែក ចាំយើងនិយាយគ្នាទៀត បានទេបង ? ពេលនេះ អូនអស់កម្លាំងហើយងងុយគេងណាស់ ។

រួចហើយ នាងក៏យកនាសាផ្ទិតលើថ្ពាល់ស្វាមី រួចហើយក៏បិទ ភ្នែកសម្ងំគេង ។ កិរិយានេះមិនបានធ្វើអោយកិត្យារំភើបចិត្តទេ ផ្ទុយទៅវិញ ភាពរមនានិងក្ដីរំភើបដែលគេមានតាំងពីព្រលប់ប៉ុន្មានចំពោះនារីបែរជាចមថយស្រកស្រុតអស់រលីង ពីបេះដូងរបស់គេ សាជាថ្មីម្ដងទៀតហើយ ភ្លាមនោះ គេគិតក្នុងចិត្តថា ៖

- ហេតុអ្វី មាលានីលាក់អតីតកាលរបស់នាងចំពោះយើងជាប្ដីរបស់ នាងដូច្នេះ ? តើនាងបានប្រព្រឹត្តអ្វីជ្រុលជ្រួស កាលពីមុនមកទេ មែនទេដឹង ?

រាត្រីនោះ មាលានីគេងលង់លក់ក្បែរស្វាមីយ៉ាងស្ងៀមស្ងាត់ ព្រោះធ្វើការអស់កម្លាំង ។ ប្លែកអីតែកិត្យាទេ ដែលគេងពិចារណា ពេញមួយយប់ទើសភ្លឺ... នឹកថ្លឹងថ្លែងអំពីសេចក្ដីស្នេហារបស់គេ ចំពោះមាលានី និងការដែលគេរៀបការនឹងនាងដោយមិនបាន ទទួលឈាមព្រហ្មចារីយ៍ពីនារីវិញជាចំណង ចំពោះទឹកចិត្តប្រតិពទ្ធ័ដ៏ធំធេងរបស់គេចំពោះនាង ។ ពិតណាស់ ! គេនៅតែមានចិត្តល្អក់ កករ ថ្វីបើគេនៅតែស្រឡាញ់នាងខ្លាំងយ៉ាងណាក៏ដោយ ។ បេះដូង របស់គេ បានប្រឡាក់ទៅដោយពណ៌សនិងពណ៌ខ្មៅលាយឡំគ្នា ធ្វើអោយគេនឹកឈឺផ្សាក្នុងឱរាយ៉ាងណាមិនដឹង... ពិបាកនឹងថ្លាថ្លែង ពណ៌នា ។ ប៉ុន្តែ គេក៏មិនដឹងថានឹងដោះស្រាយអារម្មណ៍ជំពាក់ ជំពាន់នេះយ៉ាងណាដែរដើម្បីអោយបានធូរស្រាល កាលបើមាលានី

CHANBOKEO.COM

មិនព្រមហើយមាត់ស្រដីប្រាប់គេ អំពីអតីតកាលរបស់នាង ដើម្បី
អោយគេបានជ្រះស្រឡះអារម្មណ៍ ។

ពីរបីថ្ងៃក្រោយមក...

ស្នាមរបួសលើខ្លួនកិត្យាដ៏ធ្ងន់ធ្ងរ បានរំខានមិនអោយនាយយើង
ចេញធ្វើការបានឆាប់រហ័សទេ ។ គេត្រូវគេងផ្ទះរហូតពេញមួយ អាទិត្យ
ហើយពេញមួយអាទិត្យនោះ មាលានីក៏តែងតែចេញពី ធ្វើការព្រលប់ជាងធម្មតាដែរ ។

- ហេតុអ្វីក៏អូនចេញពីធ្វើការយប់ៗម្លេះ អូននី ?

កិត្យាសួរ ។

- គឺរោងចក្រមានកិច្ចការដែលត្រូវបញ្ជូនចេញក្រៅច្រើន ហើយ
តម្រូវអោយកម្មករធ្វើការបំពេញចំនួនដែលខ្វះខាត ទើបអូនត្រូវ
ធ្វើតាមការតម្រូវរបស់ចៅហ្វាយនាយ ។

- តែបងក៏អង្គុយចាំអូនផ្សាភ្អែកដែរណា៎ ព្រោះអូនក្រមកផ្ទះ ។

មាលានីក៏ញញឹមដាក់ស្វាមី ៖

- តែអូនក៏មកដល់ផ្ទះជួបបងរាល់ថ្ងៃ យ៉ាងឆាប់រហ័សដែរ មិនឲ្យ បងអង្គុយនឹកអូនយូរពេកទេ ។

កិត្យាសម្លឹងមុខភរិយា ទំនងស្ទង់ចិត្តរបស់នាង ហើយសួរថា៖

- តើពេលនេះ បាននរណាជូនអូនដើរទៅដើរមក ?
- គ្មានទេ បង! បានដើរជាមួយបងខុមតែថ្ងៃដំបូងដែលគាត់ចូល សួរសុខទុក្ខបងហ្នឹង!
- ស្លាប់ហើយ ដើរយប់ព្រលប់ ខ្លាចណាស់អូន! ម៉េចមិនហៅប្អូន អោយទៅជួយចាំផ្លូវ ?
- ដំបូងគិតថា អោយប្អូនទៅចាំផ្លូវដែរ ប៉ុន្តែពីរនាក់បានទៅជួយ
ចាំបងស្រីខ្ញុំនៅកន្លែងផ្សេងបាត់ទៅហើយ ម្ល៉េះហើយ គ្មានប្អូនណា
ធំល្មមអាចទៅចាំផ្លូវអូនបានទៀតទេ ព្រោះគេនៅតូចៗពេក ។
- អញ្ចឹង ស្អែកបងចូលធ្វើការវិញហើយ ដើម្បីអោយបានដើរកំដរ នឹងផង
បានធ្វើការយកប្រាក់ផង ។

ភ្លាមនោះ មាលានីធ្លាក់ទឹកមុខជ្រប់ គ្រវីក្បាល ៖

- គឺ... មិនបាច់ទេ បង!
- ហេតុអីទៅ... ?

CHANBOKEO.COM

- ព្រោះបងមិនអាចទៅធ្វើការបានទេ ។
- តែបងអាចដើរបានវិញហើយ មិនជាពិបាកប៉ុន្មានទេ...
- នីមិនមែនមានន័យអញ្ចឹងទេ! ការពិតនោះ គឺ...
- ការពិតនោះ យ៉ាងម៉េចទៅ អូននី ?
- ព្រោះ... នាយកោយរោងចក្របានរើសអ្នកថ្មីធ្វើការជំនួសបងទៅ ហើយ ។

កិត្យាធ្វើភ្នែកមូលក្រឡង់ដោយការភ្ញាក់ផ្អើល ៖

- មែនឬនី ?

មាលានីងក់ក្បាល ៖

- អញ្ចឹងហើយ ទើបអូនត្រូវធ្វើការច្រើនជាងមុន ។
- ហេតុអ្វីទៅ ?
- គឺ...ដើម្បីថ្លៃព្យាបាលអោយបងឆាប់ជា...

កិត្យាសម្លឹងមុខប្រពន្ធដោយទឹកមុខស្រពោន ៖

- នី! បងមិនគួរណានាំទុក្ខនាំកង្វល់ដល់អូនសោះ ។
- មិនអីទេបង! (មាលានីគ្រវីក្បាល) យើងជាប្ដីប្រពន្ធនឹងគ្នា... មិនខុសទាស់អីទេ ដែលត្រូវតែតស៊ូដើម្បីគ្នាទៅវិញទៅមកនោះ ។

មាលាវីញញឹមកម្លាចិត្តប្ដី ។ ឃើញស្នាមញញឹមរបស់នាងដែលប្រឹងបន្លប់នូវភាពអស់កម្លាំងរបស់នាង កិត្យាក៏យកដៃទៅអង្អែល ថ្ពាល់ភរិយាថ្នមៗ ៖

- បងនឹងជាសះស្បើយស្អែកៗនេះហើយ មិនអោយអូនហត់នឿយ យូរតទៅទៀតទេ ។

អ្នកទាំងពីរក៏ញញឹមដាក់គ្នាទៅវិញទៅមកសាជាថ្មី ដើម្បីផ្ដល់ កម្លាំងចិត្តគ្នាទៅវិញទៅមក ។

ស្អែកឡើង...

កិត្យាខំក្រោកដើរជូនប្រពន្ធទៅរោងចក្រ បានពាក់កណ្ដាលផ្លូវក៏ឈឺជង្គង់មិនអាចបន្តដំណើរបាន ក៏បណ្ដោយអោយនាងដើរទៅ តែម្នាក់ឯង ។ គេក៏ត្រឡប់មកផ្ទះវិញដោយចិត្តឃ្នាន់ខ្នាញ់ ណាមួយ នឹកចង់ទៅរកការធ្វើ តែមិនអាចធ្វើបាន ណាចង់ទៅរករឿងសង្ខៅ របស់នាយស៊ុនហេង ណាមួយសង្ស័យអំពីចំណងអតីតរបស់បុរសម្នាក់នេះជាមួយមាលានី...

យប់បន្តិច គេក៏ដើរចេញទៅក្រៅទាំងឈឺទាំងជាម្ដងទៀត...

CHANBOKEO.COM

- ទៅណាហ្នឹង កិត្យាកូន ?

ពូនងសួរ ។

- បាទពុក! ... ខ្ញុំទៅចាំផ្លូវអូននី ព្រោះមិនចង់អោយដើរម្នាក់ឯង ពេលយប់ព្រលប់ ។

- ម្តុំនេះ មានចរាចរអ៊ូអរណាស់! គ្មាននរណាអាចបង្កអសន្តិសុខ អ្វីដល់រូបនាងទេ ។

ប៉ុន្តែ កិត្យានៅតែមិនអស់ចិត្ត ក៏នៅតែដើរត្រឹកៗចេញទៅ...

និយាយពីមាលានីម្តង...

ការពិត នារីយើងកើតទុក្ខពីរបីថ្ងៃហើយ តាំងពីចៅហ្វាយនាយ មកប្រាប់ថា គេបញ្ឈប់កិត្យាពីការងារ ព្រោះនាយឈប់យូរពេក ។ គេក៏បានរើសកម្មករថ្មីមកធ្វើការជំនួសទៅ ។ នារីយើងមិនដែល ហ៊ាននិយាយប្រាប់កិត្យាទេ ខ្លាចគេល្អក់កករទឹកចិត្តរិតតែខ្លាំង ជា ពិសេស ពេលនេះ គេកំពុងតែដេកឈឺផង ។ ម្យ៉ាងទៀត នាងក៏ ធ្វើការបន្ថែមម៉ោង មិនមែនដើម្បីត្រឹមតែថ្លៃព្យាបាលនោះឡើយ ប៉ុន្តែ គឺដើម្បីពន្យារពេលវេលា មិនអោយកិត្យាសាកសួរនាងពេក អំពីរឿងរ៉ាវអតីតកាលរបស់នាង ព្រោះនាងមិនចង់សើរើយកមក លាតត្រដាងសាជាថ្មី ។ នាងបានទទួលការឈឺចាប់ពីបុរសៗ គ្រប់គ្រាន់ហើយ... នាងមិនចង់អោយការរំលឹករឿងដើម នាំការឈឺចាប់ ដល់បេះដូងនាងសាជាថ្មីទេ ។ ម្យ៉ាងទៀត នាងគិតថាការជជែកគ្នា អំពីរឿងអតិតកាលរបស់នាងជាការឥតប្រយោជន៍ ព្រោះវាគ្មានអ្វី ទាក់ទងនឹងកិត្យាផង ចាំបាច់អីទៅរៀបរាប់អោយនាយស្តាប់ នាំអោយតែគេប្រមាថតម្លៃនារីរបស់នាងទទេៗ ។

ថ្ងៃនេះ នាងមកធ្វើការដូចប្រក្រតី ប៉ុន្តែនាងមានប្រផ្នូលក្នុង ចិត្ត ចម្លែកយ៉ាងណាមិនដឹង ដែលឃើញអាកប្បកិរិយារបស់កិត្យា ហាក់ដូចជាហួងហែងរូបនាងខុសធម្មតា ជាពិសេសរឿងរ៉ាវរវាង នាងនិងនាយស៊ុនហេង ។ គេមិនទាន់រលត់ភាពហួងហែងនៅក្នុងចិត្តរបស់គេទេ ថ្វីបើនៅផ្ទៃមុខខាងក្រៅ គេមិនបានបង្ហាញថា គេនៅខឹងនឹងនារីយើងតទៅទៀតក៏ដោយ ព្រោះមាណពតែងតែដេញដោលអំពីរឿងអតីតកាលរបស់នាង មិនព្រមឈប់ឈរសោះ ។

ម៉ោងជាង៨យប់...

CHANBOKEO.COM

មាលានីដើរបែកផ្លូវពីសុខុម ដែលឡើងរ៉ឺម៉កម៉ូតូចេញទៅផ្ទះ មុនបាត់ ។ មាលានីក៏ដើរឈ្ងោកមុខ យួរចាន់ស្រោកតើកទើកតែម្នាក់ ឯង ស្រាប់តែមានរថយន្តមួយមកឈប់ក្បែរដងផ្លូវ កាត់មុខដំណើរ របស់នាង ។ បុរសម្នាក់ក៏ស្ទុះចេញមកហើយស្រវាចាប់កញ្ឆក់អោប នាងចូលរថយន្តយ៉ាងលឿនដូចព្រួញ ហាក់ដូចជាបានគ្រោងការទុក មុន ។ មាលានីភ្ញាក់ព្រើតស្រែកខ្លាំងៗហើយប្រឹងរើបម្រះ ៖

- លែង...! ជួយផង! ជួយផង...!

ប៉ុន្តែ បុរសនោះបានស្រវាអោយខ្ទប់មាត់នាងដៃម្ខាង ប្រឹងបរ រថយន្តដៃម្ខាង យ៉ាងលឿនចេញទៅដែរ ។ មាលានីប្រឹងអស់ សមត្ថភាពដើម្បីរើខ្លួនពីក្រញាំដៃរបស់បុរស ទីបំផុតក៏បានដើបរួច ហើយក៏ស្រវាបើកទ្វារបំរុងលោតចេញពីរថយន្ត ។ សំណាងអាក្រក់ រថយន្តមានគន្លឹះស្វ័យប្រវត្តិ ធ្វើអោយនាងចេញមិនរួច ។

រំពេចនោះ នាងដាក់ភ្នែកមកបុរសដែលចាប់នាងវិញ ស្រាប់ តែ នាងឧទានថា ៖

- លោកតារា ?

ភ្លាមនោះ នាងឃើញគេញញឹមឡើង ៖

- មែនហើយ គឺបង! ភ្ញាក់ផ្អើលណាស់ទៅហ្អី ដែលឃើញមុខបង នោះ មាលានី ?

នារីជ្រួញចិញ្ចើមក្រញ៉ូវភ្លាម ៖

- ដាក់ខ្ញុំចុះទីនេះភ្លាមទៅ លោកតារា! បើមិនចង់អោយខ្ញុំខឹង ហើយស្អប់រូបលោកជាងនេះ ។
- មិនដាក់ទេ ព្រោះបងមានការចង់និយាយជាមួយអូន ។
- តែខ្ញុំគ្មានអ្វីត្រូវនិយាយជាមួយលោកទេ!
- អូនមិនមាន តែបងមាន!
- លោកតារា! ដាក់ខ្ញុំចុះភ្លាម!!

រំពេចនោះ រថយន្តក៏បរហួសផ្ទះរបស់នាង ។ មាលានីដាក់ភ្នែក ទៅក្រៅ ឃើញកិត្យាដើរទប់ខ្លួននឹងឈើច្រត់ ចេញមករង់ចាំនាង នៅមាត់ផ្លូវ ។ ពេលនោះ នាងក៏ចាប់ក្រសែភ្នែករបស់កិត្យាបាន ថា គេបានឃើញនាងនៅក្នុងរថយន្តជាមួយតារាដែលកំពុងបរចេញ ទៅយ៉ាងលឿននោះដែរ ។

- បងកិត្យា! (មាលានីឧទានឡើង)

រួចហើយ នាងក៏បែរមករកតារាវិញ លើកដៃសំពះ ៖

CHANBOKEO.COM

- លោកតារា! អោយខ្ញុំសូមអង្វរណា៎! ដាក់ខ្ញុំចុះវិញទៅណា៎! នោះ
ប្ដីរបស់ខ្ញុំកំពុងរង់ចាំមើលផ្លូវខ្ញុំហើយ! គេកំពុងឈឺផង... ខ្ញុំ
មិនចង់អោយគេខ្វល់ខ្វាយពីសុវត្ថិភាពរបស់ខ្ញុំទេ ។

ស្រាប់តែ តារាបើកភ្នែកធំៗតែម្ដង ។ គេចាប់ហ្វ្រាំងទុចដំណើរ រថយន្ត ហើយស្រដីថា ៖

- ភូតបងរឿងអីហ្នឹង អូននី ? យើងទើបតែបែកគ្នាប៉ុន្មានថ្ងៃនេះ ទេតើហ៎ ហេតុអ្វីក៏... ?
- មិនចម្លែកទេ លោកតារា! លោកក៏ធ្វើអ្វីប្លែកៗក្នុងពេលខ្លីៗនេះ ដែរ មិនមែនទេ ?

តារាបើកភ្នែកធំៗ ធ្វើកិរិយាថា ភ្ញាក់ផ្អើល ៖

- អូននីបានរៀបការបុរសណាដែរក្នុងប៉ុន្មានថ្ងៃកន្លងមកនេះ ? នី
កំពុងធ្វើដើម្បីបញ្ឆោះបន្សោកអោយបងមែនទេ ?
- គិតខុសហើយ លោកតារា! ការពិត គឺមាលានីរៀបការនឹងបុរស
ដែលមាលានីពេញចិត្ត មិនមែនរៀបការដោយការបង្ខិតបង្ខំពីបុរស ណាទេ ។
- បងមិនជឿទេ! បងចង់ដឹងណាស់ ថាតើគេមានគុណសម្បត្តិល្អ យ៉ាងណា
ទើបគេអាចទាក់ទាញចិត្តមាលានីចេញពីបងបាន ?
- គេមិនមែនទេវតាពីស្ថានសួគ៌ ដែលមានគុណសម្បត្តិល្អឥតខ្ចោះ នោះឡើយ ។
គេគ្រាន់តែជាមនុស្សសាមញ្ញក្រីក្រម្នាក់ ប៉ុន្តែ ហេតុ ដែលខ្ញុំបានសំរេចចិត្តជ្រើសរើសរូបគេ
ព្រោះគេមានគុណសម្បត្តិល្អ លើសលោកបន្តិច ត្រង់គេផ្ដល់កិត្តិយសចំពោះខ្ញុំ...ជាងលោក...
- ផ្ដល់កិត្តិយសជាងខ្ញុំ ?
- មែនហើយ... គឺគេមិនដែលបង្ខំចិត្តខ្ញុំរឿងអ្វីមួយទេ... ថ្វីបើគេ
ស្ថិតនៅក្នុងស្ថានការណ៍មួយដែលធ្វើអោយចិត្តគេទាល់ច្រកក៏ដោយ
- មានន័យថា មាលានីបានបង្ខំចិត្តគេវិញ... ?
- ជារឿងនៅក្នុងផ្ទះរបស់ខ្ញុំទេ លោកតារា ។ ពេលនេះ លោក ល្មមដាក់ខ្ញុំចុះហើយ
ព្រោះខ្ញុំត្រូវត្រឡប់ទៅបំរើប្ដីដែលកំពុងមាន ជំងឺផង ។
- គេមានជំងឺ ? មាលានីធ្លាក់ខ្លួនរហូតដល់រៀបការជាមួយបុរស មានជំងឺផងហ្ន៎ស ?
- ដេញដោលច្រើនម្ល៉េះ ? លោកឡើងបុណ្យជាចៅក្រមតុលាការពី អង្កាល់ដែរ ?

ដោយទាល់ច្រក តារាក៏បត់ឡានបែរក្រោយ នាំមាលានីត្រឡប់ ទៅផ្ទះនាងវិញ
ក្នុងចិត្តប្រាថ្នាទៅរកមើលថាតើ មាលានីស្រដីពិតឬ ក៏យ៉ាងណាដែលនាងរៀបការរួចហើយ
ព្រោះគេទើបតែបែកនាង

CHANBOKEO.COM

ប៉ុន្មានថ្ងៃ មុននេះសោះ ។

គ្រាន់តែរថយន្តបត់ចូលមកដល់មុខផ្ទះ មាលានីបានឃើញ កិត្យាឈរធ្វើមុខជាំខ្មៅ ចាំផ្លូវនាង ថែមទាំងមានក្រុមគ្រួសាររបស់ នាងឈរច្រូងច្រាងពីក្រោយផង ។ មាណវីចាប់ភ្លឹកភ្លាមថា គេរាល់ គ្នាច្បាស់ជាឃើញតារាបររថយន្តដឹកនាងហួសទៅ អំបាញមិញ ។ មាលានីប្រឹងញញឹមឡើង ដើម្បីលួងលោមដួងចិត្តអ្នកផ្ទះរបស់នាង ដែលមើលទំនងទៅដូចជាខ្វល់ខ្វាយសម្បើមណាស់ ។

- លោកតារា! នេះបងកិត្យា! យើងទើបតែរៀបការនឹងគ្នា ថ្មីៗ នេះឯង!

មាលានីស្ទុះទៅជិតប្តី កាន់ដៃរបស់គេ ដើម្បីណែនាំ ប៉ុន្តែកិត្យា មិនបានញញឹមទទួលភ្ញៀវទេ ។ គេជ្រួញចិញ្ចើម ហើយខាំធ្មេញ ថែមទាំងលួចគិតក្នុងចិត្តថា ៖

- នីមានលួចណាត់បុរសម្នាក់នេះ នៅក្រោយម៉ោងធ្វើការផង មែន ទេ ? ទើបអូនមកផ្ទះយឺតរាល់យប់ ? តើអូនណាត់គ្នារហូតមក ប៉ុន្មានថ្ងៃហើយ ? ហេតុអ្វីទៅ ? អូនបានរៀបការនឹងបងហើយ ម៉េចក៏មានណាត់ជួបបុរសទៀត ?

ចំណែកតារា ក៏ធ្វើមុខចម្លែកយ៉ាងណាមិនដឹង ។ គេសម្លឹងកិត្យា ហើយសម្លឹងមាលានី ដោយទឹកមុខប្រែប្រួលម្តងហាក់ដូចជាខឹង ម្តងដូចជាឆ្ងល់ ម្តងហាក់ដូចជាប្រចណ្ឌ ។ ចៃដន្យវត្តមានរបស់ សមាជិកដទៃទៀតរបស់មាលានីនៅទីនោះ បានធ្វើអោយគេត្រូវកក កិរិយាឈឹង មិនដឹងថា ត្រូវធ្វើយ៉ាងណាអោយសមរម្យ ។ បន្តិច មក គេធ្វើពើជាញញឹម ហើយស្រដីទៅកិត្យាថា ៖

- ខ្ញុំនិងមាលានីស្គាល់គ្នាបីឆ្នាំហើយ ទើបតែបែកនាងអាទិត្យមុន សោះ លុះជួបអាទិត្យនេះ ស្រាប់តែនាងប្រាប់ខ្ញុំថា នាងបានរៀប ការរួចហើយ ធ្វើអោយខ្ញុំភ្ញាក់ផ្អើលណាស់ ទើបចូលមកចង់ជួប ចង់ស្គាល់ជាមួយស្វាមីរបស់នាង... ព្រោះមិនអស់ចិត្ត...

ប៉ុន្តែ កិត្យាបែរជាឈរស្ងៀមទៅវិញ មិនឮនាយស្រដីតប ចំពោះតារាវិញយ៉ាងណាទេ ។ ឃើញកិរិយាបថទើសទាល់របស់ ស្វាមីនៅចំពោះមុខភ្ញៀវបុរស មាលានីក៏ស្រវាកាន់ដៃកិត្យាហើយ ពោលថា ៖

- សូមទោស លោកតារា! បងកិត្យាមិនស្រួលខ្លួនហើយ ។ អោយ ពួកខ្ញុំសុំខ្លួនសិន ចាស!

ថាហើយ នាងក៏ជួយដើរទប់កិត្យាចូលទៅក្នុងផ្ទះ ។ តារាបែរ សម្លឹងតាមអ្នកទាំងពីរ រហូតដល់គេចូលផ្ទះបាត់ទៅ ទើបលើកដៃ សំពះលាឪពុកម្តាយរបស់មាលានី ត្រឡប់ចូលរថយន្តវិញ ហើយក៏ បរចេញទៅទាំងទឹកមុខស្រពោន ។

CHANBOKEO.COM

នៅក្នុងបន្ទប់តែពីរនាក់មាលនីនិងកិត្យា...

កិត្យាអង្គុយធ្វើមុខក្រញូវមិនចេញស្តី ។

- បង! មិនសប្បាយចិត្តរឿងអ្វីសួរអូនមក...! អូនរង់ចាំឆ្លើយបង ហើយណា៎! (មាលានីសួរ)

កិត្យាបេក្រសៃភ្នែកមើលនារីបន្តិច ក៏នៅស្ងៀមបន្តទៀត ។ បន្តិចមក គេក៏ផ្ដេកក្បាលលើខ្នើយ បិទភ្នែកសម្ងំ ។

- បង!... នីនឹងណា៎ ថាវត្តមានរបស់លោកតារាថ្ងៃនេះ បានរំខាន ចិត្តបង ។ ប៉ុន្តែ នីក៏មានរឿងចង់ជំរាបបងដែរ តើបងអនុញ្ញាត្តិ អោយអូននិយាយទេ ?

- បងអស់កម្លាំង ញ៉័រខ្លួនណាស់នី... ចាំស្អែកបានទេ ? បងសុំ សំរាកបន្តិចសិន ។

- ចាំស្អែកធ្វើអី ? អូនចង់និយាយថ្ងៃនេះ ដើម្បីអោយជ្រះស្រឡះ កុំអោយបងមានចិត្តសង្ស័យអ្វីទៀត!

ស្រាប់តែកិត្យាងើបអង្គុយវិញ ហើយគំហកថា ៖

- បងប្រាប់ថា ចាំស្អែក ចាំនិយាយគ្នា! ឮហើយនៅ ?

គ្រាន់តែឮសម្លេងគំហករបស់កិត្យាភ្លាម មាលានីនឹកអន់ចិត្ត ស្រឡេតតែម្តង ៖

- ហេតុអ្វីចាំស្អែកផង ? បើបងចង់ដឹងការពិត បងសួរអូនមក! កុំធ្វើមុខបែបហ្នឹង កិរិយាបែបហ្នឹងដាក់អូនអោយសោះ ព្រោះអូន មិនមែនជាចោរដែលត្រូវជាប់ទោសឧក្រិដ្ឋទេ កុំសម្លឹងសម្លក់ ធ្វើ មើលតែខ្ញុំមានកំហុសអ្វីធំយ៉ាងនេះ ?

ភ្លាមនោះ ស្រាប់តែកិត្យាបើកភ្នែកធំៗឡើង គំហកបន្តថា ៖

- បើចង់ឆ្លើយណាស់ អញ្ចឹង អូនឆ្លើយពេលនេះតែម្តងអោយបង ដឹងផងទៅ ថាអូនកំពុងមានចំណងស្នេហាជាមួយបុរសប៉ុន្មាននាក់ ដែរ ? ឃើញទេ បងរៀបការនឹងអូន មិនបានមួយអាទិត្យផង បុរសពីរនាក់បានមកបង្ហាញខ្លួន ផ្តើនចិត្តបងជាប្តី យ៉ាងមុខខ្លាញ់ យ៉ាងនេះទៅហើយ ចុះទំរាំយូរជាងនេះទៅទៀត តើមានប៉ុន្មាន នាក់ទៅដែលនឹងមកបង្ហាញខ្លួនផ្តើនចិត្តបងទៀត ?

- ម៉េចបងមានប្រសាសន៍ដូច្នេះ បងកិត្យា ? និយាយហាក់ដូចជា មិនទុកកិត្តិយសអោយអូនជាប្រពន្ធរបស់បងសោះ ។

- កិត្តិយស ? អូនគិតថា អូននៅមានកិត្តិយសដែរឬ៉ស ? តើអូន មានកិត្តិយសត្រង់ណា កាលបើអូនបានឆ្លងកាត់ជីវិតជាមួយបុរស ប្លែកៗ រួចហើយធ្វើពើជាមករៀបការនឹងបង

CHIANBOKFEO.COM

ដើម្បីលាក់បាំងប្រវត្តិ អាស្រូវរបស់អូនជាមួយបុរសអស់នោះ ? ឬក៏អូនគិតថា បងនេះ ជា អាភ្លើរត់មិនទាន់កលល្បិចរបស់អូន ?

- បងកិត្យា! តើបងមានកិត្តិយសត្រង់ណាដែរទៅ ដែលប្រមាថភរិយារបស់ខ្លួនឯងដោយគំនិតសំរាមរបៀបនេះ ? តើនីបានធ្វើអ្វី ខុសដែរទើបបងមើលងាយអូនយ៉ាងអាស្រូវអញ្ជឹង ?

ពេលនេះ មាលានីក៏ទប់អារម្មណ៍មិនជាប់ដែរដែលត្រូវស្វាមីជះកំហឹងនិងគំនិតអសុរសចំពោះនាង ។

- លួ! បើគិតថា បងគ្មានកិត្តិយសជាប្ដីរបស់អូនទេ បងក៏មិននៅទីនោះនាំតែទើសមុខអូនដែរ ។ ចាប់ពីថ្ងៃនេះតទៅ អូនគ្មានកិត្យា នៅទើសមុខអូនទៀតទេ ។

ពោលចប់ កិត្យា ក៏ស្រវាទាញអាវទាញស្បែកជើងពាក់ ញែកវាំងននដើរតតេះតតះចេញទៅ ។ មាលានីឃើញដូច្នោះ ក៏ស្រដីបញ្ឆេះទៅកាន់មាណពបន្ថែមពីក្រោយថា ៖

- បងកិត្យា! បើសិនបងដើរចេញពីអូននៅពេលនេះ សូមអោយ ដើរចេញរហូតទៅហើយមាលានីនឹងស្អប់បងមួយជីវិត រួចហើយ យើងមិនបាច់ជួបគ្នាតទៀតឡើយ ទោះជាតិនេះជាតិក្រោយឬជាតិ ណាៗទាំងអស់...!

កិត្យាទុចង៉ក់ កាលបើឮសំដីមាលានីដូច្នោះ ទំនងជាកំពុងគិត ថែដន្យកំហឹងនិងការខកចិត្តចំពោះមាលានីវាមានកំស្ហួលនៅក្នុង បេះដូងរបស់គេខ្លាំងពេកធ្វើអោយគេទ្រាំមិនបាន ក៏បោះជំហាន បន្តចេញទៅដោយឥតងាកក្រោយមកមើលវិញទៅ ថាតើមាលានី កំពុងស្រក់ទឹកភ្នែកឬក៏យ៉ាងណា...

CHANBOKEO.COM

oooooooooooooooooooooo

ooooo

o

# វគ្គទី១២

## ភ្លើងស្នេហ៍រោលចិត្ត

CHANBOKEO.COM

ក្រុងភ្នំពេញ...

ពីរថ្ងៃមុនមាលានីរៀបការជាមួយកិត្យា...

មាលានីដើរចេញពីរោងចក្រ ស្រាប់តែឃើញកិត្យាដើរចេញមក ពីរោងការងាររបស់គេ ជាមួយនារីកម្មករក្មេងមួយរូបឈ្មោះហម ដែលទើបនឹងចូលធ្វើការទីនោះថ្មីៗ ឃើញនារីនោះសើចកក្អឹកៗ ហើយស្រវាអោបចង្កេះនាយពីក្រោយ ថែមទាំងឃើញកិត្យាសើចតបវិញផង ។ មាណវីយើងភ្ញាក់ព្រើត នឹកខ្ទក់ចិត្តយ៉ាងណាមិនដឹង ក៏បែរក្រោយដើរទៅផ្ទះយ៉ាងលឿនតែម្នាក់ឯង ដោយមិនរង់ចាំដើរជាមួយកិត្យាដូចទម្លាប់របស់នាងរៀងរាល់ថ្ងៃទេ ។

កិត្យាចេញមកដល់ក្រៅ រកមាលានីមិនឃើញ ក៏រភ្នែកងាករក នាងស្រាប់តែឃើញនារីដើរលឹមៗនៅខាងមុខ លាយឡំខ្លួនជាមួយ នឹងហ្វូងកម្មករដទៃទៀតដែលកំពុងដើរតាមដងផ្លូវជាមួយគ្នា ។ គេក៏លើកដៃបក់បោយលានាងហម ហើយក៏ស្ទុះរត់តាមមាលានីពី ក្រោយយ៉ាងរហ័ស ។ សំណាងមិនល្អ មាលានីបានចូលទៅដល់ផ្ទះរបស់នាង ហើយគេចខ្លួនចូលផ្ទះបាត់ ។ កិត្យាក៏ឃ្វាងមិនបាន និយាយជាមួយនាងទៅ ។

ព្រហាមស្អែកឡើង...

- ជំរាបសួរពូ!
- អឺ លើកដៃថ្វាយព្រះ កិត្យា! មានការអីហ្អែស ?

- បាទ! គឺខ្ញុំដើរមកទទួលមាលានី តែនៅចាំនៅមាត់ផ្លូវមួយសន្ទុះ ធំហើយ មិនឃើញនាង ទើបចូលមកជំរាបសួរពូ...

- អូហ៍! ពូឃើញកូននីគេចេញទៅធ្វើការ តាំងពីកន្លះម៉ោងមុន នេះ ម្ល៉េះក្មួយអើយ ។

 កិត្យាសម្តែងទឹកមុខទំនងខកចិត្ត ៖

- អញ្ចឹង ខ្ញុំជំរាបលាទៅធ្វើការវិញហើយ បាទ!

 ពូនងងក់ក្បាល ។ កិត្យាដើរសំដៅទៅរោងចក្រទាំងឱរាំជួល ចម្លែកយ៉ាងណាមិនដឹង ដែលមាលានីបានដើរគេចមុខនរ:ចំនួនពីរ ដងជាប់គ្នា ។

- មានការអ្វីទៅ អូននី... បានជាអូនគេចមិនព្រមជួបបងអញ្ចឹង ?

 កិត្យាដើរចូលធ្វើការដោយដួងចិត្តកន្ទះរា ។

 ថ្ងៃត្រង់មកដល់...

 កិត្យាស្ទុះរត់មករកមាលានី នៅកន្លែងដែលនាងនិងសុខុមតែង អង្គុយបរិភោគ ស្រាប់តែឃើញសុខុមអង្គុយតែម្នាក់ឯង ។

- បងខុម! ឯណា មាលានី ?

- នាងប្រាប់បងថា មានការធ្វើត្រូវបង្ហើយ មិនបានចេញមកញ៉ាំ បាយទេ ។

 កិត្យាឮដូច្នោះ ក៏ហក់រឹងទៅរកមាលានីនៅរោងដែលនាងធ្វើ ការ ឃើញនាងនៅធ្វើការម្នាក់ឯង ឈរវាយលេខលើកេសប្រអប់ អីវ៉ាន់ដែលត្រូវដឹកចេញទៅប្រទេសក្រៅ ។ គេក៏ស្ទុះទៅជិតហើយ ខ្សិបហៅមាណវីតិចៗ ថា ៖

- អូននី !

 មាលានីភ្ញាក់ព្រើត បែរក្រោយឃើញកិត្យាដើរមកដល់ ។ នាង ក៏បែរមុខចេញ ធ្វើដូចជាមិនឃើញវត្តមានរបស់នាយទេ រួចហើយ ក៏ចាប់ធ្វើការតទៅទៀត ។ កិត្យាឃើញកិរិយាតោះតើយរបស់នាង គេឧទានសួរនាងដោយងឿងឆ្ងល់ថា ៖

- នី! មានរឿងអីហ្នឹង បានជាគេចមុខបងដូច្នេះ ?

 គេនៅឈរចាំអោយនារីឆ្លើយមួយស្របក់ នៅតែមិនឃើញ នាងឆ្លើយតបវិញ ក៏ស្ទុះទៅជិត ចាប់កដៃរបស់នាង ហើយស្រដី ឡើងថា ៖

- អូននី! និយាយប្រាប់បងមើល៍ អោយបងបានដឹង ថាបងបាន ធ្វើអ្វីខុស ដែលធ្វើអោយអូនតោះតើយដាក់បងបែបនេះ ?

 មាលានីបម្រះដកដៃនាងចេញ តែកិត្យានៅតែច្របាច់ជាប់ ៖

CHANBOKEO.COM

- លែងខ្ញុំ បងកិត្យា!
- បងមិនលែងទេ ដរាបណា អូនមិនឆ្លើយប្រាប់បង ថាយើងកំពុង មានរឿងអ្វី ?
- នីរវល់ជាប់ធ្វើការ មិនមានវេលាជូនបង សំរាប់រវៃកញ្រែក រឿងអ្វីឡើយ ។
- កុំធ្វើដូច្នេះណា៎អូន! នេះយើងជាមនុស្សជិតដិតនឹងគ្នា មានរឿង អ្វីក៏គួរនិយាយប្រាប់គ្នាអោយដឹងដែរ មិនមែនព្រងើយដាក់គ្នាដូច្នេះ ទេអូន!
- មាលានីគ្មានកិត្តិយសគ្រប់គ្រាន់ រហូតក្លាយជាមនុស្សជិតដិត នឹង បងកិត្យាដូចគេផ្សេងនោះឡើយ ។
- ស្មើនឹងគេផ្សេង ? នរណាគេទៅ ?
- ចុះនរណាទៅដឹង ?

ភ្លាមនោះ កិត្យានឹកឃើញទៅដល់ពេលល្ងាចម្សិលដែលនាង ហាមតាមប្រអោបប្រឡែងរូបនាយពេលចេញពីធ្វើការ ៖
- អូនកំពុងប្រច័ណ្ឌនាងហាមដាក់បងមែនទេ ?
- ប្រច័ណ្ឌ ? ហេតុអ្វីមាលានីត្រូវប្រច័ណ្ឌបងផង កាលបើយើងមិន មែនជាអ្វីនឹងគ្នាផងនោះ ?
- ម៉េចក៏ថា យើងមិនមែនជាអ្វីហ្នឹងគ្នា ? នេះយើងទៅមកនឹងគ្នា យ៉ាងជិតដិតយូរណាស់មកហើយ អូនគ្មានរូបបងនៅក្នុងចិត្តអូនទេ ឬអី មាលានី ?
- ហើយចុះបងវិញនោះ មានរូបមាលានីនៅក្នុងចិត្តបងដែរឬ ?
- ម៉េចក៏ថាមិនមាននោះ ? នីជានារីតែម្នាក់គត់នៅក្នុងចិត្តបង តាំងពីថ្ងៃដំបូង ដែលបងបានឃើញអូនម្ល៉េះ!
- តើនរណាគេជឿនោះ ? ខ្លាចតែប្រព្រឹត្តផ្សេង មិនដូចមាត់!
- អញ្ចឹង បងត្រូវធ្វើម៉េចទៅ ទើបអូនជឿបង ?

មាលានីនៅស្ងៀម ងាកមុខចេញ ។ បន្តិចមក កិត្យាក៏ពោល ពន្យល់ថា ៖
- បើបងសុំអូនរៀបការ អូនយល់យ៉ាងណាដែរ មាលានី ?

មាលានីភ្ញាក់ក្រញាងកាលបើឮកិត្យាពោលដូច្នោះ ។ ឃើញនារី ឈរទ្រឹង បើកភ្នែកធំៗ កិត្យាក៏ស្រវាចាប់ដៃមាលានីមកកាន់ ៖
- នេះជាពាក្យសំដីពិតណា៎ អូននី! បើអូនមិនប្រកាន់ចំពោះប្រវត្តិ អតីតកាលល្អក់កកររបស់បង មិនប្រកាន់នូវភាពក្រីក្ររបស់បង បងអាចផ្លាស់ប្តូរខ្លួនមកផ្លូវល្អវិញ ដើម្បីអូន បានគ្រប់យ៉ាង... បង ស្រឡាញ់អូនណាស់ ណា៎មាលានី! តើអូនរៀបការនឹងបងទេ ?

CHANBOKEO.COM

គេសម្លឹងមុខមាលានីដោយក្រសែភ្នែកផ្អែមល្ហែម ៖

- សម្លឹងកែវភ្នែកបងមក អូននី នោះអូននឹងឃើញជំរៅស្នេហ៍ក្នុង ដួងចិត្តបងហើយ ។

មាលានីងើបមុខឡើងសម្លឹងនរៈ យ៉ាងយូរ បន្តិចមកក៏ឆ្លើយ តបវិញថា ៖

- អោយពេលនីគិតបន្តិចបានទេ ?
- បាទ! (កិត្យាងក់ក្បាល) ដោយក្តីពេញចិត្តជានិច្ច ។

គេញញឹមឡើងដាក់នាង ពេលឃើញមាលានីស្រាយចិញ្ចើម ក្រញូវរបស់នាងមកវិញ ។ គេក៏ពោលបន្តថា ៖

- ល្ងាចនេះ យើងដើរទៅផ្ទះជាមួយគ្នាដូចដើមណាអូន!

ស្រាប់តែមាលីនីលាន់មាត់ថា ៖

- អោយតែមិនរំខានកាលវិភាគរបស់បងជាមួយ...

ស្រាប់តែកិត្យាយកដៃខ្ទប់មាត់នាងមិនអោយនិយាយបន្ត រួច ហើយគេឈ្ងោកខ្សិបដាក់ត្រចៀកនាងថា ៖

- នារីនៅក្នុងបេះដូងរបស់កិត្យាមានតែម្នាក់ហើយនារីនៅក្នុងជីវិត របស់កិត្យាក៏មានតែម្នាក់ហ្នឹងដដែល ។ គេមានឈ្មោះថា មាលានី ដឹងទេ អូន ? ហើយពេលនេះ អូនដឹងទេ ថាគេនឹកអូនប៉ុនណាដែរ ដែលគេមិនបានឃើញរូបអូនតាំងពីម្សិលមក ?

ភ្លាមនោះគេក៏ស្រវាអោបនាងយ៉ាងណែន រួចហើយដាក់នាសា រាវរកថ្ពាល់នារី ស្រាប់តែនាងគេចយ៉ាងរហ័ស ៖

- លេងចេះគេម៉េះ បងកិត្យា ?

ថាហើយ នាងគេចខ្លួនរត់ទៅរកទីធ្លាខាងក្រៅ ដែលមានពួក កម្មករនាៗឈរនៅទីនោះ ទំនងចង់ការពារមិនអោយកិត្យាតាម ថើបនាងបានឡើយ ។ កិត្យាឃើញហើយក៏ញញឹមឡើង ហើយ ស្រដីប្រាប់នាងពីចម្ងាយថា ៖

- ល្ងាចនេះ ហាមមិនអោយទៅផ្ទះមុនបងទេណា! បើមិនដូច្នោះ ទេ ស្អែកនេះ បងដាក់ទោសអូន នៅមុខគេមុខឯងហើយ ។

ថាហើយ មាណពក៏ដើរចេញទៅ ។ បានបន្តិច គេក៏លួចងាក ក្រោយលួចមើលមាលានី ក៏ចាប់បានស្នាមញញឹមមួយនៅលើផ្ទៃមុខ របស់នាងយ៉ាងស្រស់តបមករកនាយវិញ ។ ភ្លាមនោះ បេះដូង របស់នាយក៏រណ្តំចង្វាក់ភ្លេងស្នេហាយ៉ាងពិរោះរណ្តំមួយ បំពេររូប គេពេញមួយកំណាត់ថ្ងៃ រហូតដល់ម៉ោងចេញធ្វើការ ។

CHANBOKEO.COM

លើកនេះ កិត្យាលេងហ៊ានសើចលេងចំអន់នារីណា បុរសណា ហើយ ព្រោះអារម្មណ៍គេបានធ្វើអោយមាលានីបណ្តូលចិត្ត អស់ទៅ ហើយ... ព្ធួស្ទ័រនាឡិកាប្រាប់ម៉ោងអោយផ្អាកការងារមិនទាន់ទេ កិត្យាបានស្ទុះមកដល់មាត់ទ្វារខាងក្រៅយ៉ាងលឿន ចាំនារីជាស្រេច មិនអោយខកដូចកាលពីម្សិលមិញទៀត ព្រោះកាលនោះគេអាល័យ លលេងមិត្តស្រីៗធ្វើការជាមួយគ្នា ។ រំពេចនោះ កិត្យាបានប្រទះ មាលានីដើរចេញមក ដោយមានយួរស្រោក់បាយមកជាមួយផង ៖

- សួស្តីម្ចាស់ចិត្ត! អោយបងជួយយួរស្រោក់បាយអោយទេ ?

មាលានីញញឹមទំនងអៀនខ្មាស់ ដែលនរៈយើងហៅឈ្មោះនាង ដូច្នោះ ។ ចំណែកមិត្តរបស់នាងដែលដើរចេញមកព្រមៗគ្នានោះ នាំគ្នាហ៊ោរឡើងចំអន់នាងយ៉ាងសប្បាយ ។ តាមផ្លូវ កិត្យាសង្កេត ឃើញថា មាលានីហាក់ដូចជារសាយចិត្តខ្ចក់ខ្ចាញ់ចំពោះនាយអស់រលីងហើយ ហើយក៏ប្រព្រឹត្តកិរិយាចំពោះនាយដូចធម្មតាវិញ ។

ស្អែកឡើង ព្រឹកថ្ងៃអាទិត្យ...

មាលានីក្រោកឡើងចូលសំអាតតូបពីរនាក់ប្អូនស្រីម្នាក់ ដើម្បី ទទួលភ្ញៀវដែលមកធ្វើសក់ធ្វើក្រចក និងសំអាងមុខប្រចាំអាទិត្យ ស្រាប់តែឃើញតារាបរម៉ូតូមកដល់ ។

- ទៅជាមួយបងមួយភ្លែត បានទេ មាលានី ?
- ទៅណាបងតារា ?
- គឺបងមានការផ្ទាល់ខ្លួន ចង់និយាយជាមួយអូន ។

ឃើញឥរិយាបថតារាទំនងប្លែក មាលានីមានអារម្មណ៍ហាក់ដូចជាទើសទាល់យ៉ាងណាមិនដឹងសោះ ។

- ព្រឹកនេះ ខ្ញុំមានណាត់ភ្ញៀវបីបួននាក់ ទាល់តែម៉ោងពីររសៀល ទើបទំនេរ មិនអាចទៅជាមួយបងបានទេ ។
- តែនេះជារឿងសំខាន់ក្នុងជីវិតរបស់បង ហើយបងត្រូវការអោយ អូនជួយសំរេចចិត្ត ។
- រឿងសំខាន់ ?
- មែនហើយ! ជារឿងជីវិត...!

ថាហើយ មាណពក៏ឆក់ដៃមាលានីឡើងម៉ូតូរឹង ៖

CHANBOKEO.COM

- ឆាប់ឡើង! បងចាំយូរមិនបានទេ ។ អូនទៅជាមួយបងម៉ាភ្លែត សិនទៅ ចាំបងជូនមកវិញ ។

មាលានីមិនដឹងធ្វើម៉េច ក៏ផ្ដាំនឹងប្អូនស្រីអោយប្រាប់ទៅក្រុម គ្រួសារ ហើយក៏ឡើងម៉ូតូចេញទៅ ។ ទើបឡើងជិះបានបន្តិច នាង ក៏ប្រទះកិត្យាតាមដងផ្លូវកំពុងដើរតម្រង់ទៅផ្ទះរបស់នាង ។ ស្រស់ ស្រីក៏លើកដៃជាសញ្ញា ថានាងនឹងត្រឡប់មកវិញឆាប់ៗ ហើយឲ្យ កិត្យារង់ចាំនាងនៅផ្ទះ ។

បន្តិចមក តារានាំមាលានីមកដល់ផ្ទះមួយល្វែង ដែលគេធ្លាប់ នាំនាងមកកាលពីលើកមុនម្ដង ប៉ុន្តែពេលនេះ ផ្ទះនោះមានការកែ កុនយ៉ាងស្អាតស្ទើរតែចំណាំមិនបាន ។

- បងនាំខ្ញុំមកទីនេះធ្វើអី ?
- ចូលទៅក្នុងសិនទៅ ចាំបងប្រាប់!

តារាក៏ចាក់សោរដើរចូលទៅ ។ មាលានីសង្កេតឃើញថា ផ្ទះ នោះមានការតុបតែងទំនងហាក់ដូចជាបំរុងធ្វើពិធីមង្គលការរបស់គូ ស្រករណាម្នាក់អញ្ចឹង ។

- ហេតុអ្វីផ្ទះនេះមានការតុបតែងដូច្នេះ ? (មាលានីសួរ)

តារាទាញដៃមាលានីដើរចូលទៅក្នុងបន្ទប់ដំណេកមួយ ដែល មានការតុបតែងយ៉ាងប្រណិតទំនងជាបន្ទប់ផ្សំដំណេករបស់គូស្រករ រៀបការ រួចហើយក៏ទាញដៃមាលានីអោយអង្គុយលើពូកមង្គល ។

- អត់ទេ! (មាលានីគ្រវីក្បាល) នេះជាការមិនប្រពៃទេ ដែលនី ទៅអង្គុយលើពូករបស់អ្នកដទៃ ។
- ប៉ុន្តែ បើនីព្រមរៀបការនឹងបង អូននឹងក្លាយជាម្ចាស់របស់ពូក មង្គលនេះហើយ មិនមែននារីម្នាក់នោះទេ ។

មាលានីបើកភ្នែកធំៗ ហើយដើរថយក្រោយ ៖

- នារីម្នាក់នោះ ? នារីណា ?... នេះបងតារាកំពុងតែជិតរៀបការ មែនទេ ?
- គឺ ដូចអូនឃើញស្រាប់ហើយតើហ៎!
- បើដូច្នេះមែន ហេតុអ្វីក៏បងទាញខ្ញុំមកអោយចូលជាមនុស្សទីបី ក្នុងជីវិតរបស់បងធ្វើអ្វី ?
- ព្រោះបងមិនបានស្រឡាញ់គេម្នាក់នោះ!
- បើមិនស្រឡាញ់ហេតុអ្វីក៏មានគំរោងរៀបការនឹងគ្នា ?
- គឺជាការរៀបចំរបស់ចាស់ទុំ...

CHANBOKEO.COM

- ប៉ុន្តែ យើងជាមនុស្សពេញវ័យអស់ធំហើយ គ្មានឪពុកម្តាយណា
ចាប់យើងបង្ខំអោយយើងរៀបការបានទេ ជាពិសេសកូនប្រុសដូច បង... ដើងវែងណាស់ ។
បើសិនបងមិនរួមដៃទេ ការរៀបចំពិធី បែបនេះ ប្រាកដជាមិនកើតឡើងដាច់ខាត ។
- អូននិយាយត្រូវហើយ ។ កាលដំបូង បងគិតថា នឹងរៀបការភូត លេងៗទេ
ព្រោះខាងស្រីជាអនិកជនពីអាមេរិក ។ បងចង់ទៅនៅ អាមេរិក ថៃដន្យ ខាងស្រីគេមិនព្រម
គេចង់រៀបការត្រឹមត្រូវមែន ទែនពិតប្រាកដ ណាមួយយើងក៏ជាញាតិសន្តាននឹងគ្នា ពិបាកនឹងឲ្យ
បងប្រកែកណាស់ ជាពិសេសពេលចាស់ទុំទាំងសងខាងត្រូវរ៉ូវគ្នា ។
- បើឈានដល់ថ្នាក់នេះទៅហើយ ហេតុអ្វីបងនៅមកសុំខ្ញុំជាកូន ក្រមុំរបស់បងធ្វើអ្វី ?
- ព្រោះបងគិតថា បងនឹងរៀបការជាមួយគេបណ្តោះអាសន្ន រួច ហើយ
ពេលបងទៅដល់អាមេរិកមានសិទ្ធមានសញ្ជាតិគេត្រឹមត្រូវ ហើយបងនឹងលែងលះនាង
ហើយបងនឹងវិលមករៀបការជាមួយ អូនវិញ ។ ពេលនោះ
បងនឹងធានាអូនទៅនៅអាមេរិកទាំងអស់គ្នា ណា៎អូន ។

ភ្លាមនោះ មាលានីដើរថយក្រោយក្រាកៗ ៖

- នីមិនចូលដៃជាមួយបងទេ ក្នុងរឿងនេះ ។ បងមិនបាច់ពន្យល់ ថែមទៀតអី!
នីមិនប្រព្រឹត្តអំពើបាបបែបនេះទេ ។ ការពិតបងជា បុរសបុថុជ្ជនអាត្មានិយមទេតើហ៎!

នាងស្រងឹងផង ហក់ចេញទៅក្រៅផ្ទះផង ស្រាប់តែតារាស្ទុះទៅ
ស្រវាអោបនាងពីក្រោយជាប់ ។

- បងមិនអោយអូនទៅទេ នី! អូនជានារីដែលបងស្រឡាញ់ ជា
មនុស្សតែម្នាក់ដែលបងចង់រៀបការជាមួយ... យល់ព្រមជាប្រពន្ធ
បងទៅ ណា៎អូន... យល់ព្រមទៅណា៎នី!
- អត់ទេ..! លែងខ្ញុំទៅលោកតារា!
- មិនលែងទេ លុះត្រាតែអូនយល់ព្រមនឹងបងសិន!
- មិនយល់ព្រមទេ! លែង! នីមិនបានស្រឡាញ់បងទេ!
- បើមិនស្រឡាញ់បង ហេតុអ្វីអូនទៅមកជាមួយបងយ៉ាងជិតដិត អស់រយៈជាច្រើនឆ្នាំដូច្នេះ ?
- គ្រាន់តែការរាប់អានជាញាតិ មានទៅទាស់ខុសអី បងតារា ?
- ជាញាតិ ? មិនមែនទេ! អូនបានធ្វើឲ្យបងលង់ចិត្តស្រឡាញ់ អូនយ៉ាងងប់ងល់
រួចហើយអូនសើចលេងបែបនេះ មែនទេ ?

CHANBOKEO.COM

- ផ្ដាសហើយ បងតារា! ការពិត បងគិតតែម្នាក់ឯងតើហ៎! នី មិនដែលគិតពីបង
អោយលើសពីបងប្រុស ឬញាតិសន្តានម្នាក់ទេ! ពេលនេះ នីមានម្ចាស់ចិត្តហើយ ។

- ម្ចាស់ចិត្ត ? នរណាគេ ? ហេតុអ្វីទៅ ? ហេតុអ្វីទៅ ? ហេតុអ្វី មាលានីមិនជ្រើសរើសបង ?

តារាច្របាច់ស្មាមាលានីអង្រួន ។

- អ៊ូយ! លែងខ្ញុំ បងតារា! ច្របាច់ស្មាខ្ញុំដោយកម្លាំងបាយបែប នេះ
ចង់សម្លាប់ខ្ញុំអោយស្លាប់មែនទេ ?

- មិនមែនទេ! មាលានីជាបេះដូងរបស់បង រឿងអ្វីដែលបងត្រូវ សម្លាប់អូនផង ? ការពិត
បងចង់ថ្នាក់ថ្នមអូន... ថ្នាក់ថ្នមអូនអោយ សមស្មើនឹងចិត្តដែលបងស្រឡាញ់អូនជាយូរមកហើយ ។

ថាហើយ តារាក៏កញ្ឆក់ទាញប្រាណនារីផ្ដួលទៅលើពូកយ៉ាងអស់ ទំហឹង
រួចហើយក៏ស្ទុះទម្លាក់ខ្លួនទ្រោបលើកាយមាលានីតាមកំសួល
ស្នេហាដែលបេះដូងរបស់គេកំពុងទាមទារ ។

- អត់ទេ!!

មាលានីស្រែកឡើងយ៉ាងគ្រលួច ហើយលើកជង្គង់ទ្រខ្លួនតារា
រួចហើយធាក់ចេញវិញអស់ទំហឹង ធ្វើអោយមាណពផ្ងារក្រោយដួល គ្រាំងទៅលើកម្រាល ។
មាណវីហក់ព្រមៀលទៅម្ខាង ហើយស្ទុះ រត់ចេញទៅក្រៅយ៉ាងលឿនដូចព្រួញ ។
តារាស្ទុះដើបឡើងរត់តាម នាងពីក្រោយ ស្រវាចាប់មាលានី តែចាប់ផុតៗ ៖

- ឈប់សិន នី! អោយបងសុំទោស... ស្ដាប់បងសិនបានទេ ?

ប៉ុន្តែ មាណវីលែងចង់ស្ដាប់នាយទៀតហើយ ។ នាងរត់ចេញ មកដល់ក្រៅ
ហើយក៏រត់តាមបណ្ដោយប្លុករហូតដល់ថ្នល់ធំ ហៅ រកម៉ូតូទាំងដង្ហក់ខ្យល់ ។
តារាក៏ប្រញិបញាប់បិទទ្វារចាក់សោររួចក៏ ទាញម៉ូតូបរតាមមាលានីតាមពីក្រោយយ៉ាងលឿន ។

មួយស្របក់ក្រោយមក...

មាលានីឈប់ម៉ូតូនៅមុខផ្ទះ ក៏ប្រទះនឹងកិត្យាកំពុងនៅអង្គុយ លេងជាមួយឪពុកនាង
តែនាងមិនបានគួរសមនឹងមាណពទេ បែរ ជារត់ប្រុយចូលបន្ទប់
លួចពួនខ្ញាញ់តែម្នាក់ឯងដែលស្ទើរតែក្លាយជា ចំណីខ្លានៅថ្ងៃនោះ ។ កាលដើមឡើយ
នាងចូលចិត្តតារាណាស់ គិតថាគេជាញាតិគួរអោយស្រឡាញ់រាប់អានម្នាក់ ប៉ុន្តែថ្ងៃនេះ នាង
ខឹងនឹងមាណព ហើយនឹកស្ដាយដល់ចិត្តដែលធ្លាប់ស្រឡាញ់រាប់អាន

CHANBOKEO.COM

គោរពនាយតាំងពីដើមរៀងមក ។ នាងធ្លាប់លួចពិចារណារូបគេតែ ក្នុងចិត្តម្នាក់ឯង ប្រៀបធៀបរូបគេជាមួយកិត្យា ស៊ុនហេង នាយ បែន ថាតើបុរសណាមានគុណសម្បត្តិល្អជាងគេ ដែលគួរអោយនាង ផ្ញើចិត្តផ្ញើជីវិតជាមួយបាន ។ ចៃដន្យ តារាបានបញ្ចេញនូវក្រញ៉ាំ ក្រខ្វក់របស់បុរសចំពោះនាងថ្ងៃនេះ ធ្វើអោយនាងអស់អារម្មណ៍នឹង គិតថា គេជាបុរសល្អតទៅទៀត ។ ទឹកភ្នែកពីរតំណក់ក៏ស្រក់ចុះពី នេត្រាដ៏ខ្មៅរលោងរបស់នារី ។ ស្រាប់តែនាងយកដៃជូតវិញយ៉ាង រហ័ស ហើយនិយាយប្រាប់ខ្លួនឯងថា ៖

- ហេតុអ្វី យើងត្រូវស្រក់ទឹកភ្នែកផង កាលបើយើងមិនបានធ្វើអ្វី ខុស ? នៅលើលោកនេះ មិនខ្វះទេមនុស្សល្អ ទៅស្តាយអ្វីមនុស្ស ដូចតារាដែលជាបុរសអាត្មានិយមនោះ ? យើងគួរតែជ្រើសរើស បុរសណាដែលគេផ្តល់តម្លៃមកយើងតាមប្រពៃណី ថ្វីបើគេមិនមាន ទ្រព្យ មិនមានរូប មិនមានវណ្ណៈស្មើនឹងតារាក៏ដោយ ។

មាលានីជូតទឹកភ្នែកស្អាត ដើរចេញពីបន្ទប់មកវិញ ស្រាប់តែ ឃើញតារាបើកម៉ូតូមកដល់ ។ ស្រស់ស្រីយើងធ្វើមិនឃើញ រួចក៏ ដើរហួសទៅរកកិត្យាដែលនៅអង្គុយក្បែរពូនង ហើយស្រដីថា ៖

- សូមទោសពុក! អោយខ្ញុំសុំបងកិត្យាម៉ាភ្លែត! ម៉ោះបង!

ពូនងឃើញកិរិយាចម្លែករបស់កូនស្រី ក៏បែរមើលនាង ធ្វើ ភ្នែកស្លឹង ។ ចំណែកកិត្យាក៏មិនខុសគ្នាដែរ ដែលសុខៗមាលានី មកអូសដៃនាយចេញមកទាំងតក្កហល ព្រោះអីប៉ុន្មាននាទីមុននេះ នាងមានកិរិយាហាក់ដូចជាមិនចាប់ភ្លឹកពីវត្តមានរបស់គេសោះ ។

ប៉ុន្តែមាលានីគ្មានពេលគិតច្រើនទេ ។ នាងក៏កាន់ដៃកិត្យាអូស ដើរតាមជរៀងផ្ទះ គេចពីតារា រួចហើយឡើងម៉ូតូឌុបចេញទៅ ទុក អោយតារាបែរសម្លឹងតាមអ្នកទាំងពីររហូតផុតស្រមោល ទាំងក្រសៃ ភ្នែកសោកស្តាយ...

នៅមាត់ទន្លេ លើកៅអីថ្ម ក្រោមម្លប់ឈើមួយដើម...

- ថ្ងៃនេះ មានរឿងអ្វីរំខានក្នុងចិត្ត មែនទេ អូននី ?

កិត្យាសួរនារីយើង ព្រោះនាងមានកិរិយាកន្ទះរាខុសធម្មតា ។ នារីពូហើយ មិនឆ្លើយទេ បែរជាសួរវិញថា ៖

- បងកិត្យា! តើបងស្រឡាញ់នីប៉ុនណាដែរ ?

មាណពភ្ញាក់ព្រើត ឆ្លើយវិញយ៉ាងរហ័ស ៖

CHANBOKEO.COM

- គឺ... បងស្រឡាញ់អូន ពេញបេះដូងបងតែម្តង ។

- ហើយដែលបងសុំអូនរៀបការកាលពីម្សិលជាពាក្យពិតដែរទេ ?

ម្តងនេះ កិត្យារិតតែភ្ញាក់ផ្អើលខ្លាំងថែមទៀត ៖

- គឺពាក្យពិតពីដួងចិត្តរបស់បង ឥតក្លែងក្លាយឡើយណ៎ាអូន ។

- បើដូច្នោះមែន អូនមានអ្វីមួយចង់សុំបង... មុននឹងអូនឆ្លើយ ចំពោះបងវិញ ថាយើងគួររៀបការនឹងគ្នាឬយ៉ាងណា ។

- អញ្ចឹង... អូនប្រាប់បងមក !

មាលានីសម្លឹងមុខកិត្យាយ៉ាងយូរ ទំនងចង់ស្ទង់ចិត្តនរៈ បន្ទាប់ មកក៏ស្រដីថា ៖

- តើបងធ្លាប់មានប្រពន្ធ ឬនៅមានទំនាក់ទំនងជាមួយនារីណាពី អតីតកាលដែរទេ ?

កិត្យាគ្រវីក្បាល ៖

- មិនមានទេអូននី ! មនុស្សមានអតីតកាលល្អក់កករដូចបងនេះ តើមាននារីណាគេប្រថុយមកស្នេហ៍បងទៅ អូននី ?

- អូហ៍...មានន័យថា អូននីជាមនុស្សយ៉ាប់បំផុត បើសិនជានីជ្រើស រើសបង មែនទេ ?

ស្រាប់តែកិត្យាក្រឡេកមើលនារីដោយក្រសែភ្នែកភ្លឺថ្លាបំផុត ៖

- ការពិត ជាកិត្តិយសឧត្តមចំពោះបងណាស់ បើសិននីយល់ព្រម ទទួលបងជាគូគ្រង ។ ថ្វីបើបងគ្មានអ្វីអោយនីធូរចិត្តបានមែន តែ ហើយបងសន្យាថា នឹងកែប្រែជីវិត មិនអោយធ្លាក់ផ្លូវចាស់វិញជា ដាច់ខាត ហើយមិនអោយនីព្រួយចិត្តអំពីរឿងដែលបងមានប្រវត្តិ ជំពាក់ជំពិននឹងនារីណាម្នាក់ឡើយ ។

- បើដូចពាក្យបងមែន នីសូមយល់ព្រមទទួលពាក្យបងសុំអូនរៀប ការនោះដោយពេញចិត្តបំផុត ។

- មែនឬអូននី ? (កិត្យាឧទានដោយភ្ញាក់ផ្អើលក្រៃលែង)

- ចា៎ស មែនហើយ ! ដោយមានព្រះអង្គដង្កើជាសាក្សី !

ថាហើយ នាងក៏អូសដៃនរៈទៅអុជធូបថ្វាយបង្គំព្រះអង្គភ្លាម ។ រសៀលនោះ កិត្យាត្រេកអររំភើបក្នុងចិត្តរកពាក្យអ្វីមកថ្លាថ្លែងឲ្យ សមមិនបានឡើយ ។

- យើងរៀបការនៅចំពោះមុខព្រះអង្គពេលនេះតែម្តងទៅ យ៉ាង ម៉េចដែរ បងកិត្យា ?

- ថាម៉េច ? រៀបការឥឡូវនេះ ?

- ចា៎ស !

CHANBOKEO.COM

- ប៉ុន្តែ ហេតុអ្វីក៏ឆាប់រហ័សម្ល៉េះ ?
- បងខ្លាចមែនទេ ?
- មិនខ្លាចទេ ប៉ុន្តែ គ្រាន់តែមិនយល់ថា ហេតុអ្វីបានជា...
- អញ្ចឹង បងកុំសួរច្រើនអី! យើងសំពះសុំពរពីព្រះអង្គសិនទៅ ចាំស្អែក យើងរៀបការនៅចំពោះមុខមេបារបស់យើងបង្គ្រប់កិច្ច បន្ថែមទៀត អោយសមស្របប្រពៃណីយើង ។
ស្រាប់តែ កិត្យាបែរជាមានកិរិយារេរាៗដែលនារីយើងសម្រេច ចិត្តលឿនពេក ។ មាលានីឃើញឥរិយាបថរបស់នាយយើង ក៏វាចា ឡើងថា ៖
- មិនអីទេ បងកិត្យា! បើសិនជាគិតថា បងមិនបានស្រឡាញ់អូន បងនៅអាចប្រកែកបានតើ មិនបាច់ធ្វើតាមអ្វីដែលនីស្នើទេ.. អោយ អូនសូមទោសបងផង ដែលខ្ញុំបង្ខំអោយបងរៀបការជាមួយអូន នៅចំពោះមុខព្រះអង្គ ថ្ងៃនេះ!
មាលានីទម្លាក់ទឹកមុខស្រពោន ហើយក៏ដើបដើរចេញទៅ...
- អូននី!
កិត្យាស្រែកហើយ ហើយស្ទុះទៅអូសដៃនាងអោយត្រឡប់មក វិញ រួចក៏ហុចធូបទៅអោយមាលានី ៖
- ម៉ោះ អូន! យើងចូលសំពះព្រះអង្គទាំងពីរនាក់!
ភ្លាមនោះ មាលានីក៏ញញឹមឡើងដាក់បុរសយើង ព្រមទាំងមាន ទឹកភ្នែករលីងរលោងផង ហាក់ដូចជារំភើបចិត្តចំពោះការឆ្លើយតប របស់មាណពយើង ។ កិត្យាស្រវាដៃនាងកាន់យ៉ាងណែន បង្ហាញ នូវការដែលគេមានជំនឿចិត្តលើនាង យ៉ាងមោះមុតបំផុត ។ បន្តិច មក គេក៏បន្ទន់កាយអោនកេសាថ្វាយព្រះអង្គដម្កើ មាត់ទន្លេចតុមុខ ដែលធ្លាប់ល្បីល្បាញមានមហិទ្ធិឫទ្ធិសក្តិសិទ្ធិក្រៃលែង ។
រសៀលនោះ កិត្យាសង្កេតឃើញថា មាលានីបានលាចិញ្ចើម ឈប់ក្រញូវ រួចញញឹមមកវិញយ៉ាងបំព្រង ។ ក្រោយមក មាណព ក៏នាំនារីមកផ្ទះវិញជំរាបចាស់ៗ សុំគាត់រៀបចំពិធីមង្គលការនៅ ពេលព្រឹកស្អែក ។ មិនថាតែពូនងនិងមីងមៀនទេ សូម្បីតែឪពុក ម្តាយរបស់កិត្យាក៏យកដៃរីតដើមទ្រូងដែរ ព្រោះរត់តាមការសម្រេច ចិត្តរបស់កូនដ៏ឆាប់រហ័សចាប់មិនទាន់ ប៉ុន្តែគាត់ក៏សប្បាយចិត្ត ព្រោះដឹងថាកិត្យារបស់គាត់

CHANBOKEO.COM

កំពុងកែប្រែខ្លួនមកដើរផ្លូវត្រូវវិញ ដើម្បី គ្រួសារថ្មីរបស់គេ មិនចង់ធ្វើអ្វីឲ្យល្អក់ទឹកចិត្តរបស់កូនទេ ។

ទីបំផុត ចាស់ៗបានយល់ព្រមរៀបចំពិធីសែនព្រេនដូនតារៀប កូនចៅនៅព្រឹកថ្ងៃបន្ទាប់ ។ ព្រមជាមួយគ្នានោះដែរ មាលានីនិង កិត្យាបានទៅសុំច្បាប់ពីរោងចក្របីថ្ងៃ ។ ដោយសារគេជាមនុស្ស មានប្រវត្តិការងារល្អ ហើយការសុំច្បាប់នោះជាការសុំលើកដំបូង គេក៏បានទទួលការអនុញ្ញាត្តិអោយឈប់ដើម្បីរៀបចំពិធីមង្គល ។

ចៃដន្យ មិត្តជិតដិតរបស់អ្នកទាំងពីរ មានសំរោង សារេន សុខុមជាដើម សុទ្ធតែមានមុខរបរដែលមិនអាចឈប់ធ្វើការមកចង ដៃអ្នកទាំងពីរបានទេ បានត្រឹមតែទូរស័ព្ទមកជូនពរតែប៉ុណ្ណោះ ។

ការពិត ចំពោះមាលានី ដែលបានសម្រេចចិត្តរៀបការទាំង តក្កហល ព្រោះនាងចង់គេចពីតារា ខ្លាចគេមកតាមរំខានរូបនាង ខ្លាចវត្តមានរបស់តារាទាក់ទាញក្រុមគ្រួសាររបស់គេ ឲ្យមករំខាន គ្រួសាររបស់នាង នាំតែមានរឿងរ៉ាវវែងឆ្ងាយឡើង ។ ជួនជា ចៃដន្យ កិត្យាក៏ធ្លាប់បានសុំនាងរៀបការថ្មីៗនេះដែរ ។ ថ្វីបើគេមិន មានអ្វីប្រៀបផ្ទៀបនឹងតារាបានមែន ប៉ុន្តែគេថ្នាក់ថ្នមចិត្តនាងណាស់ តាំងពីថ្ងៃដែលអ្នកទាំងពីរបានស្គាល់គ្នាមក ។ គេគោរពចិត្តនាង ច្រើនជាងនរណាទាំងអស់ដែលធ្វើការក្នុងរោងចក្រជាមួយគ្នា រហូត ដល់មានការចំអន់ព្រឹកល្ងាចពីសំណាក់មិត្តរួមការងារទាំងឡាយ ។

ចំពោះ កិត្យាវិញ ថ្វីបើការយល់ព្រមរបស់មាលានីនិងសំណើ សុំអោយរៀបការនោះ ស្ថិតនៅក្នុងលក្ខណៈតក្កហលយ៉ាងណាក៏ ដោយ គេក៏ពេញចិត្តទទួល ព្រោះគេបានលួចពេញចិត្តនារីជាយូរ មកហើយ គ្រាន់តែគេមិនហ៊ានស្រដី ។ គេខិតខំផ្លាស់ប្តូរខ្លួនគេប្លែក ពីមុន ដើម្បីអោយនាងចាប់អារម្មណ៍ ។ មិនតែប៉ុណ្ណោះ គេហ៊ាន យកខ្លួនទៅបំរើយកចិត្តឪពុកម្តាយនិងបងប្អូនមាលានីរហូតដល់ទាំង អស់គ្នាបាក់ចិត្តស្រឡាញ់នាយគ្រប់គ្នា ។

គ្រាន់តែរៀបការក្បាលដល់កន្ទេលទទួលពរពីមាតាបិតាចប់សឹង តែមិនទាន់ កិត្យាបានរត់ទៅផ្ទះប្រមូលឥវ៉ាន់សំពីងសំពោងដាក់ម៉ូតូ យកមកផ្ទះមាលានី ។

- ស្លាប់ហើយ! បងកិត្យា! ពីណាគេចិត្តល្អអោយបងយកម៉ូតូដឹក ឥវ៉ាន់ច្រើនយ៉ាងនេះ ខ្ទេចម៉ូតូគេអស់ហើយ!

CHANBOKEO.COM

មាលានីលាន់មាត់ ។ កិត្យាសើចខឹកៗ ហើយឆ្លើយថា ៖

- គឺម៉ូតូបងតើហ៎! បងចាក់សោរទុកយូរហើយ ។
- អូហ៎ ហេតុអីក៏មិនប្រើវា ?
- បើប្រើវា ធ្វើម៉េចនឹងបងបានពេលដើរជាមួយនីទៅធ្វើការ ?
- ការពិត បងឯងខូចណាស់តើហ៎!
- គឺ... មកពីបងចង់មានពេលច្រើនជាមួយនី ព្រឹកល្ងាចនោះអី ។
- សំណាងល្អណាស់ ចាប់ពីពេលនេះតទៅ បងមិនបាច់ភ័យទៀត ទេ ព្រោះបងនឹងមានពេលជាមួយអូនរហូតមួយជីវិតឯណោះ ។

កិត្យារីកមុខដូចគ្រាប់ជីរតៃម្លូង ៖

- ហើយសូមអោយយើងមានសុភមង្គលរៀងរហូតទៅណា៎អូន ។
- ចា៎ស! សូមអោយយើងទាំងពីរមានសុភមង្គលរៀងរហូតទៅ ។

អ្នកទាំងពីរក៏ញញឹមដាក់គ្នាយ៉ាងចំព្រង ។

នៅថ្ងៃដែលអ្នកទាំងពីររៀបការនោះ តារាក៏ចូលរោងការដូចគ្នា ដែរ ។ ប៉ុន្តែ មាលានីលែងខ្វល់ហើយ ថាតារានឹងមានជីវិតបែប ណា កាលបើគេបានបង្ហាញនូវឥរិយាបថមិនប្រពៃចំពោះនាង កាល ពីថ្ងៃម្សិល ។

oooooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី១៣
## ស្នេហ៍ចាកផុតទៅ...

ក្រុងភ្នំពេញ...

ឆ្នាំ២០០៧...

កិត្យាដើរចេញមកក្រៅផ្ទះទាំងតតេះតតះ ណាមួយ គេមិនទាន់ជាស្រួលបួលពីស្នាមរបួសដែលត្រូវបងប្អូននាយស៊ុនហេងវាយទាត់ ថ្ងៃមុន ណាមួយគេកំពុងរន្ធត់ញាប់ញ័រដោយភ្លើងប្រចណ្ឌនិងចិត្តឃ្នាន់ខ្នាញ់ល្មួចសង្ស័យមិនអស់មិនហើយអំពីមាលានីនិងប្រវត្តិអតីត របស់នាង ។

- ចេញទៅណាហ្នឹងកូន ? នេះ យប់ហើយណា៎ ?

ពូនងសួរទៅកិត្យា ពេលឃើញគេដើរចេញទៅក្រៅផ្ទះ ប៉ុន្តែ កិត្យាមិនឆ្លើយទេ គ្រាន់តែអោនក្បាលលើកដៃសំពះ ហើយក៏ដើរ ត្រិបៗចេញទៅ ។ ពូនងមីងមៀន មើលមុខគ្នាហើយគ្រវីក្បាល ។

- ហេតុអ្វីក្មេងសម័យនេះ គេចូលចិត្តរត់គេចបញ្ហាដូច្នេះ ? ហេតុអ្វីគេមិនប្រឈមមុខដោះស្រាយវា ? (ពូនងលាន់មាត់)

ស្រាប់តែមីងមៀនឆ្លើយថា ៖

- អោយគេទៅក៏ល្អដែរ ដើម្បីអោយគេបានរំសាយកំហឹងនៅក្រៅផ្ទះជាជាងឈ្លោះប្រកែកហើយវាយគ្នាពេញផ្ទះដែរ ។

CHANBOKEO.COM

- តែគួរអោយឆ្ងល់ណាស់ ។ គេនិយាយថា គេស្រឡាញ់គ្នាណាស់ ពេលនេះ ទើបតែរៀបការបានប៉ុន្មានថ្ងៃ ឃើញតែងងីក់ខឹងដាក់គ្នា អោយជាប់ តើកិរិយាបៀបនេះអោយយើងហៅថា គេស្រឡាញ់គ្នា ដែរឬទេ ហ្នឹង ?

- នេះគេហៅថា កិរិយាអភិវឌ្ឍន៍ ព្រោះហោចណាស់ គេមិនខឹង ហើយជេរគ្នា រួចវាយគ្នាទេ ប៉ុន្តែ គេខឹងហើយចែកផ្លូវគ្នាទៅដេក គិត ។ លុះដេកដកដង្ហើមបន្ធូរកំហឹងចោល ហើយគិតឃើញផ្លូវល្អ ក្នុងជីវិត គេក៏ត្រឡប់មកជាគ្នាដូចធម្មតាវិញ ។

- មែនហើយ! ម៉ែវាចេះនិយាយត្រូវបែបបថណាស់ដែរតើហ៎! ប៉ុន្តែ ចរិតរបស់បុរសដែលរត់គេចផ្ទះទៅក្រៅ ពេលគេខឹងប្រពន្ធ នោះក៏មិនល្អប៉ុន្មាន ជាពិសេស បើគេទៅដេកគិតពិតមែននោះ មិនអីទេ ខ្លាចតែគេទៅដេកគង មានស្រីកល់កើយ នោះច្បាស់ជាស៊យជីវិតគ្រួសារស្លាប់ហើយ ។

- មើលទៅកិត្យា គេមិនមែនជាបុរសបែបហ្នឹងទេ ពុកវា!

- សាធុ! សូមអោយដូចភ្នែកម៉ែវាមើលឃើញផងចុះ ។

ពូនងលើកដៃឡើងថ្វាយមេឃ ។

នៅក្នុងបន្ទប់ មាលានីគេងស្រក់ទឹកភ្នែកតែម្នាក់ឯងទៀត ហើយ ។ នាងមិនយល់សោះ ថាហេតុអ្វីជីវិតរបស់នាងមានភាព រសឹមរសាំម្ល៉េះ ? ចង់រៀនធ្វើពេទ្យ ក៏រៀនមិនបានចប់... ចង់រៀប ការជាមួយបុរសកំណាន់ឯស្រុកកំណើត បែរជារលាយសង្ឃឹម... ចង់មានគ្រួសារជាមួយបុរសដែលចេះថ្នាក់ថ្នម ប៉ុន្តែគេបែរក្លាយជា បុរសខ្និកខ្នក់ ប៉ិនងីក់ជាងស្រីទៅទៀត ។ សំណាងល្អ នាងមាន ឪពុកម្តាយនិងបងប្អូនដែលតែងតែផ្តល់សេចក្តីកក់ក្តៅដល់នាង កុំ អីនោះ មិនដឹងជានាងស្រកស្រុតបាក់កម្លាំងចិត្តយ៉ាងណាទេ ។

ពេលនេះ នាងគិតថា នាងស្រឡាញ់កិត្យាយ៉ាងអស់ពីពោះពី ពុង ព្រោះគេមិនដែលបង្ខំចិត្តនាងរឿងអ្វីឡើយ ខុសតែម្យ៉ាង គឺ គេឆាប់ខឹងខ្នក់ចិត្តមិនព្រមនិយាយមកក្រៅ តែបើនិយាយគឺស្រដី ដោយហឹង្សា ។ មាលានីគេងប្រែចុះប្រែឡើងយ៉ាងយូរ... មិនចេញ ទៅតាមកិត្យា ត្បិតនឹកថាគេកំពុងមានជម្ងឺ ប្រាកដជាទៅណាមិន បានឆ្ងាយឡើយ ។ ម្យ៉ាងទៀត នាងក៏ចង់សាកចិត្តរបស់គេ ថាតើ គេចាប់សំដីនាង ហើយផ្លាស់ប្តូរចិត្តដែរឬយ៉ាងណា...

CHANBOKEO.COM

ពេលវេលាកន្លងទៅយ៉ាងយឺតៗ... បង្ហួសយកតំណក់ទឹកភ្នែក រាប់មិនអស់ពីមាលានី ប៉ុន្តែកិត្យានៅតែមិនវិលវែនដែល... ម៉ោង បីជិតភ្លឺហើយ... មាលានីទ្រាំមិនបានក៏ងើបឡើងដើរចេញទៅ ក្រៅផ្ទះ តាមរកកិត្យាភ្លាម ។

ឮសូរសម្លេងទ្វារបើក ពូនងក៏ស្រែកសួរពីក្នុងផ្ទះមកថា ៖

- ទៅណាទាំងងងឹតហ្នឹងកូននី ? បើចង់ទៅរកកិត្យា ចាំភ្លឺសិនទៅ កូន... ទើបវាមានសុវត្ថិភាព ។

ថៃដន្យ មាលានីមិនបានឮសំដីរបស់គាត់ទេ ព្រោះនៅក្នុងចិត្ត នៅក្នុងអារម្មណ៍របស់នាង ទន្ទេញជាប់តែសុខទុក្ខរបស់កិត្យាតែ ម្យ៉ាងប៉ុណ្ណោះ ។

នាងក៏ដើរចេញទៅដល់ថ្នល់ធំបែរមុខតម្រង់ទៅ ភ្នំពេញ ។ ពេលនោះ ចរាចរមានតាមផ្លូវមួយៗហើយ ។ ការពិត មិនដឹងថា នាងចង់ទៅរកកិត្យានៅឯណាទេ ។ នាងគ្រាន់តែដើរ ចេញពីផ្ទះកុំអោយតប់ប្រមល់ធុញថប់កន្ទះរាក្នុងចិត្ត ។ មាលានីដើរលង់អារម្មណ៍តែម្នាក់ឯង មិនបានចាប់ភ្លឹកនឹងចរាចរតាមដងផ្លូវទេ ទីបំផុត ពេលនាងភ្ញាក់ស្មារតីឡើង នាងក៏បានមកដល់សួនច្បារ ក្បាលជ្រោយ ឃើញអ្នកស្រុកចេញដើរលក់អីវ៉ាន់ព្រោងព្រាត ។ នៅឯផ្ទៃនភា ព្រះសុរិយារះចែងចាំងយ៉ាងភ្លឺត្រកាល ។ ថៃដន្យ ដួងចិត្តរបស់នាងមិនបានទទួលអនុភាពរស្មីនោះទេ ។ ក្នុងកែវ ភ្នែករបស់នាង អ្វីៗដែលនាងសម្លឹង គឺស្ថិតនៅក្នុងភាពងងឹតទាំង អស់ ។ ភ្លាមនោះ នាងក៏បានឮសម្លេងមនុស្សស្រីហៅនាង ៖

- ក្មួយនី! សុខសប្បាយទេហ្ន៎ស ?

មាលានីងាកមើល ក៏ប្រទះនឹងមីងលក់ចាប រួចស្រាប់តែមាន អារម្មណ៍ថាងងឹតមុខខ្លាំងណាស់ បន្ទាប់មកក៏ដួលបាត់ស្មារតីទៅ ។

និយាយពីកិត្យាម្តង...

ពេលគេចេញមកដល់ក្រៅ ឈរចាំយ៉ាងយូរម៉ោង មិនឃើញនរណាម្នាក់ចេញមកតាមរូបគេអោយត្រឡប់ទៅផ្ទះសោះ ។ គេបែរ ក្រោយរកមើល ក្រែងមាលានីចេញមកតាមអង្វរករ... ប៉ុន្តែគេចាំ យូរម៉ោងហើយ មាលានីនៅតែបាត់ស្ងន្យងដែល...

CHANBOKEO.COM

- នី! អូនមិនស្រឡាញ់បង ហើយបារម្ភពីសុខទុក្ខរបស់បងទេឬ យ៉ាងណា
បានជាអូនមិនចេញមកតាមបង ?

គេក៏លើកទូរស័ព្ទហៅសំរោងជាមិត្ត ។

- សូមទោសណាំសម្លាញ់! ថ្ងៃនេះកូនឈឺដល់ទៅពីរនាក់ ។ ឯ
ប្រពន្ធបានចេញទៅទិញឥវ៉ាន់តាមខេត្ត មិនទាន់មកវិញទេ ។ គ្នា ជួយឯងមិនបានទេ ។
ពេលនេះ ឯងត្រូវពឹងខ្លួនឯង ដោះស្រាយ បញ្ហាជីវិតហើយ ។

កិត្យាទម្លាក់ទូរស័ព្ទចុះ ដើរទប់ខ្លួននឹងឈើច្រត់ ធ្វើត្រិះត្រុះៗ រេរាៗ
នៅតែមិនឃើញអ្នកផ្ទះចេញមករកនាយដដែល ។ ដោយ មិនអស់ចិត្ត គេក៏ដើរបកក្រោយវិញ
ស្រាប់តែគេនឹកស្រម័យដល់ ពាក្យមាលានីដែលស្រែកប្រាប់គេមុនពេលគេចេញពីផ្ទះមក ៖

- បងកិត្យា! បើសិនបងដើរចេញពីអូននៅពេលនេះ សូមអោយ ដើរចេញរហូតទៅ
ហើយមាលានីនឹងស្អប់បងមួយជីវិត រួចហើយ យើងមិនបាច់ជួបគ្នាតទៀតឡើយ ទោះជាតិនេះ
ជាតិក្រោយឬជាតិ ណាៗទាំងអស់...!

កិត្យាធ្លាក់ទឹកមុខជ្រប់ លែងហ៊ានបោះជំហានត្រឡប់ក្រោយ ហើយគិតក្នុងចិត្តថា ៖

- នី! តើអូនពិតជាស្អប់បងមួយជីវិតមែនហ្អែស ? ការពិត អូន មិនដែលស្រឡាញ់បងទេ
មែនទេ ? នេះ អូនលែងអធ្យាស្រ័យ ដល់បងទៀតហើយ មែនទេ អូន ?

មិនដឹងជាហេតុអ្វីទេ... កិត្យាតែងតែគិតថា គេមានចិត្តរឹង ណាស់ តែពេលនោះ
គេបែរជាមានអារម្មណ៍ថា គេកំពុងស្រក់ទឹក ភ្នែក... មិនដឹងថា
គេស្រក់ទឹកភ្នែកព្រោះអាណិតខ្លួនគេ ឬក៏ស្រក់ ទឹកភ្នែកព្រោះអាណិតមាលានី
ដែលតែងតែទទួលរងគ្រោះអំពីភាព ឆេវឆាវកំបុតកំបុយរបស់គេទេ ។
គេឈ្ងោកគិតមិនអស់មិនហើយ មិនដឹងយប់នេះ
មាលានីនឹងរត់តាមរកនាយដូចយប់មុនទៀតដែរឬ យ៉ាងណា... កិត្យានៅអង្គុយគិតម្នាក់ឯង
នៅក្រោមដំបូលតូប កញ្ញាស់លក់នំបញ្ចុកមួយ តាមផ្លូវទៅរោងចក្រ ក្នុងចិត្តនឹកគិតថា
គេនឹងបានឃើញមុខប្រពន្ធនៅពេលព្រឹក ពេលនាងចេញដើរទៅ ធ្វើការ ។

- ពូ! ភ្ញាក់ឡើង! ខ្ញុំសុំរៀបតូបលក់ឥវ៉ាន់វិញហើយពូ!

ក្មេងស្រីម្នាក់មកដាស់កិត្យា ។ គេភ្ញាក់សើងមើង ស្ទុះដើបដើរ
ចេញទៅឈរនៅចាំមើលមាលានីនៅក្រោមដើមចាមរីមួយ... តាម
ផ្លូវដែលនាងដើររាល់ព្រឹកទៅធ្វើការ ។ សំណាងមិនល្អ គេបានរង់

CHANBOKEO.COM

ចាំរហូតដល់ពួកកម្មករចូលធ្វើការអស់ហើយ ក៏នៅមិនឃើញប្រពន្ធ ដើរចេញមកសោះ ។
គេនឹកបារម្ភពីនាងយ៉ាងណាមិនដឹង ក៏ស្ទុះ ដើរបកក្រោយត្រឡប់ទៅរកមាលានីវិញ ។

គ្រាន់តែឃើញវត្តមានរបស់កិត្យាភ្លាម មីងមៀននិងពូនង សំដែង សេចក្តីត្រេកអរ ស្ទុះមកសួរនាយព្រមគ្នា ៖

- មកវិញហើយហ៊្អែស កូន ?

កិត្យាធ្វើមុខញញឹមស្ងួត ស្រាប់តែពូនងសួរនាយថា ៖

- ហើយចុះឯណាមាលានី ?

បុរសយើងភ្ញាក់ព្រើត សួរឪពុកក្មេកត្រឡប់ទៅវិញថា ៖

- ក្រែងមាលានីចេញទៅធ្វើការឬអីពុក ?
- នាងមិនបានទៅធ្វើការទេ ព្រោះនាងបានរត់ចេញតាមឯង តាំង ពីម៉ោងបីជិតភ្លឺម្ល៉េះ ។

កិត្យាប្រហោងពោះឆ្លុងតែម្តង ៖

- ហើយនាងមិនទាន់មកផ្ទះវិញទេហ៎ ?
- មិនឃើញទេ កូន ។

ពេលនេះ មាណពយើងបែកញើសពេញខ្លួនស្រាក់ៗតែម្តង ។

- អូននី! បងនាំទុក្ខអោយអូនទៀតហើយមែនទេ ? (នរ:នឹកក្នុង ចិត្ត) តើពេលនេះ អូននៅឯណា ?

ពេលនោះ កិត្យាមានអារម្មណ៍ថា ផែនដីហាក់ដូចជាចង់ក្រឡាប់ ហើយព្រះអាទិត្យក៏ធ្លាក់លិចបាត់ទៅក្នុងទឹក នៅសល់តែពិភពលោកខ្មៅងងឹតហើយរងាក្រៃលែង ។

- ពុក! ខ្ញុំសុំទោសដែលខ្ញុំឆៅឆាវ ធ្វើអោយអូននីជ្រួលច្របល់! ( កិត្យានិយាយផង លើកដៃសំពះផង) កូននឹងទៅតាមរកមាលានី ឥឡូវនេះ បើរកនាងមិនឃើញ កូនក៏មិនត្រឡប់ចូលផ្ទះវិញដែរ ។

គេអោនសំពះពូនងដែលនៅចាំផ្ទះតែម្នាក់ឯង ហើយក៏ដើរ ចេញទៅ ។ គេបានទៅរកមាលានីដល់រោងចក្រ បានជួបសំរោង និងសុខុមពេលគេចេញបរិភោគបាយថ្ងៃត្រង់ ប៉ុន្តែ អ្នកទាំងពីរ គ្រវីក្បាលប្រាប់ថា មាលានីមិនបានមកធ្វើការទេ ។ កិត្យាអង្គុយនឹកពេញមួយថ្ងៃរកនឹកថា តើមាលានីចូលចិត្តទៅកន្លែងណាខ្លះ ។ បន្តិចមក គេក៏ទៅមុខវាំងបន់ព្រះអង្គដង្កើ ៖

CHANBOKEO.COM

- សូមបារមីសក្តិសិទ្ធិបំភ្លឺផ្លូវជីវិតកូនចាបផង ។ ពេលនេះ កូន ចាបធ្វើខុសធ្ងន់ បណ្តាលអោយប្រពន្ធខ្វល់ខ្វាយ ហើយនាងក៏ចេញ បាត់ពីផ្ទះទៅដោយគ្មានដំណឹង មិនដឹងថានាងនៅកន្លែងណាទេ... ខ្ញុំដឹងខ្លួនថា ខ្ញុំស្រឡាញ់នាងណាស់ មិនថាខ្ញុំមាន អារម្មណ៍ល្អក់កករចំពោះនាងយ៉ាងណាទេ... ក៏ខ្ញុំនៅតែស្រឡាញ់នាងជានិច្ច... សូមមេត្តាជួយណែនាំផ្លូវឲ្យខ្ញុំបានជួបប្រពន្ធបណ្តូលចិត្តរបស់ខ្ញុំវិញផង!

គេនៅអង្គុយសំកុកយ៉ាងយូរនៅសួនច្បារមុខវាំង រំពេចនោះ គេក៏នឹកទៅដល់ក្បាលជ្រោយ ដែលគេធ្លាប់នាំមាលានីទៅព្រលែង ចាប ។

- មែនហើយ! មាលានីច្បាស់ជានៅទីនោះ ។

គេនឹកអរភើត ហៅម៉ូតូឌុបដឹកគេចេញទៅភ្លាម ។ ថ្វីបើគេនៅ ឈឺមុខរបួសក៏ដោយ ប៉ុន្តែក្តីបារម្ភរបស់គេចំពោះមាលានីមានទំហំ ធំធេងណាស់ ធ្វើអោយគេភ្លេចថាខ្លួនជាមនុស្សមានជំងឺរបួសគ្រាំគ្រា នោះបាត់ទៅហើយ ។

មកដល់សួនច្បារក្បាលជ្រោយ កិត្យាចុះពីម៉ូតូឌុប បែររកមើល ជុំវិញទីធ្លា មិនឃើញមាននារីម្នាក់ណាមានភិនភាគដូចមាលានីសោះ សូម្បីតែមីងលក់ចាបនិងកូនចៅក៏បាត់អស់រលីង មិនឃើញមាន ស្រមោលនរណាម្នាក់ដែរ ឃើញតែភ្ញៀវអនិកជន និងអ្នកលក់ដូរ ផ្សេងៗ ។

គេនៅសំកុកនៅទីនោះរហូតដល់ថ្ងៃលិច... ប៉ុន្តែ ក្តីសង្ឃឹម របស់គេ ក៏លិចសូន្យទៅតាមរស្មីថ្ងៃលិចដែរ ។ យប់ឡើង គេវិល ទៅផ្ទះ ជួបឪពុកម្តាយក្មេកនិងកូនចៅរបស់គាត់ ដែលកំពុងតែ ចលាចលខ្វល់ខ្វាយចំពោះមាលានីជាអតិបរមា ព្រោះនារីមិនបានវិល មកផ្ទះវិញទេ ។ ពេលនេះចម្លើយមានតែមួយគត់ គឺកិត្យាត្រូវទៅ តាមរកមាលានីដល់កម្ពុជាក្រោម ។ បុរសយើងមិនដែលស្គាល់ កម្ពុជាក្រោមទេ ហើយក៏មិនដឹងថា ព្រះត្រពាំងនោះជាអ្វីផង ។ ពូនងបានក្លាយជាជនពិការ មិនអាចដើរហើរជូនកិត្យាទៅណា មក ណាបានឡើយ ។ ចំណែកកូនចៅរបស់គាត់ជាប់ធ្វើការជាប់ រៀន គ្រប់គ្នា ទើបកិត្យាសំរេចចិត្តទៅតាមរកប្រពន្ធរបស់ខ្លួន នៅស្រុក កំណើតរបស់នាងតែម្នាក់ឯង ។ មិនទាន់បានឡើងរថយន្តផង ចាន់ណាតជាប្អូនជីទងរបស់មាលានី ក៏បានមកដល់ ហើយប្រាប់ថា ពូនងដេញឲ្យជូនដំណើរកិត្យាទៅ ព្រោះខ្លាចកិត្យាវង្វេងផ្លូវ ។

CHANBOKEO.COM

នៅរវាងបួនប្រាំថ្ងៃបន្ទាប់មក កិត្យានិងចាន់ណាតបានធ្វើដំណើរ ឡើងសោះខ្យល់ តាមសាកសួរញាតិគ្រប់គ្នាទាំងអស់ពេញខេត្តព្រះ ត្រពាំង ប៉ុន្តែ នរណាក៏គ្រវីក្បាលដែរ ថាគេមិនបានឃើញមាលានី ឡើយ ។ ពេលមួយនោះ ចាន់ណាតបាននាំកិត្យាទៅសួរនាយ បែនដល់ផ្ទះ ៖

- ណាតអើយ! បងបានការប្រពន្ធចោលនាងនី ធ្វើអោយគេខឹង នឹងបងណាស់ មិនព្រមមើលមុខបងទេ មុននឹងនាងចេញពីស្រុក ទៅរៀងរហូតមកទល់នឹងថ្ងៃនេះ ។ បងក៏ស្តាយក្រោយដែរ ប៉ុន្តែ ធ្វើម៉េចព្រេងវាសនា តម្រូវអោយយើងព្រាត់គ្នា...

កិត្យាស្តាប់ឮរឿងទាំងអស់ហើយ ក៏ត្រឡប់ចេញមកវិញទាំង ឱរាក្តុកក្តួល ។ ពេលនេះ គេបានដឹងច្បាស់ហើយ ថាមាលានីបាន តស៊ូគ្រប់យ៉ាងដើម្បីការសិក្សា ប៉ុន្តែសំណាងនាងមិនល្អ នារីមិនបាន រៀនពេទ្យហើយក៏មិនបានរៀបការជាមួយបុរស ដែលនាងប៉ុនប៉ង ទុកនោះដែរ ព្រោះគេមានប្រពន្ធចោលនាងទៅហើយ ។

មកដល់ភ្នំពេញវិញ...

ក្រុមគ្រួសាររបស់មាលានីជ្រួលច្របល់គ្រប់គ្នា ព្រោះមាលានី មិនដែលវិលត្រឡប់មកផ្ទះវិញទេ តាំងពីថ្ងៃដែលនាងចេញពីផ្ទះ ទៅតាមរកកិត្យាម្ល៉េះ ។ ហេតុដែលនាងបាត់ពីផ្ទះ បានធ្វើឲ្យមាណព យើងរិតតែខ្វល់ខ្វាយឡើង ហើយនឹកស្តាយក្រោយចំពោះភាពឆេវ ឆាវត្រមាត់ត្រមុយរបស់គេ ។ ប៉ុន្តែ ដោយឃើញសភាពទ្រុឌទ្រោម របស់កិត្យាដែលមិនបានគេង មិនបានបាយទឹកត្រឹមត្រូវ អស់ជា ច្រើនថ្ងៃកន្លងមកនេះ ពូនងនិងមីងមៀនហាក់ដូចជាកើតចិត្តនឹក អាណិតកិត្យាណាស់ ថ្វីបើគាត់ខឹងពិរោធចំពោះបុរសយើងដែលជា មេភ្លើងធ្វើអោយមាលានី ចាកចេញពីផ្ទះបាត់ខ្លួនទៅនោះក៏ដោយ ។ ពេលនេះ ពូនងមីងមៀនបែរជាគ្រវីក្បាលដកដង្ហើមធំ នៅស្ងាត់ ស្ងៀម មិនឮស្តីបន្ទោសកិត្យាអ្វីមួយម៉ាត់អោយឆ្អើលក្តុងក្តាំង ដែល ជាហេតុធ្វើឲ្យកិត្យារិតតែបន្ទោសខ្លួនឯងកាន់តែខ្លាំងឡើងៗ ។

ពីរបីថ្ងៃកន្លងទៅ...

មាលានីក៏នៅតែបាត់សូន្យដំណឹងដដែល ។ កិត្យាបានទៅរក ឪពុកម្តាយ ដើម្បីសុំកម្លាំងចិត្តពីលោក ។ ឪពុករបស់កិត្យាក៏មាន ប្រសាសន៍ប្រាប់កូនថា ៖

CHANBOKEO.COM

- ជីវិតគ្រួសារវាដូច្នេះហើយណា៎កូន! អ្វីៗត្រូវសម្រេចដោយ មនុស្សពីរនាក់ ។
បើនិយាយមិនចុះសម្រុងនឹងគ្នា លទ្ធផលគឺដូច្នេះ ឯង... វាធ្វើអោយយើងខ្វល់ខ្វាយ
ស្រាយមិនចេញ ។ ប៉ុន្តែ ក៏គ្មាន អីប្រសើរជាងគ្រួសារយើងដែរ ។ ចិត្តយើងនឹងមានសេចក្តីសុខ
កាលណាយើងទាំងពីរនាក់ចេះយល់ចិត្តគ្នា ហើយចេះបន្ទន់ចិត្ត បន្ទន់កិរិយា
ដើម្បីចុះសម្រុងនឹងគ្នា ។ កិត្យា! កូនត្រូវរៀនពន្លត់ ភាពឆេវឆាវត្រមាត់ត្រមុយរបស់កូនខ្លះទៅ
នោះជីវិតគ្រួសាររបស់ កូននិងមានសេចក្តីសុខជាងនេះមិនខាន ។
- ប៉ុន្តែ កូនទប់ចិត្តមិនបានទេប៉ា បើសិនជានារីដែលកូនរៀបការ
មិនមែនជាក្រមុំបរិសុទ្ធដូចកូនគិតស្មាននោះ! (កិត្យាតប)
- តើធ្វើម៉េចកូននឹងដឹង ថាគេក្រមុំឬមិនក្រមុំ ? (ឪពុកកិត្យាសួរ)
កាលបើកូនមិនដែលឆ្លងកាត់នារីពីមុនមកសោះនោះ ។
- ដឹងណា៎ប៉ា! ក្រែងស្រីក្រមុំតែងតែមានឈាមរក្សំពេលផ្សំដំណេក ដំបូងនោះអី ។
បើសិនមិនមានឈាមរក្សំ មានន័យថាមិនបរិសុទ្ធ!
- នរណាថា ? មិនមែនស្ត្រីទាំងអស់គ្រប់គ្នា មានឈាមរក្សំពេល ផ្សំដំណេករាត្រីទឹកឃ្មុំនោះទេ ។
- ហេតុអ្វីទៅ ប៉ា ?
- អឺ! ជួនកាលអាចគេពិការភេទ ដូចជាពិការត្រចៀក ពិការភ្នែក អញ្ចឹង
កើតមកមិនមានលក្ខណៈប្រក្រតី ជួនកាលធ្លាប់មានជំងឺអ្វី មកបៀតបៀនកាលនៅពីក្មេង
ឬក៏មានមូលហេតុផ្សេងទៀតក្នុង ជីវិតដែលមានតែពេទ្យនិងម្ចាស់ខ្លួនប៉ុណ្ណោះដែលគួរដឹង..
ប៉ុន្តែ... តើសំខាន់អ្វីទៅនឹងព្រហ្មចារីយ៍នោះ កាលបើកូនស្រឡាញ់មាលានី
ដល់ថ្នាក់ហ្នឹងទៅហើយ ?
- ក្រែងព្រហ្មចារីយ៍ ជាចំណងដៃរវាងកម្លោះក្រមុំ នៅរាត្រីទឹកឃ្មុំ នោះអី ប៉ា ?
- ចំពោះអ្នកដទៃគ្រប់គ្នា ប៉ាមិនដឹងទេ! ប៉ុន្តែ បើចំពោះរូបប៉ាវិញ
ព្រហ្មចារីយ៍នារីមិនមែនជាចំណងដៃរាត្រីទឹកឃ្មុំសំរាប់ប៉ាទេ ។
- អូហ៍ ? បើដូច្នោះ តើជាអ្វីទៅវិញ ?
- គឺជាចំណងទឹកចិត្តស្នេហារបស់គូស្រករចំពោះគ្នា ទៅវិញទៅ មកយ៉ាងផ្អែមល្ហែម ។
ព្រហ្មចារីយ៍ គ្រាន់តែជាសំបកស្បែកមួយ បន្ទះយ៉ាងស្តើង កាលបើបានទទួលការប៉ះពាល់ម្តង
ក៏ក្លាយទៅជា អស់ន័យរលីង ប៉ុន្តែទឹកចិត្តស្នេហាភក្តីរវាងគូស្រករវិញមានតម្លៃ មួយជីវិត
រហូតដល់ស្លាប់ ក៏នៅតែមានតម្លៃខ្ពង់ខ្ពស់ដដែល ឥត ផ្លាស់ប្តូរ

CHIANBOKEO.COM

ជាពិសេសតម្លៃទឹកចិត្តដែលគូជីវិតមានចំពោះគ្នាទៅវិញ ទៅមកស្មោះស្មគ្រ័ប្តូរស្លាប់ប្តូររស់ ប្តូររួមសុខទុក្ខជាមួយគ្នាមួយ ជីវិតនោះ ។ ការដែលកូនមានការសង្ស័យនៅក្នុងចិត្ត ជាការ បង្ហាញនូវការខ្វះជំនឿទុកចិត្តចំពោះគ្នា មិនហ៊ានប្រគល់នូវសេចក្តី ស្រឡាញ់ដ៏ធំធេងអោយអស់ពីចិត្តរបស់ខ្លួនចំពោះគូគាប់ កំណាញ់ នូវភាពជិតដិតស្និទស្នាលចំពោះគ្នា... ស្ត្រីគេនឹងទទួលអារម្មណ៍ថា ប្តីមិនបានស្រឡាញ់គេអស់ពីបេះដូង ដូចពាក្យដែលប្តីធ្លាប់និយាយ ប្រាប់គេឡើយ ព្រោះកិរិយារបស់ប្តីប្រកបដោយពិរុទ្ធនិងក្តីសង្ស័យ ដូច្នេះ បេះដូងរបស់នាងនឹងស្លោកស្រពោនដោយក្តីទុក្ខព្រួយ ។ ពេលនោះសេចក្តីសុខក្នុងគ្រួសារក៏ថមថយកិរិតទៅតាមនោះដែរ ។ កាលបើនារីដែលកូនស្រឡាញ់ ថមថយទឹកចិត្ត និងភាពកក់ក្តៅ ជីវិតរបស់កូនក៏ខ្វះភាពរមនាដូចគ្នា ។ ដូច្នេះកូនត្រូវដឹងណាកិត្យា! យើងមិនអាចទាមទារសេចក្តីសុខពីប្រពន្ធបានទេ កាលបើកូនពុំ បានផ្តល់ភាពរមនា សេចក្តីស្រឡាញ់និងការទុកចិត្តដល់នាងដោយ បេះដូងសទ្ធា ។ នេះជាចំណុចហុចទៅបានមក ។ បើសិនកូនហុច សេចក្តីសុខអោយគេ បេះដូងរបស់កូនច្បាស់ជាបានទទួលសេចក្តី សុខត្រឡប់មកវិញជាមិនខាន ព្រោះស្ត្រីដែលរៀបការហើយតែង តែរក្សាភក្តីភាពចំពោះគូជីវិតរបស់ខ្លួនជានិច្ច មិនងាយផ្លាស់ចិត្ត វៀចវេរនឹងស្វែងរកគូថ្មីឬក៏រកក្រៅថៃម ទុកបណ្តោះភាពតប់ ប្រមល់របស់ខ្លួន ផុយៗងាយៗដូចបុរសៗឡើយ ។ ពេលនេះ កូន ធ្វើត្រូវហើយ ដែលកូនមិនស្វែងរកនារីថ្មី ដើម្បីបញ្ជោះបន្សោក ប្រពន្ធ ឬជីវិតខ្លួនឯង ។ បើសិនកូនអាចឆ្លៀតឱកាសកែខ្លួន កែ ស្ថានការណ៍អោយបានឆាប់រហ័ស ជីវិតគ្រួសាររបស់កូននឹងបាន ទទួលសេចក្តីសុខយ៉ាងឆាប់រហ័សត្រឡប់មកវិញដែរណាកូន ។

កិត្យាឈ្ងោកមុខស្តាប់ការពន្យល់របស់ឪពុក ដោយកិរិយាស្ងាត់ ស្ងៀម ទំនងកំពុងពិចារណាប្រសាសន៍របស់លោកហើយ ។ ម្តាយ របស់កិត្យាក៏មានប្រសាសន៍បន្ថែមថា ៖

- ពេលនេះប្រហែលជាប្រពន្ធរបស់កូនកំពុងតែសាកចិត្តកូនហើយ ថាតើកូនពិតជាស្រឡាញ់គេមែន ឬក៏គ្រាន់តែជាអារម្មណ៍ឆាបឆេះ តែមួយពេល ។ បើសិនជាកូនស្រឡាញ់នាងពិតប្រាកដ កូនត្រូវតែ បង្ហាញដួងចិត្តនោះអោយនាងបានឃើញផង ថាកូនពិតជាអាចផ្លាស់ ប្តូរខ្លួនដើម្បីនាង និងដើម្បីសេចក្តីសុខរបស់កូនទាំងពីរនាក់ ។ កូន

CHANBOKEO.COM

ត្រូវត្រឡប់ទៅវិញ ត្រឡប់ទៅរកនាងអោយឃើញ នឹងអាលបាន បង្ហាញនូវសេចក្តីស្នេហាដ៏ស្រស់ថ្លាបរិសុទ្ធរបស់កូនអោយនាងបាន ឃើញ ។ ម៉ាក់ថា មាលានីច្បាស់ជារំភើបចិត្តចំពោះកូនមិនខាន! ពេលនោះ កូនប្រុសម៉ាក់ នឹងបានទទួលនូវភាពទន់ភ្លន់របស់នាង ហើយបេះដូងកូនក៏នឹងបានទទួលសេចក្តីសុខមិនលែងឡើយ ។

កិត្យាក៏រលីងរលោងទឹកភ្នែកឡើង ដោយបានទទួលនូវការណែ យ៉ាងត្រជាក់អំពីឪពុកម្តាយ មិនថាខាងឪពុកម្តាយក្មេក មិនថាខាង ឪពុកម្តាយរបស់ខ្លួនទេ ម្នាក់ៗតែងតែណែនាំកូនដោយភាពស្រទន់ ត្រជាក់ដោយទឹកចិត្តសទ្ធា ធ្វើអោយបេះដូងរបស់មាណពយើងបាន រំងាប់នូវភាពពុះកញ្ជ្រោលឆេវឆាវដោយភាពសង្ស័យនិងភាពអន្ទះ សា ជាពិសេសគឺរំលត់នូវកំហឹងប្រចណ្ឌមាលានីទៅនឹងបុរសនាៗ ដែលនាងបានស្គាល់មុនពេលមករៀបការជាមួយគេ ។

នៅផ្ទះពូនងមីងមៀន...

កិត្យាអង្គុយក្នុងមុង អោបខ្នើយមង្គលរវាងគេនឹងមាលានី ថៃ ថើបមិនចេះអស់មិនចេះហើយ... ពេលវេលាកន្លងទៅ ច្រើនថ្ងៃ ច្រើនអាទិត្យហើយ... មាលានីនៅតែបាត់ស្រមោលទៅមិនមាន ដំណឹងអ្វីបន្តិចសោះ សូម្បីតែមិត្តភក្តិដែលធ្វើការនៅរោងចក្រជា មួយនាងក៏មិនបានដឹងដែរថា នារីយើងទៅណាមកណា ព្រោះនាង បានបាត់ខ្លួនពីការងាររហូតដល់ត្រូវបញ្ឈប់ ហើយត្រូវមានអ្នកថ្មី ចូលមកធ្វើការជំនួសបាត់ទៅហើយ ។

- នី! ហេតុអ្វី ខឹងនឹងបងយូរម្ល៉េះអូន ? តើពេលនេះ អូននៅ ឯណា ? ដឹងទេ បងនឹកអូនណាស់ ហើយបងក៏ស្តាយក្រោយណាស់ ដែរ ដែលបងបណ្តោយអោយភាពល្អក់កករក្នុងចិត្តរបស់បងមក រំខានសេចក្តីសុខក្នុងគ្រួសាររបស់យើង... នី! ឆាប់វិលមកផ្ទះវិញ ណា៎ នឹងអាលអោយបងបានសូមទោសអូនផង ណា៎ប្រពន្ធបណ្តូល ចិត្ត! បងពិតជានឹកអូនខ្លាំងណាស់... មាលានី...! ជីវិតរបស់បង គ្មានពន្លឺរស្មីទេ ពេលដែលគ្មានរូបអូននៅក្បែរ... ពេលនេះបេះដូង របស់បងរងាកណ្តោចកណ្តែងរកអ្វីប្រៀបស្មើមិនបានទេ...

CHANBOKEO.COM

កិត្យាលួចស្រក់ទឹកភ្នែកតែម្នាក់ឯង ។ មែនហើយ! ជាតិជាបុរស ស៊ូស្រក់ឈាម មិនអោយស្រក់ទឹកភ្នែកទេ ប៉ុន្តែ...តើនរណា ម្នាក់ក្នុងលោកនេះដែលថា មិនធ្លាប់មានស្នេហា ? តើបុរសណាមួយ ដែលក្លាហាន មិនចេះរំជើបរំជួលចិត្តចំពោះនារីគូស្នេហ៍ដែលខ្លួន ស្រឡាញ់អស់ពីពោះនោះ ? ជាពិសេសពេលគេដឹងខ្លួនថា បាន ប្រព្រឹត្តកំហុសទៅលើនាង ?

កិត្យាសំកុកអោបខ្នើយមង្គល កើតទុក្ខរៀងរាល់យប់ មិនដែល បានធ្មេចអោយយល់សេចក្តីសុខក្នុងចិត្តបានមួយភ្លែតណាឡើយ ។

ពេលវេលាចេះតែកន្លងទៅ...

កិត្យាក៏កាន់តែរីងរៃឡើងដែរ ។ ថ្ងៃមួយ ស្រាប់តែមានអ្នករត់ម៉ូតូឌុបម្នាក់យកសំបុត្រមួយមកជូនពូនង ។ គាត់ក៏ហែកអានភ្លាម ស្រាប់តែគាត់ស្រែកវ៉ាសឡើងហៅរកកិត្យា ៖

- កិត្យា! យើងទទួលដំណឹងពីមាលានីហើយ ។

បុរសយើងត្រេកអរហើបដើងពីដី ស្ទុះរត់មកលុតជង្គង់សំពះ ឪពុកក្មេកដោយក្តីសោមនស្ស រួចហើយក៏ទទួលសំបុត្រមកអាន មានសេចក្តីយ៉ាងខ្លីថា ៖

- កូននីសុខសប្បាយទេ! សូមពុកម៉ែកុំបារម្ភពីកូនអី! ស្អែកៗកូននឹងត្រឡប់មកផ្ទះយើងវិញហើយ ពេលណាដែលកូនមានអារម្មណ៍ស្រួលក្នុងចិត្តគ្រាន់បើជាងនេះ...

ស្រាប់តែកិត្យាខកចិត្តរលីងធេងតែម្តង ដែលសំបុត្រដ៏ខ្លីនោះពុំមានចារឈ្មោះរបស់គេមួយម៉ាត់ណាសោះ រួចក៏គ្មានអសយដ្ឋានអាចអោយគេទៅរកនាងឃើញដែរ ។ ភ្លាមនោះ នរៈយើងញ័រដៃ ទម្រើកឡើង ហើយធ្វើមុខក្រហមរកស្រក់ទឹកភ្នែក ។ ពូនងឃើញ ហើយក៏យកដៃទះស្មានាយបន្ថើរៗទំនងជួយលួងលោមចិត្តកូន ប្រសារ ៖

- កិត្យា! កុំខ្វល់ខ្វាយច្រើនអី! ហោចណាស់ កូនបានដឹងថាប្រពន្ធ របស់កូនបានសុខសប្បាយដែរ ។

កិត្យាយកដៃឈ្លីថ្ងាស ទំនងចង់រំលត់នូវភាពកង្វល់ក្នុងចិត្ត ៖

CHANBOKEO.COM

- កូនមិនយល់ទេពុក ថាហេតុអ្វី អូននីមិនទុកឱកាសអោយកូន បានសុំទោសនាង ហើយបានកែឆ្នៃស្ថានការណ៍គ្រួសារអោយបាន ប្រសើរឡើងវិញ ? ហេតុអ្វីក៏នាងគេចមុខពីកូនដូច្នេះ ?

ពូនងក្រវីក្បាល ៖

- គិតខុសហើយកិត្យា! ពុកថា ពេលនេះ មាលានីកំពុងទុកឱកាស អោយកូនហើយ ទើបគេធ្វើដំណឹងមកមិនអោយកូនខ្វាយខ្វល់អំពី សុខទុក្ខរបស់នាង ។

- ទុកឱកាសយ៉ាងម៉េចកើត បើនាងមិនទាន់បានទទួលការសុំទោស ពីកូន ហើយក៏មិនទាន់អភ័យទោសអោយកូននៅឡើយនោះ ?

- គឺទុកឱកាសអោយកូនគិត ហើយកែប្រែចិត្តនិងឥរិយាបថរបស់ កូននោះអី ដើម្បីពេលថ្មីដែលនាងជួបកូនម្តងទៀត នាងនឹងជួបតែ សេចក្តីសុខរហូត គ្មានភាពសៅហ្មងព្រឹកល្ងាចដូចពេលមុនៗនោះអី ដឹងទេកូន ?

កិត្យាងើបមុខសម្លឹងពូនង ៖

- ហេតុអ្វីពុកមានជំនឿម្ល៉េះ ថាមាលានីគេគិតដូច្នេះ ?

- ព្រោះពុកជាឪពុករបស់គេ ធ្លាប់ចិញ្ចឹមគេដោយផ្ទាល់ដៃ រឿងអី ដែលពុកមិនស្គាល់ចិត្តកូននោះ ? មាលានីជាមនុស្សមានចិត្តទៀង និយាយទៀង ប្រព្រឹត្តទៀង តាំងពីតូចក្រូចឆ្មារម្ល៉េះ ។ បើនាង សម្រេចចិត្តរៀបការនឹងកូនហើយ គឺពិតជាការសម្រេចដ៏ច្បាស់លាស់របស់នាងថា នាងសាងវាសនាជីវិតជាមួយកូនយ៉ាងជាក់លាក់ ណាស់ ។ ហើយហេតុដែលនាងគេចចេញទៅនោះ ប្រហែលជាគេ ចង់អោយកូនមានឱកាសស្វែងលំនឹងក្នុងចិត្តទេដឹង មុននឹងជួបគ្នា សាជាថ្មី... ? ប្រហែលជានាង មិនចង់រស់នៅក្នុងជីវិតគ្រួសារដែល ប្រកបដោយភាពឃ្លើងឃ្លោងខ្វះលំនឹងក្នុងចិត្តនោះទេ ណ៎កូន!

កិត្យាស្តាប់ហើយ ក៏ដកដង្ហើមយូយ៉ាងវែងបន្ធូរភាពតានតឹងពី ក្នុងឱរា ៖

- បើដូច្នោះមែន កូននឹងត្រៀមខ្លួន ត្រៀមលក្ខណៈសម្បត្តិដែល អូននីពេញចិត្ត ដើម្បីទទួលគេមកផ្ទះវិញ ។

ថ្ងៃនោះ កិត្យាបានចេញទៅក្រៅដើររកការងារធ្វើពេញទីក្រុង ភ្នំពេញ ។ សំណាងល្អ ពីរថ្ងៃក្រោយមក តាមរយៈមិត្តភក្តិរបស់គេ កាលពីនៅរៀនដែលប្រាប់ដំណឹងអំពីការងារដែលគេកំពុងផ្សាយរក បុគ្គលិកថ្មី

CHANBOKEO.COM

កិត្យាបានដាក់ពាក្យប្រឡងចូល ហើយក៏បានជាប់ការងារ
ជាបុគ្គលិកជំនួយរបស់ក្រុមអង្គការក្រៅរដ្ឋាភិបាល សង្គ្រោះក្មេង ពិការមួយ ។
គេធ្វើការមួយអាទិត្យ៦ថ្ងៃ ដើម្បីរកលុយជួយទប់ទល់
សោហ៊ុយក្នុងគ្រួសារពូនងដែលបាត់បង់មាលានីទៅ ។ សល់ពេល ទំនេរ
គេតែងទៅសំកុកនៅមុខព្រះអង្គដង្កើដែលជាទីសក្ការៈសាក្សី រវាងរូបគេនឹងមាលានី
ដែលបានផ្សារភ្ជាប់និស្ស័យជាគូជីវិតនៅ ចំពោះព្រះភក្ត្រព្រះអង្គ ។
ជូនកាលគេក៏ទៅសំកុកនៅសួនច្បារ ក្បាលជ្រោយក្រែងលោបានជួបនារីកំពូលដួងចិត្តរបស់គេវិញ
ប៉ុន្តែ គេមិនដែលបានជួបនាងដូចប្រាថ្នាឡើយ ។ សព្វថ្ងៃនេះ កិត្យារស់ នៅស្ងៀមស្ងាត់
មិនសូវមាត់ក មិនសូវបញ្ចេញអារម្មណ៍មកក្រៅ អោយនរណាបានដឹង
ថាបេះដូងរបស់គេមានពណ៌យ៉ាងណាហើយ ទេ ។ គេក៏បានជួបនារីប្លែកៗជាច្រើននាក់
ដែលធ្វើការជាមួយគ្នា នៅឯការិយាល័យអង្គការ ប៉ុន្តែគ្មាននរណាម្នាក់អាចអង្រួនបេះដូង របស់គេ
អោយរំភើបរំដើបរំជួលញាប់ញ័រមកវិញឡើយ ព្រោះសូរ សម្លេងខ្សឹកខ្សួលរបស់មាលានី
តែងតែចេញមកប្រលែងអារម្មណ៍ របស់គេរៀងរាល់រាត្រី ។
នរៈយើងគេងនឹកអាល័យរូបនាងស្ទើរតែ ប្រេះទ្រូងក្ស័យសង្ខារម្ដងៗទៅហើយ...
- អូននី! តើថ្ងៃណាយើងជួបគ្នាវិញ ? ហេតុអ្វីអូនដាក់ទោសបង ឲ្យបងរីងរៃយូរម្ល៉េះអូន ?
បងនឹកអូនណាស់ មាលានី ប្រពន្ធតែ មួយរបស់បង!
   កិត្យាតែងតែធ្មេចភ្នែកប្រឡៅងជាមួយអនុស្សាវរីយ៍រវាងគេនឹង មាលានីតែម្នាក់ឯង
រៀងរាល់ពេលផ្ដេកកេសាលើខ្នើយមង្គល ដែល
ផ្ដិតស្នាមចំណងដៃរាត្រីទឹកឃ្មុំក្រមុំកម្លោះដ៏ផ្អែមល្ហែមបំផុត...

   បួនខែកន្លងទៅ...
   អាទិត្យនេះ ក្រសួងត្រូវបិទការិយាល័យបីថ្ងៃ ដើម្បីចូលរួម ប្រារព្ធបុណ្យជាតិ ។
កិត្យាឆ្លៀតពេលទំនេរតាមស៊ើបសួរដំណឹងពី មាលានីម្ចាស់បេះដូងរបស់គេ ។ ថ្ងៃនេះ
គេជិះម៉ូតូទៅក្បាលជ្រោយ ទៀតហើយ ។ គេនៅអង្គុយសំកុកលើវាលស្មៅ ម្នាក់ឯង សម្លឹង
មនុស្សម្នាទាំងឡាយទាំងដួងចិត្តខ្វាយខ្វល់ ។
   រំពេចនោះ គេហាក់ដូចជាចាប់ភ្លឹកអ្វីម្យ៉ាង ។ គេក៏ដើបឡើង
បណ្ដើរម៉ូតូទៅឈប់នៅផ្ទះតៀមតូចមួយតាមដងផ្លូវ ដែលកំពុង

តាំងគ្រឿងវត្ថុអនុស្សាវរីយ៍ប្លែកៗ មានតាំងពីខ្សែដៃ ខ្សែកអង្កាំ កងដៃវល្លិ៍ផ្ដៅ ស្បែចាក់ដោយដៃ កន្ត្រកយួរ ខោអាវក្មេងៗជាម៉ូដ ខ្មែរប្រពៃណី ។ អ្វីដែលចាប់ភ្នែកជាងគេនោះ គឺឥវាន់ទាំងឡាយ ដែលក្រងអំពីកំប្លោក ។ គេយកដៃទៅស្ទាបអង្អែលកូនតុក្កតាកុមារី មួយយ៉ាងស្រស់ស្អាត ក្រងអំពីសរសៃកំប្លោកហាល ហើយក៏ដោះ យកមកកាន់ រួចហើយក៏សួរម្ចាស់តូបដែលជាក្មេងស្រីជំទង់ម្នាក់ ៖

- ថ្លៃប៉ុន្មានដែរ នាងតូច ?

- ចាស ! មិនដឹងទេ ចាំខ្ញុំសួរម៉ែសិន !

នាងតូចនោះអើតកទៅខាងក្រោយផ្ទះ ស្រែកសួរម្ដាយនាង ស្រាប់តែមានសម្លេងក្មេងប្រុសឆ្លើយថា ៖

- ម៉ែទៅទទួលអីវ៉ាន់មកពីផ្ទះតាយាយទៀតហើយ មិនទាន់មកវិញ ទេ ។ បងឯងលក់តែអីវ៉ាន់ណាដែលបងដឹងតម្លៃសិនទៅ បន្តិច ទៀត ម៉ែយើងមកវិញហើយ ។

ក្មេងស្រីនោះក៏បែរមកវិញ ហើយស្រដីថា ៖

- ម៉ែមិននៅ ពួកយើងមិនដឹងតម្លៃទេ ពូចាំបន្តិចបានទេ ពេលម៉ែ មកដល់វិញ ចាំទិញពីគាត់ទៅ ។

កិត្យាលើកតុក្កតាមកកាន់មើលយ៉ាងយូរ ហើយលួចខ្សិបសួរ ខ្លួនឯងក្នុងចិត្តថា ៖

- តើនេះជាស្នាដៃរបស់អូនមែនទេ ប្រពន្ធសម្លាញ់របស់បង ?

ពេលនោះ កិត្យាត្រេកអររំភើបក្នុងចិត្ត យ៉ាងណាមិនដឹងទេ ស្រាប់តែឈ្លួលចុងច្រមុះ រកស្រក់ទឹកភ្នែកតែម្ដង ។ គេប្រឹងព្រិច ភ្នែកយ៉ាងញាប់ ដើម្បីបន្លប់ភាពញាប់ញ័រនៅក្នុងដួងចិត្ត បន្តិចមក ក៏និយាយទៅកាន់ក្មេងស្រីនោះថា ៖

- អោយពូសុំអង្គុយចាំក្នុងតៀមរបស់ប្អូនបានទេ ទំរាំម្ដាយរបស់ ប្អូនមកវិញ ។

- ចាស ! មានអី ! ហើយបើពូចង់ជាវឥវ៉ាន់អីៗទៀត សូមដើរ មើលតាមចិត្តចុះចាស !

កុមារីស្រដីតបដោយកិរិយាទន់ភ្លន់ ។ កិត្យាដាក់ខ្លួនចុះលើកៅអីខៀវមួយក្បែរមាត់ទ្វារ សម្លឹងគ្រប់ឥវ៉ាន់ទាំងឡាយដែលដាក់តាំង លក់នៅទីនោះ ឃើញហាក់ដូចជាមានទឹកដមស្នាដៃប្លែកៗណាស់ ហើយមួយណា ក៏មានសញ្ញាបង្ហាញអត្តសញ្ញាណរបស់ជាតិខ្មែរដែរ សមជាស្នាដៃបុគ្គលដែលស្រឡាញ់ជាតិកំណើតរបស់ខ្លួនយ៉ាងមុតមាំ បំផុត ។ កំពុងតែលួចស្ងើចសរសើរស្នាដៃរបស់អ្នកក្រងនៅក្នុងចិត្ត

CHANBOKEO.COM

កិត្យាបានដាក់ភ្នែកទៅចំក្រដាសប្រាក់ប្រាំពាន់រៀលមួយសន្លឹកដែល រុំនឹងចង់ផ្កាស្អិក បិទជញ្ជាំង ។ គេក៏លាន់មាត់សួរនារីជំទង់យាមតូប នោះថា ៖

- ការបិតលុយទុកលើជញ្ជាំងនោះ ជាសញ្ញានាំរាសីជោគជ័យដល់ការរកស៊ីរាល់ថ្ងៃរបស់គ្រួសារនាងតូចមែនទេ ?

នាងតូចនោះឮហើយក៏ញញឹមឡើង ហើយឆ្លើយថា ៖

- ចាស! អត់ទេ! ការពិត គឺជាការរំលឹកនូវសម្ពន្ធ័មិត្តភាពរបស់ញាតិពីរនាក់ដែលម៉ែរបស់ខ្ញុំបានជួបនៅម្ដុំៗនេះ ។ ម៉ែតែងរំលឹក ថាញាតិទាំងពីរនោះបានណែនាំអោយគាត់ឈប់រកស៊ីលក់កូនចាប ហើយបែរមកចាប់របរថ្មីទៀតដែលអាចនាំអោយគាត់មានរាសីល្អ ហើយរកលុយចិញ្ចឹមគ្រួសារមានប្រាក់ចំណូលច្រើនជាងមុន ។

កិត្យាភ្ញាក់ព្រើត កាលបើឮដូច្នោះ ក៏ស្រម័យទៅដល់មាលានី និងមីងលក់ចាប ។ ភ្លាមនោះ គេសួរថា ៖

- ហើយហេតុអ្វីបានជាសន្លឹកប្រាក់ ដែលដាក់តាំងលើជញ្ជាំងនោះ មានសរសេរអក្សរតូចល្អិតៗពីលើ ដូចគេចារយ័ន្តដូច្នោះ ? ឬក៏ម្ដាយរបស់ប្អូនបានយកទៅបញ្ចុះមន្តសក្ដិសិទ្ធ ដើម្បីអោយរកស៊ី ធូរធារមានបាន ?
- អត់ទេ! គឺជាស្នាមសរសេររបស់បងស្រីម្នាក់ដែលជួយបង្រៀនពួកយើងក្រងវត្ថុអនុស្សាវរីយ៍ទាំងនេះ ។ គាត់បានចារតួរអក្សរលេងពីលើលុយនោះ ពេលគាត់មកលេងពួកយើង ប៉ុន្មានថ្ងៃមុន ។

កិត្យាភ្ញាក់ក្រញាង ដូចគេចាប់គ្រវែងទម្លាក់ពីលើមេឃអញ្ចឹង! គេក៏លាន់មាត់សួរនាងទៀតថា ៖

- បងស្រីម្នាក់បង្រៀនក្រងរូបតុក្កតា និងស្នុក កន្តាំងក្បាច់ទាំង អស់នេះ ឈ្មោះមាលានីមែនទេ ?
- ចាសមែនហើយ... ម៉េចក៏ពូស្គាល់គាត់ដែរ ?

ភ្លាមនោះ កិត្យាដើបឈរឡើង ៖

- ស្គាល់! ពូស្គាល់គេច្បាស់ណាស់! នាងតូច អោយពូសុំមើល លុយមួយសន្លឹកនោះ បន្តិចបានទេ ?

នាងតូចនោះញញឹម ហើយដោះលុយនោះហុចអោយមាណព យើងភ្លាម ៖

CHANBOKEO.COM

- ពូអានចែកពួកយើងស្តាប់ផង ព្រោះខ្ញុំចង់ដឹងថា បងស្រីគាត់ សរសេរអំពីអ្វីដែរ
ព្រោះពួកយើងមិនបានរៀន មិនចេះអានអក្សរ ខ្មែរទេ ។

កិត្យាសម្លឹងកុមារី នឹកអណោចអធម្មក្នុងចិត្តណាស់ កាលបើឮ នាងតូចនោះស្រដីដូច្នោះ ព្រោះវ័យដូចនាងគួរណាស់តែបានទទួល ការសិក្សា មិនគួរណាល្ងិតល្ងង់ដូច្នោះសោះ ។ គិតទៅភាពក្រីក្រធ្វើ អោយមនុស្សរិតតែល្ងង់ខ្លៅឡើងចៀសមិនរួច ។

នរៈលូកដៃទទួលយកប្រាក់មួយសន្លឹកនោះ មកពិនិត្យមើល
រួចហើយក៏អានពាក្យដែលចារលើនោះ មានសេចក្តីថា ៖

- ពិតជាមិនយល់សោះថា បុរសម្នាក់ដែលមានចិត្តស្លូតបូតទន់ភ្លន់
អាណិតស្រណោះសូម្បីតែជីវិតកូនចាបតូចៗ ប៉ុន្តែហេតុអ្វីបានជា គេគ្មានបេះដូងទន់ភ្លន់
អាណិតស្រឡាញ់ប្រពន្ធរបស់គេ ? ចុះកូន របស់គេវិញ...
តើគេមានចិត្តមានអារម្មណ៍យ៉ាងណាដែរទៅ ចំពោះ
តំណក់លោហិតដែលគេផ្តិតចោលដោយថែដន្យ ? ឬក៏គេជាមនុស្ស អាត្មានិយម
ធ្វើពើជាអាណិតសត្វ ដើម្បីទាក់ចិត្តនារីភេទអោយលង់ អន្ទាក់កាមគុណរបស់គេ ?
បើដូច្នោះពិតមែន គេជាមនុស្សដែល គួរឲ្យខ្លាចបំផុត នៅក្នុងលោកនេះ
មិនគួរអោយជួបមុខតទៅ ទៀតទេ...!

កិត្យាអានចុះអានឡើង ទាំងដៃញ័រទទ្រើកដោយវិប្បដិសារី ៖

- ម៉េចក៏ថាបងគ្មានបេះដូងទន់ភ្លន់សំរាប់ប្រពន្ធនោះ ?

កិត្យាវាចាខ្សិបៗ ។ បេះដូងរបស់គេក៏ក្រញ្ជ្រោលឡើងស្ទើរតែ ធ្លាយទ្រូងមកក្រៅ ។
គេងើបមុខឡើងងើយមើលទៅពិដាន ដើម្បី លេបទឹកភ្នែកទុកក្នុងទ្រូង
ព្រោះក្តីអាល័យចំពោះមាលានីមាណវី ម្ចាស់ស្នេហ៍ ។
ក្មេងស្រីជំទង់នោះឃើញកិរិយាចម្លែករបស់កិត្យា ក៏នៅស្ងៀមមិនហ៊ាននិយាយសួរអ្វីទេ
គិតតែពីអង្គុយធ្វើភ្នែកម៉ក់ ។ បន្តិចមក កិត្យាទប់អារម្មណ៍បាន ក៏សួរទៅនាងតូចនោះថា ៖

- នាងតូចដឹងទេ ថាបងស្រីដែលបង្រៀនប្អូនក្រងស្មុកនោះ នៅ ឯណាដែរ ?

នាងគ្រវីក្បាល ៖

- គាត់បានផ្តាំផ្តាច់ហើយថា គាត់មិនជួបញាតិណាទេ ។
- ហេតុអ្វីទៅ ?
- ព្រោះគាត់ថា មានមនុស្សតាមយាយីជីវិតរបស់គាត់...

CHANBOKEO.COM

- ខុសហើយនាងតូច... ការពិត អ្នកដែលតាមរកបងស្រីនោះគឺជា បុរសដែលស្រឡាញ់នាងបំផុតនៅក្នុងលោកនេះ ។

ឮសំដីនោះភ្លាម នាងតូចក៏បើកភ្នែកធំៗ ។ កិត្យាងក់ក្បាល ៖

- មែនហើយ! ពូគឺជាប្ដីរបស់បងស្រីម្នាក់នោះ... ពូតាមរកនាង យូរហើយ ។

នាងតូចភ្ញាក់ក្រញាង ។ តែលុះឃើញបុរសយើងមានទឹកភ្នែក រលីងរលោង នាងក៏នឹករអាណិតពន់ពេក ក៏ស្រែកហៅប្អូនប្រុស អាយុប្រហែល១២ឆ្នាំ ឲ្យជូនដំណើរកិត្យាទៅផ្ទះតាយាយ ។

កន្លះម៉ោងក្រោយមក...

កុមារបាននាំកិត្យាមកដល់ផ្ទះឈើចាស់មួយ ដែលគ្មាននរណា នៅផ្ទះម្នាក់សោះ ព្រោះគេចេញទៅធ្វើការរកស៊ីអស់ ។ កុមារយក ដៃចង្អុលទៅខ្ទមស្បូវតូចមួយ ដែលសង់ទេរចុះចូលទៅក្នុងបឹង កំប្លោក នៅឆ្ងាយពីផ្ទះធំប្រហែលពីររយម៉ែត្រ ៖

- បងស្រីនៅទីនោះហើយ! ពូទៅជួបគាត់ទៅ ។ ខ្ញុំរត់ទៅលេង តាយាយនៅម្ដុំៗនេះទេ ។ មួយម៉ោងទៀត ចាំខ្ញុំត្រឡប់មកវិញ ។

ថាហើយ កុមារនោះក៏រត់ចេញទៅ ។ កិត្យារន្ធត់ចិត្តក្ដុកក្ដាក់ៗ ញ័រដៃញ័រជើងរកថាមិនត្រូវ ។ គេក៏បោះជំហានចូលទៅក្នុងខ្ទម ស្បូវដែលមានទ្វារបង្អួចបើកចំហយកខ្យល់អាកាស ។ នៅរានហាល ចំហៀងខ្ទមដែលសង់លយទៅក្នុងទឹកបឹងកំប្លោក កិត្យាប្រទះឃើញ មាលានីរំសាយកេសាវែងអន្លាយ អង្គុយបត់ជើងបែរខ្នងមករកគេ កំពុងពត់ខ្សែកំប្លោកស្ងួតកាច់ចុះកាច់ឡើងជារូបរាង ។ ភ្លាមនោះ បេះដូងកិត្យាក៏រណ្ដំចង្វាក់ស្នេហាយ៉ាងញាប់ញ័ររន្ថើន ។ នរៈដើរ ចូលលបៗ យឺតៗ ទំនងមិនចង់អោយម្ចាស់ខ្ទមមានការភ្ញាក់ផ្អើល រួច ហើយក៏ទៅដាក់ខ្លួនលុតជង្គង់ពីក្រោយនារី ហើយលាតរង្វង់ដៃ ស្រវាអោបចង្កេះនាងពីក្រោយយ៉ាងរហ័សព្រមទាំងស្រដីខ្សិបៗ ៖

- នី ប្រពន្ធបណ្ដូលចិត្តបង!

ស្រាប់តែមាលានីភ្ញាក់ក្រញាងបម្រះយ៉ាងរហ័ស ថែដន្យកិត្យា បានត្រៀមខ្លួនទុកជាមុនស្រេចហើយ ។ គេមិនបណ្ដោយអោយនារី ងើបគេចរត់ទៅណារួចឡើយ ។ គេស្រវាអោបនាងបន្ថែមទៀត រួចវាចាដោយសំដីអួលរកស្រក់ទឹកភ្នែក ៖

- អូននី! បងមកសុំទោសអូនហើយ! អភ័យទោសអោយបងផង ណាអូន!

ស្រាប់តែគេទប់ទឹកភ្នែកលែងជាប់តែម្តង ។ មែនហើយ! គេចង់យំទម្លាយអារម្មណ៍របស់គេយូរហើយ តែគេធ្វើមិនបាន ។ ពេល នោះគេបានត្រកងអោបនារីម្ចាស់បេះដូង ដែលគេគេងនឹករលឹក រាប់ខែមកហើយនោះ តើមិនអោយគេរំភើបចិត្តម្តេចនឹងបានទៅ ?

កិត្យាលុតជង្គង់អោបចង្កេះនារីពីក្រោយ សំរក់ទឹកភ្នែកយ៉ាងយូរ ។

ចំណែកមាលានីវិញ ក៏នៅសម្ងំស្ងៀម ក្នុងរង្វង់ដៃស្វាមី លែង រើបម្រះតទៅទៀត ។ ពេលវេលាក៏ហោះអណ្តែតទៅយ៉ាងយឺតៗ...

ពេលនោះ កិត្យាបានទទួលអារម្មណ៍ថា មាលានីក៏ទទួលភាពញាប់ញ័រក្នុងកាយមិនខុសប៉ុន្មានពីរូបគេទេ ។ ដៃនាងត្រជាក់ស្រេបដូច ទឹកកក ។ ឯខ្លួននាងញ័រទទ្រើក ។ ភ្លាមនោះ ដៃស្តាំរបស់កិត្យា ដែលស្រវាអោបចង្កេះប្រពន្ធយូរហើយ ស្រាប់តែទទួលអារម្មណ៍ថា មានអ្វីកម្រើកកញ្ជ្រោលក្នុងផ្ទៃពោះរបស់មាលានី មកប៉ះបាតដៃរបស់គេស្រាលៗ ។ កិត្យាភ្ញាក់ក្រញាងស្ទុះងើបមកឈរពីមុខនារី ហើយស្រវាលើកកាយនាងអោយឈរឡើងមកដែរ ។

- អោយបងសុំអោបកូនដែលនៅក្នុងផ្ទៃរបស់អូន ដើម្បីផ្តល់ការ កក់ក្តៅដល់គេខ្លះបានទេ ប្រពន្ធសម្លាញ់ ?

ភ្លាមនោះ កិត្យាប្រទះឃើញទឹកភ្នែកថ្លាៗ ពីរតំណក់រមៀលចុះចេញពីកែវភ្នែករបស់មាលានី ។ នរៈក៏លើកដៃទៅផ្ចិតចេញពីផ្ទៃ មុខរបស់នាង ៖

- នី! បងសុំទោសចំពោះពាក្យពេចន៍និងកិរិយា ដែលបងបានធ្វើមិនសមរម្យចំពោះអូនកន្លងមក! បងមកជួបអូនពេលនេះ គឺដើម្បីសុំចាប់ផ្តើមជីវិតជាថ្មីជាមួយអូននិងកូនរបស់យើង ដែលបំរុងនឹង ប្រសូត្រមកឆាប់ៗនេះ ។ បងសន្យាថានឹងផ្តល់សេចក្តីកក់ក្តៅដល់ គ្រួសារយើង មិនឲ្យមានរឱស្ថានដូចកាលគ្រាមុនៗទៀតឡើយ ។

ថាហើយ គេក៏ស្រវាអោបនាងយ៉ាងណែន ។ ភ្លាមនោះមាលានីក៏ទ្រោបមុខលើដើមទ្រូងកិត្យាទ្រហោយំខ្សឹកខ្សួលតែម្តង ។ កិត្យា អង្អែលខ្នងភរិយាបន្តើរៗ បញ្ជាក់នូវក្តីស្រឡាញ់និងការថ្នាក់ថ្នម ដែលគេមានចំពោះនាង ។ ទឹកភ្នែករបស់មាលានីមិនខុសឡើយពី អន្លូងទូងដាស់សតិរបស់មាណព

CHANBOKEO.COM

អោយភ្ញាក់ពីភាពសង្ស័យទាំង ឡាយដែលគេធ្លាប់មានចំពោះប្រពន្ធ ។ មែនហើយ! ឪពុកម្តាយរបស់គេមានប្រសាសន៍ត្រូវណាស់ ។ កាលបើរូបគេមិនបានប្រគល់ ភាពរមនាដល់ដួងចិត្តភរិយា មាណពក៏មិនអាចបានទទួលវិញដែរ នូវភាពរមនាដែលប្រពន្ធអាចប្រគល់មករូបគេវិញ ។ ពេលនេះ បុរសយើងបានយល់ការឈឺចាប់ផ្លូវចិត្តរបស់ភរិយាហើយ ឈឺចាប់ព្រោះប្តីមិនបានផ្តល់ភាពរមនាដល់ដួងចិត្តរបស់នាង... រហូតដល់ខំរត់មកលាក់ខ្លួនបំពួនកាយយ៉ាងឆ្ងាយពីប្តី ដើម្បីរំងាប់អារម្មណ៍...

- ឈប់យំទៅអូន! បងសន្យាថា ចាប់ពីថ្ងៃនេះតទៅ បងឈប់មានកិរិយាល្អក់កករចំពោះអូនទៀតហើយ ។ យើងមានតែសេចក្តីស្រឡាញ់ចំពោះគ្នាតែម្យ៉ាងប៉ុណ្ណោះ ។

កិត្យាក៏សំរូតខ្លួនលុតជង្គង់ចុះ យកថ្ពាល់របស់ខ្លួនទៅផ្ទិមនឹង ផ្ទៃពោះរបស់មាលានី ៖

- កូនរបស់ប៉ាអើយ! សូមអភ័យទោស អោយប៉ាផង ព្រោះជាង ប្អូនខែកន្លងមកនេះ ប៉ាមិនបានថែរក្សាម៉ាក់កូន និងរូបកូនអោយ សមជាមេគ្រួសារទេ ។ ចាប់ពេលនេះទៅ ប៉ាមិនអោយកូននិងម៉ាក់ កូនមករស់នៅរសាត់អណ្តែតដូច្នេះទៀតឡើយ...ប៉ាក្រៀមក្រំណាស់ គឺយើងក្រៀមក្រំទាំងសងខាង... អោយប៉ាសុំពេលវេលាបាននៅ ជិតម៉ាក់កូន និងនៅជិតកូន ដើម្បីថែរក្សាអ្នកទាំងពីរផងណា៎! ។

ថាហើយ គេក៏លូកដៃស្រវាអោបថង្កេះមាលានីសាជាថ្មី ដោយ សេចក្តីស្នេហាយ៉ាងធំធេង គ្មានពាក្យណានឹងថ្លែងអោយសមស្មើ បាន ។ ចំណែកមាលានីមានការភ្ញាក់ផ្អើលណាស់ ចំពោះវត្តមាន របស់កិត្យានិងភាពទន់ភ្លន់របស់គេចំពោះនាង គឺខុសផ្ទុយស្រឡះពីថ្ងៃចុងក្រោយដែលគេដើរចេញពីផ្ទះរបស់នាងទៅ... មាណវីរំជួល ចិត្តក្រៃណា ។ ដំបូងនាងគិតថានឹងគេចមិនអោយជួបគេវិញទេ មួយជីវិតនេះ តែលុះដល់ជួបមុខគេ នាងបែរជាធ្វើមិនបាន ដូចចិត្ត ដែលនាងប៉ងប្រាថ្នានោះអ្វីបន្តិចឡើយ ។ វត្តមានរបស់គេបានធ្វើឲ្យបេះដូងរបស់នាងទន់ជ្រាយហើយញាប់ញ័រស្ទើរទប់ចិត្តមិនបាន ។

ឃើញប្រពន្ធនៅឈរស្ងៀម កិត្យាក៏ចាប់ចង្កាភរិយាភ្ញើយឡើង ហើយមានវាចាទៅកាន់នាងថា ៖

- ត្រឡប់ទៅផ្ទះយើងវិញណា៎ អូននី! បងមកទទួលអូនហើយ!

មាលានីងើបមុខឡើង សម្លឹងកែវភ្នែករបស់កិត្យា ធ្វើកិរិយាហាក់ដូចជាមិនទុកចិត្តស្វាមីរបស់នាងអ្វីបន្តិចឡើយ ។

CHANBOKEO.COM

- អោយខ្ញុំសុំគិតមួយថ្ងៃសិនបានទេ ? ចាំស្អែក ខ្ញុំនឹងជូនដំណឹង!
- អត់ទេ អូននី! បងបានចាំអូនយូរណាស់ហើយ ចាំរហូតដល់
អស់ថ្ងៃស្អែកនឹងរង់ចាំទៀតហើយ ។ ស្អែកទាំងនោះបានចាកផុត អស់ហើយ
យើងមានសល់តែថ្ងៃនេះ គឺថ្ងៃដែលយើងស្រឡាញ់គ្នា ថ្នាក់ថ្នមគ្នា!
យើងមិនបាច់រង់ចាំថ្ងៃស្អែកតទៅទៀតទេអូន ។

មាលានីឈ្ងោកមុខ ជ្រួញចិញ្ចើមទំនងគិត មួយស្របក់ក៏វាចា ឡើងថា ៖

- តើធ្វើម៉េចនឹងមាលានីនឹងទៅ ថាបងឈប់ឆេវឆាវ ហើយឈប់ ចុះចេញពីផ្ទះ
ពេលបងខឹងនឹងអូនម្តងៗ ? នីពិតជាទ្រាំមិនបានទេ ដែលត្រូវចេញតាមរកប្តីព្រឹកល្ងាចៗ
ព្រោះតែគេប្រច័ណ្ឌខុសទំនង ដដែលជាងដែល...
- ប៉ុន្តែ... បងបានផ្តាច់និស្ស័យផ្តេសផ្តាសនោះចោលហើយ បង ហ៊ានសន្យាដោយជីវិត!
- ផ្តាច់និស្ស័យបានពិតមែនឬបង ?

កិត្យាងក់ក្បាល ។ មាលានីក៏វាចាបន្តទៀតថា ៖

- ហើយ បងនៅចង់នឹងទៀតទេ ថាអូនមានប្រវត្តិអាស្រូវជាមួយ បុរសណាខ្លះ ?

ឮដូច្នោះ បុរសយើងបែរជាស្រវាអោបនាងខ្លាំងជាងមុន ៖

- លែងចង់នឹងហើយ ព្រោះអតីតកាលរបស់អូនលែងសំខាន់សំរាប់ បងហើយ ។ អ្វីដែលសំខាន់
គឺបច្ចុប្បន្នរបស់អូន... ហើយបច្ចុប្បន្ន នេះ អូនគឺជាប្រពន្ធតែម្នាក់គត់របស់បង
ជានារីដែលបងស្រឡាញ់ លើសអ្វីទាំងអស់នៅក្នុងលោកនេះ!

មាលានីក៏ញញឹមឡើង ទទួលយករង្វង់ដៃនឹងការថៃថើបរបស់
ស្វាមីដោយក្តីស្រឡាញ់យ៉ាងធំធេង ។ នាងក៏ស្រវាអោបប្តីវិញយ៉ាង
ណែនដោយការនឹករលឹករកអ្វីប្រៀបមិនបាន ។ ពេលនេះ ពិភព
លោកក៏បានប្រែមានពន្លឺភ្លឺត្រកាលយ៉ាងចំព្រងវិញហើយ...

ព្រលប់ ថ្ងៃដដែល....

ទាំងឪពុកម្តាយកិត្យា ទាំងឪពុកម្តាយនិងក្រុមគ្រួសាររបស់ មាលានីមានការភ្ញាក់ផ្អើលណាស់
ដែលឃើញកិត្យាបាននាំខ្លួនប្រពន្ធ ត្រឡប់មកផ្ទះវិញដោយសុខសប្បាយ ។
ទាំងអស់គ្នាបានរត់ទទួល
នារីយើងដោយក្តីត្រេកអរសោមនស្សក្រៃលែង ។

CHANBOKEO.COM

នៅក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់គេ ដែលមានជញ្ជាំងជាក្រណាត់ វាំងននចាស់ពីរផ្ទាំង បាំងពីញែករូបគេពីក្រុមគ្រួសារ...

កិត្យារៀបកន្លែងទទួលភរិយាយ៉ាងផ្ចិតផ្ចង់បំផុត ។ ពេញមួយ ថ្ងៃនេះ គេបានសម្តែងនូវការរំភើបចិត្តចំពោះមាលានីនៅមុខគេឯង ដោយមិនមាននឹកអៀនខ្មាស់នរណាឡើយ ។ នេះជាលើកទីមួយ ហើយដែលមាលានីគិតថា កិត្យាមិនទាមទារការចាប់អារម្មណ៍ពីនាង ទេ ផ្ទុយទៅវិញ គេបែរជាផ្តល់នូវការថ្នាក់ថ្នមរបស់គេយ៉ាងទន់ ភ្លន់បំផុតមកលើរូបនាង ។ ធិតាអង្គុយសម្លឹងឥរិយាបថរបស់កិត្យា ពេញមួយថ្ងៃ ចង់នឹងថាតើគេពិតជាផ្លាស់ប្តូរមែនឬក៏យ៉ាងណា ។ បន្តិចមក កិត្យាយកដៃគោះខ្នើយមង្គល រួចហើយក៏ស្រវាទាញកាយ ប្រពន្ធអោយទំរេតលើខ្នើយថ្នមៗ ។

- គេងទៅនី! ខ្នើយមួយនេះកំពុងនឹកអូនខ្លាំងណាស់!

មាលានីទំរេតខ្លួនលើខ្នើយ ហើយស្រដីតបថា ៖

- បើសិនជាខ្នើយនេះនឹកអូនពិតមែន សូមអោយគេថ្នាក់ថ្នមចិត្ត អូនអោយត្រជាក់ យល់តែសេចក្តីសុខរាល់យប់រាល់ថ្ងៃកុំបីខាន ។

កិត្យាក៏ដាក់ក្បាលលើខ្នើយក្បែរនារី ៖

- ចំណែកម្ចាស់ខ្នើយម្នាក់ទៀតក៏នឹកអូនដូចគ្នាដែរ...

- តើគួរអោយនីជឿដែរទេ ថាម្ចាស់ខ្នើយនោះគេនឹកអូនពិតមែន ?

ភ្លាមនោះ កិត្យាយកដៃត្រកងកាយភរិយា មកផ្ទាប់នឹងដើម ទ្រូងរបស់គេ យ៉ាងណែនតែម្តង ៖

- លើកនេះ បងអោយអូនសាកល្បងចិត្តបងម៉ាស្រឡាញ់! ចង់ សាកទេអូន ?

- បងប្រាកដហើយឬ ថាបងមិនឆេវឆាឡោតដើរចោលនីអោយ គេងតែម្នាក់ឯងទៀត ?

- សូមស្បថថ្វាយព្រះ ណា៎អូន! កាលនោះ បងដើរចេញពីអូនតែ មួយយប់ទេ ស្រាប់តែដល់ពេលបងត្រឡប់មកវិញ អូនបែរជាដើរ ចោលបងដល់ទៅរាប់ខែឯណោះ!

- អញ្ចឹង បងឈប់ចង់សាកទៀតហើយហ្ន៎ស ?

- ឈប់ហើយ! បងសុំលើកទង់ជ័យសហើយណា៎! ស្រីៗគេប៉ិន ខឹងរឺបានយូរណាស់ មិនងាយរសាយទេ ។

CHANBOKEO.COM

- ពេលនេះ បងយល់ហើយឬនៅ ថាអារម្មណ៍អ្នកដែលត្រូវគេ ទន្ទឹងរង់ចាំផ្លូវគូជីវិត ពិបាកក្នុងចិត្តយ៉ាងម៉េច ?

កិត្យានៅស្ងៀម ។ បន្តិចមក មាលានីក៏ស្រដីបន្តទៀតថា ៖

- លើកក្រោយ បើយើងមានរឿងអ្វីរំខានចិត្ត យើងជជែកគ្នាដោយ ស្រួល មិនបាច់ប្រើហឹង្សាឆេវឆាវ បានទេបង ?

- បាទ! យល់ព្រម! ពេលនេះ បងកំពុងរៀនសូត្រពីជីវិតគ្រួសារ ហើយ ។ បើសិនមានការខុសឆ្គង អូនអភ័យទោសអោយបង ផងណា! កុំខឹងនឹងបង យូរខែអញ្ចឹងទៀតណាអូន ។

មាលានីសម្លឹងមុខកិត្យាដោយក្រសៃភ្នែកភ្លឺថ្លាផ្លេកៗ រួចហើយ ក៏ឆ្លើយថា ៖

- បើកាលនោះអូនមិនគេចចេញទៅទេ បងក៏មិនមានឱកាសនឹង បានស្គាល់រសជាតិនៃការបាត់បង់មនុស្សជាទីស្រឡាញ់នោះដែរ ។

- ប៉ុន្តែ ហេតុអ្វីដល់ទៅប្អូនខែផង ?

- នោះគឺការជ្រើសរើសរបស់បងតើហ៎! កាលនោះ មីងលក់ចាប បានប្ដូរមកលក់គ្រឿង វត្ថុអនុស្សាវរីយ៍ឆ្ងាយគ្នាតែប្អូនដប់ម៉ែត្រពី កន្លែងលក់ចាប ក៏បងមិនព្រមទៅរកគាត់ដែរ ។ អូនតែងតែផ្ដាំ អោយគាត់ជួយមើលផ្លូវបងជានិច្ច តែគាត់ប្រាប់ថាមិនដែលឃើញ បងមកទីនោះទេ ទើបអូនអស់សង្ឃឹមរលីងពីជីវិត លែងចង់មាន ជីវិតរស់នៅតទៅទៀត ។

- ពុទ្ធោ! អូននី! (កិត្យាឧទានដោយក្ដីអាណិតចំពោះភរិយា)

- សំណាងល្អ! ពេលដែលអូនបានដឹងថា អូនកំពុងមានផ្ទៃពោះ អូនបែរជារំភើបត្រេកអរនឹងកំណើតរបស់កូន ហើយក៏ប្ដេជ្ញដើម តស៊ូប្រឈមមុខនឹងជីវិត ដើម្បីឈាមមួយតំណក់នោះ ព្រោះគេជា ចំណងដៃនៃជីវិតក្រមុំដែលអូនប្រគល់ជូនបងក្នុងរាត្រីមង្គល... ជា សាច់ឈាមនៃសេចក្ដីស្នេហារបស់អូនចំពោះបង... អូនប្រាថ្នាចង់ ឲ្យបងបានឃើញរូបកូនរបស់យើងនៅថ្ងៃណាមួយ ដើម្បីបញ្ជាក់ថា បងគឺបុរសដែលអូនស្រឡាញ់បំផុត ក្នុងលោកនេះ ។

កិត្យារលីងរលោងទឹកភ្នែក កាលបើបានស្ដាប់ការរៀបរាប់របស់ ប្រពន្ធចប់ចុងចប់ដើម ។ គេក៏ស្រវាអោបប្រពន្ធថៃថើបដោយក្ដី រំភើបរំជើបរំជួលក្នុងចិត្តនិងក្ដីអាណិតចំពោះនាង ដែលគេធ្លាប់បាន យល់ច្រឡំលើនារី ។ ពេលនោះ គេក៏នឹកដល់គុណឪពុកម្ដាយរបស់ គេ

CHANBOKEO.COM

និងឪពុកម្តាយរបស់មាលានី ដែលរង់ចាំផ្តល់នូវកម្លាំងចិត្តនិង ការណែនាំដ៏ប្រពៃដល់រូបគេ ដែលនៅវ័យក្មេង ប្រព្រឹត្តអ្វីតាមតែ អារម្មណ៍ពុះកញ្ជ្រោល ដោយមិនគិតពីលទ្ធផលចុងក្រោយ ។ នេះ បើសិនគេមិនបានទទួលការលើកទឹកចិត្តពីឪពុកម្តាយនិងការណែនាំ របស់លោកទាំងសងខាងទេ ម្ល៉េះសមជីវិតគ្រួសាររបស់គេនឹងរអាក់ រអួលយ៉ាងណា កាលបើគេឆេវឆាវមិនព្រមស្តាប់គ្នាយ៉ាងនេះ ។

- នី! ថ្វីបើបងមានការសោកស្តាយដែលត្រូវព្រាត់រូបអូន...ព្រាត់ សេចក្តីសុខអស់ជាងបួនខែ ហើយបានធ្វើអោយអូនអស់ការងារធ្វើ ប៉ុន្តែ បងក៏សប្បាយចិត្តដែលថ្ងៃនេះ បងបានទទួលមេរៀនជីវិតដ៏ ល្អមួយ ។ បងជឿថា បងនៅសល់ពេលវេលាច្រើនណាស់ សំរាប់កែឆ្នៃខ្លួន ដើម្បីសេចក្តីសុខសុភមង្គលក្នុងគ្រួសាររបស់យើង មិនអោយដើរជាន់គន្លងចាស់តទៅទៀតឡើយ ។

- អូនក៏ត្រេកអរសោមនស្សមិនខុសគ្នាដែរ ដែលអូនបានជួបប្តី របស់អូនវិញ... ជាប្តីដែលយល់ចិត្តប្រពន្ធជាងមុន ។ អូនមិនស្តាយក្រោយទេដែលអូនបានសម្រេចចិត្តរៀបការជាមួយបង ។ យើងនឹងចាប់ដៃគ្នាសាងជីវិតគ្រួសារឲ្យយល់តែសេចក្តីសុខរៀងទៅ ។

- ចាប់ពីពេលនេះទៅ យើងឈប់វិលទៅអតីតកាល ហើយក៏ ឈប់ប្រើពាក្យថា "ចាំស្នេក" ទៀតហើយ ណា៎អូន!

- ចា៎ស! គ្មានពាក្យនោះទៀតទេ ។ យើងនឹងប្រើពេលបច្ចុប្បន្ន ដើម្បីកែឆ្នៃជីវិតរបស់យើងអោយប្រសើរឡើង ។ បើសិនយើង មានរឿងអ្វីក្នុងចិត្ត យើងពិគ្រោះគ្នាភ្លាមៗ ដោយប្រើសតិប្រាជ្ញា ប្រាសចាកនូវចិត្តទោសៈ និងអំពើហឹង្សាចំពោះគ្នា...

- រួចហើយយើងនឹងក្លាយជាមាតាបិតាគម្រូរបស់កូន...

- ចំណែកបងនិងអូនក៏ជាគូជីវិតគម្រូរបស់សង្គមយើងផងដែរ!

- ហើយគ្រួសាររបស់យើងនឹងជួបតែសុភមង្គលតរៀងទៅ ។

គូស្នេហ៍ទាំងទ្វេហាក៏ញញឹមដាក់គ្នាយ៉ាងបំព្រង ។ សូរសៀងសំណើចសុភមង្គលក៏លាន់ឡើងរអឺក ក្នុងបន្ទប់រមនា ដែលមានតែក្រណាត់វាំងននពណ៌ខៀវជាជញ្ជាំង...

CHANBOKEO.COM

# ចប់

CHANBOKEO . COM